CAMBODIAN LITERARY READER AND GLOSSARY

អក្សរសាស្ត្រខ្មែរ

Franklin E. Huffman
and
Im Proum

VISIT…

LANZAROTE Caliente.com

CAMBODIAN LITERARY READER AND GLOSSARY

Cambodian Literary Reader and Glossary
Franklin E. Huffman and Im Proum

This is the third in a series of Cambodian readers prepared by Franklin Huffman and Im Proum, following their *Cambodian System of Writing and Beginning Reader* and *Intermediate Cambodian Reader.* The reader contains thirty-two selections from some of the most important and best-known works of Cambodian literature in a variety of genres—historical prose, folktales, epic poetry, didactic verse, religious literature, the modern novel, poems and songs, and so forth. The introduction is a general survey in English of Cambodian literature, and each section has an introduction in Cambodian. For pedagogical reasons, the selections are presented roughly in reverse chronological order, from modern prose to the very esoteric and somewhat archaic verse of the Ream-Kei (the Cambodian version of the Ramayana). The reader concludes with a bibliography of some sixty items on Cambodian literature.

The glossary combines the 4,000 or so items introduced in this reader with the more than 6,000 introduced in the previous two readers. The definitions are more general and complete than one usually finds in a simple reader glossary, in which definitions are normally context-specific.

Other Cambodian-language texts available from Cornell Southeast Asia Program

Cambodian System of Writing and Beginning Reader
Franklin E. Huffman with the assistance of
Chhom-Rak Thong Lambert and Im Proum

Intermediate Cambodian Reader
edited by Franklin E. Huffman with the assistance of
Im Proum

Modern Spoken Cambodian
Franklin E. Huffman with the assistance of
Charan Promchan and Chhom-Rak Thong Lambert

ទប៉្ជខេមរភាសា

INTERMEDIATE CAMBODIAN READER

edited by Franklin E. Huffman

with the assistance of Im Proum

Southeast Asia Program
120 Uris Hall
Cornell University, Ithaca, NY 14853

Copyright © 1977 by Yale University.
All rights reserved. This book may not be
reproduced, in whole or in part, in any form
(except by reviewers for the public press),
without written permission from the publishers.

Reprinted with permission, 1988
by Cornell University, Southeast Asia Program,
Ithaca, New York 14853

Library of Congress Catalöging in Publication Dates

Huffman, Franklin E.
Cambodian literary reader and glossary.
(Yale linguistic series)
Bibliographer: p.
1. Khmer language—Readers. I. Proum, Im, joint author. II. Title. III. Series.
PL4325.H8 495.9'3'286421 76-50538

ISBN: 978-0-87727-523-7

TABLE OF CONTENTS

INTRODUCTION	1
PART ONE: READING SELECTIONS	11
I. Political Criticism	13
1. ចចកចង់ស្លៀកកូនចៀមហើយ	13
II. Modern Novel	19
2. ផ្កាក្រពុំ	19
3. បក្សីចាំក្រុង	31
III. Historical Prose	38
4. ព្រះសុរិយោវង្ស	39
5. ពញ្ញាស្ពក៊ាលោក មឿង	47
6. ព្រះចន្ទរាជា	54
7. អាចារ្យលាក់	63
8. គុកនយោបាយ	71
IV. Miscellaneous Short Poems and Songs	79
9. កាព្យសាស្ត្រខ្មែរ	79
10. បទអញ្ជើញគ្រូ	106
11. សុបិន	108
12. ភ្លេងការ (ទី ១)	111
(ទី ២)	113
13. សរសើរហេមន្តមាស	116
14. អាយ៉ៃ (ទី ១)	126
15. អាយ៉ៃ (ទី ២)	134
V. Didactic Literature	143
16. គតិលោក	143
17. ច្បាប់ក្រម	149
18. ច្បាប់កេរ្តិ៍កាល	160

19. ច្បាប់ពាក្យចាស់ 167

20. ច្បាប់ប្រុស 173

VI. Romantic Epic 189

21. ទុំទាវ 189

VII. Mythological Epic 208

22. កាកី 208

23. មាយើង 220

24. ហង្សយន្ត 227

25. ទិព្វសង្វារ 236

26. ព្រះជិនវង្ស 251

VIII. Religious Epic 274

27. សុបិនកុមារ 274

28. ក្រុងសុភមិត្រ 279

29. សព្វសិទ្ធ 289

30. មហាវេស្សន្តរជាតក 298

IX. Ream-Kei 309

31. រាមកេរ្តិ៍ (ទី ១) 309

32. រាមកេរ្តិ៍ (ទី ២) 315

BIBLIOGRAPHY 321

PART TWO: CAMBODIAN-ENGLISH GLOSSARY

INTRODUCTION

This book is the third and final volume of a series of Cambodian readers which began with the authors' Cambodian System of Writing and Beginning Reader (New Haven, Yale University Press, 1970) and their Intermediate Cambodian Reader (New Haven, Yale University Press, 1972). However, it may be used independently as a survey of Cambodian literature, since it includes a cumulative glossary of the vocabulary introduced in all three volumes.

Cambodian literature as a topic is vast; it covers a period of thirteen centuries, from the earliest Khmer inscriptions of the seventh century to the present; it includes a variety of genres: historical prose, folktales, epic poetry, didactic verse, religious literature, modern novel, etc.; and, like any great literature, draws its inspiration from a variety of sources: native Khmer, Chinese, Hindu, Buddhist, Thai, French, etc. Obviously one can only scratch the surface in a textbook of this kind; our objectives are to give the student some understanding of the richness and complexity of Cambodian literature, and to provide him with the linguistic tools to pursue it further on his own.

Part One of the book consists of thirty-two reading selections taken from some of the most important and best-known works of Cambodian literature; these are in turn divided into nine major categories or 'genres' which they seem to typify. The introductions in Cambodian preceding the major sections, as well as the introductory notes preceding the individual readings, were written by Im Proum. It should be pointed out, however, that the pervasive blending of seemingly contradictory elements - the secular with the religious, the human with the supernatural, the historical with the legendary - characteristic of much of Cambodian literature renders its classification extremely problematic; perhaps this explains the fact that most previous attempts at classification have been primarily chronological (Aymonier 1900, Maspero 1929, Coedès 1931, Bernard-Thierry 1955b, Ly-Theam-Teng 1960).

With considerable trepidation, then, we present the following classification and description of the readings contained in this volume:

I. Political Criticism

Reading 1 is a typical example of journalistic political criticism by allusion or parable; it involves a dialogue between a wolf (the government) and a lamb (the citizen), which appeared in the journal '<u>National Salvation Youth</u>' in 1970.

II. Modern Novel

The prose novel is a relatively recent phenomenon in Cambodian literature, having developed as recently as about 1940 as a result of Western influence; prior to that time prose fiction would not have been considered a respectable form of literature, since traditional literature was almost by definition in verse. Today there is a great proliferation of modern novels, some dealing with popular contemporary themes, such as /pkaa krɑpum/ [The Unopened Flower] by R. Kovid (Reading 2), while others are modern renditions of traditional legends, such as /baqsəy cam kroŋ/ [The Protected One] by Biv-Chhay-Leang (Reading 3).

III. Historical Prose

There is a lively debate among historians concerning the status of Southeast Asian historical documents. With regard to the Cambodian chronicles, Henri Maspero states: 'Cambodian literature does not contain historical documents in the sense in which we understand them. It possesses only chronicles, of which none, unfortunately, has come down to us in its original form, the successive kings of Cambodia having modified them following their own fancies, and the scribes having injected legends to which they attach much more importance than to historical fact' (Maspero, 1929, p. 300). Coedès adds that 'The accounts are rarely in proportion to the importance of the facts being related; cremations [and] insignificant ceremonies are described at great length, while the essential events are disposed of in a few lines' (Coedès, 1931). The crucial point would appear to be what the writer considers to be 'essential'; and in fact Coedès goes on to

say, 'In spite of all their faults, these Cambodian documents are nevertheless a source of primary importance for the history of the country' (Coedès, 1931). These chronicles are of two kinds: 1) the Royal Chronicles, of which the oldest version in existence was commissioned by King Ang Duong in 1813, and which are kept in the National Library in Phnom Penh, and 2) privately commissioned chronicles, which are for the most part inscribed on palm-leaf manuscripts and which reside either in the National Library or in various monasteries around the country; it is safe to assume that many of these have yet to be brought to light by historians. The most recent of these to be published in book form is the /qaekkəsaa məhaaboroh kmae/ [Documents on Great Khmer Figures] (Eng-Sot, 1969), from which Readings 4-7 are taken. Reading 8 is an excerpt from a more modern form of historical prose - an autobiography by Bunchan-Mol which sheds light on political events in Cambodia during the first half of the 20th century (Bunchan-Mol, 1971).

IV. Miscellaneous Short Poems and Songs

Traditional Cambodian literature is almost exclusively in verse; thus while Readings 1-8 are in prose, the remainder, except for 16 and 30, are in verse. Cambodian poetry is composed in a great number of styles or meters of varying complexity, each with its individual name and rhyme pattern. Styles are defined in terms of number of stanzas, number of lines per stanza, number of syllables per line, and rhyme position, which may be both internal (e.g. syllable 2 with syllable 4 in the same line) and external (e.g. syllable 4 of line 1 with syllable 2 of line 2); 'rhyme' itself is of three kinds: 1) same initial (alliteration), 2) same vowel and final (rhyme in the Western sense), and 3) repetition of the entire syllable. The specification of all these features results in styles of extreme complexity, and places stringent demands on syntax. In fact a fascinating linguistic question which deserves further study is whether Cambodian poetry simply admits of great 'poetic license' in its word order, or whether in fact Cambodian verse should be interpreted more impressionistically as a kind of 'word painting'. Reading 9, which was written by Im Proum, describes and illustrates forty-one of

the most common /bαt/, or metric styles, drawn from various sources on Cambodian versification (Roeské 1913, Chim-Peov 1959, Ieng-Say 1966, Jacob 1966, Leang-Hap-An 1971); each subsequent reading is preceded by the name of the /bαt/ in which it is composed, so that the student can refer to its explication in Reading 9. Reading 10 is a traditional chant used in the invocation of spirits through a medium in the event of serious illness; since it exists only as an oral tradition, we are grateful to Mme. Pich-Sal, former member of the Commission des Moeurs et Coutumes du Cambodge, for supplying us with the Cambodian text, through the intermediary of Mr. Jay Scarborough. Reading 11 is a short love poem by Kim-Samon, a modern poet who writes on traditional themes (Kim-Samon, 1972). Reading 12 consists of two traditional wedding songs, the first entreating the prospective bride to emerge from her chamber, the second originally a royal lullaby which has come to be associated with wedding ceremonies in general (Neov and Nhek-Nuv, 1965). Reading 13, the title of which could be translated 'In Praise of Winter', is a romantic poem ascribed to the poet king Sri Dhammaraja (1627-30). Readings 14 (Srey-Ou and Nhong-Soeung, 1951) and 15 (Chhim-Sum, 1951) are typical examples of the popular /qaayay/, or extemporaneous musical dialogue between a man and a woman, usually sung by more-or-less professional performers skilled in the art.

V. Didactic Literature

Reading 16 is the philosophical introduction to the Gatiloka, or 'Art of Good Conduct', which is a 10-volume collection of moralistic fables, most of which have the same Indic origin as the fables of Aesop and La Fontaine, but some of which have entirely local origins, compiled by Oknha Suttantaprija In, a well-known Cambodian author and scholar.

The space accorded in this volume to the /cbap/ or 'Codes of Conduct' reflects the importance of this didactic verse in the curriculum of Cambodian students and in Cambodian life and culture in general. Composed between the 14th and 18th centuries, of uncertain date and authorship, repeatedly recopied and passed on orally from generation to generation, these Codes provide invaluable insight into both traditional and contemporary Cambodian

society and morality. Solange Bernard-Thierry describes them as follows: 'The language is archaic, full of Sanskrit and Pali words in the interest of erudition. The syntax is poetic, almost entirely devoid of linking particles [author's translation of the original 'presque entièrement dépourvue d'articulations'], which renders translation difficult, or using archaic particles no longer current in the modern language. The style, very concise, is characterized by the juxtaposition of antitheses, the sentences grouped two by two or three by three, developing striking comparisons, metaphors, or parallel ideas... The /cbap/ are musical, lyrical, designed to be easily retained' (Bernard-Thierry, 1969, p. 175). Of the some twenty existing /cbap/, we have chosen four of the best-known, in the order in which they are traditionally taught to students. The /cbap krɑm/, or 'Code of Conventions' (Reading 17), deals with the conventions of proper conduct of a student toward his teacher. The /cbap kei kaal/, or 'Code of the Glorious Tradition' (Reading 18), deals primarily with principles of domestic economy and practical success, and might be considered a kind of 'Poor Richard's Almanac'. The /cbap piəq cah/, or 'Traditional Morality' (Reading 19), is a collection of pithy admonitions about successful human relations in everyday life, many of which are known and recited as proverbs. The /cbap proh/, or 'Codes of Conduct for Men' (Reading 20), deals with prescriptive morality for young men in the successful conduct of family life; our exegesis of this latter /cbap/ owes a great deal to the translation by Philip Jenner (Jenner, typescript).

VI. Romantic Epic

Reading 21 is from the classic Cambodian romantic poem Tum-Teav, sometimes known as Teav-Ek, which is generally thought to have been composed (or put into writing) by the poet Santhor Mok at the end of the nineteenth century (Som, 1966). Although it is certainly one of the best known and loved of all Cambodian poems, certain characteristics appear to justify assigning it to a unique category in Cambodian literature which might be best described by the Western term 'romantic epic':

1) it appears to be purely Cambodian, rather than Indic, in its inspiration;

2) set in the 16th century, its characters and events are human and ordinary; it is almost devoid of the supernatural and mystical elements characteristic of stories of Indic inspiration;

3) unlike most Cambodian epics, which are tragi-comedies, it is unrelieved tragedy; Keng Vannsak remarks that 'Tum and Teav, our Romeo and Juliet, made the mistake of abandonning themselves to love, and of searching for the absolute in death', by consequence of which they 'are not unanimously considered to be true heroes' (Keng Vannsak, 1967, p. 46).

VII. Mythological Epic

Cambodia's literary debt to India cannot be denied, but it has been by no means a slavish imitation: in the course of retelling and recopying over the centuries, the themes, characters, and settings have taken on a peculiarly Cambodian flavor, and indigenous episodes, themes, and attitudes have been inserted; their skillful versification by Cambodian poets alone assures their status as an indigenous form of expression. While abounding in supernaturalism, magic, monsters, demons, and characters of royal estate, the Cambodian mythological epics tend to be more human, more realistic, and more pragmatic, not to say cynical, than their Indic counterparts. Of uncertain date and authorship, these epics are either sung to the accompaniment of the /caapəy/, or enacted as drama. Reading 22 is from the epic love poem /kaakəy/ [Kākī], a fickle beauty whose amorous inclinations lead to disaster (Ang Duong, 1966). Reading 23 is from the story of /miə yəəŋ/ [Mea Yoeung], and deals with the theme of loyalty to one's king (The Story of Mea Yoeung, 1961). Reading 24 is an excerpt from the tale of the /hɑŋ yŭən/ [Mechanized Swan], which abounds in magical acts and fantastic contraptions (The Story of Hang-Yon, 1966). Reading 25 is from the five-volume epic of /tɨp-sɑŋwaa/ [Tip-Sangvar], a valiant princess who fought against an army of wicked giants whose king wanted her as a daughter-in-law (The Story of Tip-Sangvar, 1963). Reading 26 is from the four-volume epic /prĕəh-cɨnnəwŭəŋ/ [Preah Chinavong], attributed to the poet Hing during the reign of King Ang-Duong; it deals with the adversities of a prince cast out of his father's palace at an early age through the machinations of a concubine, and his

ultimate triumph over them through virtue and considerable divine intervention (Hing, 1964); this story is one of the most popular subjects of dramatization in the Cambodian theater.

VIII. Religious Epic

There are two categories of religious literature in Cambodia:

1) that written and studied in the Pali language, notably the Tripitaka (Three Baskets), or Buddhist canon, consisting of a) the Vinaya (discipline or rules of conduct for the Sangha), b) the Sutras (which include the Buddha's discourses and the 547 Jataka tales or stories of the Buddha's earlier reincarnations as a Bodhisatva), and c) the Abhidhamma (metaphysics or highest law of Buddhism, in the form of questions and answers), and

2) that which, although religious in origin, has been composed in Cambodian and popularized as literature among the laity.

The readings in this section fall in the latter category. Although essentially Buddhist in origin, the Cambodian versions exhibit a syncretism of Buddhist elements, both Theravada and Mahayana, Brahman influences, animistic beliefs, and traditional Khmer morality. Reading 27, /sobən-komaa/ [Soben Komar], is a traditional vehicle for teaching morality in the pagoda schools (The Story of Soben Komar, 1966). Reading 28, /kroŋ-sopphəmɨt/ (Kao, Krungsubhamitra, 1967), and Reading 29, /sɑp-sɨt/ (Tan, Sabhasiddhi, 1966), are stories from the <u>Paññasajataka</u>, fifty apochryphal birth stories not included in the Tripitaka, but very popular in Cambodia, Thailand, and Laos. Reading 30 is from the /mɔhaa-weesəndɑɑ-ciədɑq/ [Mahā Vessantara Jātaka], which is the most popular of the original 547 Jatakas of the Tripitaka, and which is recited (in Pali), with Cambodian translation and commentary, for hours on end to patient listeners at religious festivals (Nhok-Thêm, 1964). Concerning the Jatakas, Keng Vannsak says, 'The Bodhisatvas, tragic or mystical heroes, are known to the Khmers, but are neither admired nor venerated... Only the human and pathetic Bodhisatva Preah Vesantar is remembered and repeated, because he accepted the worst contradictions between the quest for perfection and social, familial, and sentimental exigencies' (Keng Vannsak, 1969, p. 43). In Reading 30 we have omitted the verses in Pali as being beyond the scope of this textbook, leaving only

the Cambodian translation and commentary.

IX. Ream-Kei

Readings 31 and 32 are from the Ream-Kei, or Cambodian version of the Rāmāyana (Reamker, Vol. 1, 1964, and Vol. 6, 1961), of which only Fascicles 1-10 and 75-80 have been found and published by the Buddhist Institute. The Ream-Kei deserves to be placed in a category of its own, both because of the archaism of its vocabulary and metric style and because of its unique place in Cambodian literature. Although obviously based originally on the Hindu epic of Rama and Sita by Valmiki, it contains many passages of purely Cambodian origin, and its concise and elegant style leads many to consider it the unchallenged chef-d'oeuvre of Cambodian literature.

For pedagogical reasons, the reading selections are presented roughly in reverse chronological order, from the modern prose of Section I through the very esoteric and somewhat archaic verse of the Ream-Kei in Section IX. Although a broad definition of Cambodian literature would include also the Pre-Angkorian and Angkorian inscriptions, their study is an exercise roughly equivalent to the exegesis of Old and Middle English, and we have therefore omitted them as being beyond the scope of this textbook. The only other important category of Cambodian literature not represented in this volume are the numerous and popular folktales (Buddhist Institute, Collection of Cambodian Folktales, 8 vols., 1959-72), which, due to their relatively simple style, were more suitable for inclusion in the Beginning and Intermediate volumes.

Part Two of this volume consists of a final alphabetical Cambodian-English Glossary containing not only the some 4,000 vocabulary items introduced in this volume, but also the 6,000 items contained in the previous two volumes. This rather comprehensive glossary makes the book independently useful as a textbook on Cambodian literature, and constitutes a Cambodian-English dictionary of some 10,000 entries.

We would like to take this opportunity to express our gratitude to Mrs. Sivone Kong Proum, wife of the co-author and Cambodian Lecturer at Cornell University, for her patient and masterful typing of the Cambodian text for this volume.

Although this work was begun in response to the needs of our advanced students of Cambodian at Cornell University, it soon developed into a far more fascinating (and ambitious) project than we had anticipated, one to which we have devoted untold hours of work over a period of three years, often to the neglect of more urgent priorities. Our reward - and, we hope, that of potential users of the book - is a fuller appreciation of the incredible richness and complexity of Cambodian literature.

F.E.H.
I.P.

Ithaca, New York
May 1976

Part One

Reading Selections

I. POLITICAL CRITICISM

១. ចចកចង់ត្បកកូនចៀមហើយ

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

'ចចកចង់ត្បកកូនចៀមហើយ' ជាអត្ថបទមួយដកស្រង់ចេញពីទស្សនាវដ្ដី 'យុវជនស្រោចស្រង់ជាតិ' ។ អត្ថបទរបៀបនេះមានកន្លែងយ៉ាងធំទូលាយនៅក្នុងទស្សនាវដ្ដីនិងសារពត៌មានផ្សេង ៗ នៅស្រុកខ្មែរសម័យថ្មី ។ មានកត្តាមួយយ៉ាងសំខាន់ដែលបណ្ដាលឲ្យស្រុកខ្មែរសម្បូណ៌ទៅដោយអត្ថបទយ៉ាងនេះ : តាំងពីដើមរហូតមកដល់ឆ្នាំ ១៩៧០ ស្រុកខ្មែរជាស្រុកមានស្ដេច ។ នៅក្រោមអំណាចស្ដេច ការទិទានមន្ត្រីអ្នករាជការ ឬរបបគ្រប់គ្រងមិនសូវមានទាល់តែសោះ ។ បើអ្នកឯណាមួយហ៊ានធ្វើទិទាន អ្នកនោះត្រូវចោទថាមើលងាយ 'ព្រះចេស្ដា' ...ទោស : កំបុតក ។ ម្ល៉ោះហើយគេមិនដែលទិទានស្ដេចទេ ។ បើគេយល់ឃើញថា មន្ត្រី ឬស្ដេចណាមួយធ្វើខុសឆ្គងខ្លាំងពេក គេទៅបញ្ចុះបញ្ចូលរាស្ត្រឲ្យធ្វើសង្គ្រាមប្រឆាំងតែម្ដង ។ ក្នុងអតីតកាលដ៏មិនយូរអង្វែងមកនេះ ថ្វីបើមានការបើកឲ្យមានសេរីភាពខ្លះក្នុងការសំដែងគំនិតក៏ដោយ ការទិទានមិនចំ ឬបញ្ឆិតបញ្ឆៀងនៅតែមានហូរហែរដូច្នោះ ព្រោះតែគេនៅតែញញើត ។ 'ចចកចង់ត្បកកូនចៀមហើយ' ជាឧទាហរណ៍មួយដ៏ជាក់ស្ដែងនៃការទិទានបញ្ឆិតបញ្ឆៀងយ៉ាងខ្លាំង យ៉ាងក្លាហាន និងយ៉ាងប៉ិនប្រសប់ ។

អត្ថបទ

- ចែន អាប្រចម៉ក់ ឯងអីក៏ក្លាហានម្ល៉េះឥឡូវហ្នឹង ?
- ញុទ ឥឡូវនេះខ្ញុំធ្វើដំណើរទៅកាន់សាធារណរដ្ឋទេ ខ្ញុំមិនមែនចង់កាច់រាងដាក់លោកឯណា ។
- ចុះឯងដើរនៅមុខអញហើយ ឯងថាមិនឃើញអញឬ ?
- ខ្ញុំដើរតាមផ្លូវសាធារណរដ្ឋ ខ្ញុំត្រូវតែខំព្យាយាម ខ្ញុំគ្មានពេលមើលលោកឈររាំងផ្លូវគេនុះទេ ព្រោះគេទាំងអស់គ្នា មានទីដៅគ្រប់ ៗ រូប គឺដើរឆ្ពោះទៅកាន់របបសាធារណរដ្ឋនិយម ។
- ឱ៍ គ្រាន់តែបានដើរទៅរករបបថ្មីនេះ ឯងលែងគោរពអ្នកធំហើយ ឯងហ៊ានវាយឫកដាក់អញផង ។
- ចែនម្នាលចចកអើយ បើខ្លួនយកតែបង្គួមមកប្រើជំនួសគំនិតទេ កុំច្បាច់មករារាំងផ្លូវគេធ្វើអី គឺគិត

ធ្វើដូចម្ដេចរកតែកន្លែងខ្លួនឲ្យបានស្រួលទៅបានហើយ ចំណែកគេ គេត្រូវការឯករាជ្យ សន្តិភាព អាព្យាក្រិត្យ សមភាព សេរីភាព និងយុត្តិធម៌ ។

- ចុះបើគ្រាន់តែត្រូវការអារបស់អស់នេះ ហេតុដូចម្ដេចបានជាឯងមិនលំអានកាយខ្លះផង? នឹងអញជាស្អីទេ?

- អូអើ ភ្លេចគិតទៅ ចចកគឺជាអ្នកប្រហារឬអ្នកចាប់ចងធ្វើបាបត្រីតូចតាច តាមតែកម្លាំងកំហឹងរបស់ខ្លួន គ្មានបានយកច្បាប់ក្បួនមកពិនិត្យឲ្យបានហ្មត់ចត់ទេ គេយកតែអំណាចអំពើសាហាវមកធ្វើជាត្រីមុខជរាប ។ នេះហើយចំណេះចេះតែឯង ព្រោះឃើញគេជាធូលី មិនថាអញ្ចឹងឬលោកចចក?

- ហើ ឯងនេះឥឡូវចេះប្រើស្ដីសំបើមណាស់ ឯងនៅក្មេងណាស់កុំចេះតែបញ្ចេញពេក ក្រែងវាផុតអំនួតណ៎ាអានាង ។

- កាលលោកចចកឯងពីក្មេងក៏បៅទឹកដោះម៉ែដែរ ខ្ញុំពីក្មេងក៏បៅទឹកដោះម្ដាយខ្ញុំដែរ គិតទៅយើងតាំងពីកើតមកមានទំហំជីវិតប៉ុន ៗ គ្នា គ្មានធ្ងន់ឬស្រាលជាងគ្នាទេ ។ ទើបតែដល់ខ្លួនធំទេ ទើបឯងភ្លេចជាតិទឹកដោះព្រោះមកពីបរិភោគសាច់-ឈាម-ឆ្អឹងត្រីគនានាវាច្រើនពេក ។ ចំណែកខ្ញុំមានតែស្មៅខ្ចីទេ តែហ៊ានស៊ីសាច់ត្រីគឯទៀត ៗ មុខជាច្បាក់ធ្មេញភ្លាម ហើយជីវិតខ្ញុំក៏អត់នឹយដែរ ។ ការនិយាយនេះមិនមែនខ្ញុំបញ្ចេញនូវប្រើស្ដីជូនលោកស្ដាប់ទេ គឺខ្ញុំនិយាយទៅតាមដំណើរថ្មី ដែលមានចែងក្នុងច្បាប់ក្បួនរបស់អ្នកដឹកនាំថ្មីយើង គឺរដ្ឋាភិបាលស្រោចស្រង់ជាតិ ។ ម៉េចលោកយល់ហើយឬនៅ?

- អញពេលប៉ុណ្ណឹងហើយ ឯងនៅតែរឹងមាត់ទៀតឬអាក្មេងកំសាក!

- ឱមហាចចក ឯងកំសាកឬខ្ញុំកំសាក ។ ខ្ញុំនិយាយទៅរកឯងគោរពឯងជាចាស់ចំណាស់ ព្រោះឯងជាសត្វធ្លាប់មានការពិសោធន៍គ្រប់ផ្លូវ តែបែបជាសំដីឯងវិញប្រែប្រួលបានទៅនឹងសត្វត្មាតដែលវាស្រែកទាសាច់ស្អុយបរិភោគដូច្នោះ ។ ឯងអួតខ្លួនសុទ្ធជាអ្នកកាន់អំណាចត្រឹមត្រូវតាមច្បាប់ តាមត្រមា តែដល់ឯងប្រើការវិញឯងយកច្បាប់ឈ្លូស ច្បាប់ក្ដាម ច្បាប់ស្វាមកប្រើ នេះមិនគឺការកំសាករបស់ឯងទេឬ? នែ៎ម្នាលស៊ីសាច់ហុតឈាមគេអើយ ល្មមកែសតិសម្បជញ្ញៈខ្លួនខ្លះទៅ ព្រោះពេលនេះគេលែងប្រើរបៀបស៊ីរនុកទៀតហើយ ឯងក៏ល្មមដូរចំណី ដូរខួរក្បាលចេញទៅ ។

- ឯងជាក្មេងជាន់ក្រោយ ឯងម៉េចក៏ព្រហើនហ៊ានប្រដៅអញជាមនុស្សចាស់ផងឬ?

- មនុស្សចាស់បានបង្រៀនក្មេងឲ្យចេះគិតគូរ ដល់ក្មេងចេះគិតហើយគេមិនអាចចាត់ទុកថាក្មេងវាខ្វាក់រហូតទេ ហើយគេក៏មិនអាចចាត់ទុកថាក្មេងនោះវាចេះជាងចាស់ដែរ ។ ប៉ុន្តែក្មេងវានៅមានស្មារតីថ្មី អវៈយវៈថ្មី គឺមិនដែលប្រឡាក់កំអែលស្អុយគគ្រុក ដូចពួកចចកឯងដែលមានក្លិនអសោជខ្លះមកហើយនោះទេ ។ ក្មេងឃើញចាស់ធ្វើខុសគេថាខុស ឃើញធ្វើត្រូវគេថាត្រូវ

មិនមែនដូចចាស់ៗទេ មួយថ្ងៃៗ គិតត្រិះរិះរករបៀបថ្មី រកថ្នាំថ្មីមកលួងក្មេងឱ្យពុលទៅតាមឆន្ទៈរបស់ខ្លួន ។ តើរបៀបនេះឬដែលគេហៅថាសេរីភាពរបស់មនុស្ស ។

- ចុះយើងមានទាន់ខ្វាក់ឯណា ម៉េចឯងថាមិនឃើញសេរីភាព ។

- អញមានថាឯងខ្វាក់ពីកាលណា ប៉ុន្តែអញថាឯងឃើញសេរីភាពវាមិនច្បាស់ ទាល់តែទៅទិញ 'វែនតា' ពីស្ថានព្រះឥន្ទមកទើបឯងយល់ច្បាស់ពាក្យសេរីភាព និងសមភាព ។ គេមិនមែនយករបស់ដ៏មានតម្លៃនេះ មកជាន់ញីនឹងជើងដូចពួកឯងទេ គេត្រូវចេះយកវាមកប្រើឱ្យសមទៅតាមកាលៈទេសៈ និងតាមព្រំដែនរបស់វា ។ គេមិនដែលយកវាមកប្រើឱ្យហួស ឬមកញីចោលដូចមហាត្មាតងឯងអស់នោះទេ កុំស្អីបន្តិចមកហៅគេទៅសំឡុតនោះ ។ ស្រុកយើងសម័យ ១៨មីនា ១៩៧០ គេលែងលេងល្បែងហ៊ាហ៊ីដូចជំនាន់អ៊ុំម៉ាល្ងិនទៀតហើយ ។ កុំប្រើមេអាចោងចាស់ទៀត ក្រែងវាញាក់ស្លុល ។

- ម៉េចឯងចង់សាកជាមួយអញឬ?

- ទេ យើងជាក្មេងខ្ចីឆ្អឹងទន់ ទៅសាកកម្លាំងជាមួយឯងម្ដេចនឹងឈ្នះ ។ ប៉ុន្តែបើកម្លាំងចិត្តគំនិតយើងមិនខ្លាច ។ យើងយកការពិចារណា ការត្រិះរិះមកសាកល្បង យើងយកការពិតមកលាតត្រដាង ដើម្បីស្លាតស្លុំដល់សង្គមយុវជនជាន់ក្រោយ យើងនិយាយពីសេចក្ដីល្អដើម្បីឱ្យសាធារណជនដឹងបានល្អ ដូច្នេះយើងគ្មានខ្លាចស្លាប់ទេគ្រាន់តែនិយាយ បើនិយាយហើយស្លាប់ក្រោយចុះ វាប្រសើរជាងស្លាប់មិនបាននិយាយ គឺយើងបរិភោគដើម្បីរស់មិនមែនរស់ដើម្បីតែស៊ីដូចហ្វូងចចកឯងទេ ជាចុងក្រោយនេះឯងចង់ធ្វើអ្វីយើងធ្វើចុះ ព្រោះអំណាចរាស្ត្រនៅលើឯងហើយ តែឯងកុំភ្លេចថាយើងជាកូនរាស្ត្រតូចមួយដែរ ។

- សូមលាហើយម្នាលចចកអើយ ព្រោះយើងគ្មានពេលយូរមកជជែកជាមួយឯងទេ យើងយកពេលនេះកសាងជាតិវិញវាប្រសើរជាង ដូច្នេះឯងត្រឡប់ទៅផ្ទះវិញសំរាន្តយ៉ាងស្កប់ ហើយឱ្យយល់សប្តិល្អចុះ ។

យើងសូមអរគុណម្នាលឯងច្រើនណាស់ហើយ ។

-កូនចៀម-

(យុវជនស្រោចស្រង់ជាតិ , ឆ្នាំទី ១, លេខ ២២ , ទំព័រ ២១ - ២៣)

POLITICAL CRITICISM

ចចកចង់ត្បុកកូនចៀមហើយ

Introductory Note

ចចក wolf

ត្បុក to rap the head with the knuckles

ចៀម sheep

បុព្វកថា /boppəkəthaa/ foreword, introduction

អត្ថបទ /qattəbɑt/ article, text, composition

ស្រង់ to extract

ដកស្រង់ to extract, to excerpt, to take out (a passage from a book)

ទស្សនាវដ្ដី /tuə̆hsənaawədəy/ journal, magazine

ស្រោចស្រង់ to save, to salvage

សារព័ត៌មាន /saa-poədɑmiən/ news, newspaper

សម័យថ្មី modern times, recent times

កត្តា /kattaa/ factor

រិះគន់ to criticize

របបគ្រប់គ្រង system of government

ព្រះចេស្ដា /preə̆h-ceihsdaa/ king

កំបុត truncated

កំបុតក decapitated

ធ្វើខុសឆ្គង to make mistakes, misbehave, be in the wrong

បញ្ចុះបញ្ចូល to persuade

សំដែងគំនិត to express one's ideas

បញ្ឆិតបញ្ឆៀង to equivocate, allude to indirectly

ប៉ិនប្រសប់ clever

Text

ប្រចម៉ក់ tiny; little one

អីក៏...ម្ល៉េះ why...so?, why...like that?

ឥឡូវហ្នឹង now, this time

កាច់រាង to perform or utter with affected elegance

រាំង to obstruct

រាំងផ្លូវ to obstruct one's way

នុះ general demonstrative used to refer back to a previously expressed (or implied) action or idea

ទិសដៅ goal, objective, destination

រូប person

សាធារណរដ្ឋនិយម republicanism

វាយឫក (ដាក់) to be affected, put on airs (toward)

អ៊ើយ conciliatory final particle

ខ្លួន you (familiar)

រារាំង to obstruct

ទ៏យ(=ទ៏្យ)

តំណែង position, office

លំអោន to bow, bend over

អើ say, by the way (Coll. resp. part.)

ប្រហារ to kill (Lit)

ម្រឹគ four-legged wild animal (tiger, deer, etc.)

តូចតាច little, small, insignificant

ហ្មត់ចត់ thorough(ly), careful(ly)

ត្រីមុខ primary importance, supreme authority

ចំណេះចេះតែឯង you're always right, you know everything

ធូលី dust

មិនថាអញ្ចឹងឬ...? isn't that right?

ហើ exclamation of astonishment, indignation, or disapproval (superior to inferior)

សំបើម impressive; here: a lot

បញ្ចេញ to show off

អំនួត a boast

ផុតអំនួត be dead (lit: have nothing more to boast about)

អានាង My Boy, My Dear Young Fellow (condescending)

បៅ to suck (teat or rubber nipple)

ជាតិ taste, flavor

រដ្ឋាភិបាលស្រោចស្រង់ជាតិ Government of National Salvation (it is traditional in Cambodian politics to designate each new cabinet by a different name; e.g. the last administration under Sihanouk was called the 'government of last chance')

រឹងមាត់ to be stubborn

អាក្មេង you kid (disrespectful)

កំសាក coward

ចំណាស់ elderly

ការពិសោធន៍ experience; experiment

គ្រប់ផ្លូវ every field

ប្រៀបបានទៅនឹង is like..., is comparable to...

ត្មាត vulture

ស្រែកទា to cry out for, to clamor for

អួតខ្លួន to brag, to boast

ប្រើការ to actually do, to put into practice

ឈ្លូស a small deer

ច្បាប់ឈ្លូស code of the deer

ក្ដាម crab

ច្បាប់ឈ្លូស ច្បាប់ក្ដាម ច្បាប់ស្វា 'the law of the jungle'

ទ៉ែន particle used to get one's attention, usually disapproving

ស៊ីសាច់ហុតឈាម to take the very life-blood of the people (lit: eat the flesh and drink the blood)

ល្មម it's about time...

សតិសម្បជញ្ញៈ /satteqsɑmpañcəññeə̆q/ conscience

រនុក bolt, lock

ស៊ីរនុក to destroy one's support, to bite the hand that feeds you

ដូរ to change, to exchange

ក្មេងជំនាន់ក្រោយ later generation, the younger generation

ចេះគិតគូរ to be wise, to know right from wrong

ចាត់ទុកថា to consider as

អវៈយវៈ arms and legs, limbs (Lit)

ប្រឡាក់ to be soiled, stained, dirty

កំអែល dirt, filth

គគ្រុក stinking and full of worms; here: instensifier

ក្លិន smell, odor

អសោច stinking, disgusting

ពុល to be poisoned

ពីកាលណា when, since when... (used here as conj)

វ៉ែនតា eye glasses

ពីស្ថានព្រះឥន្ទ from the realm of Indra (i.e. magic, supernatural)

ជាន់ to step on

ព្ញៀ to crumple (tv)

កុំស៊ីបន្តិច whatever comes up

សំឡុត to threaten

ព្យាហ៊ី charlatan, purveyor of folk remedies

អ៊ុំម៉ាណូរិន (personal name)

មេអាប៉ោង a kind of dice with six faces

ស្នូល axle

សាក to try, to challenge, to test

ប៉ុន្តែបើកម្លាំងចិត្តគំនិត but if [you want to match] wits

ស្អាតស្អំ clean

ជាចុងក្រោយនេះ finally, after all, in the end

កសាង to build

សំរាន្ត to sleep (polite)

ស្កប់ to have slept well, be well-rested

យល់សប្តិ /yŭəl-sɑp/ to dream, have a dream

II. MODERN NOVEL

លោកនរិវង្សគោរិទ និងលោកប៊ិវឆៃលាង ជាអ្នកនិពន្ធពីរនាក់ក្នុងចំណោមអ្នកនិពន្ធជាច្រើននៃចលនាអក្សរសាស្ត្រខ្មែរសម័យទំនើប ។ យើងបានស្រង់យកជំពូកទីមួយនៃរឿងផ្កាក្រពុំរបស់លោកនរិវង្សគោរិទ និងជំពូកទីដប់បីនៃរឿង បក្សីចាំក្រុង របស់លោកប៊ិវឆៃលាង ជាឧទាហរណ៍នៃប្រលោមលោកសម័យទំនើប ។

ប្រលោមលោកសម័យទំនើប មានលក្ខណៈប្លែកពីសម័យមុន ៗ ច្រើន :

១. សរសេរជាពាក្យរាយ

២. គ្មានអច្ឆរិយៈ

៣. លែងយកគំនិតពីអក្សរសាស្ត្រនិងវប្បធម៌ឥណ្ឌា

៤. មិនសូវទាក់ទងនឹងរឿងសាសនា (ពុទ្ធសាសនា)

៥. យកលំនាំតាមអក្សរសាស្ត្រនិងវប្បធម៌បារាំង

ឯចំណែកផ្នែករឿងវិញ មានពីរដែលលើសលុបអ្វីៗទៀតគឺ :

១. បញ្ហានៃជីវិតរបស់មនុស្សក្នុងសង្គមដែលគេរស់នៅ ដូចជារឿង ផ្កាក្រពុំជាដើម

២. រឿងបុរាណដែលមាននៅក្នុងឯកសារផ្សេង ៗ ឬគ្រាន់តែនិទានត ៗ គ្នាមក ឥតមានជាលាយលក្ខណ៍អក្សរទេឡើយ ដូចមានរឿងបក្សីចាំក្រុង របស់លោកប៊ិវឆៃលាងជាគំរូស្រាប់ ។

២. ផ្កាក្រពុំ

ដោយ

នរិវង្សគោរិទ

បុព្វកថា

នាងណារ៉ាន់ ក្រោយមាតាបិតានាងស្លាប់ទៅ ក៏ទៅនៅជាមួយនឹងលោកជាន់ដែលជាឪពុកធំរបស់នាង ។ នាងត្រូវប្រពន្ធលោកជាន់ធ្វើទុក្ខទោសឥតត្រាប្រណីទេឡើយ ។ សេចក្ដីដកស្រង់មកនេះបង្ហាញឱ្យឃើញនូវចិត្តកំណាចឃោរឃៅរបស់លោកស្រីជាន់ ។

អត្ថបទ

- នរណាធ្វើអ្វីនៅក្នុងបន្ទប់ហ្នឹង ?

សូរស្រែកសួរពីផ្ទះធំមក ។ ម្ចាស់របស់សំឡេងនេះគឺជាស្ត្រីចំណាស់ម្នាក់អាយុប្រមាណ ៤៥ ឆ្នាំ ។ រូបរាងស្រស់បស់តាមលម្រស់ភាពមនុស្សចាស់ ។ ប៉ុន្តែទឹកមុខគាត់ប្រៀបបាននឹងសត្វខ្លាមួយយ៉ាងកាចសាហាវ ។

- ចា៎ះ ខ្ញុំ ។ សូរឆ្លើយតបមកវិញ ប៉ុន្តែមិនសូវជាច្បាស់ប៉ុន្មានទេ ។
- នរណា ហ៎ះ? សូរសួរផ្ទួនមកម្តងទៀត រួចហើយម្ចាស់សំឡេង ក៏ដើរបង្ហួលចូលទៅក្នុងបន្ទប់នោះ ។

នៅមុខនារីចំណាស់នេះ កញ្ញាម្នាក់កំពុងរអិលខ្លួនចុះអំពីកៅអី មៀងភ្នែកមករកម្ចាស់សំឡេង ដែលកំពុងឈរប្រជែងដែលសម្លឹងតែរទៅរក ។

- ចុះឯងចូលមកសម្ងំនៅធ្វើអី ក្នុងកន្លែងនេះ? គាត់សួរទុកកន្ទុយសំឡេងបញ្ជាក់ថា មានអំណាចជាទីបំផុត ។
- សាលនី...អានសៀវភៅ ។
- អើ! មើលម៉ោងមើលិ៍ ប៉ុន្មានហើយ?
- ចា៎ះ! ម៉ោងនៅមិនទាន់ ៥ ទេ ។
- ម៉េចក៏ម៉ោងមិនទាន់ ៥ ?
- សាលនីក្មេងសាលានេះទើបតែនឹងចេញលេងម្តង ។

ដោយសារមានហេតុផលច្បាស់លាស់ដូច្នេះ ម្ចាស់សំឡេងត្រូវនៅស្ងៀម ព្រោះគាត់គ្មានពាក្យនឹងបន្ថែមតទៅទៀត ។

ប៉ុន្តែដោយគាត់ប្រកាន់អំណាចជាអ្នកខ្ពស់ លោកស្រីខំបញ្ចេញសំឡេងទាំងកម្រោលមកទៀត

- អានសៀវភៅ ម៉េចចាំបាច់បិទទ្វារផង? ប្រយ័ត្នខ្លួនឱ្យមែនទែនណ៎ះ ស្អីទៀងអាងយកការអានសៀវភៅមកធ្វើជាម្ចាស់ ។ ល្ហើយ! ល្មមហើយ ល្មមចេញមកមើលខាងក្រៅខ្លះផង ។ ផ្ទះសំបែងមិនទាន់បោស តុទូនៅក្រខ្វក់ទាំងអស់ ។ ទៅ! ចេញទៅ ដល់បោសជូតរួចហើយ ល្មមបង្កាត់ភ្លើងដាំបាយតែម្តងទៅ ។

សន្សឹម ៗ ដើរត្រុន ៗ ជៀសផ្លូវម្ចាស់អំណាចចេញមកក្រៅ ។ លុះផុតទ្វារបន្ទប់ហើយទើបក្រោកឈរដើរ ។ ឯម្ចាស់សម្លេងដែលបរិបូណ៌ទៅដោយមហាអំណាចនោះ លុះបានបញ្ចេញសម្លេងមហាកំដៅអស់ចិត្តហើយ ក៏គេចចេញទៅយ៉ាខាងក្រៅបាត់ទៅ ។

នេះគឺជាជីវភាពរស់នៅសព្វថ្ងៃរបស់ណារ៉ាន់ ។

ណារ៉ាន់ជាកញ្ញាកំព្រាឪពុកម្តាយតាំងតែពីនៅតូចម្ល៉េះ ។ មាតាបិតានាងនៅភូមិព្រែក

កុយរការកោង ។

ថ្ងៃមួយ ឪពុកម្ដាយកញ្ញាណារ៉ាន់ នាំគ្នាពីរនាក់ប្ដីប្រពន្ធឡើងកប៉ាល់ចុះមកភ្នំពេញ ដើម្បីលក់ពោត ។ លុះមកដល់កោះថ្មី ស្រាប់តែកប៉ាល់កើលលើផ្គត់ក្រឡាប់លិចទៅ ។ ជនអភ័ព្វទាំងពីរក៏ដល់នូវក្ដីមរណៈក្នុងពេលនោះ ដោយបន្សល់ទុកនូវកូនស្រីកំសត់ឲ្យនៅជាមួយបងផាន់របស់គាត់ ។

លោកផាន់ជាចាឡាត់ស្រុកមុខកំពូល ។ លុះណារ៉ាន់អាយុបាន ៤ ខួប លោកត្រូវផ្លាស់មកធ្វើការនៅភ្នំពេញវិញក្នុងតំណែងជានាយការិយាល័យកិច្ចការទូទៅ នៅក្រសួងមហាផ្ទៃ ។ ឯលោកស្រីផាន់ហៅសាផែ ចិញ្ចឹមណារ៉ាន់ទាំងទើសទាំងទាល់ ព្រោះលោកប្រុសបានអង្វរអ្នកស្រីពេក ។ លោកសំ-ផាន់មានសេចក្ដីអាណិតមេត្តាណារ៉ាន់ណាស់ ។ លោកបានតាំងចិត្តថានឹងជួយទំនុកបម្រុងកញ្ញាឲ្យបានរៀនសូត្រចេះដឹងជ្រៅជ្រះនឹងគេ ។ ចំណេះនេះឯង អាចសាងជីវិតណារ៉ាន់ឲ្យឈោងទៅកាន់ឋានៈឧត្ដុង្គឧត្ដមបាន ។

ប៉ុន្តែផ្ទុយគ្នាស្រឡះ នេះគ្រាន់តែជាការគិតរបស់លោកផាន់ប៉ុណ្ណោះ ព្រោះធម្មតាស្រីតែងមានអំណាចលើបុរស ។ ដូច្នេះលោកផាន់មិនអាចរឹងទទឹងនឹងអ្នកស្រីបានឡើយ ។ បើសិនជាចចេសក្រែងលោអ្នកស្រីខឹង...

ទីបំផុតធំសាផែគិតតែពីឃ្លានីសណារ៉ាន់មិនឲ្យនាងបានរៀនសូត្រកើតសោះ ដោយគាត់ខ្លាចក្រែងកញ្ញាអភ័ព្វនេះ ដណ្ដើមសេចក្ដីសុខអំពីគាត់...

មិនតែប៉ុណ្ណោះ ធំផែនៅមានធីតាម្នាក់ទៀតអាយុស្រហាលគ្នានឹងណារ៉ាន់ដែរ ។ រូបសម្បត្តិក្ដី ចរិយាសម្បត្តិក្ដី ណារ៉ាន់ផ្ដាច់ធីតាធំសាផែ ចិតសិបភាគរយ (៧០ %) ។ ឯការរៀនសូត្រទៀត ក៏ណារ៉ាន់ឆ្លៀវឆ្លាតលើសកូនស្រីរបស់គាត់ ។ ដូច្នោះបានជាធំផែគាត់ដឹងច្បាស់ថា បើសិនជាមិនបង្ខាំងណារ៉ាន់ឲ្យធ្វើការផ្ទះទេ មុខជាណារ៉ាន់ត្រូវមានឋានៈអណ្ដែតលើធីតារបស់គាត់ ទៅក្នុងពេលអនាគតជាមិនខាន...

ហេតុហ្នឹងហើយបានជាណារ៉ាន់ នាងត្រូវឈប់សិក្សាក្នុងពេលដែលនាងទើបតែបានអាយុ ១៤ ឆ្នាំម្ល៉េះ...

ឥឡូវនេះធីតាកំព្រា កំពុងតែអង្គុយបង្កាត់ភ្លើងនៅក្នុងផ្ទះបាយ ដោយសេចក្ដីប្រយ័ត្នជាទីបំផុត ដ្បិតអ្នកស្រីកម្រិតគ្រាប់ឈើគូសឲ្យក្នុងការធ្វើម្ហូបមួយពេល ត្រឹមតែមួយគ្រាប់ប៉ុណ្ណោះ ។ រាល់ ៣ ថ្ងៃ នារីកំសត់ត្រូវប្រតិបត្តិនាទីជាអ្នកចំអិនអាហារបម្រុងគ្រួសារ ហើយនាងត្រូវធ្វើកិច្ចការក្នុងផ្ទះទាំងអស់ ដោយយកចិត្តទុកដាក់ ។ បើទុកជានាងនឿយហត់ដល់ទៅម្ល៉ោះក្ដី អ្នកស្រីសាផែនៅតែរករឿងស្ដីបន្ទោសបានទៀត ។ ស្ដីនេះមិនតិចអី ស្ដីស្ទើរមិនលស់ពេលណា...

អីយ៉ូយ! ណារ៉ាន់បន្លឺវាចាក្នុងពេលដែលនាងគូសឈើគូសរលត់ ។ នាងភ័យណាស់ ព្រោះអ្នក

មីងកម្រិតឲ្យត្រឹមតែមួយគ្រាប់ផ្ទះ តើបានពីណាមកទៀត ? កញ្ញាខំក្រឡេកមើលឆ្វេង-ស្តាំចុះឡើង ៗ លុះមិនឃើញអ្នកស្រីទេ នាងក៏ក្រោកដើរទៅក្បែរទូចាន ព្រោះទីនោះមានឈើគូសមួយប្រអប់ដែលនាងបានលួចលាក់ទុក ។ សន្សឹម ៗ លួចយកប្រអប់ឈើគូសនោះយ៉ាងថ្នម ៗ ហើយដកយកមួយគ្រាប់ចេញមក ក្រៅពីនោះលាក់ទុកនៅក្នុងទីដើមវិញ ។ ប៉ុន្តែលុះគ្រាន់តែងាកខ្លួនបំរុងដើរមករកជើងក្រាន ស្រាប់តែសម្រែកមីងសារីផបន្ទរឡើងយ៉ាងខ្លាំង ៗ

- ធ្វើស្ដីហ្នឹះ? ...

ណារ៉ាន់ស្ទើរតែរលំទាំងឈរ ព្រោះសេចក្តីតក់ស្លុតតែខំឆ្លើយថា :

- ចា៎ះ ឥតអីទេ !

- ឥតអីទេ? ...នារីចំណាស់ផ្ទួនពាក្យ ព្រមទាំងវាយឫកខ្លាដើរចូលមករក លូកដៃមកចាប់កដៃស្តាំណារ៉ាន់ប្រចាប់ជាប់ ។ គ្រាប់ឈើគូសនោះនៅជាប់នឹងដៃកញ្ញា ។ ឯសម្រែកអ្នកមីងឃើញក៏រឹតតែខ្លាំងឡើង ៗ

'ឈើគូស'! យកឈើគូសមកលាក់ទុកកន្លែងនេះ

- ចា៎ះ?

ណារ៉ាន់ភ្ញៀវខ្លួនដូចកូនកណ្តុរគ្រុន ! នៅស្ងៀមពុំឆ្លើយមួយម៉ាត់សោះ

- សួរ...ម៉េចក៏មិននិយាយ ?

-'ចា៎ះ វារលត់ទៅ! ...' សំឡេងភ្ញៀវ ៗ តិច ៗ

- រលត់? ...ម៉េចបានជារលត់ ? មិនដឹងឈើគូសថ្លៃទេសម័យឥឡូវ ? ចុះបានឈើគូសពីណាមកលាក់ទុកនៅទីនេះ?

- ចា៎ះ! ទិញមក! ...

- ទឺ! ...អ្នកមុំអ្នកមានផង? ចុះអ្នកមានបានប្រាក់ពីណាមកហ្នឹះ?

- ចា៎ះ! សន្សំទុកអំពីប្រាក់ដែលលោកអ៊ំឲ្យទុកទទួលទានចំណី ។

- វានៅសល់ច្រើនដល់ម្លឹងឬ ? ល្អហើយ ពេលក្រោយវាស្រណុកនឹងបន្ថយទៀត ។

គ្រាន់តែចោលកំទេចពាក្យមហាអំណាចបានប៉ុណ្ណេះ រំពេចនោះ អ្នកមីងសារីផស្ទុះតម្រង់ទៅមើលកន្លែង ដែលណារ៉ាន់លាក់ឈើគូស ។ អ្នកស្រីលូកដៃទៅកន្ត្រៀតសសរនិងទូចានហើយដកយកឈើគូសប្រអប់នោះចេញមក ។ រលែងស្តីអ្វីទាំងអស់ គាត់យកឈើគូសនោះដើរចេញតែម្តងទៅ ។ ធីតាឃើញខំសំឡឹងមើលតាមយ៉ាងសែនស្តាយ ។ ឈើគូសហ្នឹងឯងធ្លាប់ជួយនាងមិនឲ្យអ្នកស្រីខឹង ចុះបើនារីចាស់ដណ្តើមផ្តាច់យកទៅទៀត ចាប់តាំងពីពេលនេះទៅ នឹងត្រូវវិកិនរាល់ពេលធ្វើម្ហូបទៀតជាមិនខាន...

សំឡឹងទៅជើងក្រាន ភ្លើងមិនទាន់ឆេះ ដួងភក្ត្របស់ណារ៉ាន់ធ្លាក់ស្រពោនមួយរំពេច ។

ដឹងធ្វើម្ដេចទើបអាចឲ្យភ្លើងឆេះបាន ? ក្រឡេកទៅក្រឡេកមក ស្រាប់តែឃើញឈើគូសមួយគ្រាប់នៅត្រង់កន្លៀតគំនរឧស ទឹកមុខកញ្ញាក៏បានថ្លាឡើងវិញ តែមិនទាន់ជារីករាយប៉ុន្មានទេ ព្រោះនៅមិនទាន់ដឹងជាដូចម្ដេចទៀត? ធីតាក៏ទៅយកឈើគូសនោះមកចាត់ការបង្កាត់ភ្លើងជាថ្មី ។ នាងខំប្រយ័ត្នប្រយែងជាទីបំផុតដើម្បីកុំឲ្យឈើគូសនោះរលត់ទៅបាន...ទីបំផុត ភ្លើងក្នុងជើងក្រានក៏បានឆេះឡើង ។ នារីកំសត់បញ្ចេញខ្យល់ស្មុគស្មាញមួយភឺសសិន...ហឺះ!...ហើយយកផ្លិតបក់ភ្លើងឲ្យរឹតតែឆេះល្អឡើង ។ នាងក្រោកទៅវាល់អង្ករដាក់ឆ្នាំង លាងយ៉ាងស្អាត យកមកដាក់លើជើងក្រានវិញ ។ លំដាប់តមកក៏បែរមកចិតបន្លែនិងធ្វើកិច្ចការដទៃ ៗ ទៀត...

មិនយូរប៉ុន្មាន សម្លេងមហាអំណាចក៏លាន់ឮឡើង :

- បាយឆ្អិនហើយនៅ?

កញ្ញាកំព្រាងាកមករកម្ចាស់របស់សម្លេង បែរជាឃើញធីតាលោកផាន់វិញ

- 'នៅទេអ្នកបង!...'

ឡារីធីតាផំសាផែ សម្លឹងណារ៉ាន់ដោយបញ្ចេញអាការក្អាញ់!

- 'ប្រញាប់ប្រញាល់បន្តិចឡើង ! ខ្ញុំឃ្លានជិតស្លាប់ទៅហើយ !'
- 'ចុះឲ្យខ្ញុំបង្ខំឲ្យលឿនជាងនេះទៅទៀតឯណាបាន ដូចអ្នកបងឃើញស្រាប់'
- 'យី! នៅតបតករកអញទៀតអ្ហះ? បន្តិចប្ដឹងអ្នកម៉ាក់ឲ្យល្អមើលឥឡូវហ្នឹង!' ឡារីចោលមហាអំណាចហើយក៏ដើរចេញទៅ...

អកុសលផ្ដល់ឲ្យណារ៉ាន់មិនស្រាកស្រាន្តសោះ ។ ទឹកភ្នែកជូតក្បាលជង្គង់ស្ទើររាល់តែម៉ោង គេថ្កៀបគេរឹតសេរីភាពរបស់នាងមិនឲ្យមានបន្តិចបន្តួចឡើយ ។ ចុះដល់ពេលណាទើបណារ៉ាន់បានគេចផុតអំពីរណ្ដៅនរកនេះ?...

ហេតុតែជីវភាពរបស់នាង អាស្រ័យនៅដោយសារគេ ណារ៉ាន់ត្រូវតែតស៊ូទ្រាំសេចក្ដីឈឺចាប់និងសេចក្ដីទុក្ខទោមនស្សទ្វេទនាចិត្តទាំងប៉ុន្មាន ដោយលេបទឹកភ្នែករាល់ពេលព្រលឹមនិងព្រលប់ ។ នារីនឹកថា នេះជាកម្មរបស់នាងមកពីអតីតជាតិ ។ ប៉ុន្តែគង់មានថ្ងៃណាមួយ ព្រះជាម្ចាស់នឹងទ្រង់បើកព្រះនេត្រប្រោសនាងខ្លះជាមិនខាន បើសិនជានាងចេះតែធ្វើសេចក្ដីល្អឲ្យរហូតតែដូច្នេះទៅ ។

ឥឡូវកញ្ញាមានអាយុ ១៦ ឆ្នាំហើយ នាងបានលាសាលាចេញមកអស់ថេរៈវេលា ២ ឆ្នាំគត់ព្រោះតែមីងសារ៉ែឈ្នានីសនាង ។ ធីតាកំសត់រៀនបានត្រឹមថ្នាក់ទី ៥ ទំនើបប៉ុណ្ណោះ ដោយត្រូវអ្នកមីងសំ-ផាន់បង្ខំឲ្យឈប់ ឯឡារីធីតាលោកសំ-ផាន់បានរៀនបន្តទៅទៀត នាងបានរៀនដល់ថ្នាក់ទី ៣ ទំនើបជាតិ នៃអនុវិទ្យាល័យព្រះនរោត្ដម ហើយក៏លាសាលាឈប់ដែរដោយសារ

ចេះតែប្រឡងធ្លាក់ជាញឹកញាប់ និងអាល័យតែបញ្ចេញញ្ញរាងផង ហើយក៏ខ្ជិលរៀនតែម្តងទៅ...

ប៉ុន្តែឡារីមានជោគប្រសើរជាងណារ៉ាន់ ព្រោះនាងបានធ្វើការនៅក្នុងហាងជំនួញមួយ ប្រកបដោយប្រាក់ខែយ៉ាងគ្រប់គ្រាន់ ។ ចំណែកនារីកំសត់យើង នៅតែនឹងផ្ទះធ្វើការក្នុងផ្ទះគ្រប់បែបយ៉ាង ស្រដៀងនឹងស្រីបម្រើរបស់គេដូច្នោះ ។ នាងបានទទួលប្រាក់បំណាច់ក្នុងមួយខែ ៗ ត្រឹមតែ ៧០-៨០ រៀលប៉ុណ្ណោះ ។ ហេតុនោះបានជាកញ្ញាគ្មានសំពត់អាវគ្រឿងអលង្ការអ្វីផ្សេង ៗ ស្រមាប់តាក់តែងខ្លួននឹងគេឡើយ ។ នាងស្លៀកពាក់តែមួយបន្លាស់តាំងពីថ្មីរហូតដល់ចាស់ ។

ឯឡារី សម្បូរណ៍សប្បាយចាយ ដោយឥតនឹកខ្លាចខ្វះឡើយ ។ ក្រៅពីប្រាក់ខែរបស់នាង នៅមានប្រាក់ជំនួយអំពីអ្នកមីងសារ៉ែផងជាច្រើនទៀត ។ ព្រោះហេតុដូច្នេះឯកធីតានៃលោកសំ-ផាន់ ខំតាក់តែងកាយដោយគ្រឿងអលង្ការផ្សេង ៗ តាមតែចិត្តនឹកចង់ តែងស្អាតហួសខ្លួន នាំឲ្យមើលដូចជាប្រដៀវចងគ្រឿងទៅវិញ ។ ចេញដើរទៅមួយគ្រា នាងផ្លាស់មួយឈុត សូម្បីតែពេលទៅធ្វើការក៏ដូចគ្នា...

ឱ! គួរឲ្យអាណិតអ្នកស្រីសារ៉ែណាស់ដែរ ! មិនយូរប៉ុន្មាន ស្វាមីអ្នកស្រីក៏ធ្វើមរណកាលលាអ្នកស្រីទៅកាន់ភពថ្មីបាត់ទៅ ។ ដោយសារតែលោកប្រុសនេះអាស្រ័យសុរាច្រើន ដល់ខែក្តៅដូចជាខែចែត្រនេះ ក៏លោកពិសាច្រើនដែរ ម្ល៉ោះហើយនាំឲ្យលោកខ្យល់ចាប់ក្តៅអន្ទះអន្ទែង រហូតដល់លាអ្នកស្រីទៅកាន់ឋានថ្មីតែម្តងទៅ...។

មិនមែនត្រឹមតែអ្នកស្រីសោកសៅទេ ណារ៉ាន់ក៏រងទុក្ខជាងគេ ។ កាលដែលលោកប្រុសនៅរស់ លោកជួយទំនុកបំរុងនាង តែងលួចឲ្យប្រាក់កាសចាយរាល់ ៗ ថ្ងៃ មិនឲ្យលោកស្រីជ្រាបទេ ។ មួយទៀត បើសិនជាលោកនៅរស់ ទុកជាដូចម្តេចក៏អ្នកស្រីញញើតខ្លះដែរ ។ លុះដល់អស់ពីលោកទៅ មហាអំណាចអ្នកស្រីសពលោកសំ-ផាន់ រឹតតែផ្សាយធំឡើង ៗ ទ្វេមួយដល់ដប់ ។

វេលាល្ងាចថ្ងៃមួយ គ្រួសារអ្នកមីងសារ៉ែផងបានបញ្ចប់ការបរិភោគពេលល្ងាចរួចហើយ ។ ណារ៉ាន់បានទំនេរដៃបន្តិច នាងទើបតែនឹងទុកដាក់ចានក្បានរួច ស្រាប់តែត្រូវអ្នកស្រីសពលោកសំ-ផាន់មានប្រសាសន៍ :

- 'អីណារ៉ាន់ ! មកអាយ !'

មិនបង្អង់យូរ កញ្ញាក៏សត់ដើរត្រុក ៗ ចូលមករកម្តាយធំដែលកំពុងពាក់មុខខ្លា ។ ដល់ហើយដាក់ខ្លួនអង្គុយបត់ជើងដោយសុភាព ចាំស្តាប់ពាក្យបញ្ជារបស់អ្នកមានអំណាច ។

- 'ណារ៉ាន់ !' ពេលនេះ អញសុំរំលឹកឯងម្តង ថ្ងៃមុខថ្ងៃក្រោយ បើសិនជាលោកមេមានីមក

ម៉ែរ៉ាន់ឯងកុំចង់មកបញ្ចេញមុខបញ្ចេញមាត់ឲ្យគេឃើញអ្វី នាំឲ្យអញអាម៉ាស់មុខណាស់ ឮទេ?

នារីកំសត់មិនសូវជាបានពិចារណាឲ្យវែង ក៏ឆ្លើយកាត់មកវិញ :

- ចុះបើគេចេះតែនិយាយមករកខ្ញុំ ៗ
- កុំនិយាយ! កុំតវ៉ា! ឮទេ?

ណារ៉ាន់ត្រូវតែទទួលពាក្យ :

- ចា៎ះ! ៗ
- លោកមេធាវីគេមានឋានៈខ្ពង់ខ្ពស់ណាស់ ជាកូនលោកអ្នកមានធំមួយរូបនៅទីក្រុងភ្នំពេញនេះ ៗ កាលគេឃើញឯងក្រខ្សត់យ៉ាងនេះ គេខ្ពើមគេ ហើយការដែលគេមកលេងផ្ទះនេះ គឺគេជាមិត្តនិងឡាវីកូនស្រីអញ ៗ
- សេចក្ដីពិត គឺគេមកឃើញខ្ញុំខាងក្នុងដោយខ្លួនគេ ៗ
- មិនត្រូវតវ៉ា! ស្ដាប់តែអញនិយាយបានហើយឮទេ?

ណារ៉ាន់ត្រូវបិទមាត់ លេបសេចក្ដីទុក្ខទោមនស្សក្នុងពោះដោយអាការៈយ៉ាងអន្ទះអន្ទែង ៗ អ្នកស្រីសារ៉ែផពោលបន្ត :

- លោកមេធាវីនិងឡាវី គេស្រឡាញ់គ្នា បើអីចឹងឯងកុំមកទទាក់ទទាមពីមុខពីមាត់គេអ្វី នាំឲ្យគេយករឿងយកកេរទៅនិយាយប្រាប់អ្នកដទៃថា នៅផ្ទះអញមានមនុស្សល្ងើយ អញមិនគិតប្រៀនប្រដៅឲ្យចេះរបៀបរបបគួរសមមិនស្គាល់មនុស្សទាបមនុស្សខ្ពស់សោះ ៗ

ណារ៉ាន់ត្រូវនៅស្ងៀម ព្រោះគ្មានអ្វីឲ្យប្រសើរក្រៅពីនៅស្ងៀមឡើយ...

(ទរិវង្ស - គោវិទ, ផ្កាក្រពុំ, ទំព័រ ១ - ១៣)

MODERN NOVEL

ប្រលោមលោក novel

ទរិវង្ស - គោវិទ /reəqwiwuŋ koowɨt/ R. Kovit (a contemporary author)

ប៊ិវ - ឆៃលាង Biv Chhay Leang (a well-known contemporary author of historical fiction)

ក្រពុំ unopened, still in the bud

ផ្កាក្រពុំ name of a modern novel (lit: Unopened Flower)

បក្សី /baqsəy/ female bird; birds in general (Lit)

ក្រុង to cover, to protect off-spring (hens and some birds)

បក្សីចាំក្រុង hero of the novel of the same name (lit: [the one that] the bird protected)

ឧទាហរណ៍ /qutiəhaɑ/ example

ផ្លែក (=ប្លែក) different, strange

អច្ឆរិយៈ /qacchariyeə̆q/ supernatural

វប្បធម៌ /wappəthɔə/ culture; cultural

យកលំនាំតាម to imitate, draw inspiration from

ទិដ្ឋរឿង theme

លើសលុប to exceed, predominate over; exceeding(ly), predominant(ly)

ឯកសារ document, chronicle

ជាលាយលក្ខណ៍អក្សរ in writing

ផ្កាក្រពុំ

Introductory Note

ណារ៉ាន់ Naran (heroine of the story)

ផាន់ Phan (Naran's uncle)

ឪពុកធំ uncle, older brother of either parent

ទុក្ខទោស suffering

ធ្វើទុក្ខទោស to mistreat, to abuse

ត្រាប្រណី to have compassion for

ឥតត្រាប្រណី mercilessly

ឃោរឃៅ cruel, harsh

Text

តម្លៃ value

អ្វី what?

ចំណាស់ elderly; rather old; age

សម្រស់ charm (n)

ប្រៀបបាននឹង is like, can be compared with

ហ៊ះ /qəh/ coll. question particle

ផ្ទួន to repeat; again, over again

បង្ហួស to go beyond (an original or intended destination)

រំអិលខ្លួន to slide over, move over

មៀងភ្នែក to glance sidelong, to look out of the corner of one's eyes

ជ្រែងកែង to put hands on hips (as a sign of authority)

ត្រែវ staringly, wide-eyed

ទុកកន្ទុយសំឡេង to emphasize a word by drawing it out

ជាទីបំផុត supreme, highest; supremely, extremely

សាសនិ...(=ជំរាបប្របសាសនិ)

polite response (inferior to superior)

អាន to read, to pronounce (Lit)

...មើល... /məə/ ...and see; imperative final particle

ចេញលេង take a break between classes

ហេតុផល proof

ច្បាស់លាស់ clearly

អ្នកខ្ពស់ a person of the upper class, member of the elite

កម្រោល brutish, crude, volatile

ប្រយ័ត្នខ្លួន you be careful!

ណ៊ះ /nəh!/ hortatory particle

អ្វីទៀង whatever comes up, in every case, invariably

ក្រខ្វក់ ugly, dirty

បង្កាត់ភ្លើង to start a fire

ក្រុន ៗ in a subdued manner, bent over and inconspicuous (indicative of self-effacement in Southeast Asia)

ជៀសផ្លូវ to go around, to bypass

បញ្ចេញសំឡេង to utter

អស់ចិត្ត to be satisfied

ព្រែកកុយ place name

វកាកោង place name (lit: bent tree)

កោះថ្មី place name (lit: new island)

កើល to run aground

ដល់នូវក្ដីមរណៈ met with death, went to [their] deaths

បន្សល់ទុក to leave [something] behind (a legacy, amount, etc.)

បាឡាត់ស្រុក Assistant District Chief

មុខកំពូល a district in Kandal Province

ខួប year of age (for children); anniversary

សាផៃ Saphay (Naran's aunt)

ទាំងទើសទាំងទាល់ reluctantly

សំផាន់ Samphan (personal name)

មេត្តា to have pity on

តាំងចិត្ត to resolve, intend, be determined to

ចេះដឹង be learned, be educated

នឹងគេ like other people

នេះឯង this (previously referred to)

ទៅកាន់ toward

ឧត្តុងឧត្តម /qutdoŋ-qutdɑm/ eminent, high, excellent

ផ្ទុយគ្នាស្រឡះ completely different (here: contrarily)

រឹងទទឹង stubborn, unyielding

ខ័ក្រែងលោ to fear, be afraid (that)

ធំ (=ធំសាផៃ) short form of /qəwpuk-thom, mdaay-thom/; here: Aunt

ធំផៃ Aunt Phai

ធីតា /thidaa/ girl, daughter (Lit)

ស្របាល same, equal (with regard to time or age)

ស្របាលគ្នានឹង same age as

រូបសម្បត្តិ /ruup-sɑmbat/ physique, looks

ក្ដី...ក្ដី whether...or

ចរិយាសម្បត្តិ /caqriyaa-sɑmbat/ personality, manner

ផ្ដាច់ better; to surpass

ឆ្លៀវឆ្លាត smart, intelligent

បង្ខាំង to confine, to shut up

ការផ្ទះ housework

ហេតុហ្នឹងហើយបានជា this is the reason why

កម្រិត to fix, decree; to allot

គ្រាប់ classifier for matches, grains, pills, etc.

គ្រាប់ឈើគូស a match

នាទីជា to have the duty of

ចំអិន to cook (until done)

បម្រុង for, intended for

ដល់ទៅម្ល៉េះក្ដី even to such an extent

រករឿង to find fault, to provoke

អី (មិនតិចអី) so, very, to any extent (not just a little)

លស់ to skip, miss; intermittent

មិនលស់ពេលណា all the time, incessantly

អីយ៉ូយ exclamation of pain or despair

បន្លឺ to make a sound, cause to be heard, utter; to sound

គូស to strike (a match); to draw (a line), mark through

ចុះឡើងៗ back and forth

ថ្នមៗ gently

ក្រៅពីនោះ the rest, the others

ដើម origin; original

បំនុង in order to, with the intention of

សម្រែក yell, shout (n)

បន្ទរ to join in (singing); here: to speak up

ស្ដី (ធ្វើស្ដី) what? (what are you doing?)

រលំ to fall down

រលំទាំងឈរ to fall down from a standing position, to collapse

ឆ្លើយឆក to find an excuse

ផ្ទួនពាក្យ to repeat (in agreement)

វាយឫកខ្លា to act ferocious (lit: act like a tiger)

លូកដៃ to reach for

ច្របាច់ to squeeze (with the hand)

ជាប់នឹងដៃ in the hand

ញ័រខ្លួន to tremble

កណ្ដុរ /kɑndao/ mouse, rat

អ្នកមុំ Young Lady (sarcastic)

បន្ថយ to lessen, decrease (tv)

ចោលកំទេចពាក្យ to get in the last word, to make a sarcastic response

កន្លៀត nook, corner

ធីតាយើង the daughter (lit: our daughter, i.e. the one we're talking about)

ហ្នឹងឯង that same thing

ចុះបើ but if

កិន to blame, to scold (Coll; lit: to crush)

ដួងភក្ត្រ /duəŋ-phĕəq/ face (Lit)

ធ្លាក់ស្រពោន to sadden, to fall (of one's face)

ក្រឡេកទៅក្រឡេកមក look here and there

គំនរ pile, stack (n)

អុស /qoh/ logs, firewood

ចាត់ការ to prepare (to)

ប្រយ័ត្នប្រយែង be careful

បញ្ចេញខ្យល់ស្ញុគស្ញាញ to sigh in relief

ភឹស expulsion of breath (verbal classifier)

ហ៊ឹះ /hɨh/ interjection of frustration, sigh of relief

ផ្លិត a hand fan

ចិត to slice, to cut up

បែរជា instead

ឡាវី Lavi (Saphay's daughter)

ក្ដាញ់ exasperated

ប្រញាប់ប្រញាល់ to hurry

ឯណាបាន where can one...?

តបតរក to sass, talk back to

បន្តិច Watch out or I'll...

អ្នកម៉ាក់ Mother (in snobbish circles)

ឱ្យល្អមើល really make a spectacle

ឥឡូវហ្នឹង right this minute

ចោលមហាអំណាច to show one's authority

ផ្ដល់ឱ្យ to happen to

ស្រាកស្រាន្ត to be abated, relieved

ទឹកភ្នែកជូតក្បាលជង្គង់ to cry, to suffer (lit: to dry one's tears with one's knees)

ថ្កៀប to grip with pincers

រណ្ដៅ ditch

ដោយសារគេ to depend on others

តស៊ូ to struggle, resist, bear up

ទោមនស្ស /too-mənŏəh/ frustrated, disgusted with oneself

វេទនាចិត្ត to suffer (mentally)

លេបទឹកភ្នែក to suffer (lit: to swallow one's tears)

គង់មានថ្ងៃណាមួយ one of these days

ថេរៈ period of time, duration

ប្រឡងធ្លាក់ to fail examinations

បញ្ចេញរាង to show off (one's body)

ជោគ luck

ហាងជំនួញ store, business office, commercial firm

ប្រាក់ខែ salary

នៅតែនឹងផ្ទះ just stay home

គ្រប់បែបយ៉ាង of all kinds

ស្រដៀងនឹង just like

ស្រីបម្រើ female servant

ប្រាក់បំណាច់ bonus, commission; here: allowance

គ្រឿងអលង្ការ /krɨəŋ-qalaŋkaa/ jewelry

បន្លាស់ classifier for changes of clothing

សម្បូរណ៌សប្បាយ affluent

ប្រាក់ជំនួយ supplementary allowance, subsidy

ឯកធីតា the only daughter

តាមតែចិត្តនឹកចង់ according to the whims

ហួសខ្លួន excessive, exaggerated

ដូចជាប្រចៀវចងគ្រឿង gaudy, garish, overdressed (lit: like a bat wearing jewelry)

ឈុត classifier for sets (of dishes, clothes, etc.)

សូម្បីតែ even

គួរឱ្យអាណិត too bad for..., unfortunate, one should pity

មិនយូរប៉ុន្មាន not too long

ភព /phup/ world

លោកប្រុស the husband (polite, very formal)

សុរា liquor

ខ្យល់ចាប់ to have a fainting spell

អន្ទះអន្ទែង agitated, impatient, restless

សោកសៅ to grieve

ទំនុកបំរុង to take responsibility for, provide for

ទុកជាដូចម្ដេច somehow, one way or another

អត់ពី without

អត់ពីលោកទៅ after he was gone (here: when he had died)

ទ្វេមួយផល់ដប់ ten-fold

ទំនេរវៀជ to have free time

ចានក្បាន dishes

អី hey! (interjection)

មកអាយ come here (archaic)

ម្ដាយធំ aunt, older sister of either parent

ពាក់មុខខ្លា to glower, scowl (lit: wear a tiger's face)

ផាក់ខ្លួន to stoop

អង្គុយបត់ជើង to sit with legs folded to one side

ថ្ងៃមុខថ្ងៃក្រោយ in the future

មោនី Moni (personal name)

ម៉ែ term of address for woman of same age (used sarcastically here)

បញ្ចេញមុខបញ្ចេញមាត់ to show (oneself) often, put (oneself) in the public view, make (oneself) conspicuous

អាម៉ាស់មុខ to be ashamed, to lose face

ទទួលពាក្យ to accept (criticism, orders, etc.) without question, to obey

មួយរូប a person

ខ្ពើម to be disgusted by

ការដែលគេមកលេង... the fact that he comes to visit

សេចក្ដីពិត the truth

ខាងក្នុង inside (the other room, not in the living room)

ដោយខ្លួនគេ by himself, of his own accord

អីចឹង(=អញ្ចឹង) therefore (Coll)

ទទាក់ទទាម to be in the way, to interfere

មកទទាក់ទទាមពីមុខពីមាត់គេ to come and bother them, get in their way

កេរ(=កេរ្ដិ៍) reputation

ឈ្លើយ odd, droll, not appropriate

ប្រៀនប្រដៅ to educate, instruct, advise

របៀបរបប manner, manners

ស្ងៀម quiet, still

ប្រសើរ good, proper

៣. បក្សីចាំក្រុង

ដោយ

ប៊ិវ ឆៃ លាង

បុព្វកថា

បក្សីចាំក្រុងលុះអាយុបាន ២៣ ឆ្នាំក៏បបួលតាគោហ៊ិទៅព្រះរាជធានីមហានគរដើម្បីនឹងរកម្តាយអ្នក ។ លុះទៅដល់កណ្តាលផ្លូវ បក្សីចាំក្រុង តាគោហ៊ិ និងនាយឬ ជួយរំដោះនាងបុស្បគន្ធ ពីកណ្តាប់ដៃ ពលក្ការឱ្យរួចពីទុក្ខទោស ។ ដំណើរទៅព្រះរាជធានីមហានគរក៏ត្រូវអាក់ខាន...

អត្ថបទ

មិត្តយើងធ្វើដំណើរអស់ ១ ថ្ងៃ ១ រាត្រី ទើបបានមកដល់ជាយទីក្រុង វេលាថ្ងៃរសៀល ។ ឃើញឈប់សំរាកនៅក្រោមម្លប់ឈើ ចងសេះឱ្យស៊ីស្មៅនៅជិតនោះ ។ បក្សីចាំក្រុងទាញព្រួញ ១ មកដាក់ផ្ទាប់នឹងខ្សែធ្នូ ដើម្បីនឹងល្បងថ្វីដៃមើល ប៉ុន្តែខណៈនោះស្រាប់តែឮសូរសំឡេងស្នែងប្រកូកនឹងសូរសន្ធាប់ជើងសេះលាន់ទ្រហឹងពេញព្រៃ អ្នកក៏ដាក់ធ្នូចុះ ។ បន្តិចទៀត យើងឃើញកងទ័ព ១ ក្រុមកំពុងដេញចាប់ប្រើសមួយ ។ ប្រើសនេះរត់មកដល់មុខមិត្តយើងទាំងបីក៏ដួលដេកទៅ ដ្បិតវាត្រូវរបួសនឹងអស់កម្លាំងខ្លាំងពេក ។

តាគោហ៊ិនឹងបក្សីចាំក្រុង មានសេចក្តីអាណិតដាប់ចិត្តធម៌មេត្តា ក៏ទៅលើកសត្វរងគ្រោះយកទៅលាក់ក្នុងគុម្ពោតជិតខាង ធ្នូនិងដាវលាក់នៅទីនោះដែរ រួចត្រឡប់មកអង្គុយកន្លែងដដែលវិញ ធ្វើឫកពាជាអ្នកដំណើរទុគ៌ត ។

លំដាប់នោះ ទ័ពសេះក៏មកដល់ ឈប់នៅចំពោះមុខយើង ។ ទាហានទាំងនោះនៅក្រោមបញ្ជាការរបស់ឧកញ៉ាក្រឡាហោមពលក្ការ ដែលយើងបានឃើញមុខលោកចំនួន ១៦ ឆ្នាំហើយ ។ វ័យពលក្ការមិននៅក្មេងដូចកាលគ្រាមុនទេ ឆ្នាំទី ៣៨ បានរត់មកទាន់លោកក្នុងថ្ងៃនេះ ។

គាត់ឯងបីនាក់ហ្នឹងមកពីស្រុកណា? ពលក្ការស្រែកសួរ ឃើញប្រើសមួយរត់មកទីនេះទេ?
- បាទប្រាស តាគោហ៊ិឆ្លើយយ៉ាងគោរព ពួកយើងជាអ្នកដំណើរស្វែងរកទទួលទាន ហើយពុំបានឃើញប្រើសរបស់លោកទេ ។

ក្រឡាហោមមិនចេញស្តី ចោលភ្នែកទៅលើរូបរាងកាយនាយឬមិនដាក់ភ្នែក ព្រោះគេឃើញមាឌវាធំសម្បើមចំឡែកគួរឱ្យខ្លាច ។ ពលក្ការលោតចុះពីខ្នងសេះ សំដែងអាការឃោរឃៅមើលងាយអ្នកខ្សត់ខ្សោយ ។

- កញ្ញាសំងនិយាយថាមិនឃើញប្រើសដូចជាមិនទំនងសោះ ក្រឡាហោមនុញស្សាតាគោហ៊ី ដោយសំដីប្រមាថ ឯងយកទៅលាក់ឯណា ឱ្យមកអញយ៉ាងឆាប់?

ខណៈនោះ ចតុប្បាទដែលតាយកទៅលាក់ដើម្បីជួយសង្គ្រោះវានោះក៏ប្រកាច់ព្រុលប្រាល ទធាក់ជើងដើង ជាហេតុឱ្យពលការសើច ចាប់សក់ក្បាលតាគោហ៊ីជាប់ថែមទាំងវាយគាត់ ១ ជើងទៀតផង ។

- ម្តេចក៏លោកហ៊ានវាយឪពុកខ្ញុំ? បក្សីចាំក្រុងស្រែកសួរ ដោយចាប់ជើងពលការ ។

ពលការលែងសក់ក្បាលបុរសចាស់ ងាកមកវាយចៅកម្លោះ តែវាយមិនបានដោយអ្នករហ័ស ចាប់កជើងវាជាប់ម៉ឹងដូចដង្កាប់ ។ នាយហ្លួឃើញដូច្នោះ ក៏ស្ទុះរត់ទៅយកដាវដែលលាក់នោះមកឱ្យបក្សីចាំក្រុង តែមិនបានដូចបំណងព្រោះពួកវិរជនចូលទៅប្រយុទ្ធជាមួយវា ។ ហ្លួមិនជាអ្នកកំឡាំងខាងដាវទេ វាបានចាប់បោកខ្ទាំងរលំដួលដេកអស់ជាច្រើននាក់ ។

ពួកទាហានព្រួតចាប់ហ្លួវីវក់ ខ្លះកាប់ ខ្លះចាក់ តែធ្វើហ្លួមិនបែក ហ្លួចាប់បានអាម្នាក់លើកឡើងវងកាត់ធ្វើជាអាវុធ មនុស្សបែបនេះគ្រវីម្តង ៣ បោកត្រូវក្បាលពួកសត្រូវដួលរលដូចគេហាលអាខ្លះបាក់ភ្លៅ អាខ្លះបែកក្បាល ស្លាប់មិនតិចទេ ។ ឯតាគោហ៊ីត្រូវខ្ទាំងក៏ទ្វជាប់គាត់កាប់ដកឃ្លារត់ ។ បក្សីចាំក្រុង ដៃទទេត្រូវអាពលការដេញកាប់ម្តង ៣ រហើយសក់ប្រហោងអស់ពោះពុង ។ អ្នកដោះខ្លួនមកដល់ទីលាក់ដាវហើយ ក៏ចាប់អាវុធនេះក្រោកឡើងស៊ីសងគ្នាយ៉ាងពេញកម្លាំង ។

កំពុងប្រយុទ្ធជាប់ដៃ ស្រាប់តែទាហានម្នាក់ជិះសេះមកដល់ហើយស្រែកថា :

- ប្រុង! ព្រះករុណាជាអម្ចាស់ស្តេចយាងមកហើយ ។ ពលការលែងតដៃនឹងគូសត្រូវ បញ្ជាឱ្យប្រមូលកងសេនាឈរជាពួកតាមបណ្តោយផ្លូវ ដើម្បីនឹងធ្វើគារវភាពជាកិត្តិយសដល់ព្រះមហារាជ ។ ចំណែកមិត្តយើងទាំងបីនាក់ ពេលនោះតើមានសភាពដូចម្តេចខ្លះ?

តាគោហ៊ី បក្សីចាំក្រុងនឹងនាយហ្លួយល់ថាជាឱកាសដ៏ប្រសើររបស់ខ្លួនហើយ ។ មិត្តយើងឡើងជិះសេះប្រុងដោះខ្លួនរត់ តែត្រូវទាហានពលការ ២០ នាក់ព័ទ្ធជាប់ក្រញាំ ។

លំដាប់នោះ ព្រះទីនាំងមួយទឹមដោយអាជានេយ្យបានពួតផែ្សងពពកធូលីមកឈប់ង៉ក់នៅកណ្តាលជួរមនុស្ស ។ អ្នកបររទេះនេះមានភេទជាស្រ្តី មិនមែនតួអង្គព្រះចមពលទ្បើយ ។ គឺជានារីឆើតឆាយ ១ រូប មានវ័យប្រមាណ ២០ ឆ្នាំប៉ុណ្ណោះ សាច់សភ្លឺ វង់ភក្រ្តក្រពុំខ្លី បបូរមាត់ស្រស់ក្រហមតាមធម្មជាតិ សម្លៀកបំពាក់រំលេចដោយក្បាច់សុវណ្ណយ៉ាងវិចិត្រ ។ កញ្ញាចុះមកដី នាំយកទឹកមុខដ៏ភិតភ័យមកបង្ហាញលោកក្រឡាហោម ៣ ហាក់ដូចជាភ្ញាក់ តែពុំបានបង្គាប់ឱ្យកងឯកភាពរបស់ខ្លួនសំដែងសេចក្តីគោរពដល់យុវតីនេះទេ ។ លោកធ្វើមុខយ៉ាងមាំ ស្ងាត់ស្ងៀម ចាំស្តាប់វាចានាង ។

ថ្វីដ្បិតតែទ្រង់យាត្រាមក ១ អង្គឯង កណ្ដែងកណ្ដោចកណ្ដាលព្រៃ ព្រះនាងបុស្បគន្ធ ព្រះទេពីព្រះចៅសត្វពអនុរាជ នៅតែរក្សាព្រះទ័យក្លាហានជាដរាប ។ ម្ចាស់ក្សត្រីគួរណាស់តែបានទទួលកិត្តិយសពីឧកញ៉ាក្រឡាហោម តែទ្រង់បែរជាត្រូវកងទ័ពបែរខ្នងទទួលវិញ ។ ពុំមានព្រះសវនីយថាដូចម្ដេច ព្រះនាងបានយាងទៅកាន់ដៃពលការ ហើយទ្រង់បន្លឺព្រះវាចារន្ធត់ញាប់ញ័រឡើង ។

- ជួយខ្ញុំផងលោក ! ...ជួយខ្ញុំផង! ព្រះអង្គកាត់ទោសប្រហារជីវិតខ្ញុំហើយ ! ...ខ្ញុំដឹងខ្លួនមុនក៏បានរត់មកសុំឱ្យលោកជួយ ! ខ្ញុំមិនត្រឡប់ទៅឯប្រាសាទវិញទេ ។

មិត្តយើងទាំងបីបានចាប់អារម្មណ៍ទៅលើព្រឹត្តិការណ៍នេះជាខ្លាំង ។ បក្សីចាំក្រុងទើបនឹងឃើញរូបស្រីក្នុងវាំងជាលើកដំបូង អ្នកព្រឺព្រួចសម្លឹងភក្ត្រព្រះនាងមិនដាក់ភ្នែក ហើយខំផ្ទៀងត្រចៀកស្ដាប់វាចានាងតទៅទៀត ។

លុះមិនឮសំដីពលការ ឆ្លើយតបមកវិញដូចម្ដេចនោះ បុស្បគន្ធក៏មានព្រះសវនីយទៀតថា :

- ឱ ! លោកមិនអាណិតខ្ញុំទេ? ម្ដេចលោកធ្វើព្រងើយតោះតើយដូច្នេះ ? ខ្ញុំប្រថុយដោះខ្លួនមកនេះសង្ឃឹមតែលើរូបលោកប៉ុណ្ណោះ ។

- ចាប់ព្រះនាងឱ្យជាប់ ! ពលការបង្គាប់ ទូលព្រះបង្គំត្រូវនាំព្រះនាងទៅថ្វាយព្រះករុណាជាម្ចាស់វិញ ។

សម្លេងនេះហាក់នឹងមកក្ដិចបេះដូងស្រីតន់ឱ្យរបូតចេញទៅ សេនាបានចោមរោមព្រះនាងមួយរំពេច ។

- សុំលោកអាណិតខ្ញុំទៅ ! បុស្បគន្ធស្រដីគួរឱ្យអាណិត ឱ! ...ជួយខ្ញុំផងលោកអើយ ! ខ្ញុំគ្មានធ្វើអ្វីខុសទេ ! កំហុសរបស់ខ្ញុំគ្រាន់តែដោះលែងមនុស្សទោសពីរនាក់ប៉ុណ្ណោះ... ។

ទោះនាងខំស្រែកខំអំពាវនាវ បញ្ចេញរឿងហេតុឱ្យគេដឹងយ៉ាងណាក៏ទាហានទាំងនោះមិនអាចស្ដាប់ឮឡើយ ។ គ្មាននរណាម្នាក់ហ៊ានចេញមុខទៅជួយព្រះនាងឡើយ... បក្សីចាំក្រុងមានបេះដូងលោតកញ្ច្រាល ហាក់នឹងរបើកសន្ទុះទ្រូងចេញមក ។ អ្នកបានស្រង់រសផ្អែមនៃវាចាស្រីមិនមានភ្លេចឃ្លាណាមួយសោះ អ្នកឮថា កំហុសរបស់នាងគ្រាន់តែដោះលែងមនុស្សទោសពីរនាក់ប៉ុណ្ណោះ ។ មាណពក៏ញាក់សេះបំបោលផ្លោះផ្លោងកាត់ខ្លាំងសត្រូវ ពួកវាដួលប្រចងាប់ប្រចងើល តាគោហ៊ើនឹងនាយហ្វូកក៏ឆ្លៀតឱកាសនោះបង្ហោះជំនិះទៅជាមួយដែរ ។

ពួកកងទ័ពផ្អើលដេញតាមយ៉ាងកងរំពង ។ មិត្តយើងមកដល់ផ្លូវបែកមួយ ក៏បែកគ្នាហើយសន្មតទៅជួបគ្នានៅផ្លូវខាងមុខ ។ តាគោហ៊ើដោះខ្លួនចូលព្រៃ បក្សីចាំក្រុងនឹងនាយបំរើទៅកាន់មាគ៌ា ១ ដែលយើងឃើញព្រះទីនាំងកំពុងបរយ៉ាងលឿន ដោយមានទ័ពសេះ ១ ក្រុមតូចនៅអមមុខក្រោយ ។ មាណពនឹងសហការីបានបង្ខំពាជី ឱ្យបោលមានល្បឿនដូចខ្យល់ ។ មិនយូរប៉ុន្មាន

ជំហានសេះមិត្តយើងទាំងពីរក៏មកទាន់រទេះសេះ ។ ហួយឹតធ្នូបាញ់ បក្សីចាំក្រុងក៏បាញ់ដែរ បាញ់ត្រូវខ្មាំងស្លាប់ធ្លាក់រាយតាមផ្លូវ ។

រថយានបរមកដល់ដំបូកធំ ១ ក៏ឈប់ស្ងៀមត្រង់នោះ ។ ទាហាន ៨ នាក់ដែលនៅរស់បានឈមមុខមកតយុទ្ធដោយដាវនៅលើខ្នងសេះ ។ នាយកងទ័ពម្នាក់បានចាត់ពល ៤ នាក់ឱ្យបន្តដំណើរពង្រត់ព្រះនាងក្សត្រីទៅមុខទៀត ។ គ្នាយើងពីរនាក់តនឹងដាវ ៤ របស់បច្ចាមិត្ត ការប្រឡូកអាវុធនេះអស្ចារ្យណាស់ ហួកាច់ដាវចោលព្រោះវាខឹងនឹងដាវមិនដូចចិត្តវា វាស្ទុះទៅចំអាមួយនោះធ្លាយបំពង់ក...អាម្នាក់ទៀតលោតមកជួយ ហួចាប់យួរតែដៃម្ខាងបោកខ្ទាក់ទៅលើដីទល់ផ្អុកធ្វើមាត់ស្ញេញ...ដាវចៅបក្សីចាំក្រុងបានហូតជីវិតអាសត្រូវទាំងពីរសូន្យ នៅគ្រាជាបន្ទាប់ រួចអ្នកទាំងពីរញាក់អាជានេយ្យដេញតាមអាបួននាក់ខាងមុខទៀត ។

ខណៈនោះតាគោហ៊ិបានមកទាន់ហើយ គាត់ក៏ស្រែកឡើងថា :

- អាពលក្ការលើកគ្នាសន្ធឹកមកតាមក្រោយហើយ ។

មិត្តទាំងបី បានមកទាន់ព្រះទីនាំងនៅក្នុងព្រៃដីមានឈើខ្ពស់ធំ ៗ ។ ចៅបក្សីហក់ពីសេះទៅកាប់សារថីត្រូវ ១ ដាវធ្លាក់ស្លាប់ ១ រំពេច រទេះឥតអ្នកបរក៏នៅតែវិលកង់ទៅមុខដរាប

តាគោហ៊ិនឹងនាយហួបំផាយជំនិះ ដ៏ក្លាហានរបស់ខ្លួនដេញតាមរទេះនោះជាបន្ទាន់ ។ ឯបក្សីចាំក្រុងត្រូវពួកវាបីនាក់ព័ទ្ធជាប់ វាបង្ហើរដាវយ៉ាងសាហាវមកលើខ្លួនអ្នកកម្លោះ ៗ បានមុជគេចពួនទៅក្រោមមែកឈើធំ ១ ដែលមានរាងកោងដូចឥន្ទធនូ ។

អាពាលទាំងពីរកាប់របើកសាច់ឈើ បើសិនជាត្រូវម្ល៉េះអ្នកគ្មានឆ្អឹងធ្វើបុណ្យទេ ។ សូរសន្ធឹកជើងសេះកាន់តែមកជិត មាណពយល់ថាជាពេលគ្រោះថ្នាក់យ៉ាងធំរបស់អ្នកពិត ។ អ្នកដោះខ្លួនរត់ តែអាពីរនាក់នៅតែតាមកាប់យ៉ាងកិតពីក្រោយ ។ អ្នកធ្វើជាទាក់ជើងដួលហើយត្រមង់ចុងអាវុធពេញអំណាចចំពោះវាទាំងពីរនាក់ ដូចយកដែកទៅដេរខ្លួនវាផ្ទាប់តែម្តង ។

យុវជនហូតដាវដែលមានពណ៌ក្រហម មកបញ្ចូលក្នុងស្រោមរួចឡើងផែលសេះទៅតាមមិត្តអ្នកទាំងពីរ ។ សេះអ្នកលឿនអស្ចារ្យ អ្នកបានមកទាន់តាគោហ៊ិនឹងនាយហួដែលខំប្រឹងបំបោលជំនិះឥតងាកក្រោយ ។ ក្នុងព្រះទីនាំងព្រះនាងបុស្បគន្ធពុំមានកម្រើក ព្រះវរកាយដល់តិចតួចឡើយ ដោយទ្រង់សន្លប់ បាត់ព្រះស្មារតីទៅហើយ ។ សេះចេះតែបោលគ្មានស្គាល់ទិសដំបន់អ្វី ។ កម្លោះបានលោតពីខ្នងសេះទៅចាប់ទប់ខ្សែព្រះទីនាំងជាប់ កង់យានវិលមួយ ៗ រួចក៏ឈប់ស្ងៀម ។ បក្សីចាំក្រុងលើកត្រកងខ្លួននារីផ្ទុកលើខ្នងសេះ កាត់ចំណងចេញពីដៃនាង គឺជាលើកដំបូងហើយដែលមាណពបានប៉ះពាល់ខ្លួនស្ត្រីភាពក្នុងជីវិតនេះ ។

សំឡាញ់យើងទាំងបីបានគេចសេះចូលទៅក្នុងព្រៃនាំព្រះវររាជទេពីទៅជាមួយ ដោយឥត

បានជួបប្រទះនឹងឧបសគ្គអ្វីឡើយ ៗ កងទាហានពលក្ការបាត់ដាន រកតាមយើងមិនបាន ៗ

(ប៊ិវ-ចៃ-លាង, បក្សីចាំក្រុង, ទំព័រ ១៤០-១៤១)

បក្សីចាំក្រុង

Introductory Note

តោហ៊ី personal name

មហានគរ Angkor

អ្នក his or her (3rd person possessive pronoun; Lit)

ហួ personal name

បុស្សគុន /bohsəkŭən/ personal name

ពលក្ការ /pŭəlləkaa/ personal name

អាក់ខាន interrupted

Text

មិត្តយើង our friends (the three who took the trip)

ព្រួញ arrows

ខ្សែធ្នូ the string of a bow

ស្នែងប្រកួក a wind instrument made of animal horn

សន្ធាប់ (=សន្ធឹក) a deafening noise

ប្រើស deer, elk

ជាប់ចិត្ត attached (to), involved (with)

ធម៌មេត្តា compassion

រងគ្រោះ victimized

លំដាប់នោះ at that time

បញ្ជាការ command (n)

វ័យ age (Lit)

តាស់ឯង you (Pej)

ចេញស្តី to speak

រូបរាងកាយ body, figure

មិនដាក់ភ្នែក fixedly (of staring)

កញ្ចាស់ឯង you cld goat, old man (disrespectful)

ទំនង likely, credible

មិនទំនង doesn't make sense

ចតុប្បាទ /cattobaat/ quadruped

ប្រកាច់ to twitch, to have muscular spasms

ព្រុស sound of falling or thrashing about

ព្រុសព្រាស id.

ទាត់ដៃជើង to kick the arms and legs (iv)

ចៅកម្លោះ young man

មុឹង tightly

ដង្កាប់ pliers

រលំ to fall from a standing position

កំប្រាំងខាង good at...

ព្រួត to join forces against, gang up on

វីវក់ frantically, violently

ធ្វើ...បែក to be able to beat off, overcome

អាម្នាក់ one (of them)

រងកាត់ to ward off a blow (here: use as a shield)

រេល to collapse, to spread out (from a pile)

រេលដូចគេហាល lying all over the place (lit: spread about as if someone had laid [them] out [on purpose])

ភ្លៅ thigh(s)

ផ្អាក to pause

ដៃទទេ empty-handed

រហើយសក់ brushing the hair (i.e. barely missing the head)

ពោះពុង stomach

ប្រហោងពោះពុង to have an empty or sinking feeling in the stomach

ដោះខ្លួន to escape, to make a getaway

ស៊ុលងគ្នា to contest, challenge, compete (with)

ជាប់ដៃ engaged, engrossed

ប្រុង to be on guard, alert

តដៃ to fight back

គូសត្រូវ /kuu-sattrəw/ adversaries, opponents

គារវភាព /kiərəweəq-phiəp/ salute, greeting

ព្រះមហារាជ the king

ក្រញង់ stiff, rigid; here: unable to move or escape

ព្រះទីនាំង royal conveyance

អាជានេយ្យ /qaacəniy/ horse (Lit)

ពួត to wring, to twist; here: to stir up, to churn up

ងក់ abruptly (of stopping)

តួអង្គ body, person (Roy)

ព្រះចមពល /preəh-cɑɑm-puəl/ the king (Lit)

វង់ភក្ត្រ /wuəŋ-pheəq/ face (Lit)

ក្រពុំខ្ចី young, tender

សុវណ្ណ /sowan/ gold (Lit)

វិចិត្រ nice, refined

កងឯកភាព personal guard unit

មុខម៉ាំងម៉ាំ serious face, stern face

យាត្រាមក to come (Roy)

មួយអង្គឯង alone (Roy)

កណ្ដែងកណ្ដោច (=កណ្ដោចកណ្ដែង) lonely, desolated

ព្រះទេពី wife (Roy)

ព្រះចៅ the king

សន្ធពអនុរាជ personal name

រក្សាព្រះទ័យ to comport oneself (Roy)

ម្ចាស់ក្សត្រី queen

គួរណាស់តែបាន really should have

ព្រះសវនីយ /saqwənəy/ to talk (Roy)

រន្ធត់ frightened

កាត់ទោស to condemn, to sentence

ដឹងខ្លួនមុន to know in advance

ផ្ទៀងត្រចៀក to give ear, pay strict attention

តោះតើយ unconcerned

ក្តិច to pinch

បេះដូង heart

ក្តិចបេះដូង...ទ្រាំរបូតចេញទៅ break one's heart (lit: pinch the heart until it falls out)

តន់ precious, beloved

ឡោម to encircle, to surround

មនុស្សទោស prisoner

ទោះយ៉ាងណា...ក៏ no matter what, even though...

ចេញមុខ to dare, defy, stand up

កញ្ច្រាល to rear up, buck, jump (of a horse, etc.)

សន្ទះទ្រូង sternum, chest

ស្រស់ to taste, hear, smell, partake of

ស្រី her (i.e. of the girl)

មាណព /miənup/ young unmarried man

ញាក់ to jerk, to shake

ញាក់សេះ to shake (the reins) of a horse (to make him go)

បំបោល to cause (animals) to run

ផ្លោះ to make a flying leap

ផ្លោង to throw over

ផ្លោះផ្លោង flying over, soaring over

ប្រងាប់ប្រងើល falling and rolling, higgledy-piggledy

បង្ហោះ to fly (something), to cause to fly

កងរំពង tumultuous(ly), noisi(ly)

ផ្លូវបែក crossroads

នាយបំរើ male servant

មាគ៌ា /miəkiə/ route, road; way, line, policy

សហការី /sahaqkaarəy/ colleague, collaborator

ពាជី horse (Lit)

រថយាន carriage

ឈមមុខ to face, face up to

ប្រឡូក to be entangled (in a fight, etc.)

មិនដូចចិត្ត not satisfactory

យួរ to hold or carry in one hand

ទល់ផ្អក to get hurt (from falling)

ហូតជីវិត to kill (Eleg)

លើកគ្នា to join forces, cooperate

សន្ធឹក many, a large number, in great numbers

ហក់ to jump at, to lunge

សារថី driver (of a carriage)

បំផាយ to cause to gallop

បង្វើរ to cause to fly (here: to brandish)

ឥន្ទធនូ /qəntənuu/ rainbow (Indra's crossbow)

ពាល young wicked person, ruffian

សាច់ឈើ inner flesh, core (of a tree), meat (fruit)

កាប់វះបើកសាច់ឈើ lay open the flesh of the tree

អ្នកគ្មានឆ្អឹងធ្វើបុណ្យទេ there would be nothing left of him (lit: he would have no bones left to have a [funeral] ceremony)

កិត on the tail, close behind

ទាក់ជើង to trip (iv)

តម្រង់ to aim, direct (at)

ពេញអំណាច in full force

ហូត withdraw, pull out, extract (from a sheath, etc.)

ស្រោម sheath

ផែល to jump on (horse, bicycle, etc.), to jump astride

វរ /wɔrĕəq/ beautiful, precious, desirable

ព្រះវរកាយ beautiful body (Roy)

ព្រះស្មារតី consciousness (Roy)

គ្មានស្គាល់ទិសដំបន់អ្វី without knowing where to go, uncontrolled

ស្ត្រីភាព /sətrəy-phiəp/ woman, 'a real live girl'

ចៃដន្យ /cay-dɑn/ circumstance

ព្រះវររាជទេវី queen

បាត់ដាន to lose track, lose the trace

ស្រុកខ្មែរមានភ័ព្វវាសនាដ៏ក្រៃលែង ដោយមានឯកសារជាលាយលក្ខណ៍អក្សរដ៏ច្រើនដែលអ្នកប្រាជ្ញខ្មែរជំនាន់មុន បានព្យាយាមយកចិត្តទុកដាក់ចារជាសាស្ត្រាជាច្រើន ទុកមកដល់សព្វថ្ងៃនេះ ។ ក្នុងពេលនេះយើងលើកយកតែឯកសារមួយប្រភេទមកនិយាយសិនគឺ : 'ឯកសារប្រវត្តិសាស្ត្រ' ។ ឯកសារប្រវត្តិសាស្ត្រ ក៏ដូចជាឯកសារប្រភេទផ្សេង ៗ ទៀតដែរ ច្រើនតែតម្កល់ទុកនៅក្នុងវត្តអារាមផ្សេង ៗ នៅក្នុងស្រុកខ្មែរ ។ លុះមកដល់ពេលថ្មី ៗ នេះ ទើបគេយកមកតម្កល់នៅបណ្ណាល័យផ្សេង ៗ នៅភ្នំពេញ ។ ប៉ុន្តែយើងស្មានថានៅមានឯកសារជាច្រើនទៀតដែលរាត់រាយរប៉ាត់រប៉ាយ មិនទាន់បានរកឃើញយកមកពិនិត្យមើល ឬបោះពុម្ពផ្សាយនៅឡើយទេ ។

ឯកសារទាំងនេះ ដូចឯកសារទាំងឡាយនៅប្រទេសនានាដែរ មិនសូវស្របគ្នាប៉ុន្មានទេ ។ ដូចជារឿងឃ្លាំងមឿង សាស្ត្រាវត្តកំពង់ត្រឡាចក្រោមថា គាត់ជាអ្នកទំនុកបំរុងធ្វើការថ្វាយព្រះចន្ទរាជា ។ ឯកសារក្រុមល្ខោនជាតិថា ឃ្លាំងមឿងធ្វើការបំរើព្រះជ័យអស្ចារ្យ បុត្រព្រះចន្ទរាជា ។ ប៉ុន្តែមានសេចក្តីខ្លះក្នុងឯកសារទាំងពីរនេះដែលគួរឲ្យចាប់អារម្មណ៍ : ឯកសារកំពង់ត្រឡាចក្រោមនិយាយថា ឃ្លាំងមឿងជួយទំនុកបំរុងព្រះចន្ទរាជានៅពេលដែលទ្រង់ចូលមកដល់ដែនដីខ្មែរវិញ ក្រោយទ្រង់បោកស្តេចសៀមថាទ្រង់ទៅទាក់ដំរីសមកថ្វាយ ។ ឯឯកសារក្រុមល្ខោនជាតិថា ឃ្លាំងមឿងទៅក្រាបថ្វាយបង្គំសុំបំរើព្រះជ័យអស្ចារ្យ ក្រោយស្តេចចូលក្នុងដែនកម្ពុជា ដោយបោកស្តេចសៀមថាទ្រង់ទៅទាក់ដំរីសយកទៅថ្វាយដែរ ។

អស់លោកអ្នកដែលធ្លាប់មានការទាក់ទងស្រាវជ្រាវខាងឯកសារប្រវត្តិសាស្ត្រ គង់ជ្រាបបានថាឯកសារប្រវត្តិសាស្ត្រ ជាឯកសារដែលចាត់ថាទៀងទាត់ឬបានការទាំងស្រុងនោះពុំបានឡើយ ។ ផ្នែកភាគច្រើននៃឯកសារប្រវត្តិសាស្ត្រជំនាន់ដើម នៃប្រទេសកម្ពុជា គេសឹងនឹងចាត់ទុកបានថា ជារឿងព្រេង ។ រឿងរ៉ាវនឹងព្រឹត្តិការណ៍ជាច្រើន វាហួសនិស្ស័យពេករកជឿមិនកើត ។

កង្វះនៃការទៀងទាត់នៅក្នុងឯកសារប្រវត្តិសាស្ត្របុរាណ មានឡើងដោយសារកត្តាដូចតទៅ :

១ - អ្នកសរសេរឯកសារមិនខំយកចិត្តទុកដាក់តែក្នុងសាច់រឿងទេ តែខំបញ្ចេញនូវវិចីកាសល្បនឹងចំណេះផ្សេង ៗ របស់គេ ។

២ - អ្នកសរសេរឯកសារជំនាន់បុរាណ ត្រូវស្តេចឬនាហ្មឺនធំ ៗ ចាត់តាំងស្មើរតែទាំងអស់ ។ គោលបំណងរបស់គេមិនមែនខិតខំយកព្រឹត្តិការណ៍ពិត មកលាតត្រដាងទេ តែផ្ទុយទៅវិញគេខំបំពេញចិត្តអ្នកដែលចាត់តាំងគេ ឲ្យធ្វើជាអ្នកសរសេរឯកសារ ។

យើងបានស្រង់យកអត្ថបទ ដែលលោក អេង - សុត បានចម្លងចេញមកពីសាស្ត្រាវត្តកំពង់ត្រ

ខាងក្រោម ។ អត្ថបទទាំងនោះគឺ :

១.- ព្រះសុរិយោវង្ស

២.- ពញាសួគ៌ាលោក មឿង (ឃ្លាំង-មឿង)

៣.- ព្រះចន្ទរាជា

៤.- អាចារ្យលាក់

ឯកសារប្រវត្តិសាស្ត្រដែលយើងស្រង់មកនេះសរសេរជាពាក្យងាយយល់ ប៉ុន្តែគេឃើញមានពាក្យខ្មែរបុរាណលាយឡំខ្លះដែរ ។ សេចក្តីឬថ្ងៃខែក្នុងឯកសារនេះ ឥតមានកែប្រែឬបញ្ចេញបញ្ចូលទេ ទោះបីយើងឃើញខុសឆ្គងយ៉ាងណាក៏ដោយ ។

ឯកសារប្រវត្តិសាស្ត្រមួយទៀត ដែលដកស្រង់ចេញមកពីសៀវភៅមួយនិពន្ធដោយលោកប៉ិណ្ឌចន្ទ-ម៉ុល ដែលមានឈ្មោះថា : 'គុកនយោបាយ' ។ សៀវភៅគុកនយោបាយជាស្វ័យជីវប្រវត្តិ (កម្រមានណាស់នៅស្រុកខ្មែរ) ជាឯកសារមួយយ៉ាងសំខាន់ដែលអាចបញ្ចេញពន្លឺខ្លះអំពីចលនាប្រឆាំងនឹងបារាំង ក្នុងសម័យអាណានិគមនិយម ។

៤- ព្រះសុរិយោវង្ស

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

(តាមឯកសារ)

ព្រះសុរិយោវង្ស នៅពេលដែលទ្រង់លើកទ័ពមកជួយវាយព្រះជេដ្ឋារបស់ព្រះអង្គ ត្រូវទ័ពសៀមវាយបែកបាក់ខ្ចាត់ខ្ចាយ ហើយព្រះអង្គក៏ទ្រង់រត់ទៅស្រុកលាវទៅ ។ ឯព្រះបាទសម្តេចព្រះលំពង់រាជធិបតីកំពុងតែច្បាំងនឹងទ័ពសៀមនៅមហានគរមិនទាន់ចាញ់ឈ្នះផង ក៏ព្រះអង្គមានរោគាព្យាធិមកបៀតបៀន ហើយក៏ទ្រង់ទិវង្គតទៅ ។ បន្តិចក្រោយមក មហានគរក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃសៀម ។

អត្ថបទនេះថ្លែងអំពីព្រះបាទសុរិយោវង្ស កាលដែលព្រះអង្គត្រឡប់ពីស្រុកលាវមក ហើយវាយដណ្តើមយកមហានគរ បានពីកណ្តាប់ដៃសៀមវិញ ។

អត្ថបទ

ព្រះចៅកំបង់ពិសីទៀងសោយរាជ្យស្នងព្រះជេដ្ឋា ក្នុងឆ្នាំកុរឯកស័កព.ស. ១៩០៣ គ.ស. ១៣៥៩ ម.ស. ១២៨១ ច.ស. ៧២១ ។ ស្តេចថ្មីនេះសោយរាជ្យបានមួយខែ ទទួលពេលនោះព្រះសុរិយោវង្ស ដែលស្តេចបានប្រជុំទ័ពនៅខេត្តបាសាននោះបានឫក្សហើយ ព្រះអង្គ

ក៏លើកទ័ពទាំងជើងទឹកជើងគោក ចេញតាមរយៈផ្លូវទៅព្រះមហានគរ (អង្គធំ) ។ ចំណែកឯសម្ដេចព្រះទេពី ស្ដេចបានចុះព្រះទីនាំងនាវាបណ្ដោយតាមក្រោយកងទ័ព ទៅដល់ទីមួយអន្លើហើយ ក៏សម្ដេចព្រះមហេសីស្ដេចទតទៅឃើញភ្នំមួយឈ្មោះភ្នំព្រាយ មានទីរហោថានល្អជាទីមនោរម្យ ។ ស្ដេចចតព្រះទីនាំងនៅទីនោះ ហើយយាងឡើងទៅលើកំពូល ស្ដេចទតឃើញមានសាលាទេវរូបមួយស្ដុកស្ដម្ភប្រពៃណាស់ ។ ស្ដេចទ្រង់បន់ស្រន់បួងសួងថា : សូមឲ្យព្រះទេវរូបដែលស្ថិតនៅក្នុងទីភ្នំព្រាយនេះ ជួយបីបាច់ថែរក្សាកងទ័ពព្រះស្វាមីរបស់ព្រះអង្គ ឲ្យបានជ័យជំនះផង ។ ថាបើព្រះស្វាមីស្រេចការសង្គ្រាមហើយកាលណា ព្រះអង្គនឹងតាំងតែងសាងថានទេវរូបឲ្យប្រពៃថ្វាយជាពុំខាន ។

លុះសម្រេចសង្គ្រាមហើយ សម្ដេចព្រះទេពីក៏ឲ្យជាងធ្វើថ្វាយ តាមសេចក្ដីដែលបួងសួង ព្រោះហេតុនោះហើយទើបបានជាភ្នំព្រាយនោះប្រែឈ្មោះមកហៅថា ភ្នំព្រះទេពី រៀងមកវិញ ។

កាលព្រះសុរិយោវង្សទ្រង់លើកទ័ពចូលទៅវាយព្រះនគរ ក្នុងគ្រានោះមន្ត្រីខ្មែរដែលនៅក្នុងព្រះមហានគរ ដឹងថាអម្ចាស់របស់ខ្លួនលើកទ័ពមកដល់ហើយ ក៏ពុំបានយកចិត្តទុកដាក់ជួយច្បាំងសៀមឡើយ គឺងាកចិត្តមករកអម្ចាស់របស់ខ្លួន ។ កាលព្រះចៅកំបង់ពិសី លើកទ័ពចេញទៅតតាំងច្បាំងនឹងព្រះស្រីសុរិយោវង្សនោះ ទ័ពខ្មែរដែលនៅជាមួយសៀម ក៏ជួយវាយពីខាងក្រោយខ្ទប់កងទ័ពសៀមឥតសំចៃដៃឡើយ ។ កងទ័ពសៀមដែលនៅជាកណ្ដាលនៃកងទ័ពខ្មែរ ត្រូវកងទ័ពខ្មែរបាញ់ចាក់កាប់សម្លាប់ ស្លាប់ពលសៀមអស់ជាច្រើន ទាំងព្រះចៅកំបង់ពិសីក៏សុគតក្នុងសង្គ្រាមដែរ ។ ព្រះស្រីសុរិយោវង្សទ្រង់ឲ្យចាប់ឈ្លើយសៀម ក្នុង ១០ ភាគបាន ៩ ភាគ រត់រួចតែមួយភាគប៉ុណ្ណោះ ។ ព្រះអង្គយកនគរវិញបានក្នុងឆ្នាំកុរឯកស័ក ព.ស. ១៩០៣ គ.ស. ១៣៥៩ ។ ដោយព្រះតេជានុភាពដែលទ្រង់បានជ័យជំនះ ហើយព្រះសុរិយោវង្សក៏ទ្រង់ឡើងរាជាភិសេក (អភិសេកក្សត្រិយ៍ដែលបានជ័យជំនះលើសឹកសត្រូវ ហើយបានទទួលរាជ្យ) ជាក្សត្រខត្យាវង្សតព្រះមហាប្រយូរវង្សរៀងមក ។

ព្រះស្រីសុរិយោវង្សព្រះអង្គឡើងសោយរាជ្យ ទទួលរាជាភិសេកក្នុងឆ្នាំកុរឯកស័កព.ស. ១៩០៣ គ.ស. ១៣៥៩ ម.ស. ១២៨១ ច.ស. ៧២១ ក្នុងព្រះជន្មាយុ ៤១ ឆ្នាំ ព្រះអង្គទ្រង់ព្រះនាមថាព្រះបាទសម្ដេចព្រះស្រីសុរិយោវង្ស ហើយទ្រង់ប្រទានរង្វាន់ពិសេសជាយសស័ក្តិទ្រព្យសម្បត្តិ ឲ្យសេនាទាហានដែលមានបំណាច់បានជួយបង្ក្រាបអរិន្ទ (មកពី អរិ = ឥន្ទ ប្រែថា សត្រូវជាធំ) រាជភ័យរី (ប្រហែលជាបានន័យថា ភ័យ កើតមកពីស្ដេចជាសត្រូវ) ។ ព្រះអង្គទ្រង់តាំងសេនាបតីមន្ត្រីគ្រប់តំណែង ។ អស់ពួកបរមរាជវង្សានុវង្ស ក៏ចូលមកជួបជុំជាបរមសុខរៀងមក ។ ព្រះអង្គទ្រង់ព្រះករុណាប្រោសប្រទានព្រះរាជបុត្រព្រះសុរិយោទ័យជាមហាឧបរាជ

ដែលសុគតក្នុងសង្គ្រាមនោះ ដែលត្រូវជាក្មួយព្រះទូតនឹងព្រះអង្គ ឲ្យឡើងជាទីសម្តេចមហាឧបរាជស្នងព្រះបិតា ។

គិតតាំងពីសៀមវាយបានព្រះនគរ ក្នុងឆ្នាំមមីឆស័កដល់មកឆ្នាំកុរឯកស័ក ត្រូវជា ៦ ឆ្នាំ ទើបព្រះបរមបពិត្រព្រះស្រីសុរិយោវង្ស ស្តេចបង្ក្រាបរាជសត្រូវបាន ហើយយកបានព្រះនគរវិញ ទ្រង់គង់នៅជាសុខស្ថាពរ (ពាក្យនេះមានតាំងពីបុរាណកាលមក) រៀងមក ។ ទ្រង់ត្រាស់បង្គាប់ឲ្យចៅពញាចក្រីនាំសេនាទាហានទេហិពល លើកទៅវាយស្រុករាយរងចុះចូលមកជាស្រុកខ្មែររៀងមក ។

នេះនឹងស្រដីពីក្រុងស្រីអយុធ្យាវិញ ។ កាលព្រះរាមាធិបតី (ស្តេចសៀម) សុគតទៅ ព្រះបរមរាជាជាបងថ្លៃឡើងសោយរាជ្យ ស្នងព្រះរាមាធិបតី ។ ព្រះបរមរាជាសុគតទៅ ព្រះចៅឡាន ដែលជាព្រះរាជបុត្រព្រះបរមរាជា ឡើងសោយរាជ្យស្នងព្រះបិតា ។ ព្រះចៅឡានសោយរាជ្យបាន ៧ ថ្ងៃ ព្រះរាមាសួរដែលជាព្រះរាជបុត្រព្រះរាមាធិបតី ចាក់ព្រះចៅឡានសុគតទៅ ហើយឡើងសោយរាជខ្លួនឯងវិញ ។ ដល់ឆ្នាំជូតទោស័ក ព្រះរាមាសួរលើកទ័ពទៅវាយនគរឈៀងរ៉ាយឬជាងរ៉ាយ (លាវពោះខ្មៅ) ។ ក្នុងពេលជំណាលគ្នានោះ សៀមដែលនៅប្រទល់ដែនទល់នឹងប្រទេសខ្មែរ បានលើកទ័ពមកកំហែងទារយកប្រជានុរាស្ត្រខ្មែរបានជាងមួយរយភាគយកទៅស្រុកវា ។ ចៅហ្វាយស្រុក ក្រមការខេត្តខាងខ្មែរលើកទ័ពតាមទៅដណ្តើមពីសៀមមកវិញ ។ សៀមក៏លើកពលជាងពីរពាន់នាក់មកច្បាំងនឹងទ័ពចៅហ្វាយស្រុកខ្មែរ ។ ចៅហ្វាយស្រុកនឹងក្រមការខេត្តខ្មែរតស៊ូនឹងទ័ពសៀម ហើយប្តឹងបកសំបុត្រជូនមកលោកសេនាបតីឲ្យយកសេចក្តីក្រាបបង្គំទូលព្រះករុណា ក៏ទ្រង់ជ្រាបគ្រប់ប្រការ ។ ព្រះបរមបពិត្រព្រះស្រីសុរិយោវង្ស ជាអម្ចាស់ផែនដីប្រទេសកម្ពុជា កាលទ្រង់ជ្រាបដំណឹងនេះហើយ ក៏បង្គាប់ទៅចៅហ្វាយស្រុក ឲ្យកេណ្ឌរាស្ត្រខេត្តទ្រាំងមួយ បាសាក់មួយ ព្រះត្រពាំងមួយ ទីម៉ៅមួយ ក្រមួនសមួយ ទឹកខ្មៅមួយ ពាមកំពតកំពង់សោមមួយ បានពលប្រាំម៉ឺននាក់ ហើយទ្រង់ចាត់ចៅពញាពិស្ណុលោកចៅហ្វាយស្រុកទ្រាំង ឲ្យធ្វើជាមេទ័ពធំ ឲ្យចៅហ្វាយស្រុកបាសាក់ធ្វើជាមេទ័ពមុខ ចូលទៅច្បាំងនឹងសៀម ។ ទ័ពនេះឈ្នះសៀមហើយក៏លើកទៅវាយស្រុកសំរ៉ែមួយ ស្រុករយ៉ង់មួយ ស្រុកចន្ទបូរ (ចាន់តាប៊ុន) មួយ ស្រុកជលបូរីមួយ ហើយកៀរគ្រួសៀមបាន ៩០០០ នាក់ទើបលើកទ័ពត្រឡប់មកប្រទេសកម្ពុជាវិញ រួចឡើងទៅក្រាបបង្គំទូលថ្វាយព្រះករុណាសូមទ្រង់ជ្រាបគ្រប់ប្រការ ។ ព្រះករុណាទ្រង់ព្រះអំណរណាស់ ទ្រង់ប្រទានរង្វាន់ដល់នាយកងនាយទ័ព ដល់នាយទាហាននឹងសេនាទាហានតាមគុណបំណាច់ ។ តមក ព្រះករុណាទ្រង់ព្រះរាជកំណត់ទៅគ្រប់ចៅហ្វាយស្រុកតូចធំ ឲ្យត្រៀមខ្លួនប្រុងប្រៀបរៀបរៀងទៅបង្ហាត់សេនាទាហាន ឲ្យមានគ្រប់ខែត្រជាទីបង្ការរក្សាព្រះនគរតទៅ ។

ព្រះរាមាសួរ ក្រុងទេព ដែលលើកទ័ពទៅវាយស្រុកលាវនោះ កាលបានជ័យជំនះឈ្នះលាវ យកបានស្រុកជាងរ៉ាយហើយកេៀរគ្រួសារលាវបានជាច្រើន ហើយទើបលើកទ័ពត្រឡប់ទៅក្រុងស្រីអយុធ្យាវិញ ។ លុះមកដល់ហើយ ទ្រង់ជ្រាបថាខ្មែរលើកទ័ពមកវាយបានស្រុកបួនដំបន់ ព្រមទាំងកេៀរគ្រួយកទៅជាច្រើនទៀតផង ។ ទ្រង់ខ្ញាល់ណាស់ ទើបត្រាស់ឲ្យកេណ្ឌកងទ័ពលើកមកធ្វើសង្គ្រាមនឹងខ្មែរ ។ លុះដល់ឆ្នាំឆ្លូវត្រីស័ក ទ្រង់ត្រាស់បង្គាប់ចៅពញាជ័យដំរុងឲ្យធ្វើជាមេទ័ពមុខ ព្រះរាមាសួរអង្គឯងជាទ័ពហ្លួង លើកមកវាយស្រុកទាំងបួនតំបន់បានទៅវិញ ហើយបំរុងនឹងលើកទ័ពមកវាយមហានគរទៀត ។ ប៉ុន្តែនាយគយខ្មែរដែលនៅល្បាតព្រំដែន កាលបើដឹងថាទ័ពសៀមលើកមកហើយ ក៏ចាត់សំបុត្រឲ្យបំរើសេះចូលមកប្តឹងសេនាបតី ឲ្យនាំឡើងក្រាបបង្គំទូលព្រះករុណាសូមទ្រង់ជ្រាបគ្រប់ប្រការ ។ ព្រះករុណា កាលបើបានទ្រង់ជ្រាបហើយ ក៏ត្រាស់ឲ្យប្រមូលសេនាទាហាន ដែលបានហាត់ហ្វឹកហ្វឺនបំរុងការណ៍ក្នុងខែត្រជិត ៗ នោះមកប្រជុំគ្នា ទ្រង់ត្រាស់បង្គាប់ឲ្យមហាឧបរាជ ធ្វើជាមេទ័ពធំ នាំទាហានជើងទឹកចេញទៅរាំងទ័ពសៀម ។ ព្រះមហាឧបរាជលើកទ័ពចេញទៅប្រទះនឹងសត្រូវនៅស្ពានញែក ទើបទ្រង់ចាត់ឲ្យតាំងបន្ទាយរាយច្រមូង ទប់ទល់នឹងទ័ពសៀមនៅទីនោះឥតមានរុញរាទៀយ ។ ចៅពញាពិជ័យដំរុងនាយទ័ពមុខ កាលបើឃើញទ័ពខ្មែរមកដល់ហើយ ក៏បរពលឲ្យចូលវាយបន្ទាយខ្មែរ ខ្មែរក៏បរពលច្បាំងទល់មកវិញ ។ ចម្បាំងពុំទាន់ចាញ់ឈ្នះទាំងសងខាងនៅឡើយផង ក៏ស្រាប់តែព្រះរាមាសួរចាត់ឲ្យធ្វើបន្ទាយឆាក (បន្ទាយឆាកគឺបន្ទាយដែលចាក់ផែនខុសពីទិសដែលត្រូវធ្វើ) ពីទូឆេងស្តាំ ហើយបាញ់ផ្ទប់ចូលមក ។ ព្រះមហាឧបរាជខ្មែរដែលនៅក្នុងចំណោម យល់ឃើញថាទ័ពសត្រូវលើកថែមមកច្រើនលើសកម្លាំងណាស់នឹងទ្រាំពុំបាន ក៏រាថយចុះមកនៅក្នុងពាម គង់ក្នុងព្រះទីនាំងនាវា ដើម្បីឲ្យកងទ័ពជើងទឹកលើកទៅជួយកងទ័ពជើងគោក ។ ខណៈនោះ ទ័ពសៀមក៏ចោមរោម បាញ់តម្រង់ព្រះទីនាំងនាវាសន្ធាប់យ៉ាងខ្លាំងឥតសំចៃឡើយ ។ មួយស្របក់ក្រោយមក គ្រាប់កាំភ្លើងសត្រូវក៏រត់មកត្រូវធុងរំសេវខាងខ្មែរ បែកឆេះធ្លាយហើយត្រូវសម្តេចព្រះមហាឧបរាជនឹងទាហានក្នុងកងទ័ព ស្លាប់នឹងពិការជាច្រើននាក់ ។ ទ័ពខ្មែរឃើញហេតុដូច្នេះហើយ ក៏ផ្អើលភ្ញាក់បរាជ័យ រត់បែកខ្ញែកប្រួលយកតែអាយុសព្វ ៣ ខ្លួន ។ ទ័ពសៀមដេញសន្ធាប់ ហើយចាប់បានសម្តេចព្រះមហាឧបរាជ យកមកទុកបាន ៣ ថ្ងៃព្រះអង្គក៏ទ្រង់សុគតទៅ ។

ព្រះបាទសម្តេចព្រះសុរិយោវង្ស កាលទ្រង់បានជ្រាបថា ៖ ទ័ពព្រះអង្គបែកហើយ ព្រមទាំងសៀមចាប់បានព្រះមហាឧបរាជទៅទៀតនោះ ស្តេចក៏លើកសេនាយោធាជាកងទ័ពធំចេញទៅពីទូ ចោមច្បាំងនឹងទ័ពសៀមទៀត ។ ទ័ពសៀមរអារែងអស់កម្លាំងច្បាំងតថ្វីដែលនឹងទ័ពសម្តេចព្រះសុរិយោវង្សពុំបាន ក៏រាថយមកវិញ ។ ខណៈនោះ ទ័ពខ្មែរយល់ថាបានការហើយ

ក៏ចោមចាក់កាប់សម្លាប់ពួកទ័ពសៀម ឥតត្រាប្រណីឡើយ ។ សៀមនឹងតតាំងច្បាំងពុំកើត ក៏បែកទ័ពរត់ខ្ចាត់ខ្ចាយ ហើយបាក់ទ័ពរត់ទៅស្រុកវិញអស់ ។ ទ័ពខ្មែរចាប់បានឈ្លើយសៀមជាច្រើននាក់ នាំមកក្រាបបង្គំទូលថ្វាយ រួចហើយដេញទ័ពសៀមឱ្យចេញផុតពីដែនដីខ្មែរ ទើបត្រឡប់មកប្រទេសកម្ពុជាវិញ ។

ព្រះបាទសម្ដេចព្រះស្រីសុរិយោវង្ស ព្រះអង្គបង្ក្រាបទ័ពសៀមរាបទាបហើយ ស្ដេចក៏យាងចូលទៅព្រះមហានគរ សោយរាជសម្បត្តិ ប្រកបដោយនូវយុត្តិធម៌ អាណាប្រជានុរាស្ត្រក្នុងព័ទ្ធសីមា (ព័ទ្ធសីមា = សីមាមួយយ៉ាងដែលព្រះសង្ឃទុកជាគោល សម្រាប់កំណត់ព្រំដែន ក្នុងការធ្វើសង្ឃកិច្ចផ្សេង ៗ ។ ព័ទ្ធសីមាក្នុងទីនេះ គឺព្រំដែនប្រទេសនីមួយ ៗ ។) ក៏បានសុខសប្បាយគ្រប់ ៗ គ្នា ។

(ឯកសារមហាបុរសខ្មែរ, ទំព័រ ៣៥ - ៤០)

HISTORICAL PROSE

វាសនា fortune, destiny, fate

ភ័ព្វវាសនា /phŏəp-wiəhsənaa/ fortune

មានភ័ព្វវាសនា to be fortunate, lucky

ឯកសារ /qaekkəsaa/ document(s), evidence

តម្កល់ទុក to keep, to preserve

វត្តអារាម wat, pagoda

រាត់រាយ dispersed, disseminated

រប៉ាត់រប៉ាយ scattered

ឃ្លាំងមឿង the best known of all Cambodian heroes (perhaps legendary)

វត្តកំពង់ត្រឡាចក្រោម Vat Kompong Tralach Krom

ទំនុកបំរុង to take care of, to support

ព្រះចន្ទរាជា /preəh-can-riəciə/ (King) Chan Raja (1516-1568)

ល្ខោនជាតិ National Theater (drama school run by the government)

ព្រះជ័យអស្ចារ្យ name of a king

គួរឱ្យចាប់អារម្មណ៍ captivating, interesting

បោក to deceive

ក្រាបថ្វាយបង្គំ to prostrate oneself (here: to put oneself at the service of the king)

បានការ to be useful, effective

ទាំងស្រុង completely, wholly, entirely

ហួសវិស័យ incredible

កង្វះ /kɑŋwah/ lack, insufficiency

កត្តា /kattaa/ factor

វចីកោសល្យ /wĕəqcəykaosɑl/ eloquence; oratory

លាតត្រដាង to lay out, spread out; expose

អេង-សុត Eng Sot (pers. n.)

ព្រះសុរិយោវង្ស /prĕəh-souriyaowŭəŋ/ (King) Soriyavong

(1416-1425)
ពញ្ញា /puə̆ññiə, pəñiə/ title replaced later by /qokñaa/; the term /pəñiə/ remained in use, but for a much lower-ranking official
ពញ្ញាសួគ៌ាលោក /pəñiə-suəkiə-look/ a title
អាចារ្យលាក់ Leak the Wise (name of a rebel leader)
លាយឡំ mixed with, mixed together
ថ្ងៃខែ date

បញ្ចេញបញ្ចូល to change, alter (lit: to invent and add)
ខុសឆ្គង to make mistakes, to be wrong
ប៊ុណ្ណចន្ទ-ម៉ុល Bunchan Mol (pers. n.)

គុកនយោបាយ name of a novel by Bunchan Mol (lit: Political Prison)
ស្វ័យជីវប្រវត្តិ autobiography

កម្រមាន rare

បញ្ចេញពន្លឺ to brighten, to shed light

ព្រះសុរិយោវង្ស

Introductory Note

ព្រះជេដ្ឋា older brother (Roy)

បែកបាក់ to disperse, break up (iv)

ព្រះបាទសម្តេចព្រះលំពង់រាជាធិបតី King Lampong Rajathipati

មហានគរ Angkor

មិនទាន់ចាញ់ឈ្នះផង inconclusive, outcome (of the battle) not yet decided
ទិវង្គត /tiq-wuə̆ŋkuə̆t/ death; to die (Roy)

Text

ព្រះចៅកំពង់ពិសី (King) Kambong Pisei
ស្នង replacement, succession; replacing, in place of
ឆ្នាំកុរ /cnam kao/ year of the pig (of the 12-animal cycle)
ឯកស័ក /qaekkəsaq/ first year (of the 10-year cycle)
ម.ស. /məhaasaqkəraac/ an era that started in 78 A.D.
ច.ស. /colləsaqkəraac/ an era that started in 638 A.D.
ទទួលពេលនោះ it so happens that, it happened that
បាសាន name of a former province

ឫក្ស /rɨk/ propitious time (in astrology)

បានឫក្ស propitious

ជើងទឹក by water; navy

ជើងគោក by land; army

តាមរយៈផ្លូវ by way of

ព្រះមហានគរ (អង្គរធំ) Angkor

ព្រះទីនាំងនាវា royal ship or barge

ព្រះមហេសី /preə̆h-məhaesəy/ queen

ប្រាយ demon, malevolent spirit

ភ្នំប្រាយ name of a mountain

រហោឋាន isolated, remote

មនោរម្យ /mənoorum/ enchanting

ទេវរុក្ខ /teewəruk/ spirit of the forest
សាលាទេវរុក្ខ a small square pavilion built for the forest spirit
តាំងតែង to institute, to erect

រៀងមក from then on

ងាកចិត្ត to switch one's loyalty or devotion
តតាំង to fight

ឥតសំចៃដៃ vigorously, with all one's force (lit: without sparing the hands)
នៅជាកណ្តាល in the middle

តេជានុភាព /daeciənuphiəp/ power

រាជាភិសេក /riəciəphisaek/ to be crowned as official king;

coronation
អភិសេក /qaqphisaek/ to crown

ខត្តិយវង្ស /khatsaawŭəŋ/ noble family, warrior family
ប្រយូរវង្ស royal lineage

ព្រះជន្មាយុ /preə̆h-cŭənnəmiəyuq/ age (Roy)
ប្រទាន to give (Roy)

បំណាច់ service

បង្ក្រាប to put down (a rebellion, etc.)
អរិន្ទ /qaqrɨn/ principal enemy

រាជភ័យរី /riəccəphɨyrii/ betrayer of the king, traitor against the crown
បរមរាជវង្សានុវង្ស family (Roy) /barommǝriǝccǝwŭǝŋsaanuwŭǝŋ/
បរមសុខ /barommǝsok/ to be well (Roy)
ប្រទាន to give (Roy); here: to appoint
ព្រះសុរិយោទ័យ (King) Soriyotey

មហាឧបរាជ /məhaa-qupperaac/ Vice-King
ក្មួយព្រះទួត great-nephew (?)

ឆ្នាំមមី year of the horse (of the 12-animal cycle)
ឆស័ក /chaasaq/ 6th year (of the 10-year cycle)
បរមបពិត្រ /barommǝbapɨt/ title

ចៅពញាចក្រី /caw-pəñiə-cakrəy/ title
រាយរង unimportant

ចុះចូល to submit, to give in

ក្រុងស្រីអយុធ្យា Ayuthia (capital of Thailand 1350-1767)
ព្រះរាមាធិបតី Rama Thibodi, King of Ayuthia 1350-1369
ព្រះបរមរាជា (King) Boromaraja

ព្រះចៅឡាន (King) Chao Lan

ព្រះរាជបុត្រ /preə̆h-riəccəbot/ son (Roy)
ព្រះរាមាសួរ (King) Ramesuen, son of Rama Thibodi

ចាក់ to stab

ឆ្នាំជូត Year of the Rat

ទោស័ក 2nd year (of the 10-year cycle)
ឈៀងរ៉ាយ Chiengrai (Thailand)

ជាងរ៉ាយ = ឈៀងរ៉ាយ

លាវពោះខ្មៅ Lao of Chiengrai (lit: black-stomach Lao)
ក្នុងពេលជំណាលគ្នានោះ at that same time, concurrently

មួយរយភាគ 100 percent (?)

បកសំបុត្រ to return a letter (commonly used to mean to write or send a letter)
គ្រប់ប្រការ everything, every aspect
អម្ចាស់ (=ម្ចាស់)

អម្ចាស់ផែនដី the king (lit: the owner of the land)
ទ្រាំង name of a former province (now a /srok/ in Takaew)
ញលាក់ name of a former province

ព្រះត្រពាំង name of a former province
ឱម៉ៅ name of a former province

ក្រមួនស name of a former province (lit: white wax)
ទឹកខ្មៅ name of a former province (lit: black water)
ពាមកំពត name of a former province (now Kompot city)
កំពង់សោម name of a former province (now Kompong Som city)
ពញាពិស្ណុលោក /pəñiə-pihsnulook/ a title
សំយ៉ែ name of a former province

រយ៉ង់ Rayong (Thailand)

ចន្ទបូរ = ចាន់តាប៊ុន Chantaburi (Thailand)
ជលបុរី Chonburi (Thailand)

កៀរ to round up, herd together

គ្រួ family

ព្រះអំណរ to be pleased, happy (Roy)

ត្រៀមខ្លួន to be ready, be prepared to

រៀបរៀង to be organized, systematized, or coordinated

បង្ការ to prevent, to deter

ជាទីបង្ការ as a precaution

ក្រុងទេព Krungthep (lit: city of the angels; here: Ayuthia)

ខ្ញាល់ to be angry (Roy)

ឆ្នាំឆ្លូវ Year of the Ox

ត្រីស័ក 3rd (of the 10-year cycle)

ពញ្ញាជ័យ title

ដំរុង Damrong (pers. n.)

ចាត់សំបុត្រ to send a message or letter

បំរើសេះ messenger, circuit rider

ការណ៍ event, happening; affair; eventuality

ហ្វឹកហ្វឺន /wək-wəɨn/ to train, drill

បំរុងការណ៍ to be prepared for any eventuality

ស្ពានញែក name of a bridge

ចម្រូង a spike, sharpened stake

រាយ distributed (here: planted)

រុញរា to dilly-dally, to delay

ឥតបានរុញរា without delay, immediately

បន្ទាយឆាក a fortress with extended wings or parapets

ផ្ទប់ from both sides

រា to back up

រាថយ to back up, to retreat

ពាម (=ពាមកំពត) Kompot

ពិការ wounded

ចោម to surround

ចោមរោម to surround

សន្ធាប់ to shout loudly and menacingly (in order to cause panic or to intimidate)

ឥតសំចៃ vigorously

ធុង barrel, cask

រំសេវ gunpowder

ផ្អើល to be startled, surprised

ប្រាស to run off, scurry away

ប្រាសយកតែអាយុ to run for one's life

រអាដៃ weary

ចួនការហើយ to be an opportune moment, to have an advantage

បាក់ទ័ព [with the] forces broken, in disarray

ឈ្លើយ prisoner of war

រាបទាប flat, level (here: levelled)

ព័ទ្ធសីមា to plant a boundary stone (here: border, boundary)

សង្ឃកិច្ច /saŋkhəkəc/ religious ceremony

៥. ពញាសួគ៌ាលោកមឿង (ឃ្លាំងមឿង)

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

(តាមឯកសារ)

ឃ្លាំងមឿង លុះបានដំណឹងថាពញាចន្ទរាជា ស្ដេចត្រឡប់មកដល់បាត់ដំបងហើយ ក៏ដើរបញ្ចុះបញ្ចូលបានស្ម័គ្របក្សពួកជាច្រើនទៅសម្លាប់ចៅហ្វាយស្រុកខេត្តពោធិ៍សាត់ ដែលជារាជការរបស់ស្ដេចកន ៗ រួចហើយក៏នាំទ័ពរបស់គាត់ទៅថ្វាយបង្គំព្រះចន្ទរាជា ៗ ព្រះចន្ទរាជាទ្រង់មានព្រះអំណរណាស់ ហើយទ្រង់តាំងគាត់ជា 'ចៅពញាសួគ៌ាលោក' ចៅហ្វាយស្រុកខេត្តពោធិ៍សាត់និងជាមេទ័ព ៗ ឯកូនប្រុសគាត់ទាំងបួននាក់ ក៏បានទទួលឋានន្តរសក្ដិជាមេទ័ពមុខ ក្រោយ ឆ្វេង ស្ដាំ ដែរ ៗ តមកមេទ័ពទាំងប្រាំនាក់ក៏ចេញទៅច្បាំងនឹងទ័ពស្ដេចកន ៗ លុះដល់ឃើញថាច្បាំងមិនឈ្នះទេ ទើបថយត្រឡប់មកចូលបន្ទាយពោធិ៍សាត់វិញ ៗ

ក្រោយមក ដោយគាត់មិនដឹងធ្វើដូចម្ដេចដើម្បីនឹងបំផ្លាញកងទ័ពរបស់ស្ដេចកនបាន ឃ្លាំងមឿងក៏សម្រេចចិត្តសម្លាប់ខ្លួនឯង ដោយអះអាងថាខ្លួនគាត់នឹងទៅកេណ្ឌកងទ័ពខ្មោចឱ្យមកជួយវាយកំចាត់ កងទ័ពរបស់ស្ដេចកន ៗ នៅពេលដែលគាត់ធ្វើអត្តឃាតកម្មនោះ អ្នកមេនាងខៀវនិងកូនប្រុសរបស់គាត់ពីរនាក់ក៏បានធ្វើអត្តឃាតកម្មដែរ ៗ

អត្ថបទ

ចៅពញាសួគ៌ាលោកមឿងនឹងកូនទាំងបួននាក់ នាំសេនាទាហានទេពពលថយទ័ពទៅក្រាបបង្គំគាល់ ព្រះចៅពញាចន្ទរាជានៅបន្ទាយពោធិ៍សាត់ ព្រមទាំងក្រាបបង្គំទូលតាមហេតុគ្រប់ប្រការ ៗ ចៅពញាចក្រី ឃើញចៅពញាសួគ៌ាលោកបន្ថយទ័ពទៅនោះ មិនហ៊ានដេញតាមទៅទេ ដោយខ្លាចចាញ់កលតាមឿងផង ដោយព្រះអាទិត្យអស្ដង្គតរលត់រស្មីហើយផង ៗ

លុះព្រឹកឡើង ចៅពញាចក្រីបម្រុងនឹងលើកទ័ពតាមចៅពញាសួគ៌ាលោក តែទទួលពេលនោះ សម្ដេចចៅហ្វាកៅនាំពល ៥០.០០០នាក់ឆ្លងមកដល់ដែរ ចៅពញាចក្រីក៏បញ្ឈប់ទ័ពរង់ចាំចៅហ្វាកៅ ដែលនឹងចាត់ទ័ពជាថ្មីវិញ ៗ

វេលានោះចៅហ្វាកៅ បានចាត់ទ័ពជា ៥ កងដូចតទៅនេះ

១. ឱ្យចៅពញាចក្រីដែកវឃុំពល ៣០.០០០នាក់ ជាមេទ័ពមុខ (ទ័ពស្រួច) ៗ

២. ឱ្យចៅពញារាជាមេត្រីទិព្វ ចៅហ្វាយស្រុកខែត្រភ្នំពេញ ឃុំពល ២០.០០០ នាក់ជាមេកងទ័ព ប៉ែកឆ្វេង ៗ

៣. ឱ្យចៅពញាស្រែន្យសេនាឫទ្ធីជ័យ ចៅហ្វាយស្រុកខែត្រលង្វែក ឃុំពល ១៥.០០០

នាក់ ជាទ័ពកណ្ដាល ។

៤. ឲ្យចៅពញាសេនាសង្គ្រាមស្មស ចៅហ្វាយស្រុកខែត្រអមរគិរិន្ទបុរឬអម្រិន្ទបុរ គឺស្រុកបរិបូណ៌ ឃុំពល ១៦.០០០នាក់ ជាទ័ពក្រោយ ។

៥. ឯខ្លួនសម្ដេចចៅហ្វាកោឯង ឃុំពល ៤០.០០០នាក់ ជាមេទ័ពធំ ។

សម្ដេចចៅហ្វាកោ លើកទ័ពដេញតាមទ័ពចៅពញាសួគ៌ាលោកមឿង ដែលថយទ័ពមកក្រាបបង្គំទូលចៅពញាចន្ទរាជានោះ ។ គ្រាដែលចៅហ្វាកោលើកទ័ពដេញតាមមកនោះ កងទ័ពចៅពញាសួគ៌ាលោកមឿង បានចូលទៅក្នុងបន្ទាយអស់ទៅហើយ ។

សម្ដេចចៅពញាចន្ទរាជា កាលទ្រង់បានជ្រាបថា : កងទ័ពខាងគេលើកមកច្រើនណាស់ដូច្នេះហើយ ទ្រង់ក៏ត្រាស់ឲ្យកេណ្ឌពលបាន ២០.០០០នាក់ ឲ្យទៀងការពារបន្ទាយ ។ លុះកងទ័ពខាងចៅហ្វាកោ មកចោមវាយបន្ទាយ ទ្រង់ក៏ឲ្យទ័ពក្នុងបន្ទាយបាញ់ព្រួញ ចោលដុំថ្មទៅ ត្រូវកងទ័ពសម្ដេចចៅហ្វាកោស្លាប់អស់ជាច្រើន ។ ចៅហ្វាកោខំដេញពលឲ្យពានកំផែងបន្ទាយ ណែនណាន់តាន់តាប់ ដូចស្រមោចរោមស្កុរ តែវាយមិនបាន ។ កាលដឹងថាវាយយកបន្ទាយសម្ដេចចៅពញាចន្ទរាជាពុំបាន ក៏ឲ្យចៅហ្វាកោបោះទ័ពព័ទ្ធចោមបន្ទាយនោះឲ្យជាប់ដើម្បីទប់ទ័ពខាងក្នុងមិនឲ្យចេញរួចផង ឲ្យអត់បាយបរិភោគជនរាបត្រូវស្លាប់ឬត្រូវដាច់ពោះគ្រប់ ៗ គ្នាផង ។

សម្ដេចចៅហ្វាកោ ចៅហ្វាចក្រីកែវ ឲ្យពលចោមបន្ទាយរហូតដល់ ១២ខែ ។ កងទ័ពខាងសម្ដេចចៅពញាចន្ទរាជាចេញពីបន្ទាយពុំរួចមែន ស្បៀងអាហារក្នុងបន្ទាយក៏ចេះតែហោចទៅ ៗ គួរឲ្យបារម្ភណាស់ ដោយបន្ទាយនោះមិនទាន់មានការប្រុងប្រៀបមាំមួន ប៉ុន្តែដោយហេតុព្រះបារមីរបស់ព្រះអង្គ ដែលបានសាងមកពីអតីតកាល បណ្ដាលឲ្យកងជញ្ជូនស្បៀងខាងសម្ដេចចៅហ្វាកោ បញ្ជូនទៅពុំទាន់ ។ ដូច្នេះសម្ដេចចៅហ្វាកោក៏ឲ្យថយកងទ័ព មកតាំងបន្ទាយឆ្ងាយពីបន្ទាយព្រះចន្ទរាជា ចម្ងាយ ៣សិនឲ្យទ័ពព័ទ្ធជុំវិញទៀត ។ ការណ៍ដែលចៅហ្វាកោឲ្យថយទ័ពនេះ ប្រយោជន៍ឲ្យកងទ័ពផ្លាស់ប្ដូរគ្នា ចេញទៅរកស្បៀងអាហារក្នុងភូមិជិតខាង ។

សម្ដេចចៅពញាចន្ទរាជា កាលទតឃើញថាកងទ័ពសត្រូវថយឃ្លាតពីបន្ទាយព្រះអង្គហើយ ព្រះអង្គក៏ទ្រង់ត្រាស់ប្រឹក្សានឹងនាយកង នាយទ័ពថា : 'ទ័ពសត្រូវរំលៀកចេញពីបន្ទាយយើងបន្តិចហើយ ការណ៍នេះល្អប្រពៃហើយ ជាឱកាសឲ្យយើងគិតដោះដៃចេញពីសត្រូវបានដោយស្រួល ចុះយើងនឹងគិតធ្វើយ៉ាងណា ដើម្បីឲ្យចេញរួចពីចំណោមនេះ?' ។ ចៅពញាសួគ៌ាលោកមឿងក្រាបទូលថា : 'បើយើងនឹងគិតវាយទំលាយចេញនោះក៏ចេញមិនរួចដែរ ពីព្រោះពលយើងមានតែ ២០.០០០នាក់ ឯពលខាងគេ មានដល់ទៅជាង ១០០.០០០នាក់ បើយើង

ចេញរួចទៅ   ទ័ពទាំងសងខាងក៏គង់ស្លាប់ច្រើនជាមិនខាន   បើយើងនឹងតែនៅក្នុងបន្ទាយនេះ មិនចេញទទួលច្បាំងសោះក៏មិនបានដែរ   ពីព្រោះបន្ទាយរបស់យើងទើបនឹងតាំងថ្មី   ឯស្បៀងអាហារក៏ពុំទាន់មានបរិបូរណ៍   ដល់យូរទៅក្រែងលំបាកក្នុងការខ្វះខាតគ្រប់យ៉ាង   ទូលព្រះបង្គំជាខ្ញុំគិតយកគំនិតមួយមកសូមទទួលអាសា   គឺទៅកេណ្ឌកងទ័ពបីសាចឱ្យមកចោមវាយទ័ពចៅហ្វាកៅ   បើទ្រង់ព្រះរាជានុញ្ញាត   ទូលព្រះបង្គំយល់ឃើញច្បាស់ថា   មុខជានឹងឈ្នះសត្រូវដោយងាយ   បើទ្រង់ព្រះករុណាពិសេសយល់ព្រមផងនោះ   សូមឱ្យជីករណ្ដៅកណ្ដាលបន្ទាយនេះឱ្យបានជាប្រញាប់ ដើម្បីទូលព្រះបង្គំនឹងបានគិតការថ្វាយឱ្យទាន់ពេលវេលា '   ។

សម្ដេចចៅពញាចន្ទរាជា   កាលទ្រង់ព្រះសណ្ដាប់ចៅពញាសួគ៌ាលោកទូលសុំយ៉ាងនេះ ទ្រង់ពុំជឿសោះទេ   ទើបទ្រង់គ្រវីព្រះសិរសាហើយត្រាស់ថា : ' ពីបុរាណរៀងមក   យើងពុំដែលឮថា   មានឈ្មោះណាទៅកេណ្ឌយកខ្មោចបិសាច   មកជួយច្បាំងមនុស្សដល់ម្ដងឡើយ   ណ្ហើយ អ្នកចៅពញា   លែងគិតគំនិតបែបនេះទៅចុះ   ព្រោះជាគំនិតមិនដែលមានអ្នកណាគិតមកពីមុនផង   នឹងជាកិច្ចការមួយដែលខ្ញុំមិនជឿថាមានប្រសិទ្ធភាពទាល់តែសោះផង'   ។

ចៅពញាសួគ៌ាលោកមឿងក្រាបទូលថា : ' បើទ្រង់មិនសព្វព្រះហឫទ័យឱ្យគិតធ្វើតាមចំណេះនឹងតាមមន្តវិជ្ជាការទូលព្រះបង្គំទេ   នោះទូលព្រះបង្គំនឹងអារកឱ្យស្លាប់នៅទីនេះក្នុងឥឡូវនេះហើយ   ព្រោះបើនឹងរស់នៅតទៅ   ក៏មិនបានជួយយកអាសាថែនដីថ្វាយព្រះអង្គដល់កម្រិតដែរ'   ។

ថាហើយ   ចៅពញាសួគ៌ាលោកមឿងក៏ហូតដាវនឹងអារក   តាមពាក្យដែលខ្លួនបានក្រាបទូល   ។   ខណៈនោះ   សម្ដេចចៅពញាចន្ទរាជាទ្រង់ក្រឡេកព្រះនេត្រាឃើញទាន់   ក៏ទ្រង់ស្ទុះទៅចាប់ដាវនោះចេញពីដៃ   ហើយទ្រង់ត្រាស់ថា : 'កុំ ! កុំ ចៅពញា   កុំសម្លាប់ខ្លួន   ខ្ញុំស្ដាយលោកណាស់   ខ្ញុំព្រមតាមចៅពញាហើយ   ដូច្នេះបើចៅពញាគិតឃើញដូចម្ដេចស្រួល   សូមចៅពញាធ្វើតាមគំនិតនោះចុះ '   ។

ចៅពញាសួគ៌ាលោកឮហើយ   មានអំណរណាស់   ទើបថ្វាយបង្គំលាចេញមកក្រៅដំណាក់ ហើយក៏ចាត់កូនទាហានឱ្យជីករណ្ដៅធំមួយ   ជម្រៅ ៨ហត្ថ ៤ ជ្រុង   ឱ្យធ្វើរានទេវតា ៧ ថ្នាក់ ដាក់បាយសី   ទឹកអប់នឹងគ្រឿងបូជា   ហើយឱ្យធ្វើរាជវតិព័ទ្ធជុំវិញ   ។   លុះពួកពលធ្វើតាមបង្គាប់សព្វគ្រប់ហើយ   ចៅពញាសួគ៌ាលោកមឿងក៏ស្លៀកសពាក់ស   ហើយឱ្យរៀបភ្លេងចាំប្រគំទាំង ៨ទិស   ។

ខណៈនោះ   ពញាមឿងកាលឱ្យពលជីករណ្ដៅជម្រៅ ៨ហត្ថ ៤ជ្រុងហើយ   ក៏ថ្វាយបង្គំលាសម្ដេចចៅពញាចន្ទរាជា   ទៅកេណ្ឌបីសាចឱ្យជួយធ្វើសង្គ្រាម   ។   មុននឹងទៅកេណ្ឌបិសាចនោះ ពញាមឿងបានផ្ដាំនឹងពញាចន្ទជាសំឡាញ់   ដែលជាជំទប់មឿងភ្នំក្រវាញថា   'ឱ្យសម្លាញ់ឯង

នៅជាមេស្រឹងជំនួសអញ ដើម្បីនិយាយតពីព្រះមហាក្សត្រមកអញ កុំបីឱ្យព្រះអង្គនិយាយផ្ទាល់នឹងអញឡើយ មួយទៀត បើដល់ថ្ងៃស្អែកពេញបូណ៌មីខែពិសាខ វេលាយប់ បើឯងឮស្គរសន្ធឹកខ្ទរខ្ទារមេឃ ក្នុងដីហើយ ឱ្យឯងក្រាបបង្គំទូលព្រះបរមបពិត្រ សូមឱ្យទ័ពទៅចោមបន្ទាយសត្រូវជាប្រញាប់ចុះ' ។

ឯអ្នកមេនាងខៀវ កាលឮថាពញាមេស្រឹងសម្លាប់ខ្លួនទៅកណ្ឌទ័ពបិសាចហើយ ក៏មានចិត្តឈឺឆ្អាលជួយដែនដីដែរ ។ កាលឃើញពញាមេស្រឹងចូលក្នុងរោងរាជវ័តិ តាំងពិធីបួងសួងទេវតាដូច្នោះ អ្នកមេនាងក៏ថ្វាយបង្គំលាសម្ដេចចៅពញាចន្ទរាជា ចូលទៅក្នុងទីព្រះរាជពិធីដែរ ។ លុះបួងសួងទេវតាស្រេចហើយ អ្នកមេនាងខៀវនឹងពញាសួគ៌ាលោកមេស្រឹងក៏លោតទាំងពីរនាក់ទៅក្នុងរណ្ដៅ ។ ព្រះបរមបពិត្រនឹងបណ្ដាជាខ្ញុំ ក្រុមរាជការជួយឃាត់ផងក៏ពុំស្ដាប់ ។ ក្នុងគ្រានោះ កូនពញាមេស្រឹង ៤នាក់ ដែលព្រះបរមបពិត្រស្ដេចបានតាំងជាមន្ត្រីទាំង ៤នាក់រួចហើយនោះគឺ

១. ឈ្មោះកែវ ទ្រង់បានតាំងជា 'ចៅពញាវង្សាអគ្គរាជ'

២. ឈ្មោះកែ ទ្រង់បានតាំងជា 'ចៅពញាបវរទេសរាជ'

៣. ឈ្មោះទេព ទ្រង់បានតាំងជា 'ចៅពញាវិបុលរាជ'

៤. ឈ្មោះសុខ ទ្រង់បានតាំងជា 'ពញារាជតេជះ' ។

កូនទាំង ៤នាក់នោះ កាលឃើញបិតាលោតសម្លាប់ខ្លួនទៅកណ្ឌបិសាចដូច្នោះ ក៏និយាយគិតគ្នាថា : ' បិតាយើងទៅតែម្នាក់ឯង គ្មានគេទៅជួយបម្រើជួយគិតកណ្ឌបិសាចផងសោះ បើយ៉ាងនេះក្រែងឱ្យពុកយើងធ្វើការនេះពុំទាន់ការ ដូច្នេះត្រូវយើងទៅកណ្ឌទ័ពខ្មោច ជាមួយនឹងគាត់' ។ ថាតែប៉ុណ្ណោះកូនទាំង ៤នាក់នោះ ក៏ស្ទុះលោតទៅតាមបិតាទាំងអស់គ្នា ។ តែខណៈនោះ ខ្ញុំរាជការចាប់មិនឱ្យលោតតាម ដើម្បីឃាត់ឱ្យនៅធ្វើរាជការបានពីរនាក់មកវិញគឺ ចៅពញាវិបុលរាជទេព ១ ចៅពញារាជតេជះសុខ ១ ។ ឯចៅពញាវង្សាអគ្គរាជកែវនឹងចៅពញាបវរទេសរាជកែ (ឬអង់) ជាកូនទី ១ ទី ២ នោះ ខ្ញុំរាជការចាប់ឃាត់ពុំទាន់ ក៏លោតចុះទៅក្នុងរណ្ដៅស្លាប់ជាមួយបិតាទៅ ។ អ្នកមេនាងខៀវក៏លោតសម្លាប់ខ្លួនទៅក្នុងរណ្ដៅ រួមជា ៤នាក់ ។ (ខ្មោចទាំង ៤នាក់នោះបានកើតឡើងជាដំបូកឃ្លាំងមឿង ដល់សព្វថ្ងៃនេះ) ។

លុះដល់ព្រះចន្ទចរត្រង់ ក្នុងថ្ងៃពេញបូណ៌មីខែពិសាខនោះ ក៏ស្រាប់តែឮស្គរសន្ធឹកខ្ទរខ្ទារមហិមានៅពីលើមេឃនឹងនៅក្នុងដី នាំឱ្យភិតភ័យតក្កមាទ៉ែក្រៃលែង ហាក់បីដូចជាកក្រើកក្រឡាមហាប្រថពី ។ ខណៈនោះ ពញាចន្ទមេស្រឹងយកសេចក្ដីក្រាបបង្គំទូលសម្ដេចចៅពញាចន្ទរាជាតាមបណ្ដាំចៅពញាសួគ៌ាលោកមេស្រឹង ដែលបានផ្ដាំនោះ ។ សម្ដេចចៅពញាចន្ទរាជា

ក៏លើកទ័ពចេញទៅចោមបន្ទាយសត្រូវ ។ ឯកងទ័ពសត្រូវបានព្រួសសន្ធឹកខ្ទរខ្ទារ លើកមកក្នុងដីលើមេឃ សន្ធឹកដូចជារន្ទះដូចផ្ទោះ ក៏ភិតភ័យញ័រជើងញ័រដៃរន្ធត់តក់ស្លុត រត់ចោលបន្ទាយចោលសស្ត្រាវុធរត់គេចវេះខ្លួនឱ្យរួចជីវិតតែសព្វខ្លួន ។ សម្ដេចចៅពញាចន្ទរាជា ព្រះអង្គលើកពលយោធាចូលក្នុងបន្ទាយអាសត្រូវ ហើយទ្រង់ចាត់កងទ័ពឱ្យដេញតាមទ័ពអាសត្រូវទៅ ។ ព្រះអង្គបានគ្រឿងសស្ត្រាវុធ ស្បៀងអាហារ សេះ ដំរីជាច្រើនដែលនៅក្នុងបន្ទាយនោះទាំងប៉ុន្មាន ។

(ឯកសារមហាបុរសខ្មែរ , ទំព័រ ១៨៦ - ១៩១)

ពញាសួគ៌ាលោកមឿង

<u>Introductory Note</u>

ស្ម័គ្របក្សពួក supporter, partisan

ស្ដេចកន a usurper (King of Cambodia 1512-1525)

តាំង to appoint

មេទ័ពធំ commander of the main army

ឋានន្តរសក្ដិ /thaanɑntəraqsaq/ rank, position

មេទ័ពមុខ commander of the vanguard

មេទ័ពក្រោយ commander of the rear guard

មេទ័ពឆ្វេង commander of the left flank

មេទ័ពស្ដាំ commander of the right flank

អត្តឃាតកម្ម /qattaqkhiətəkam/ suicide (Lit)

អ្នកមេនាង (=អ្នកម្នាង) concubine or unofficial wife

<u>Text</u>

តាមហេតុគ្រប់ប្រការ concerning all the events, about the whole situation

សម្ដេចចៅហ្វា title indicating a high-ranking prince (here: conferred)

កៅ Kau (uncle of Sdac Kân)

ចាត់ to organize

កែវ (personal name)

ឃុំពល to raise and command forces

ទ័ពស្រួច vanguard, front-line forces

ចៅពញារាជាមេត្រី (title)

ទិព្វ Tip (pers. n.)

ខេត្តភ្នំពេញ name of a former province

ចៅពញាស្រែនស្យេនាឫទ្ធី (title)

ជ័យ Chey (pers. n.)

ខេត្តលវែក name of a former province

ចៅពញាសេនាសង្គ្រាម (military title)

អមរគិរិន្ទបុរ (= អម្រិន្ទបុរ = បរិបូណ៌) name of a former province

ពាន to storm, go over

ណែនណាន់តាន់តាប់ crowded, in great crowds, packed together

ដូចស្រមោចរោមស្ករ all over the place (lit: like ants surrounding sugar)

បោះ (ទ័ព) to encamp, pitch camp

ព័ទ្ធ /poə̆t/ to surround

ដាច់ពោះ to starve

ចេះតែហោចទៅ ៗ /ceh-tae haoc tɨw, haoc tɨw/ increasingly scarce

បារមី power, virtue, chastity

សិន = ២០ព្យាម (ព្យាម = distance across outstretched arms)

ប្រយោជន៍នឹង for the purpose of

ព្រឹក្សា (= ប្រឹក្សា) to advise, consult

រំលៀក to move out

ចំណោម encirclement

ទំលាយ to pierce, penetrate, traverse, push through

ចេញរួច to be able to get out

រឹងតែ to insist on

ទទួលច្បាំង to accept the challenge (to fight)

ការខ្វះខាត lack, shortage

អាសា (= រក្សា)

រាជានុញ្ញាត to give royal permission; royal permission

ព្រះករុណាពិសេស the King

គ្រវី to shake

សិរសា /seirəsaa/ head (Roy)

បិសាច (=បីសាច) /bəysaac/ ghost, spirit

ប្រសិទ្ធភាព /prasətthəphiəp/ effectiveness

មានប្រសិទ្ធភាព effective

សព្វព្រះហឫទ័យ = សព្វព្រះរាជហឫទ័យ happy, pleased, satisfied (Roy)

មន្តវិជ្ជាការ magic formula

អារ to cut, to slash, to saw

ដល់កម្រិត to the utmost, extremely

ហូត to draw out, extract (as a sword from a sheath, a paper from among others)

ព្រះនេត្រា eye (Roy)

ដំណាក់ residence (Roy)

ហត្ថ /hat/ cubit (distance from elbow to fingertips)

បួនជ្រុង square

រានទេវតា an altar

ប្រគំ to play (orchestra)

ពញាចន្ទ a friend and deputy of /kleəŋ mɨəŋ/

ជំទប់ assistant, deputy to the /mee-khum/

ស្មឹង hermit

មេស្មឹង spiritual medium

ភ្នំក្រវាញ Cardamom Mountains (here: probably a region in Pursat Province)

និយាយតពីព្រះមហាក្សត្រមកអញ act as a medium between the king and me

កុំបីនឹង so as not to have...

ខ្ទរខ្ទារ vibrant, resonant

ព្រះបរមបពិត្រ /preəh-barommәbaapɨt/ (title for the king)

ខៀវ (pers. n.)

តាំងពិធី to perform a ceremony

បណ្ដាជាខ្ញុំ entourage (lit: servants, slaves)

កែវ Kev (one of the four sons of /kleəŋ mɨəŋ/)

ចៅពញាវង្សាអគ្គរាជ (title)

ក៉ែ = អង់ one of the four sons of /kleəŋ mɨəŋ/

ចៅពញាបវរទេសរាជ /caw-pəñiə-baarətehsəriəc/ (title)

ទេព one of the four sons of /kleəŋ mɨəŋ/

ចៅពញាវិបុលរាជ (title)

សុខ one of the four sons of /kleəŋ mɨəŋ/

ចៅពញារាជតេជះ /caw-pəñiə-riəccədaeceəh/ (title)

ពុំទាន់ការ not be able to do [it] in time

អង់ (= ក៉ែ) one of the four sons of /kleəŋ mɨəŋ/

ចរ (= ដើរ) to go, walk (Lit)

ព្រះចន្ទចរត្រង់ the moon is directly overhead

ពេញបូរមី full moon

មហិមា /məheqmiə/ extremely

ក្រឡា surface (of earth); court, yard

រន្ទះ lightning

សស្ត្រាវុធ /sattraawut/ weapon

៦. ព្រះចន្ទរាជា

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

(តាមឯកសារ)

ព្រះចន្ទរាជា លុះឮដំណឹងថាស្ដេចកនធ្វើគត់ស្រីសុគន្ធបទ ជាព្រះជេដ្ឋាហើយ ទ្រង់ក៏រកឧបាយកលរត់ចេញពីស្រុកសៀម ។ នៅឆ្នាំ ១៥១៦ ព្រះអង្គទ្រង់ច្បាកស្ដេចស្រុកសៀមបានពលសៀម ៥.០០០ នាក់ រត់ចូលមកស្រុកខ្មែរ ដោយកុហក់ស្ដេចសៀមថាទៅទាក់ដំរីមកថ្វាយ ។ លុះមកដល់ស្រុកខ្មែរកាលណា ស្ដេចក៏ចាប់ធ្វើសង្គ្រាមនឹងស្ដេចកន ។ នៅឆ្នាំ ១៥២៥ ព្រះអង្គមានជ័យជំនះលើស្ដេចកន ស្រុកខ្មែរបានសុខសាន្តត្រាណ ។ ព្រះអង្គក៏ឡើងសោយរាជ្យជាមហាក្សត្រពេញបរិបូណ៌លក្ខណៈតរៀងទៅ ។

សេចក្ដីស្រង់មកនេះថ្លែងអំពីស្ដេចសៀម ក្រោយដែលព្រះចន្ទរាជាទ្រង់បានឡើងសោយរាជ្យហើយ ក៏ធ្វើចុតហ្មាយបង្គាប់ឲ្យព្រះចន្ទរាជាយកសួយសារអាករទៅថ្វាយ ។ ព្រះចន្ទរាជាមិនព្រមធ្វើតាមបង្គាប់ ស្ដេចសៀមក៏លើកទ័ពចូលមកស្រុកខ្មែរ ។

នៅក្នុងសង្គ្រាមជាក្រោយមក ទ័ពខ្មែរមានជ័យជំនះលើទ័ពសៀម ។ ព្រះចន្ទរាជាសោយរាជ្យជាសុខសាន្តរហូតដល់ទិវង្គត់ (១៥៦៦) ។

អត្ថបទ

ផែនដី ព្រះបរមខត្តិយាមហាចន្ទរាជា

នេះនឹងនិយាយអំពីក្រុងទេពបូរីស្រីអយុធ្យា ប្រទេសសៀមវិញ ។ សម្ដេចព្រះចៅចក្រពត្រាធិរាជ សម័យថ្ងៃមួយនោះ ចេញគង់ចុងព្រះទោងរម ជួបជុំអគ្គមហាសេនា សេនាធិបតី មន្ត្រីតូចធំ ខ្ញុំរាជការ ក្រាបបង្គំគាល់តាមតំណែង ទើបព្រះអង្គទ្រង់មានព្រះរាជឱង្ការត្រាស់ប្រិក្សាថា : ចៅពញាចន្ទរាជាបានត្រឡប់ទៅក្រុងកម្ពុជា ប្រាបសឹកសង្គ្រាមបានជាធំនោះ ព្រោះដោយអំណាចរេហ៍ពល ស្បៀងអាហារ គ្រឿងសស្ត្រាវុធ ដំរីសេះរបស់យើងឲ្យទៅ ។ ឥឡូវបានសម្រេចហើយ តែពុំឃើញឲ្យនាំសួយសារមកថ្វាយយើងនៅឡើយ ។ ដូច្នេះ យើងគួរលើកទ័ពទៅប្រាបប្រាម ឬធ្វើដោយប្រការដូចម្ដេច ។ ទើបអគ្គមហាសេនា សេនាបតី មន្ត្រីតូចធំ ខ្ញុំរាជការ ទទួលព្រះរាជបរិហារប្រិក្សាយល់ព្រម ក្រាបបង្គំទូលថា : កាលចៅពញាចន្ទរាជាទទួលព្រះរាជឱង្ការទៅទាក់ដំរីស ហើយមានពុតត្បុតរត់ទៅស្រុកនោះ យើងបានឲ្យបម្រើទៅតាមយកខ្លួនមកនោះ ពញាចន្ទរាជាបានសញ្ញាថា បើខ្លួនបានសម្រេចព្រះនគរកាលណា នឹងនាំសួយសារមកក្រាបទូលថ្វាយ ។ ឥឡូវនេះ ពញា

ចន្ទបានសម្រេចហើយ តែកន្តើយព្រងើយទៅនេះ គួរតែយើងលើកយោធាទាហានទៅប្រាបប្រាម ឲ្យដឹងថ្មីថែង ៗ តែថាធ្វើដូច្នេះ ដូចជាទាស់នឹងច្បាប់ទំនៀមទៅហើយ ព្រោះផែនដីក្រុងកម្ពុជានេះ ពីដើមជាឯករាជ្យដែរ តែក្រោយមកបានពឹងបារមីផែនដីក្រុងទេពនេះជាច្រើនផង មានទាំងខ្លួនពញាអុង សុវណ្ណខៈលោក នៅជាតួយ៉ាងសព្វថ្ងៃនេះស្រាប់ ៗ ដូច្នេះ ទូលព្រះបង្គំយល់ថា គួរតែមានព្រះរាជសារឲ្យទៅរំលឹកម្តងសិន បើកាលណាឃើញថា ចៅពញាចន្ទរឹងទទឹង សឹមយើងលើកទៅធ្វើទោសឲ្យបានសម្រេច ៗ

ព្រះចៅចក្រពត្រាធិរាជទ្រង់ព្រះសណ្ដាប់អស់មន្ត្រីទៅ ទ្រង់យល់ផ្លូវត្រូវសេចក្តីហើយ ទើបទ្រង់ត្រាស់ឲ្យតែងព្រះរាជសារ ចាត់ឲ្យចៅពញាមហាទេព មហាមន្ត្រី នឹងព្រះរាជវរានុកូល ជារាជទូត ឧបទូត ត្រីទូត អញ្ជើញព្រះរាជសារនោះមកដល់ក្រុងកម្ពុជាធិបតី ៗ ទូតទាំង ៣នាក់មកដល់ក្រៅបន្ទាយនគរ ក៏ឲ្យបម្រើទៅប្តឹងសេនាបតី តាមដើងសារដែលចៅហ្វាយស្រុកពោធិសាត់បញ្ជូនមកនោះគ្រប់ប្រការ ៗ

ក្នុងខណៈនោះ សម្តេចចៅហ្វាទឡ្ហៈ នឹងសេនាបតីទាំង ៤សម្រាប់ នាំយកសេចក្តីក្រាបបង្គំទូលព្រះបាទបរមនាថបរមបពិត្រ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ជ្រាបសព្វគ្រប់ហើយ ព្រះបរមនាថបរមបពិត្រ ស្តេចត្រាស់ថា : ជាតិអាសៀមនេះ ចិត្តវាលាមកអាក្រក់ពន់ប្រមាណណាស់ បានជាកាលផែនដីប្រថមក្សត្រខត្តិយាវង្សគ្រងរាជ្យ ក្នុងមហានគរនោះនៀងមកទ្រង់ឲ្យសាងប្រាសាទរាជដំណាក់ជាន់ក្រៅ ចាំទទួលព្រះរាជទូតគ្រប់ប្រទេស ច្រើនតំបន់នោះផងឡូវ សៀមវាឲ្យរាជទូតវាអញ្ជើញព្រះរាជសារវាមកនេះ ត្រូវយើងឲ្យធ្វើព្រះនៅងព្រះពន្លា ទទួលព្រះរាជសារនោះក្រៅកំផែងព្រះនគរដែរ ៗ អគ្គមហាសេនា សេនាបតី ទទួលព្រះរាជឱង្ការហើយ ចាត់មន្ត្រីក្រុមមេការ ឲ្យកណ្ដុរាស្ត្រធ្វើព្រះនៅង ព្រះពន្លា រាយទ័ពទាហានឲ្យចាំរក្សាច្រើនសង្កាត់ កំណត់តែ ៣ថ្ងៃ ៣យប់ ក៏រួចដូចព្រះរាជបញ្ជាការ ទើបក្រុមមេការក៏យកសេចក្តីចូលទៅប្តឹងសេនាបតី សេនាបតីយកសេចក្តីនាំឡើងក្រាបបង្គំទូល ទ្រង់ជ្រាបគ្រប់ប្រការ ៗ សម័យថ្ងៃនោះ ព្រះបរមបពិត្រទ្រង់ព្រះចិន្តាថា : រាជទូតសៀមមកនេះ យើងនឹងចេញទទួលវាឲ្យរួសរាន់ពេក ហាក់ដូចជាយើងកោតខ្លាចវាខ្លាំងណាស់ ទើបទ្រង់ត្រាស់បង្គាប់លួងរាជាមាត្យ មហាមាត្យថា : ឲ្យទៅប្រាប់រាជទូតសៀមថា ឲ្យវារង់ចាំ ១៥ថ្ងៃទៀត ព្រះករុណានឹងចេញទទួល ៗ តែស្តេចបានអាយ័តរាជាមាត្យ មហាមាត្យថា : ឲ្យចាត់ស្បៀងអាហារនាំយកទៅឲ្យវាឲ្យបរិបូណ៌ ៗ ព្រះរាជបម្រើទាំងពីរក៏ថ្វាយបង្គំលា ចេញទៅធ្វើតាមព្រះរាជបញ្ជាគ្រប់ប្រការ ៗ

ក្រោយនោះ ១៥ថ្ងៃ ព្រះបាទបរមនាថបរមបពិត្រ ជាអម្ចាស់ជីវិតលើត្បូង ស្តេចទ្រង់គ្រឿងអលង្ការ មហាឧត្តម ព្រមទាំងព្រះបរមវង្សានុវង្ស នឹងអគ្គមហាសេនា សេ

នាបតី មន្ត្រីតូចធំ ខ្ញុំរាជការ ចាំផ្ទែស្ដេចព្រះរាជដំណើរទៅប្រថាប់នៅព្រះពន្លាភាក់ ។ លង់លុះព្រឹកព្រាងហើយ ព្រះបរមបពិត្រ ជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គចេញទៅគង់លើព្រះរាជយានុកាមាត្រមាស ទ្រីភាលឧត្ដម ព្រះបរមវង្សា សេនាបតី មន្ត្រីតូចធំ ខ្ញុំព្រះរាជការ ហែស្ដេចចេញប្រថាប់ លើព្រះពន្លាភាក់ខាងជើងបន្ទាយព្រះនគរ ១០សិនប្លួយ ។ រាជទូតសៀមទាំង ៣ក៏ក្រាបថ្វាយបង្គំ ថ្វាយព្រះរាជសារ ។ ព្រះបរមនាថបរមបពិត្រ ទ្រង់ត្រាស់ឱ្យលាមប្រែសេចក្ដី ។

អាលក្សប្រែថ្វាយថា :

'ព្រះរាជសារ សុន្ទរបវរសេដ្ឋា មហាវិមល ពណាការ សម្ដេចព្រះចៅចក្រពត្រាធិរាជ ព្រះចៅក្រុងមហានគរ បវរធារាវតី ស្រីអយុធ្យា មហារដ្ឋរាជធានីបុរីរម្យ ឧត្ដមមហាថាន ជាសម្ដេចព្រះបិតុលាធិរាជ ។

ចម្រើនផ្លូវព្រះរាជមេត្រីមក សម្ដេចព្រះបរមរាជា រាមាធិបតី ព្រះចៅក្រុងកម្ពុជា ជាសម្ដេចព្រះភគិនេយ្យា

បានទ្រង់ជ្រាប,

ដ្បិតក្រុងកម្ពុជានេះ កាលពីដើម តាំងពីផែនដីព្រះលំពង់រាជា ព្រះបាទសម្ដេចព្រះស្រីសុរិយោវង្សនោះ សៀមបានវាយបែកមហានគរ ពីរបីដង ហើយបានយកមហានគរនេះជាចំណុះទៀត ។ ក្រោយមកទៀត ក្នុងផែនដីព្រះបាទសម្ដេចព្រះធម្មរាជា ព្រះធម្មរាជាក៏មានព្រះរាជសារទៅដល់យើងឱ្យសង្គ្រោះព្រះអង្គផង ។ យើងក៏បានជួយ បានយកទាំងសម្ដេចព្រះស្រីរាជា ព្រះសុរិយោទ័យទៅទុកក្នុងក្រុងយើង ហើយរាជសម្បត្តិខ្មែរ ក៏យើងឱ្យប្រលចជារបស់សម្ដេចព្រះធម្មរាជា ជាព្រះបិតារបស់សម្ដេចព្រះក្ឫយ ។ ចំពោះព្រះក្ឫយទៀត កាលភិតភ័យក្នុងគ្រាអាព្រះស្ដេចកនវាយបែកព្រះនគរនោះ សម្ដេចព្រះក្ឫយក៏បានរត់ចូលទៅពឹងបុណ្យបារមីក្រុងទេពបុរី ស្រីអយុធ្យាដែរ ក្រុងទេពបូរីក៏ចាត់ពលថ្មើរជើង និងពលសេះដំរី ឱ្យជូនសម្ដេចព្រះក្ឫយត្រឡប់មកក្រុងកម្ពុជា ហើយព្រះក្ឫយបានសន្មតនឹងម៉ឺនពេជ្រពិចិត្តថា : ផែព្រះក្ឫយបានសម្រេចព្រះនគរកាលណា ព្រះក្ឫយនឹងនាំសួយទៅថ្វាយយើង ជាព្រះបិតុលា ។ ឥឡូវព្រះក្ឫយសម្រេចព្រះនគរហើយ ម្ដេចឡើយក៏ពុំឃើញនាំសួយសារ ផ្កាមាសទៅថ្វាយយើងតាមទំនៀម ដូច្នេះឱ្យព្រះក្ឫយចាត់ឱ្យនាំសួយសារ ផ្កាមាស ប្រាក់ ទៅថ្វាយយើងជាព្រះបិតុលាឱ្យត្រឹមត្រូវតាមទំនៀម' ។

ព្រះបរមនាថបរមខត្តិយាមហាចន្ទរាជាធិរាជ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ជ្រាបសេចក្ដីក្នុងព្រះរាជសារហើយ ទ្រង់ព្រះពិរោធណាស់ ផែទ្រង់ខំសង្កត់អត់ទុកក្នុងព្រះរាជហឫទ័យ ហើយក្លែងធ្វើជាទ្រង់ព្រះសម្រួលក្អាកក្អាយ ទើបទ្រង់ត្រាស់ថា : ក្រុងកម្ពុជាធិបតីមហាឥន្ទបត្តបុរី

នេះ កាលដើមឡើយ ជានាយកលើនគរនានាទាំងអស់ ទាំងអាសៀមនេះ ក៏តែងនាំសួយសារមកក្រាបទូលថ្វាយព្រះមហាក្សត្រខ្មែរ ក្នុងមហានគរនេះ ពុំដែលខាតខានមួយរដូវឡើយ ។ លុះក្រោយមក ដល់ផែនដីព្រះបទុមសូរវង្ស ព្រះអង្គមានព្រះនេត្រទិព្វទ្រង់យល់ថា : ពញាទោងនោះ ជាព្រះរៀមផ្ទាល់ព្រះអង្គរួមព្រះមាតាមួយ បែកទៅនៅស្រុកសុខោទ័យ ក៏ទ្រង់តាំងឱ្យជាឯករាជ្យនៅក្នុងស្រុកនោះ ឱ្យសៀមទាំង ៧ស្រុកឡើងស្ដាប់បង្គាប់សម្ដេចព្រះជេដ្ឋា ។ ទ្រង់ខ័ណ្ឌព្រំបុរី ត្រឹមនគររាជសីមា ។ លុះឥតពីព្រះទោងទៅ ស្រុកសៀមក៏នៅឱ្យនាំសុវណ្ណបុប្ផា តម្បារផ្កាមាស មកក្រាបទូលថ្វាយជាចំណុះស្រុកមហានគរតមកទៀត ។ លុះដល់ស្រុកសៀមកើតសង្គ្រាមនឹងលាវពោះខ្មៅ លាវនោះតាំងឡើងជាព្រះមហាក្សត្រ ហើយបានបង្ក្រាបព្រះរាជត្រកូលពញាទោងបាន ក៏តាំងខ្លួនជាឯករាជ្យ ។ លុះដល់មកផែនដីសម្ដេចព្រះបរមរាជា សៀមឡើងរាជ្យ ជាសម្ដេចព្រះរាមាធិបតី សៀមលើកទ័ពមកធ្វើសង្គ្រាមនឹងព្រះបរមរាជា តែពុំបានធ្វើតាមទំនៀមព្រះមហាក្សត្រ គឺឱ្យសំបុត្រចុតហ្មាយមកប្រាប់ជាមុនថា សុំធ្វើសង្គ្រាមទេ ។ ស្រាប់តែឱ្យលបលើកជាទ័ព មកចោមបំបែកមហានគរ ដោយខ្មែរពុំដឹងខ្លួន ។ ជ័យជំនះនេះនឹងរាប់ថា មានរិទ្ធីអានុភាពក៏ពុំបាន ។ កាលយើងទៅនៅស្រុកសៀម ៩ ឆ្នាំនោះទៀត យើងបានសុំឱ្យកងទ័ពមកជួយយើងច្រើនផង ក៏ព្រះចៅចក្រពត្តិពុំឱ្យកងទ័ព នឹងស្បៀងអាហារយើងសោះ ។ ហេតុតែកុសលផលរបស់ក្រុងកម្ពុជាធិបតីមិនឱ្យប្រទេសយើងទាបថោក ក៏បណ្ដាលឱ្យព្រះចៅចក្រពត្តិចាញ់ឧបាយកលយើង ឱ្យយើងទៅទាក់ដំរីស យើងក៏រត់មកចប្បាំងបាន ដោយបញ្ញាធិការនឹងតម្រិះប្រាជ្ញា បុណ្យវាសនារបស់យើងទៅ ។ តើព្រះចៅចក្រពត្តិ មានឱ្យអ្វីជាកម្លាំងមក ក៏បានជាឱ្យមកតាមទារសួយសារដូច្នេះ ឥឡូវនេះបើយើងព្រមថ្វាយ ក៏ជាការឥតប្រយោជន៍ដែរ ។ ទ្រង់ត្រាស់តែម្ល៉ោះហើយ ក៏ទ្រង់ឱ្យអាលក្សណ៍តែងព្រះរាជសារ ប្រគល់ឱ្យព្រះរាជទូតទាំង ៣នាយ នាំត្រឡប់ទៅក្រុងទេពបុរី ស្រីអយុធ្យាវិញ ។ ព្រះរាជទូតទាំង ៣នាក់ បានឮព្រះបរិហារត្រាស់កណ្ដាលជំនុំ ជាសេចក្ដីផ្ទុញផ្ទាល់ដូច្នោះ ក៏នឹកក្រេវក្រោធពន់ប្រមាណ តែពុំអាចហ៊ានឆ្លើយទាស់ព្រះរាជឱង្ការ ព្រោះសេចក្ដីដែលព្រះអង្គត្រាស់ទាំងប៉ុន្មាននោះ ជាសេចក្ដីសុចរិតពិតត្រង់ប្រាកដទាំងអស់ ក៏ថ្វាយបង្គំទទួលព្រះរាជសារ ហើយនាំត្រឡប់ទៅក្រាបទូលថ្វាយព្រះចៅចក្រពត្តិវិញ ។

ស្ដេចសៀមឱ្យសៀមប្រែព្រះរាជសារទៅ មានសេចក្ដីថា :

'ព្រះរាជសុន្ទរបវរ ព្រះបាទសម្ដេចព្រះរាជឱង្ការ ព្រះបរមរាមា មហាចន្ទរាជាធិរាជ រាមាធិបតី សិរីយសោធរ បវរវង្សកូល កំពូលកម្ពុជា មហាឥន្ទបត្តបុរីរម្យ ឧត្តមកុររដ្ឋ រាជធានី ។

ចម្រើនផ្លូវព្រះរាជមេត្រី តបមកសម្ដេចព្រះចៅចក្រពត្តិ ព្រះចៅក្រុងទេពបុរី ស្រីអយុធ្យា ជាសម្ដេចព្រះបិតុលា

បានទ្រង់ជ្រាប,

ដ្បិតយើងជាក្មួយ បានឃើញព្រះរាជសារ មើលឃើញសេចក្ដីទាស់ច្រើនប្រការណាស់ ពុំត្រូវតាមប្រពៃណីអំពីបុរាណរាជវង្សវង្សមកទេ ។ ឯក្រុងកម្ពុជាធិបតីមហានគរនេះ ជានគរធំឧត្តមប្រសើរណាស់ ក្រុងស្រីអយុធ្យាធ្លាប់តែជាចំណុះចុះចូល ថ្វាយសួយសាររវៀងមក ច្រើនផែនដី ។ កាលយើងធ្វើសង្គ្រាមនឹងអាព្រះស្ដេចកននោះទៀត ក៏សៀមពុំបានជួយកម្លាំងសឹកអ្វីសោះ នឹងឲ្យនាំសួយសារមកថ្វាយសម្ដេចព្រះបិតុលានេះ មិនគួរ ។ យើងបានជំនុំយល់ព្រមនឹងព្រះវង្សានុវង្ស អគ្គមហាសេនា សេនាបតី មន្ត្រីតូចធំ ខ្ញុំព្រះរាជការទាំងប៉ុន្មានទៅ យល់ថា សៀមពុំបានមានគុណជួយអ្វីសោះទេ មានតែលបលើកជាទ័ពចោរទៅប្លន់រាស្ត្រ យកព្រះនគរ ពុំមានព្រះរាជសារណាត់សង្គ្រាម តាមប្រពៃណីក្សត្រ ហើយក៏តែងកៀរគ្រួខ្មែរ ប្រែទុច្ចរិតខ្លាំងណាស់ នឹងជៀស្លាប់យកជាទីពឹងពុំគួរ ' ។

សម្ដេចព្រះចៅចក្រពត្រាធិរាជ ទ្រង់ព្រះសណ្ដាប់ចប់ទ្រង់ព្រះពិរោធណាស់ ទ្រង់ត្រាស់ថា : ពញាលង្វែកនិយាយតមកយើងក្នុងព្រះរាជសារនេះ ឃើញថាជាសេចក្ដីព្រហើនភ្លើនព្រះរាជអាជ្ញាខ្លាំងណាស់ ដូច្នេះមានតែយើងគិតធ្វើសង្គ្រាមនឹងពញាលង្វែក ឲ្យឃើញថ្វីដៃម្ដង ។ ខ្មែរធ្លាប់បែកនគរនឹងដៃសៀមពីរបីដងហើយ នៅតែពុំទាន់រាង បើយើងឈ្នះបានព្រះនគរម្ដងនេះទៀត យើងនឹងកៀរយករាស្ត្រឲ្យអស់ពីនគរវា មកទុកក្នុងនគរយើងឲ្យស្យាមប្រទេសនេះរាងចាលថ្វីដៃយើងតទៅ ។ តើអស់សេនាបតី មន្ត្រីគ្រប់ក្រសួង យល់ដូចម្ដេច ។ សេនាបតី មន្ត្រីទាំងពួង ក៏ថ្វាយបង្គំក្រាបទូលថា : ទ្រង់ព្រះតម្រិះនេះ យើងខ្ញុំទូលព្រះបង្គំយល់ថាត្រូវព្រម ៗ គ្នា ។

ព្រះបាទចក្រពត្តិរាជាធិរាជ បានទ្រង់ព្រះសណ្ដាប់អស់មុខមន្ត្រី យកសេចក្ដីក្រាបបង្គំត្រូវនឹងព្រះតម្រិះនោះ ពេញព្រះរាជហឫទ័យណាស់ ទើបទ្រង់ត្រាស់ឲ្យកេណ្ឌកងទ័ព ។ លុះបានរេហ៍ពលមកជួបជុំហើយ នៅព.ស. ២០៧៤ គ.ស. ១៥៣០ ម.ស. ១៤៥២ ច.ស. ៨៩២ ឆ្នាំខាលទោស័ក សម្ដេចព្រះចៅចក្រពត្តិរាជាធិរាជ ត្រាស់ចាត់មេកងទ័ពមុខក្រោយ ឆ្វេងស្ដាំស្រេច សម្ដេចព្រះចៅចក្រពត្រាធិរាជ ទ្រង់គ្រឿងសម្រាប់ពិជ័យយុទ្ធនាស្រេច ស្ដេចឡើងគង់ព្រះទីនាំងគជេន្ទ្រឈ្មោះប្លាយមង្គលទ្វីប ហើយក៏ឲ្យគោះគងទូងភេរី លើកយោធាមុខក្រោយ ឆ្វេងស្ដាំ តាមក្បួនពិជ័យសង្គ្រាមដើរ ។ ទ័ពធំមកត្រូវនគររាជសីមានឹងមហានគរ ។

(ឯកសារមហាបុរសខ្មែរ, ទំព័រ ៣២១ - ៣២៨)

ព្រះចន្ទរាជា

Introductory Note

ធ្វើគត់ to kill (Roy)

ស្រីសុគន្ធបទ /srəy-sokŭənthəbɑt/ King of Cambodia 1504-12, brother of Chan Raja

សុខសាន្តត្រាណ peaceful, quiet, at peace

ពេញបរិបូណ៌លក្ខណៈ legally, with full rights and attributes

ចុតហ្មាយ letter, message (Roy)

ជាសុខសាន្ត peacefully

ទិវង្គត់ /tiq-wŭəŋkŭət/ death; to die (Roy)

Text

ផែនដី world; kingdom

ព្រះបរមខត្តិយាមហាចន្ទរាជា (King) Chan Raja

ចៅពញាចន្ទរាជា (King) Chan Raja

ក្រុងទេពបុរីស្រីអយុធ្យា Ayuthia

ព្រះចៅចក្រពត្រាធិរាជ /prĕəh-caw-caqkrəpŏətraathiriəc/ title of Ramathibodi II

សម័យថ្ងៃមួយនោះ one day

ព្រះរោងរម /prĕəh-rooŋ-rum/ secondary or auxiliary hall

សេនា commander, officer (lower than /seinaapədəy/)

អគ្គមហាសេនា very high-ranking military officer (higher than /seinaapədəy/)

សេនាធិបតី commander (higher than /seinaa/)

ក្រាបបង្គំគាល់ to have an audience with (Roy)

ត្រាស /trah/ to say, decree (Roy)

ប្រឹក្សា to advise, consult

ក្រុងកម្ពុជា Cambodia

សួយសារ tribute (material)

ប្រាប to subdue

ប្រាម to warn

ប្រាបប្រាម to subdue, bring under subjection

បរិហារ to fulminate, rant; to talk, comment

ទទួលព្រះរាជបរិហារ having heard the King's comments

ទទួលព្រះរាជឱង្ការ undertake [to carry out] the King's words

សញ្ញា to promise

សម្រេចព្រះនគរ gain accession to the throne

ឲ្យដឹងថ្វីដៃ to show [our] power, let [him] know who's boss

តែថា but if

សុវណ្ណខៈលោក /sowannəkhaqlook/ (title?)

តួយ៉ាង example

ព្រះរាជសារ royal letter, royal communication

រំលឹក to remind

រឹងទទឹង obstinate, dogged, stubborn

លើក (= លើកទ័ព)

ព្រះសណ្ដាប់ to listen (Roy)

យល់ផ្លូវត្រូវសេចក្ដី come to a decision based on the situation

តែង to write up, to draft, to compose

ចៅពញាមហាទេព (title)

មហាមន្ត្រី (title)

ព្រះរាជវង្សានុកូល royal family (here: members)

ឧបទូត deputy ambassador

ត្រីទូត third-ranking diplomat

អញ្ជើញ to take, to carry

ក្រុងកម្ពុជាធិបតី Kingdom of Cambodia

ដើងសា messenger

ចៅហ្វាទឡ្ហៈ /cawwaatəlaq/ Prime Minister

សេនាបតីទាំង ៤ សម្រាប់ commanders of all four ministries: Army, Navy, Interior, and Justice

ព្រះពុទ្ធបរមនាថបរមបពិត្រជាអម្ចាស់ជីវិតលើត្បូង the King (Chan Raja)

លាមក /liəmuə̆q/ excrement (Lit)

ចិត្តលាមក dirty, crooked, vile-hearted

ពន់ប្រមាណ extremely

ប្រថម (=បឋម)

ប្រថមក្សត្រ earlier kings

ខត្តិយាវង្ស (=ខត្យាវង្ស)

គម្រង (=គ្រង)

ជាន់ក្រៅ outside (of the city)

មេការ head of provincial public works

ក្រុមមេការ construction forces

សម័យថ្ងៃនោះ that day

យើងនឹងចេញទទួលវាឱ្យរួសរាន់ពេក [if] we are too quick to receive them

រាជាមាត្យ /riəciəmaat/ royal servant, royal aide

មហាមាត្យ palace official (same rank as /seinaapədəy/)

អាជ្ញាត to give strict orders to, to instruct

អលង្ការ /qalaŋkaa/ jewelry, regalia

ទ្រង់ auxiliary which typically precedes verbs describing royal action; sometimes precedes nouns with the meaning: to do; to put on; to hold

ទ្រង់គ្រឿងអលង្ការ to don [his] regalia

មហាឧត្តម excellent (here: impressive)

លង់លុះ when

លង់លុះព្រឹកព្រាងហើយ when it was light, at daybreak

ឱភាស light (here: shining, brilliant)

ព្រះរាជយានុកាមាត្យមាស golden palanquin

ព្រះបរមវង្សា Royal Family

ពួយ approximately

លាម translator, interpreter

អាលក្ស /qaalaq/ palace officials in charge of inventory and royal treasury

សុន្ទរ (=ពីរោះ) /sontəreə̆q/ euphonious

បវរ /bɑɑ-wɔɔ/ excellent, superior

សេដ្ឋា /setthaa/ extraordinary, great

វិមល /wiqmuə̆l/ pure, clean

ពលាការ (=ពលិការ) offering, tax, tribute (here: tributary)

សម្ដេចព្រះចៅចក្រពត្រាធិរាជ---ឧត្តមថាន title of King Rama Thibodi of Ayuthia

ព្រះបិតុលា /preə̆h-peqtolaa/ paternal uncle

សម្ដេចព្រះបិតុលា royal uncle

មេត្រី friendship, affection

ចម្រើនផ្លូវព្រះរាជមេត្រីមក standard form of written salutation between kings: to (lit: with growing royal friendship to)

សម្ដេចព្រះបរមរាជារាមាធិបតី title of Chan Raja

សម្ដេចព្រះភាគិនេយ្យា /-pheə̆qkineeyoo/ royal nephew

លំពង់រាជា Lampong Raja (king of Angkor 1409-1416)

ព្រះស្រីសុរិយោវង្ស (=ព្រះសុរិយោវង្ស)

វាយបែក to sack, capture, defeat

ចំណុះ vassal, dependant; to be under the suzerainty of

ធម្មរាជា Dhammaraja (king of Cambodia 1473-1504; father of Chan Raja)

ព្រះស្រីរាជា Sri Raja (king of Cambodia 1459-1473)

ព្រះសុរិយោទ័យ name of a Prince

រាជសម្បត្តិ /riəccəsɑmbat/ throne

បុណ្យបារមី power

ពលថ្មើរជើង army, ground forces

ម៉ឺនពេជ្រពិចិត្រ /məɨn-pɨc-picət/ title of a Thai official

សួយ tribute

ផ្កាមាស artificial flower made of gold and traditionally presented to an overlord as a symbol of vassalage

ពិរោធ anger; to be angry (Roy)

សង្កត់អត់ទុកក្នុងព្រះរាជហឫទ័យ to control oneself, keep one's composure (Roy)

ក្លែង to pretend, to disguise

ព្រះសម្រួល to be at ease, composed, relaxed; to laugh (Roy)

ក្អាកក្អាយ jovial, genial, vivacious

ក្រុងកម្ពុជាធិបតីមហាឥន្ទបត្តបុរី /-qəntəbat-borəy/ Cambodia

នាយក /niəyŭəq/ chief, head, sovereign

ពុំដែលខានតខានមួយដងទេឡើយ never missing a single time

បទុមសូរ្យវង្ស /batum-soriyawŭəŋ/ Batom Suryavong

ទិព្វ /tɨp/ magic

ពញារោង legendary Cambodian prince, builder of Sukhothai

ព្រះរៀម elder brother (Roy)

រួមព្រះមាតាមួយ having the same mother

សុខោទ័យ /sokhaotɨy/ Sukhothai

ឡើងស្តាប់បង្គាប់ come under the control (of)

ព្រំបុរី border, territorial limit

នគររាជសីមា Nokor Raja Sima (the present Thai province of Nakorn Ratchasima)

ឥតពី (= អត់ពី)

ព្រះរោង (= ពញារោង)

សុវណ្ណបុប្ផា (= ផ្កាមាស) /sowannəbopphaa/ gold flower tribute

តម្រារ (= ស្លឹក = សន្លឹក) leaf, sheet, surface

លាវពោះខ្មៅ Lao of Chiengrai (lit: black-stomach Lao)

រាប់ថា...ពុំបាន cannot be considered as...

រិទ្ធិអានុភាព power

កុសលផល /kosal-phal/ accumulated merit

ទាបថោក cheap, lowly

បញ្ញាធិការ superior intelligence, great intelligence

តម្រិះប្រាជ្ញា intelligence

នាយ chief, head (functions like /neəq/)

កណ្តាលជំនុំ in the midst of the assembly

ផ្ទុញផ្ទាល់ to treat with contemptuous mirth

ក្រេវក្រោធ to be angry

សៀម (= សាម)

ព្រះបាទសម្តេច---កុនរជ្ជរាជធានី title of Chan Raja

សេចក្តីទាស់ objectionable or inappropriate things

ប្រវេណី (= ប្រពៃណី) custom, tradition

បុរាណរាជ្យ earlier reigns

ចុះចូល to surrender, submit, concede

ព្រះវង្សានុវង្ស (= ព្រះរាជវង្សានុវង្ស)

ណាត់សង្គ្រាម to declare war

ក្រស័ត្រ (= ក្សត្រ)

ក៏ប្រែ to become

ជឿស្តាប់ជាទីពឹងពុំគួរ can't be relied on, unworthy of trust

ពញាលក្ខក Chan Raja

សេចក្តីព្រហើនក្លើន disrespect, arrogance (for)

ព្រះរាជអាជ្ញា royal order, royal authority

រាង to have learned one's lesson, be properly taught

ស្យាមប្រទេស Siam (here: Siamese territory)

រាងចាល (=រាង)

ព្រះតម្រិះ to think, decide (Roy)

ព្រម ៗ គ្នា all together (here: unanimously)

ពេញព្រះរាជហឫទ័យ satisfied, happy (Roy)

ឆ្នាំខាល year of the Tiger

ពិជ័យ victory

យុទ្ធនា /yutthənia/ war

គ្រឿងសម្រាប់ពិជ័យយុទ្ធនា paraphernalia of war

គង់ to sit on, to ride on (Roy, Clergy)

គជេន្ទ្រ /kəceen/ elephant (Lit)

ញ្លយមង្គលទ្វីប name of the king's elephant

គង gong

ទូង to sound, to strike (gong, drum, etc.)

ភេរី big drum

តាមក្បួនពិជ័យសង្គ្រាម in martial fashion (lit: in accordance with the principles of victorious battle)

៧. អាចារ្យលាក់

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

(តាមឯកសារ)

នៅក្នុងរជ្ជកាលព្រះបាទនរោត្តម មានការបះបោរកើតឡើងស្ទើរតែគ្មានឈប់ឈរសោះ ជាពិសេសនៅពេលដែលព្រះអង្គទើបនឹងចាប់ឡើងសោយរាជ្យ ។ ការបះបោរនៅពេលនោះមិនដូចជាការបះបោរនៅគ្រាមុន ៗ ទេ...ការបះបោរក្នុងសម័យព្រះបាទនរោត្តម ភាគច្រើនមានហេតុពីរប្រការ ទីមួយ គេប្រឆាំងនឹងស្ដេចនរោត្តម ដែលគេយល់ថាជាអ្នកលក់ស្រុកខ្មែរទៅឱ្យបារាំង ទីពីរ គេចង់កំចាត់អាណានិគមនិយមបារាំងឱ្យផុតពីដីខ្មែរ ។ នៅពេលនោះ ប្រជាជនខ្មែរត្រូវស្លាប់ជាច្រើន ដោយទ័ពរបស់ស្ដេចឯងផង និងដោយទ័ពរបស់បារាំងផង ។

សេចក្ដីដកស្រង់មកនេះ គ្រាន់តែជាឧទាហរណ៍នៃការតស៊ូយ៉ាងក្លាហាននៃប្រជាជនខ្មែរប្រឆាំងនឹងអំណាចអាណានិគមនិយម ។

អត្ថបទ

នៅក្នុងខែជេស្ឋឆ្នាំខាលអដ្ឋស័កនោះ មានជនក្បត់ឈ្មោះអាលាក់ តាំងខ្លួនធ្វើជាអ្នកសិល ហើយលើកខ្លួនជាកូនល្ហងពោធិកំបោរ ។ វាបញ្ចុះបញ្ចូលក្មួយ ស្មៀង និងរាស្ត្រខ្មែរទៃព្រៃលើ ហើយលើកជាទ័ពទៅច្បាំងនឹងសេនាទាហាន បារាំងដែល នៅបន្ទាយរោងដំរី រួចវាលើកទ័ពត្រឡប់មកខេត្តត្បូងឃ្មុំ ។ ឧកញ៉ាអរជូនស៊ូបានដឹង ក៏កែណ្ឌពលបញ្ចូលជាកងទ័ពជាប្រញាប់ ។ អាលាក់លើកទ័ពមកច្បាំងនឹងទ័ពឧកញ៉ាអរជូនស៊ូ បាញ់ត្រូវឧកញ៉ាអរជូនរបួសជាខ្លាំង ។ សេនាទាហានក៏នាំឧកញ៉ាអរជូនជិះទូកឆ្លងទន្លេពាមមង្គល មកមើលរបួសក្នុងខែត្រកំពុងសៀម ។ ចំណែកខាងអាលាក់លើកទ័ពត្រឡប់ទៅសង្កត់រាស្ត្រខែត្របាភ្នំ រំដួល ស្វាយទាប ខាងទៃព្រៃលើ សឹងចុះចូលច្រើន ។ ឧកញ៉ាអរជូនស៊ូ ក៏ធ្វើសំបុត្រមកក្រាបបង្គំទូល សូមទ្រង់ជ្រាបគ្រប់ប្រការ ។ ក្រោយពីនោះ ឧកញ៉ាអរជូនលើកទ័ពត្រឡប់ឆ្លងទៅបោះនៅពាមមង្គល ខែត្រត្បូងឃ្មុំ ។ អាលាក់បានដឹង លើកទ័ពមកច្បាំងទៀត ។ ឧកញ៉ាអរជូនស៊ូត្រូវនឹងគ្រាប់កាំភ្លើង ទទួលអនិច្ចកម្មក្នុងសង្គ្រាម ។ កងទ័ពខ្មោចឧកញ៉ាអរជូន បរាជ័យរត់ខ្ចាត់ខ្ចាយអស់ទៅ ។ អាលាក់បានបោះទ័ពនៅទីនោះ ។ ព្រះបាទសម្ដេចព្រះនរោត្តមទ្រង់បានជ្រាបថា 'ឧកញ៉ាអរជូនស៊ូទទួលអនិច្ចកម្មហើយ' ទ្រង់ព្រះមេត្តាប្រោសតាំងឧកញ៉ាពិភក្ដីទិព្វរាជរស់ ឱ្យឡើងយសស័ក្តិជា 'ឧកញ៉ាអរជូន' រួចទ្រង់ចាត់ឱ្យចេញទៅឈររក្សាខេត្តត្បូងឃ្មុំ ទ្រង់ចាត់ឧកញ៉ាក្រឡាហោមបាន ឱ្យនាំសេនាទាហានចេញទៅច្បាំងនឹងអាលាក់ ។ លោកឧកញ៉ាបាន លុះ

បានទៅដល់ខេត្តបាភ្នំ ជួបនឹងឧកញ៉ាធម្មាតេជោវែហន ឧកញ៉ាចក្រីពេជ្រ ឧកញ៉ាជ័យយោធាសង្គ្រាមទុំ បានបញ្ចូលទ័ពជាមួយគ្នាលើកចេញពីខែត្របាភ្នំ កាត់ទៅខែត្រត្បូងឃ្មុំដល់ខែត្រព្រះត្រពាំងរាំង ចោះទ័ពនៅភូមិទីព្រៀងខ្វាយ ។ អាលាក់បានដឹង លើកទ័ពត្រឡប់មកច្បាំងនឹងទ័ពឧកញ៉ាក្រឡាហោមញ៉ន នៅខេត្តពារាំង ។ ថ្ងៃអង្គារ ៥ កើត ខែអាសាធ ឆ្នាំខាលអដ្ឋស័ក កងទ័ពអាលាក់ចោមព័ទ្ធធ្វើគត់ឧកញ៉ាក្រឡាហោមញ៉ន ៣ ទទួលអនិច្ចកម្មក្នុងសង្គ្រាមនៅភូមិទីព្រៀងខ្វាយខេត្តពារាំង ។ សេនាទាហានខែនខ្មោចឧកញ៉ាញ៉នំនាំគ្នារត់ខ្ចាត់ខ្ចាយ ។ ពួកកងទ័ពអាលាក់ចាប់បានឧកញ៉ាធម្មាតេជោវែហន ឧកញ៉ាចក្រីពេជ្រ ឧកញ៉ាជ័យយោធាសង្គ្រាមទុំ តែវាមិនសម្លាប់ទេ វាចាត់សេនាទាហានឱ្យឃុំទុកកុំឱ្យរត់រួច ។ អាលាក់ក៏ចោះទ័ពនៅទីនោះ ។

ព្រះបាទសម្តេចព្រះនរោត្តមទ្រង់ជ្រាបថា 'ឧកញ៉ាក្រឡាហោមញ៉នទទួលអនិច្ចកម្មទៅហើយ' ក៏ទ្រង់ចាត់ឧកញ៉ាបវរនាយកម៉ៅ ១ ឧកញ៉ាបវរនាយកសេក ១ ឱ្យនាំសេនាទាហានទៅចោះនៅកំពង់ខ្សាច់ស ខេត្តបាភ្នំ ឱ្យកេណ្ឌបណ្តារាស្ត្របញ្ចូលក្នុងកងទ័ព លើកទៅច្បាំងនឹងទ័ពអាលាក់ទៀត ។ មិនតែប៉ុណ្ណោះ ទ្រង់ចាត់ឧកញ៉ាវិបុលរាជវ៉ែនឱ្យលើកទ័ពទៅចោះនៅពាមមង្គល ខេត្តបាភ្នំ ត្បូងឃ្មុំ រួបរួមនឹងចៅហ្វាយស្រុកខាងទន្លេធំ ឱ្យលើកទៅច្បាំងនឹងអាលាក់ ឱ្យចោមព័ទ្ធចាប់សម្លាប់វា ។ រួចទ្រង់ចាត់ព្រះវែស្រនជ័យលឹងឱ្យចុះទៅស្រុកទីព្រនគរ សុំទ័ពអាត់មួរវ៉ាល់មកច្បាំងនឹងទ័ពអាលាក់ ។ អាត់មួរវ៉ាល់ចាត់អំប្រេយ៉ាឌីបូរវ៉ាសាញ៉ែចេរ ឱ្យនាំសេនាទាហានបារាំងសែស ៥០ ចុះកប៉ាល់បើកចេញពីស្រុកទីព្រនគរឡើងមកដល់ស្រុកភ្នំពេញ ហើយឡើងគំនាប់ថ្វាយបង្គំគាល់ព្រះបាទសម្តេចព្រះនរោត្តម ក៏ចុះកប៉ាល់បើកទៅទន្លេធំ ជួបនឹងឧកញ៉ាវិបុលរាជវ៉ែននៅពាមមង្គល ចាំទទួលច្បាំងនឹងអាលាក់ ។

ថ្ងៃអាទិត្យ ១០ កើត ខែអាសាធ ឆ្នាំខាលអដ្ឋស័ក ព្រះបាទសម្តេចព្រះនរោត្តមទ្រង់ព្រះមេត្តាប្រោស តាំងនាមអ្នកអក ៤ គឺ អ្នកអកមង្គលនារី ១ អ្នកអកវររាជវង្សា ១ អ្នកអកអង្គអគ្គកញ្ញា ១ អ្នកអកស្រីគ្គានុរក្ស ១ ។ ទ្រង់តាំងអ្នកយាយ ៤ គឺ អ្នកយាយទេពយុរយារ ១ អ្នកយាយចិត្តាភិសេក ១ អ្នកយាយកោមលធិរាជ ១ អ្នកយាយឯកអគ្គវង្សា ១ ។ ក្នុងឆ្នាំខាលអដ្ឋស័កនោះ ព្រះអង្គម្ចាស់ឧបលប្រសូតព្រះរាជបុត្រ ១ អង្គព្រះនាមព្រះអង្គម្ចាស់ពារ ។ ព្រះនាងចមសុជាតិបញ្ញានូនសម្ភពព្រះរាជបុត្រី ១ អង្គព្រះនាមព្រះអង្គម្ចាស់គន្ធា ។ ព្រះនាងចមព្រះញាតិញ៉ិកសម្ភពព្រះរាជបុត្រី ១ អង្គព្រះនាមព្រះអង្គម្ចាស់សុតាវតី ។

ថ្ងៃព្រហស្បតិ៍ ៦ កើត ខែមិគសិរ ឆ្នាំខាលអដ្ឋស័ក អាលាក់លើកទ័ពផ្លូវមកត្រើយខាងលិច ចូលដល់ក្រុងឧដុង្គមានជ័យ ច្បាំងដេញទ័ពឧកញ៉ាវង្សាអគ្គរាជអ៊ុម ឧកញ៉ាពិស្ណុលោកព្រាំរត់ខ្ចាត់ខ្ចាយ ហើយវាលើកទ័ពដេញតាមមកដល់ខែត្រភ្នំពេញ ចោះទ័ពនៅខាងកើតវត្តកំពែង

ជាខាងលិចវាលសម្លាប់នាយ ។ ឯអំប្រេយ៉ាសឺបូវ៉ាសាពាំងចេរបានដឹងថាអាឡាក់លើកទ័ពឆ្លងមកត្រើយខាងលិចហើយ ក៏នាំសេនាទាហានចុះកប៉ាល់មកក្រុងភ្នំពេញ ។ ថ្ងៃ ៦ រោច ខែមិគសិរ ឆ្នាំខាល អាឡាក់លើកទ័ពចូលដល់ស្ពានយមរាជ បោះទ័ពនៅទីនោះ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ចាត់ឧកញ៉ាវង្សាអគ្គរាជអុំ ១ ឧកញ៉ារាជាមេត្រីមុំ ១ ឧកញ៉ាស្រីនគរបាលមាន់ ១ ឱ្យលើកទ័ពទៅទទួលច្បាំងនឹងអាឡាក់ នៅស្ពានយមរាជ ពុំឈ្នះពុំចាញ់ ។ អាឡាក់ថយទ័ពទៅបោះនៅទីដដែល ។

ថ្ងៃអាទិត្យ ១ កើត ខែបុស្ស ឆ្នាំខាលអដ្ឋស័ក ព្រះបាទនរោត្តមទ្រង់ព្រះមេត្តាប្រោសតាំងឧកញ៉ាឥស្សរៈអក្ខរាប្រាក់ ឱ្យឡើងយសស័ក្ដិជា 'ឧកញ៉ាវាំងវរវៀងជ័យ' ។ តាំងឧកញ៉ាឥស្សរាពាណិជសៅរ៍ជា 'ឧកញ៉ាមហាឥស្សរានរិន្ទ ឥន្ទវិជិត រតនោត្តម បរមរាជុត្តមគ្គ មហាសេនាធិបតី អភ័យភេរីបារា ក្រុមពាហុ សមុហៈ ព្រះក្រឡាហោម' ។ តាំងឧកញ៉ាប្រសើរសុរិវង្សម៉ៅជា 'ឧកញ៉ាប្រសើរសុរិវង្ស សមន្តពង្ស វិសុទ្ធិរសរដ្ឋ វិវឌ្ឍរឿងឫទ្ធិ វិចិត្រប្រីជា អភ័យភេរីបារា ក្រុមពាហុ សមុហមហាផ្ទៃ ទីចក្រី' ។

ថ្ងៃចន្ទ ២ កើត ខែបុស្ស ឆ្នាំខាល ព្រឹកម៉ោង ៧ លោកប៉ូចេរ មេទ័ពបារាំងចាត់បារាំងសក្ដិ ២ ម្នាក់ ឱ្យនាំសេនាទាហានបារាំង ៥០ ទាហានយួន ៩០ នាក់ លើកទៅច្បាំងនឹងអាឡាក់ យកខ្មែរ ៣ នាក់ឱ្យនាំផ្លូវទៅផង លុះទៅដល់បានច្បាំងគ្នាពុំរួញរា ។ លុះសេនាទាហានបារាំង-យួនបាញ់ត្រូវពលទ័ពអាឡាក់របួសស្លាប់ច្រើននាក់ អាឡាក់ទ្រាំពុំបាន នាំសេនាទាហានរត់ខ្ចាត់ខ្ចាយ ចោលរទេះ សេះ ដំរី គ្រឿងប្រដាប់នៅទីនោះ ។ អាឡាក់ទៅបោះទ័ពនៅត្រពាំងឈ្លូក ក្នុងខែត្រសំរោងទង ខាងលិចក្រុងឧដុង្គមានជ័យ ។ លោកសក្ដិ ២ មេទ័ពបារាំងនាំសេនាទាហានត្រឡប់មកភ្នំពេញវិញ ។

ថ្ងៃពុធ ៤ កើត ខែបុស្ស ឆ្នាំខាល ទ្រង់ចាត់ឧកញ៉ាប្រសើរសុរិវង្សម៉ៅ ឱ្យលើកទ័ពផ្លូវគោក ជាមួយនឹងសក្ដិ ២ មេទ័ពបារាំងសែស តាមទៅច្បាំងនឹងអាឡាក់ទៀត ។ ឯឧកញ៉ាតេជោអី លើកទ័ពចេញពីខែត្រពារាំង ឆ្លងទន្លេមកត្រើយខាងលិច តាមទ័ពអាឡាក់ដល់ក្រុងឧដុង្គមានជ័យ ជួបនឹងឧកញ៉ាប្រសើរសុរិវង្សម៉ៅ នឹងលោកសក្ដិ ២ បារាំងសែស បានដឹងថា 'អាឡាក់បោះទ័ពនៅត្រពាំងឈ្លូក' ហើយក៏ប្រមូលកងទ័ពតាមទៅច្បាំងនឹងទ័ពអាឡាក់ ទ័ពវាបែករត់ខ្ចាត់ខ្ចាយអស់ ។ ឯអាឡាក់ជាប់តែសេនាទាហាន ៣០ នាក់គត់ រត់ឆ្លងទៅត្រើយខាងកើត ។ ឧកញ៉ាប្រសើរសុរិវង្សម៉ៅ ឧកញ៉ាតេជោអី លោកសក្ដិ ២ លើកទ័ពត្រឡប់មកភ្នំពេញវិញ ក្រាបបង្គំទូលសូមទ្រង់ជ្រាបគ្រប់ប្រការ ។

ថ្ងៃអាទិត្យ ៨ កើត ខែបុស្ស ឆ្នាំខាល ពួកកងទ័ពអាឡាក់លើកទ័ពមកចោមចាប់សង្ឃ

រាជបារាំង នៅភូមិមាត់ក្រសាស់ ធ្វើគត់ហើយដុតផ្ទះវិនាសអស់ រួចមកដុតបន្ទាយខាងត្បូងវត្តអារាទីកំប្រុតឆេះអស់ទៀត ។ ថ្ងៃអង្គារ ១៣ កើត ខែផល្គុន អាឡាក់លើកកងទ័ពមកបោះនៅព្រៃកល្បង ក្នុងខែត្រខ្សាច់កណ្ដាលទៀងមកដល់វត្តអារាទីកំប្រុត ខែត្រស្វាឯម ។ ព្រះបាទសម្ដេចព្រះនរោត្ដម ព្រមមួយអន្លើដោយខ្ញុំរាជការជាច្រើន ស្ដេចយាងចុះគង់ព្រះទីនាំងកប៉ាល់ឈ្មោះ 'ព្រះទេវតសង្ហាត' ។ ឯលោកប៉ូចេរ មេទ័ពបារាំងនឹងទាហានបារាំងសែស ជិះកប៉ាល់ ១ ទៀត ។ ស្ដេចចេញព្រះរាជដំណើរនាំសេនាទាហានទៅបាញ់ទ័ពអាឡាក់ ៗ បរាជ័យ រត់ខ្ចាត់ខ្ចាយ ហើយស្ដេចចេញព្រះរាជដំណើរបង្ហួសទៅពាមមង្គល ក្នុងខែត្រត្បូងឃ្មុំ ។ ឯទ័ពអាឡាក់កាលបរាជ័យហើយ រត់ឡើងទៅព្រៃលើ បញ្ចុះបញ្ចូលរាស្ត្របានច្រើន ហើយលើកកងទ័ពទៅបោះនៅខែត្រពារាំង តាំងទ័ពនៅទីនោះ ។ ឧកញ៉ាមហាឥស្សរាសៅរ៍ ឧកញ៉ាអរជូនរស់បោះទ័ពនៅខេត្តត្បូងឃ្មុំ ។ ឯឧកញ៉ាអាទិច្ចគាមវ៍នសេនាសៅរ៍ ចៅហ្វាយស្រុកខែត្រទទឹងថ្ងៃ បានដឹងថា 'អាឡាក់លើកទ័ពមកបោះនៅខែត្រពារាំង' ក៏លើកសេនាទាហានទៅដល់ភូមិព្រៃល្វា ព្រៃកន្ទៅ ច្បាំងគ្នានៅទីនោះ ។ ទ័ពអាឡាក់បាញ់កាំភ្លើងមកត្រូវឧកញ៉ាអាទិច្ចគាមវ៍នសេនាសៅរ៍ ៗ ទទួលអនិច្ចកម្មក្នុងសង្គ្រាម ។ ពួកកងទ័ពនៃខ្មោចឧកញ៉ាសៅរ៍ក៏រត់ខ្ចាត់ខ្ចាយ ។ ឯអាឡាក់លើកទ័ពទៅបោះនៅភូមិប្របូត ក្នុងខែត្រស្វាយទាប ដើម្បីរាំងទ័ពបារាំងសែសនៅបន្ទាយទេរាងដំរី កុំឱ្យលើកទ័ពមកជួយទ័ពខាងលិចបាន ។

ថ្ងៃចន្ទ ១ កើត ខែជេស្ឋ ឆ្នាំថោះនពស័ក លោកអាត់មួរ៉ាល់ដែលឈរស្រុកព្រៃនគរ បានចាត់កងទ័ពបារាំងសែស ឱ្យហែសម្ដេចព្រះស៊ីសុវត្ថិ ហរិរាជរតនៃក្រៃកែវហ្វា ចេញពីស្រុកព្រៃនគរ តាមផ្លូវជើងគោក ឱ្យមកជួយបង្ក្រាបទ័ពអាឡាក់ តាមផ្លូវបន្ទាយទេរាងដំរី ដល់ខែត្របាភ្នំ រំដួល ស្វាយទាប ។ អាឡាក់បានដឹង ពុំហ៊ានទទួលច្បាំង ក៏នាំកងទ័ពដោះថយទៅបោះក្នុងខែត្រព្រៃវែង រង់ចាំស្ដាប់ការ ។ ឯទាហានបារាំងសែសដែលហែជូនស្ដេចមកនោះ ទ្រង់ឱ្យត្រឡប់ទៅស្រុកព្រៃនគរវិញ ។ ក្រោយពីនោះ សម្ដេចព្រះស៊ីសុវត្ថិ មន្ត្រីខ្ញុំរាជការ ឱ្យកេណ្ឌរាស្ត្របញ្ចូលជាកងទ័ពបានច្រើន ហើយលើកកាត់ទៅដល់ខែត្រព្រៃវែង វាយទ័ពអាឡាក់ ៗ បរាជ័យ នាំសេនាទាហានទៅតាំងទ័ពនៅភូមិសុរិល ក្នុងខែត្រត្បូងឃ្មុំ ។ ចំណែកគ្រួរដែលអាឡាក់កៀរយកមកបានទាំងប៉ុន្មាន ក៏នាំគ្នារត់មកចូលស្ដេចទាំងអស់ ។ ទ្រង់បានបើកឱ្យទៅនៅតាមភូមិលំនៅរបស់ខ្លួនវិញ ។ ទើបសម្ដេចព្រះស៊ីសុវត្ថិ ស្ដេចលើកទ័ពពីខេត្តព្រៃវែង ទៅបោះនៅពាមមង្គល ខែត្រត្បូងឃ្មុំ ដាក់គយល្បាតប្រយ័ត្នម៉ាំមួន រួចត្រាស់បង្គាប់ឱ្យធ្វើដំណាក់គង់នៅទីនោះ ។

ឯព្រះបាទសម្ដេចព្រះនរោត្តមទ្រង់ជ្រាបថា 'សម្ដេចព្រះកែវហ្វាជាព្រះអនុជ ស្ដេចយាងពីព្រៃនគរមកជួយវាយទ័ពអាឡាក់ ឥឡូវស្ដេចមកបោះទ័ពនៅពាមមង្គល ខែត្រត្បូងឃ្មុំ' ក៏

ទ្រង់មានព្រះបន្ទូលប្រាប់ពួកនឹងសេនាបតីទាំងឡាយថា 'ត្រូវយើងទៅគួរសមនឹងសម្ដេចព្រះកែវហ្វាទើបគួរ' ។ នាម៉ឺនសព្វមុខមន្ត្រីក៏យល់ព្រមតាមព្រះទ័យ ។ ថ្ងៃចន្ទ ៥ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក វេលាម៉ោង ៧ ព្រឹក ព្រះបាទសម្ដេចព្រះនរោត្ដមស្ដេចយាងចុះគង់ព្រះទីនាំងកប៉ាល់ឈ្មោះ 'ព្រះទេវគសង្ខាត' នឹងមន្ត្រីខ្ញុំរាជការហែស្ដេចជាច្រើន ។ ឯលោកមេទ័ពប៉ូចែរជិះកប៉ាល់មួយទៀត បើកចេញទៅតាមផ្លូវទន្លេធំ ដល់ពាមមង្គល ខែត្រត្បូងឃ្មុំ ។ សម្ដេចព្រះកែវហ្វាទ្រង់ជ្រាប ស្ដេចចុះមកថ្វាយបង្គំក្នុងព្រះទីនាំងកប៉ាល់ ។ ព្រះទៀមនឹងព្រះអនុជទ្រង់ធ្វើបដិសណ្ឋារកិច្ចទៅវិញទៅមក ។ កាលស្ដេចទាំងពីរព្រះអង្គទ្រង់សំណេះសំណាល សួរសុខទុក្ខទៅវិញទៅមករួចហើយ សម្ដេចព្រះកែវហ្វាថ្វាយបង្គំលាឡើងទៅគង់ក្នុងដំណាក់ដដែលវិញ ឯព្រះបាទសម្ដេចព្រះនរោត្ដម ស្ដេចយាងមកភ្នំពេញ ។ ចំណែកអាលាក់ដឹងថា 'សម្ដេចព្រះកែវហ្វាស្ដេចលើកទ័ពមកច្បាំងនៅពាមមង្គល' ក៏នាំស្ម័គ្របក្សពួកដោះចេញពីភូមិសុរិល ខែត្រត្បូងឃ្មុំទៅខែត្រក្រចេះ ឆ្លងទៅខែត្រកំពង់ស្វាយ និយាយបញ្ញុះបញ្ចូលក្រមការនឹងរាស្ត្រ ។ ក្រមការនឹងរាស្ត្របញ្ឆោតអាលាក់ថាចុះចូល តែចុះចូលតែមាត់ លុះប្រមូលគ្នាបានច្រើនហើយ ក៏លើកដេញចោមព័ទ្ធចាប់បានខ្លួនអាលាក់នឹងសេនាអាលាក់ ៤នាក់ទៀត ក៏នាំមកថ្វាយ តែនាំមកដល់ពាក់កណ្ដាល អាលាក់ឈឺចិត្ត អត់អាហារអនិច្ចកម្មទៅ ។ ក្រមការនឹងបណ្ដារាស្ត្របានកាត់យកតែក្បាលនាំមកថ្វាយនៅក្រុងភ្នំពេញ ។ កងសេនានៃអាលាក់ ស្ដេចឱ្យប្រហារជីវិតតាមទោសក្បត់ ។ ឯក្បាលអាលាក់ ស្ដេចឱ្យសែងបណ្ដើរអាប្រកាសតាមផ្លូវផ្លាផ្សារ ៣ ថ្ងៃ ហើយយកទៅដោតចោលនៅជិតផ្លូវវាលបឹងតេជោ កុំឱ្យជនទាំងពួងយកជាបែបយ៉ាងតទៅ ។ រួចទ្រង់ព្រះរាជទានប្រាក់ សំពត់អាវ ជារង្វាន់ក្រមការនឹងបណ្ដារាស្ត្រដែលចាប់អាលាក់បាន តាមគុណបំណាច់ ។

(ឯកសារមហាបុរសខ្មែរ, ទំព័រ ១១២៤ - ១១៣០)

អាចារ្យលាក់

Introductory Note

រជ្ជកាល /raccəkaal/ reign

ព្រះបាទនរោត្ដម Norodom, King of Cambodia, 1860-1904

គ្មានឈប់ឈរ unceasingly

កំចាត់ to expel, chase out

អាណានិគមនិយម colonialism

Text

អដ្ឋស័ក /qattəsaq/ 8th year (of the 10-year cycle)

ជនក្បត់ /cuən-kbat/ traitor

អាលាក់ (= អាចារ្យលាក់)

អ្នកសីល wise man, sage

លើកខ្លួនជាកូន claim to be the son of

ល្វង (= ហ្លួង) royal or conferred title

ពោធិកំបោរ /poo-kαmbao/ name of a rebel leader
កួយ Kuy (name of a tribal group in Cambodia)
ស្ទៀង Stieng (name of a tribal group in Cambodia)
ខ្មែរព្រៃលើ Highland Cambodians

រោងដំរី place name (lit: elephant pavilion)
ខេត្តត្បូងឃ្មុំ name of a former province
ឧកញ៉ាអរជូន (title)

ស៊ូ personal name

កេណ្ឌ...បញ្ចូល to mobilize additional forces
ពាមមង្គល place name

ខេត្តកំពង់សៀម name of a former province
ខេត្តបាភ្នំ name of a former province
ខេត្តសំដួល name of a former province
ខេត្តស្វាយទាប name of a former province
សឹងចុះចូលច្រើន subjugated in considerable numbers
បោះ to encamp

ខ្មោច deceased, the late...

ខ្ចាត់ខ្ចាយ scattered, in disarray

ឧកញ៉ាពិភក្តីទិព្វរាជ /qokñaa-pipheə̆q-kədəy-tɨppəriəc/ (title)
រស់ personal name

ឈរ to be stationed (at, in)

ឧកញ៉ាក្រឡាហោម Minister of the Navy and Water Transport
ប៉ាន personal name

ឧកញ៉ាធម្មាតេជោ /-thoə̆mmiədaecoo/ (title)
ហែន personal name

ឧកញ៉ាចក្រី Minister of the Army and Land Transport
ពេជ្រ personal name

ឧកញ៉ាជ័យយោធាសង្គ្រាម (title)

ទុំ personal name

រាំង to bar, block, obstruct

រាំងបោះទ័ព establish a defense line
ព្រៃញាយ name of a village

ខេត្តពារាំង name of a former province
ឧកញ៉ាបវរនាយក (title) /qokñaa-bαwɔɔniəyuə̆q/
ម៉ៅ personal name

សេក personal name

កំពង់ខ្សាច់ស place name

ឧកញ៉ាវិបុលរាជ title

ប៉ែន personal name

ព្រះស្រែនជ័យ title

លឹង personal name

អាត់មួរ៉ាល់ /qatmuəral/ (Fr. Admiral)
អំប្រេយ៉ាឌីបូរ៉ាសាញ៉ូទេរ name of a French officer
អ្នកអក position (for older women in the palace)
អ្នកអកមង្គលនារី /-muə̆ŋkuə̆l-niərii/ (title)
អ្នកអកវររាជវង្សា /-wɔreə̆q-riəc-wuə̆ŋsaa/ (title)
អ្នកអកអង្គអគ្គកញ្ញា /-qαŋ-qakeə̆q-kaññaa/ (title)
អ្នកអកស្រង្គារនុរក្ស /-srəŋkiənureə̆q/ (title)
អ្នកយាយ position (lower in rank than /neə̆q-qααq/, but higher than /cah/ and /tum/)
អ្នកយាយទេពយុរយ៉ា /-teepəyuurəyiə/ (title)
អ្នកយាយចិត្តាភិសេក /-cəttaaphisaek/ (title)
អ្នកយាយកោមលធិរាជ /-kaomuə̆l-thiriəc/ (title)
អ្នកយាយឯកអគ្គវង្សា /-qaek-qakeə̆q-wuə̆ŋsaa/ (title)
ព្រះអង្គម្ចាស់ title for children of the king
ឧបល /qobαl/ name of a concubine

ប្រសូត to give birth (Roy)

ព្រះរាជបុត្រ /preə̆h-riəccəbot/ prince

ពារ name of a prince

ព្រះនាងចមសុជាតិបុប្ផ name of a concubine

ឌួន name of a concubine

សម្ភព to give birth (concubine)

គន្ធា name of a prince

ព្រះនាងចមព្រះញាតិ title of a concubine

ញិក name of a concubine

សុតាវតី /sottaawədəy/ name of a prince

ខែមិគសិរ /mɨkkəsei/ November-December (lunar system)

ឧកញ៉ាវង្សាអគ្គរាជ (title)

អ៊ុម personal name

ឧកញ៉ាពិស្ណុលោក /-pihsnulook/ (title)

ព្រំ personal name

កំពែង (Wat) Kompeng

វាលសម្លាប់នាយ place name

ស្ពានយមរាជ /-yumməriəc/ name of a bridge

ឧកញ៉ារាជាមេត្រី (title)

មុំ /mom/ personal name

ឧកញ៉ាស្រីនគរបាល (title)

មាន់ personal name

ខែបុស្ស /-boh/ December-January (lunar system)

ប្រាក់ personal name

ឧកញ៉ាវាំងវរវៀងជ័យ (title)

ឧកញ៉ាឥស្សរាពាណិជ (title)

សៅរិ៍ personal name

ឧកញ៉ាមហាឥស្សរា---ព្រះក្រឡាហោម full title of Minister of the Navy

ឧកញ៉ាប្រសើរសុរិវង្ស (title)

ម៉ៅ personal name

ឧកញ៉ាប្រសើរសុរិវង្ស---ទិចក្រី full title of Minister of the Army

ប៉ូចេរ name of a French officer

ត្រពាំងឈូក place name (lit: Lotus Pond)

ខែត្រសំរោងទង name of a former province

ឧកញ៉ាតេជោ /qoknaa-daecoo/ (title)

អី personal name

ជាប់តែសេនាទាហាន ៣០ នាក់គត់ having only thirty soldiers with him

សង្ឃរាជបារាំង French Archbishop

មាត់ក្រសាស់ name of a village

អារីក្សត្រ a village across the Mekong from Phnom Penh

ព្រែកលួង place name

ខែត្រខ្សាច់កណ្ដាល name of a former province

ខែត្រស្វាឯម name of a former province

ព្រមមូលអស្លី finally decided

ដោយ along with

ព្រះទេវតសង្ខាត name of a ship

ឧកញ៉ាអាទិច្ចតាមរ័នសេនា (title)

ខែត្រទទឹងថ្ងៃ name of a former province

ព្រៃស្លា name of a village (lit: areca-palm forest)

ព្រែកខ្លៅ name of a village

ឧកញ៉ាឥស្សរៈអក្ខរា /-qehsəraq-qaqkhəraa/ (title)

ប្រសូត name of a village

ខែត្រស្វាយទាប name of a former province

ឆ្នាំថោះ year of the Hare

នព្វស័ក /nuppəsaq/ 9th year (of the 10-year cycle)

ស៊ីសុវត្ថិ Sisovath (King of Cambodia 1904-1927, younger brother

of Norodom)

ហរិរាជរតនីទីក្រៃកែវហ្វា /haqririəc-roə̆ttəniy-kray-kaewwaa/(title)

ដោះថយ to retreat

ខែត្រព្រៃវែង Prey Veng Province

ស្ដាប់ការ to scout, spy, reconnoitre

សុរិល /sorɨl/ name of a village

គ្រួរ (=គ្រួ) family

បើកឱ្យ to allow, permit

គយ to observe

ដាក់គយល្បាត to post a watch, set sentries

ព្រះអនុជ /preə̆h-qanoc/ younger brother (Roy)

ប្រួរញ to discuss

គួរសម to pay respects

ខែស្រាពណ៍ July-August (lunar system)

បដិសណ្ឋារកិច្ច /pədeqsɑnthaarəkəc/ greetings

សំណេះសំណាល to exchange fond memories, reminisce

ខែត្រក្រចេះ Kratie Province

ក្រុមការ /krommakaa/ title (very low-ranking official)

តែមាត់ in word only (but not in deed)

ឈឺចិត្ត hurt and disappointed, heartbroken, humiliated

អត់អាហារ to fast, refuse food; without food

ប្រហារជីវិត to kill (Lit)

តាមទោសក្បត់ depending on the extent to which they were guilty of treason

បណ្ដើរ to walk, parade (tv)

អាក្រាស to revile, repudiate aloud

ផ្លូវធ្លា main street

ឱ្យសែងបណ្ដើរអាក្រាសតាមផ្លូវធ្លាផ្សារ ៣ ថ្ងៃ had it carried through the main street of the market and reviled for three days

ដោតចោល leave stuck on a pole

វាលបឹងតេជោ place name

យកជាបែបយ៉ាង take as an example

៨. គុកនយោបាយ

ដោយ

ប៊ុណ្ណចន្ទ - ម៉ុល

បុព្វកថា

លោកប៊ុណ្ណចន្ទ - ម៉ុល ជាខ្មែរអ្នកស្នេហាជាតិម្នាក់ ដែលខំតស៊ូនឹងអាណានិគមនិយមបារាំង នៅសម័យសង្គ្រាមពិភពលោកលើកទី ២ ។ លោកបានរួបរួមនឹងខ្មែរអ្នកជាតិនិយមជាច្រើនរូបទៀត មានអាចារ្យចៀវ លោកប៉ាច - ឈឿន ជាដើម ធ្វើការតស៊ូនេះ ។ លោកបានចូលរួមក្នុងបាតុកម្មប្រឆាំងបារាំងជាលើកដំបូងនៅទីក្រុងភ្នំពេញ ។ ក្រោយមក លោកក៏ត្រូវបារាំងចាប់យកទៅនារទេសនៅកោះត្រឡាច ។ ក្រោយជីពុនមានជោគជ័យមួយភ្លែតនៅឥណ្ឌូចិន លោកក៏បានកងទ័ពជីពុននាំចូលមកស្រុកខ្មែរវិញ ។ វិរបុរសខ្មែរខ្លះ ឥតមានសំណាងដូចលោកប៊ុណ្ណចន្ទ - ម៉ុល ទេ ដូចជាអាចារ្យចៀវជាដើម ត្រូវស្លាប់ចោលឆ្អឹងនៅលើកោះត្រឡាច គួរឱ្យសង្វេគពន់ពេកណាស់ ។

ចំពូកទី ១ នៃគុកនយោបាយ និយាយអំពីការចាប់ផ្ដើមតស៊ូប្រឆាំងនឹងបារាំង នៃលោកប៊ុណ្ណចន្ទ - ម៉ុលនិងក្រុមរបស់គាត់ ។

អត្ថបទ

ការតស៊ូចាប់ផ្ដើមដំបូងតាមផ្លូវសារពត៌មាន

ជំនាន់នោះ ប្រជារាស្ត្រយើងមានសេចក្ដីលំបាកវេទនាកាន់តែខ្លាំងឡើង ៗ ដោយបារាំងធ្វើបាប ហើយជាឱកាសល្អហុចឱ្យផង ដ្បិតពេលនោះបារាំងវាកំពុងតែជាប់ដៃធ្វើសឹកសង្គ្រាមជាមួយអាល្លឺម៉ង់ផង ហើយតមកវាច្បាំងនឹងសៀមទៀត ពុំអាចដឹកនាំគ្រឿងអាវុធយុទ្ធភ័ណ្ឌមកបង្ក្រាបយើងបានឡើយ ។ នៅស្រុកយើង វាប្រើតែអាវុធចាស់តាំងពី ១៩១៤ មក ហួសសម័យទៅហើយ ។ ហេតុនេះហើយបានជាវាច្បាំងចាញ់សៀម ។ ដឹកទ័ព កេណ្ឌទេះឬរថយន្តឈ្នួលអ្នកស្រុក ដើម្បីបំភាន់ខ្មែរថាបារាំងខ្លាំងពូកែ ដឹកតែទ័ព កាំភ្លើងចុះឡើងបន្លាចខ្មែរ កុំឱ្យហ៊ានតនឹងបារាំង ។

គ្រានោះ ទើបមានវីរជន អ្នកស្នេហាជាតិមុតមាំមួយចំនួន ឥតខ្លាចគុកច្រវាក់ ឥតខ្លាចចោលស្រុក ឥតខ្លាចស្លាប់ មុនដំបូង បានលបលាក់ដឹកនាំបបួលគ្នាឱ្យធ្វើការ តស៊ូប្រឆាំងនឹងបារាំងយកឥស្សរភាពពីវាមកវិញ ក្នុងពេលដែលបារាំងកំពុងមានអំណាចនៅឡើយ គឺថាចង្កូមឬធ្មុងវានៅពេញមាត់ ស្រួចវែងនៅឡើយ វាចង់ធ្វើអ្វីយើងក៏បានតាមចិត្តវា ឥតអ្វីទប់បានឡើយ ។ ក្នុងបណ្ដាវីរជនទាំងនោះ មានលោកស៊ឺង - ង៉ុកថាញ់ជាមេដឹកនាំ

បាននាំគ្នាតស៊ូធ្វើបដិវត្តន៍ឡើង ។ ការតស៊ូនេះ ចាប់ផ្ដើមដំបូងក្នុងឆ្នាំ ១៩៣៦ តាមផ្លូវសារព័ត៌មានមួយ ឈ្មោះសារព័ត៌មាន 'នគរវត្ត' ។ អ្នកផ្ដួចផ្ដើមគំនិតក្នុងការបង្កើតសារព័ត៌មាននេះ ឱ្យមានឡើងក្នុងកាលណោះ គឺលោកស៊ឹង-ង៉ុកថាញ់ ។ លោកតែងមានប្រសាសន៍ប្រាប់អ្នកដែលធ្វើការក្នុងព្រះរាជបណ្ណាល័យជាមួយគ្នា អំពីគោលបំណងចង់បង្កើតនូវសារព័ត៌មាននេះ ដើម្បីធ្វើជាមធ្យោបាយ ផ្សាយគំនិតអប់រំប្រជាពលរដ្ឋឱ្យភ្ញាក់រលឹកឡើង ។ ឯលោកស៊ឹម-វ៉ា ដែលជាមិត្តជិតស្និទ្ធនឹងលោកដែរ ហើយដែលជាអ្នកនយោបាយដូចគ្នានោះ ក៏តែងទៅមករកលោកប្រាស្រ័យទាក់ទង ពិគ្រោះគ្នាតែពីការបង្កើតនូវកាសែតនគរវត្តនោះឯង ។ ពិសេសទៅទៀត លោកប៉ាច-ឈឿន ដែលជាមិត្តដែរនោះ ក៏បានព្រមស្ម័គ្រឈរឈ្មោះ ជាចាងហ្វាងសារព័ត៌មាននោះដែរ ។

លុះព្រមព្រៀងគ្នាដូច្នេះហើយ ទើបសម្រេចសុំច្បាប់បើកកាសែតតាមផ្លូវការឡើង ។ សូមជ្រាបថា ការសុំច្បាប់បើកកាសែតកាលណោះ ជាការលំបាកណាស់ ។ ពុំមែនសុំភ្លាមបានបើកភ្លាមទេ ពីព្រោះក្រសួងមានសមត្ថកិច្ច ពុំមែនស្ថិតនៅតែក្នុងប្រទេសខ្មែរប៉ុណ្ណោះទេ គឺនៅរហូតដល់ទៅក្រុងព្រៃនគរនឹងហាណូយឯណោះ ។ មុនដំបូង ពាក្យសុំរបស់យើងត្រូវជូនទៅលោករេស៊ីដង់ស៊ុយពែរីយើ នៅភ្នំពេញ លោករេស៊ីដង់ស៊ុយពែរីយើពិនិត្យពាក្យសុំនោះ រួចត្រូវបញ្ជូនទៅលោក Gouverneur Général de l'Indochine នៅឯក្រុងហាណូយឯណោះ ។ លោកនោះពិនិត្យហើយ ទើបបញ្ជូនត្រឡប់មកភ្នំពេញ សម្រេចឱ្យបើកឬមិនអនុញ្ញាតឱ្យបើក ។ ឯពាក្យសុំបើកកាសែតនេះ ត្រូវក្រសួងសមត្ថកិច្ចអាណានិគមបញ្ជូនទៅមក ហើយអនុញ្ញាតឱ្យបើកនៅក្នុង គ.ស. ១៩៣៦ នោះ ។

សារព័ត៌មាននេះ មានគោលបំណងសរសេរពន្យល់ ណែនាំ ដាស់បងប្អូនខ្មែរយើងដែលដេកលក់ ដែលរងកម្មវេទនា ដែលល្ហាក់ស្បាត ធ្លាប់ខ្លាចបារាំងចាប់ដាក់គុកឬសម្លាប់ ឱ្យភ្ញាក់ស្មារតីឡើង ឱ្យចេះស្នេហាជាតិ ឱ្យចេះតស៊ូកុំខ្លាចស្លាប់ ដើម្បីដណ្ដើមយកឥស្សរភាពពីបារាំងមកវិញ ដែលវាប្លន់យកពីយើងទៅជិត ១០០ ឆ្នាំហើយនោះ ។

ពេលនោះស្រុកខ្មែរក្រកាសែតណាស់ ។ កាសែតមួយឈ្មោះស្រុកខ្មែរ ឈ្មោះសានយ៉េណេរ៉ុង ធ្វើតែមិនសូវបានប្រយោជន៍ទេ ព្រោះខ្លាចមិនហ៊ាននិយាយ ។

ក្នុងការសរសេរកាសែតនគរវត្តមុនដំបូង លោកស៊ឹង-ង៉ុកថាញ់ បាននិយាយឱ្យលោកអ៊ុក-សេន ដែលធ្វើការនៅធម្មការដែរថា : ឱ្យជួយសរសេរកាសែតនេះផង ព្រោះព្រឹក ៗ ទំនេរ ។ កាលណោះព្រះរាជបណ្ណាល័យចូលធ្វើការពីម៉ោង ១១ ជិតថ្ងៃត្រង់ ទៅទល់នឹងម៉ោង ១៧ កន្លះល្ងាច ។ លោកអ៊ុក-សេនក៏ទទួលដោយគោរព ។ រាល់ព្រឹក លោកអ៊ុក-សេនតែងទៅផ្ទះលោកស៊ឹង-ង៉ុកថាញ់ នៅខាងលិចវត្តលង្កា ដើម្បីធ្វើអត្ថបទផ្សេង ៗ មាន

បកប្រែនូវដំណឹងនានាប្រទេស ចេញពីកាសែតបារាំងសែស មកជាភាសាខ្មែរជាដើម ។ ជួនកាលទៅផ្ទះលោកស៊ឹម-វ៉ា សរសេរតាមពាក្យលោកស៊ឹម-វ៉ាដែលថាឲ្យសរសេរ ។ ការព្យាយាមរបៀបនេះមានជារាល់ពេល ។ លុះពេលយប់ម៉ោង ១៩ ទទួលទានបាយរួច លោកអ៊ុក-សេនប្រមូលអត្ថបទដែលមានមកហើយនោះ ទៅជួបជុំគ្នានឹងផ្ទះលោកស៊ឹម-វ៉ា (នៅផ្សារស៊ីទឿប ផ្លូវអាចារ្យហែម-ចៀវ អតីតត្រសក់ផ្អែម) សព្វថ្ងៃនេះ ។ ពេលប្រជុំនោះ គឺមានលោកស៊ឹង-ង៉ុកថាញ់ លោកស៊ឹម-វ៉ា លោកពិទូរ្យក្រសេម លោកញ៉ុក-ថែម លោកជុំ-មួង ។ល។ អស់លោកទាំងនេះសុទ្ធតែមានអត្ថបទរៀង ៗ ខ្លួន ហើយលោកអៀង-សាយជាអ្នកគូររូបចុះកាសែត ព្រមទាំងធ្វើអត្ថបទកំប្លែងមានខ្លឹមសារ ។

ក្នុងការប្រជុំនោះ លោកអ៊ុក-សេនជាអ្នកសូត្រអត្ថបទទាំងនោះឲ្យអង្គប្រជុំស្ដាប់ ។ បើមានទើសទាក់ឬគ្នាំគ្នងនូវពាក្យពេចន៍ឬអង្គសេចក្ដីមិនសមរម្យ ដោយប្រការដូចម្ដេច អង្គប្រជុំត្រូវកែសម្រួលឬលុបចោល ឬបំពេញសេចក្ដីនោះថែមទៀតឲ្យគ្រប់គ្រាន់ ។ លោកស៊ឹង-ង៉ុកថាញ់ធ្វើការដោយមធ្យ័តណាស់ ពិនិត្យពិច័យនូវសេចក្ដីក្នុងអត្ថបទនីមួយ ៗ មិនឲ្យគ្នាំគ្នង ថ្លោះធ្លោយឡើយ ។ ប្រជុំកែរួចហើយ ឲ្យលោកអ៊ុក-សេនយកទៅចម្លងសាជាថ្មីឡើងវិញ ឲ្យបានត្រឹមត្រូវនឹងឲ្យច្បាស់លាស់ ឲ្យដើម្បីងាយដល់ការតម្រៀបអក្សរដាក់ពុម្ព ។ កាលណោះបោះនៅរោងពុម្ពអាល្លីយ៉ែស ។ ចំពោះអត្ថបទដែលត្រូវយកទៅឲ្យរោងពុម្ពនោះ គឺលោកស៊ឹង-ង៉ុកថាញ់នឹងលោកអ៊ុក-សេនជាអ្នកយកទៅ ។ លោកស៊ឹង-ង៉ុកថាញ់ឬក៏លោកអ៊ុក-សេនទៅកែអក្សរខុសត្រូវនៅនឹងរោងពុម្ព ។ លោកស៊ឹង-ង៉ុកថាញ់ធ្វើការប្រិតប្រៀនណាស់ សំណៅនោះលុះត្រាតែពិនិត្យជាគម្រប់បីលើក ទើបលោកចុះហត្ថលេខាឲ្យបោះ ។

លុះកិច្ចការក្នុងកាសែតកាន់តែច្រើនឡើង ក៏បានហៅលោកនួនប៊ុត (សព្វថ្ងៃម្ចាស់បណ្ណាគារប៊ុត-នាង) ឲ្យជួយធ្វើការលោកអ៊ុក-សេន គឺជួយចម្លងអត្ថបទ ប្រមូលអត្ថបទ ជួយកែអក្សរខុសត្រូវ ព្រមទាំងជួយដឹកនាំកាសែតពីរោងពុម្ព ទៅកាន់ទីសំណាក់ការបណ្ដោះអាសន្ន ដែលកាលណោះនៅនឹងផ្ទះលោកស៊ឹម-វ៉ា ។

សូមប្រជាបថា លោកចាងហ្វាងប៉ាច-ឈឺន នៅពេលដំបូងនេះ លោកពុំទាន់បានមកកាន់ការក្នុងកាសែតឲ្យបានមាំមួនទេ លោកនៅជាប់រវល់ការងាររបស់លោកឯហាងគ្រឹះស្ថានហ្សង់កុងឯណោះ លោកជាជើងសារជំនួញហាងឡានហ្សង់កុង ។ ម្ល៉ោះហើយកិច្ចការកាសែតទាំងមូលត្រូវនៅលើលោកស៊ឹង-ង៉ុកថាញ់ និងលោកស៊ឹម-វ៉ាចាត់ចែងទាំងស្រុង ។

លុះក្រោយមក ទើបជួលផ្ទះមួយបានធ្វើជាទីស្នាក់ការ នៅរុក្ខវិថីវែរដង់ (ឥឡូវនេះជាផ្លូវ ១៨ មីនា) ។ មកដល់ត្រង់ណេះ ទើបលោកប៉ាច-ឈឺនចេញជួយកាសែតពេញទំហឹង សុខចិត្តលះបង់ប្រាក់ខែមុខងារចេញពីហាងហ្សង់កុងទាំងអស់ ។

លោកស៊ឹង-ង៉ុកថាញ់ លោកស៊ឹម-វ៉ា និងលោកចាងហ្វាងប៉ាច-ឈឺន ក៏នាំគ្នារៀបចំទីស្នាក់ការឱ្យបានសមរម្យ គឺមានតុកៅអីតូចធំជាការិយាល័យ និងមានបុគ្គលិកច្រើននាក់ទៀតនៅធ្វើការ ។ មានអ្នកធំអ្នកតូចឡើងចុះកុះករ នៅទីស្នាក់ការនោះរាល់ថ្ងៃ ។ សូមប្រាប់ថា អ្នកធ្វើការប្រចាំការរាល់ថ្ងៃជាមួយលោកប៉ាច-ឈឺន គឺលោកម៉ៅ-ហុងដែលមាននាទីជាអ្នកកាន់លុយកាក់ (ហេរញ្ញិក) លោកអ៊ឹម-សុខជាលេខាធិការផ្ទាល់លោកចាងហ្វាង ។ ឯលោកនួន-ប៊ុតក៏មានការិយាល័យខាងអត្ថបទដែរ ។ តទៅ មានលេខហារីនិងកម្មករអ្នករត់កាសែត ចំនួនពីរបីនាក់ទៀត ។

តែយើងនៅខ្វះខាតបន្តិចទៀត ដោយទីស្នាក់ការនោះពុំមានភ្លើងអគ្គិសនីធ្វើការយប់ៗ ។ ដូច្នេះយប់ៗ ក៏តាំងយកអត្ថបទទៅប្រជុំគ្នានៅនឹងផ្ទះលោកស៊ុន-វ៉ាន់ ។ គ្រានោះ អង្គការកាសែតត្រូវបានទទួលសមាជិកពីរនាក់ទៀត គឺលោកស៊ុន-វ៉ាន់និងលោកប៊ូ-ហ៊ង ។ លុះជំនុំធ្វើការយប់ៗ នៅផ្ទះលោកស៊ុន-វ៉ាន់មិនបានប៉ុន្មាន លោកស៊ុន-វ៉ាន់ក៏លក់ផ្ទះនោះឱ្យគេ ខានជំនុំនឹងផ្ទះនោះទៅ ទើបនាំគ្នាទៅជំនុំនឹងផ្ទះលោកស៊ឹង-ង៉ុកថាញ់... ហើយតមកទៀតជំនុំនៅផ្ទះលោកប៉ាច-ឈឺន នៅខាងជើងវិទ្យាល័យស៊ីសុវត្ថិ (ឥឡូវនេះវិទ្យាល័យភ្នំពេញ) ។

សូមប្រាប់ថា កាសែតនគរវត្តចាប់ចេញដំបូងតែពីរដងទេក្នុងមួយអាទិត្យ កាសែតនេះលក់ ១ សន្លឹក ៨ សេន ។ លុះចេញយូរបន្តិចទៅ កាន់តែលក់ដាច់ឡើង ក៏បញ្ចុះមកនៅត្រឹម ៥ សេនវិញ ។

ទាំងបីនាក់ គឺលោកស៊ឹង-ង៉ុកថាញ់ លោកចាងហ្វាងប៉ាច-ឈឺន និងលោកស៊ឹម-វ៉ា ក៏ផ្តើមគំនិតបង្កើតជាសមាគម មានលក្ខន្តិកៈត្រឹមត្រូវ ដើម្បីរកធនធានជាដើមទុនបង្កើតរោងពុម្ពខ្លួនឯង ត្រូវទិញម៉ាស៊ីនធំតូចសម្រាប់បោះពុម្ពកាសែតនិងសៀវភៅ ឬដំណឹងផ្សេងៗ ខ្លួនឯងនិងជួលបោះឱ្យគេ ព្រមទាំងបង្កើតឱ្យមានជាគ្រឿងលក់ដូរដោយខ្លួនឯងផង ។

គិតត្រូវគ្នាហើយ ក៏រើទីស្នាក់ការទៅតាំងនៅកន្លែងថ្មីមួយទៀត នៅប្រជុំផ្លូវស៊ីសុវត្ថិនិងមាយវ៉ាន (ជិតមាត់ទន្លេ) ដែលជាកន្លែងធំទូលាយស្អាតបាត មានភ្លើងអគ្គិសនីអាចឱ្យធ្វើការយប់ៗបានផង មានផ្លិតបក់ឱ្យល្ហើយៗ ស្រួលធ្វើការទៀត ។ ផ្ទះនោះឈ្មោះសេឡិចហោតិល នៅពីខាងមុខផ្ទះនោះ មានរង្គសាលមួយឈ្មោះឡារ៉ែសួកមាត់ទន្លេចតុមុខ ។ តាំងពីបានទីស្នាក់ការថ្មីនេះមក ការជំនុំធ្វើការយប់ៗ តែងធ្វើការនៅទីនេះ លែងដើរទៅឯណេះម្តងឯណោះម្តងទៀតហើយ ។ ហើយគ្រោងការណ៍ដែលគិតនោះ ក៏បានរៀបចំឡើងនៅទីនោះដែរ ។

តាំងពីពេលនោះមក លោកអ៊ុក-សេនលែងបានជួយធ្វើការទៀតហើយ ដោយរវល់នឹងកិច្ចការច្រើនពេក ។ លោកនួន-ប៊ុតក៏កាន់ការនោះតមកទៀត ។

អ្នកនិពន្ធកាសែតនោះ ក្រៅពីលោកទាំងប៉ុន្មាននាក់ដែលមានរាប់ឈ្មោះមកហើយ ក្រោយ

នោះមានលោកមហាសម៉នម្នាក់មកជួយទៀត ។ មុនដំបូងមានអស់លោកជាច្រើនប្រហែល ២០ នាក់ ជាអ្នកជួយសរសេរដែរ ប៉ុន្តែចេះតែរបេះអស់ ដោយអស់លោកទាំងនោះមិនសូវស៊ូ ដ្បិតធ្វើការទទេឥតឈ្នួល នៅសល់តែប៉ុន្មាននាក់ដែលមាននាមខាងលើប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ត្រូវពួករាជនិយមកៀបគ្រាមកំហែងខ្លាំងណាស់ ដែលធ្វើឲ្យអ្នកនិពន្ធខ្លះរួញខ្លួន ខ្លាចគ្រោះថ្នាក់ដល់ជីវិត លែងសូវហ៊ានគិតបញ្ចេញគំនិតអ្វី ៗ ទាំងអស់ ។

មានរឿងមួយដែលត្រូវចងចាំ : កាលណោះ ពេលដែលព្រះបរមរាជវាំងធ្វើពិធីចម្រើនព្រះជន្ម ព្រះករុណាព្រះមុនីវង្សមានឥស្សរជនបារាំងខ្មែរត្រៀបត្រា ។ កាលណោះ ជនអ្នកនៅក្នុងវាំងនឹងខ្ញុំបាទទាំង សឹងតែបានដឹងថា អ្នកដឹកនាំការសែតនគរវត្តនេះគឺលោកស៊ឹង - ង៉ុកថាញ់ ឯលោកស៊ឹង - ង៉ុកថាញ់ ពេលនោះក៏បានចូលរួមក្នុងពិធីនោះដែរ ។ ពេលនោះ ប្រហែលជាមាននរណាចូលទៅខ្សឹបទូលហើយក៏មិនដឹង ស្រាប់តែព្រះករុណាព្រះមុនីវង្ស (ដែលមិនស្គាល់មុខលោកស៊ឹង - ង៉ុកថាញ់ ឮតែឈ្មោះនិងសកម្មភាពដែលគេទូលនោះ) ស្រែកដោយក្តីក្រេវក្រោធសួរថា : អាណាមួយឈ្មោះង៉ុកថាញ់? លោកស៊ឹង - ង៉ុកថាញ់ប្រណម្យដាក់មុខ ។ ហ្លួងស្រែកគម្រាមថា : អាឯងបង្កើតការសែតចង់ប្រឆាំងនឹងបារាំងឬ ? ឯងចង់ប្រឆាំងនឹងអញជាម្ចាស់ផែនដីឬ ? នែប្រយ័ត្នណា ប្រយ័ត្នស្លាប់ ! ។

(ប៊ុណ្ណចន្ទ - ម៉ុល, គុកនយោបាយ, ទំព័រ ៨ - ១៩)

គុកនយោបាយ

Introductory Note

សង្គ្រាមពិភពលោកលើកទី ២ World War II

អ្នកជាតិនិយម nationalist

ចៀវ name of a famous bonze-politician

ប៉ាច - ឈឿន name of a Cambodian politician

បាតុកម្ម demonstration

និរទេស /niərəteeh/ to exile

កោះត្រឡាច name of an island in the South China Sea, which was used by the French to keep hard-core criminal and political prisoners

ជីពុន /cipun, cəpun/ Japanese

ឥណ្ឌូចិន /qəndoucən/ Indochina

វីរបុរស /wireə̆qborah/ hero

ស្លាប់ចោលឆ្អឹង to die in exile (lit: to die and have one's bones discarded)

សង្វេគ sad, mournful

Text

សារពត៌មាន newspaper; the press

តាមផ្លូវសារពត៌មាន by means of the press

ឱកាសល្អហុចឲ្យ a good opportunity was presented

អាល្លឺម៉ង់ (= អាល្លឺម៉ង់ដ៍) German; the Germans

យុទ្ធភ័ណ្ឌ /yutthəphŏən/ paraphernalia of war

អាវុធយុទ្ធភ័ណ្ឌ weapons and paraphernalia of war

ហួសសម័យ outdated, obsolete

កេណ្ឌ to conscript, draft; here: commandeer, requisition

បំភាន់ to deceive, trick, fool

បន្លាច to scare, frighten

តនឹង to challenge

វីរជន (= វីរបុរស) hero

មុតមាំ strongly, intensely, staunchly

ច្រវាក់ chain

ចោលស្រុក to be exiled (lit: to abandon the country)

លបលាក់ to do something in secret, surreptitiously

គ្នីគ្នា acquaintances, partisans

ធ្មុង pectoral fin

ទលែម intensifier for /sruəc/

ចង្កូមឬធ្មុងនៅពេញមាត់ស្រួចទលែម fully armed, dangerous (lit: have a mouthful of sharp teeth [as well as] sharp fins)

ស៊ឹង-ង៉ុកថាញ់ /səɨŋ-ŋok-than/ Son Ngoc Thanh, a Cambodian politician

មេដឹកនាំ leader, chief

បដិវត្តន៍ /paqdewŏət/ revolution; revolutionary

នគរវត្ត name of a revolutionary newspaper in 1936

ផ្ដួចផ្ដើមគំនិត to initiate, instigate

ណោះ (= នោះ)

មធ្យោបាយ /mattyoobaay/ way, means

ភ្ញាក់រលឹក to wake up, become aware

ស៊ឹម-វ៉ា Sim Var, a Cambodian politician, former prime minister

ជិតស្និត close, intimate

ប្រាស្រ័យ (= ប្រស្រ័យ) to like, to respect; to talk, to reminisce

ស្ម័គ្រ /smaq/ to volunteer

ឈរឈ្មោះ to be named as; to run (for elective office)

សូមជ្រាបថា bear in mind that (lit: please understand that)

ក្រសួងមានសមត្ថកិច្ច department in charge, authorities concerned

ហាណូយ Hanoi

ពាក្យសុំ application

រេស៊ីដង់ស៊ុយប៉េរីយើ (Fr. Résident Supérieur)

រងកម្មវេទនា /rɔɔŋ kam-weetəniə/ to suffer, undergo suffering

ញាក់ស្បាត terror-stricken

ភ្ញាក់ស្មារតី to awaken, become aware

ស្រុកខ្មែរ name of a newspaper

ឈ្មោះ [someone] named

សានយ៉េណេរ៉ុង (personal name)

ធ្វើ to manage, to handle

និយាយទៀ to request (of)

អ៊ុក-សេន (personal name)

ធម្មការ (Ministry of) Religion

ទៅទល់នឹង up until

វត្តលង្កា /wŏət laŋkaa/ Vat Langka

បក to translate

នានាប្រទេស foreign, abroad, various countries

ផ្សារស៊ីឡឹប name of a section of Phnom Penh (lit: Hoaxing Market)

អាចារ្យហែម-ចៀវ (personal name)

អតីត /qadɨt/ formerly, in the past

ត្រសក់ផ្អែម name of a street (lit: Sweet Cucumber)

ពិទូរ្យ title (lit: Lapis lazuli)

ក្រសែម (pers. n.)

ញ៉ុក-ថែម Nhok Them (pers. n.)

ជុំ-មួង (pers. n.)

អៀង-សាយ (pers. n.)

ចុះកាសែត to put or publish in the newspaper

ខ្លឹមសារ meaning, depth, substance

សូត្រ to recite; here: to read

អង្គប្រជុំ quorum; meeting, assembly

ទើសទាក់ unpolished, inappropriate

ពាក្យពេចន៍ words, wording

អង្គសេចក្ដី topic, theme

សមរម្យ /sɑm-rum/ appropriate

ដោយប្រការដូចម្ដេច in any respect, in any way

កែសម្រួល to smooth, to correct

លុបចោល to take out, cut out (lit: erase)

មធ្យ័ត /mattyat/ rigorous, careful, painstaking

ពិនិត្យពិច័យ to audit, to check

ថ្លោះធ្លោយ to slip up, make a mistake

សាជាថ្មី anew, again

តម្រៀប to set, compose (movable type)

ពុម្ព /pum/ a press

តម្រៀបអក្សរដាក់ពុម្ព compose type for the press

បោះ to print, to publish

រោងពុម្ព printing establishment, press

អាស្លីយ៉ែស name of a printing establishment

ប្រិតប្រៀន rigorous, careful

សំណៅ printer's proofs

ជាគ្រប់បីលើក (all of) three times

ហត្ថលេខា /hatthəleikhaa/ signature

ចុះហត្ថលេខា to sign

នួន-ប៊ុត Nuon-Bouth (pers. n.)

ប៊ុត-នាង Bouth-Neang (name of a bookstore in Phnom Penh)

ទីសំណាក់ការ headquarters

កាន់ការ to take charge

ជាប់រវល់ busy

គ្រឹះស្ថាន firm, company, place of business

គ្រឹះស្ថានហ្សង់កុង name of an automobile dealership in Phnom Penh

ដើងសារជំនួញ dealer, agent (usually of a foreign company)

ទីស្នាក់ការ (=ទីសំណាក់ការ)

វែរដង់ name of an avenue in Phnom Penh (Fr. Verdun; now March 18 Avenue)

មុខងារ duty, position

ប្រចាំការ full time (lit: to be on hand to watch over business)

ម៉ៅ-ហុង (pers. n.)

នាទី duty, function

ហេរញ្ញិក (=ហិរញ្ញិក) /heiraññək/ treasurer

អ៊ិម-សុខ (pers. n.)

លេខហារី clerk, messenger

អ្នករត់កាសែត paper boy

ក៏តាំង to proceed to (do something)

ស៊ុន-វ៉ាន់ (pers. n.)

ប៊ូ-ហ៊ិង (pers. n.)

មិនបានប៉ុន្មាន not very long, for a short time

សន្លឹក issue, copy

សេន cent

លក់ដាច់ to sell (successfully),

to move (of merchandise)
បញ្ចុះ to reduce, lower

លក្ខន្តិកៈ /lĕəqkhantəkaq/ official charter, body of rules

ធនធាន /thŭən-thiən/ resources, funds
ដើមទុន capital (for investment)

គិតត្រូវគ្នាហើយ having agreed among themselves
ដើរ to move

មាឃវ៉ាន់ /maqkəwan/ name of a street in Phnom Penh
មាត់ទន្លេ bank of the river, waterfront
ផ្លិត a fan

ល្ហើយ to feel cool and pleasant (only by movement of air)
សេទ្រិចហោតិល name of a building

រង្គសាល theater

ឡារ៉េសួក name of a theater (Fr. La Resource)
គ្រោងការណ៍ plan (n)

មហា title of a learned monk, usually retained after leaving the priesthood
សម៉ន (pers. n.)

របេះ to fall away, fall off, leave
ឈ្នួល wages

រាជនិយម royalist; monarchism

ពួករាជនិយម royalists

កៀប to squeeze, to pressure

គម្រាម to threaten

កំហែង to threaten

រួញខ្លួន to back down, withdraw (lit: to shrink back, draw oneself up)
លែងសូវហ៊ាន no longer dared, rather unwilling
ចងចាំ to remember

ព្រះជន្ម /prĕəh-cŭən/ age (Roy)

ពិធីចម្រើនព្រះជន្ម birthday ceremony (Roy)
មុនីវង្ស Monivong (King of Cambodia 1927-40)
ត្រៀបត្រា in great crowds, spread around in great numbers
ខ្ញុំរាំង French collaborators (lit: French slaves)
ក្តី (=សេចក្តី)

ប្រណម្យ (=សំពះ) to greet with hands together (to royalty)

ដាក់មុខ to look down, to lower one's gaze respectfully
ហ្អែង you (derogatory)

IV. MISCELLANEOUS SHORT POEMS AND SONGS

៨. កាព្យសាស្ត្រខ្មែរ

(ដោយអ្នកនិពន្ធ)

កំណាព្យមានកន្លែងដ៏ធំទូលាយនៅក្នុងអក្សរសាស្ត្រខ្មែរ ។ បើនិយាយមែនទែនទៅ ស្ទើរតែមួយរយភាគរយនៃអក្សរសាស្ត្រតន្តីជាកំណាព្យ ។ ទោះនៅសម័យអង្គរក៏ដោយ ក៏គេនិយមកំណាព្យណាស់ដែរ ប៉ុន្តែនៅពេលនោះ ដោយហេតុស្រុកខ្មែរនិយមភាសាសំស្ក្រិតថាជាភាសាដ៏ថ្លៃថ្នូរ អ្នកនិពន្ធសិលាចារិកប្រើភាសាសំស្ក្រិតវិញក្នុងការសរសេរកំណាព្យ ។ ទាល់តែមកដល់សតវត្សទីដប់ប្រាំពីរ ទើបគេប្រើភាសាខ្មែរខ្លះជាកំណាព្យក្នុងការសាងសិលាចារិក ។

ដូច្នេះ ដើម្បីនឹងក្រេបជញ្ជាក់នូវសោភ័ណនៃអក្សរសាស្ត្រខ្មែរ គេត្រូវការជាបឋមការដឹងយល់អំពីកាព្យសាស្ត្រខ្មែរ ។ ម្យ៉ាងទៀត ការដឹងយល់អំពីកាព្យសាស្ត្រ ជាការចាំបាច់បំផុត ពីព្រោះសំឡេងហើយនឹងចុងចួនជាប្រដាប់ដ៏សំខាន់បំផុតរបស់កវី ដើម្បីនឹងសំដែងការរំជួលចិត្តយ៉ាងលាយទំរូគ្នានៅក្នុងកំណាព្យនិមួយ ៗ ។

ពាក្យប្រើក្នុងការពិពណ៌នាអំពីកាព្យសាស្ត្រ :

១. បទ

២. វគ្គ

៣. ឃ្លា

៤. ព្យាង្គ

៥. ចួន
- ចុងចួន
  - ខាងក្រៅឃ្លា
  - ខាងក្នុងឃ្លា
- ចួនអក្សរដើមព្យាង្គ
  - ខាងក្រៅឃ្លា
  - ខាងក្នុងឃ្លា
- ពាក្យដដែល
  - ខាងក្រៅឃ្លា
  - ខាងក្នុងឃ្លា

៦. ចង្វាក់

៧. ពាក្យតក់

បទបុរាណ

នៅមុនសម័យក្រុងឧដុង្គមានជ័យ គេប្រើតែបទប្រាំទេគឺ :

១. បទកាកគតិ

២. បទពំនោល

៣. បទភុជង្គលីលា

៤. បទបន្ទោលកាក

៥. បទព្រហ្មគីតិ

បទសម័យ

គេចាប់ប្រើនៅក្នុងរជ្ជកាលព្រះបាទអង្គដួងនឹងព្រះបាទនរោត្តម ។ បទដែលគេនិយមប្រើជាងគេនោះគឺ :

៦. បទជាប់ទង (ពាក្យ ៤)

៧. បទពាក្យ ៦ (បទកន្ទុំរុយ) (បទកន្ទែកបលោតលើគោក)

៨. បទពាក្យ ៧ (សាមញ្ញ)

៩. បទនរោ

១០. បទកខ

១១. បទគោពន្លឺស្ទឹង

១២. បទនាគកេងទំរុកទំរាត

១៣. បទអក្សរសង្វារ

១៤. បទកន្ទែកបលោតកណ្តាលស្រះ

១៥. បទអក្សរល្បួន

១៦. បទស្ទ្រុកទិនវិលាស

១៧. បទត្រឡាចឡើងត្រើង

១៨. បទមូរខ្វាក់កែវ

១៩. បទសោរទិនវិលាស

២០. បទថយក្រោយ

២១. បទជាប់ទង (ពាក្យ ៧)

២២. បទពាក្យ ៨ (សាមញ្ញ)

២៣. បទផ្កាឈូកទឹក

២៤. បទឆ័ត្របីជាន់

២៥. បទនាគបរិព័ន្ធ

២៦. បទត្រីពិធព័ន្ធ

២៧. បទនាគរាជប្លែងឫទ្ធិ

២៨. បទក្របច្រកវាទ្យ

២៩. បទរមាំងដើរទិព្រ

៣០. បទយតិភង្គ

៣១. បទសប្បាត់សបឹង

៣២. បទពាក្យ ៩ (សាមញ្ញ)

៣៣. បទរលកខ្ទប់ច្រាំង

៣៤. បទកង្កែបលោតស្លាក់ពេជ្រ

៣៥. បទសទ្យាបល្លូន

៣៦. បទព្រះចន្ទ្របាំងឆ័ត្រ

៣៧. បទសារថីទាញរថ

៣៨. បទសិង្ហតោលេងកន្ទុយ

៣៩. បទពាក្យ ១០ (សាមញ្ញ)

៤០. បទត្រឡាចឡើងទ្រើង (ពាក្យ ១០)

៤១. បទពាក្យ ១១

សញ្ញាផ្សេង ៗ

០ ០ ០ ០ ០ ០ ០ ០	:	ព្យាង្គ
________________	:	ចុងចួន
----------------	:	ចួនអក្សរដើមព្យាង្គ
-.-.-.-.-.-.-.-	:	ពាក្យដដែល

សេចក្ដីបញ្ជាក់

កំណាព្យដែលយើងយកមកដាក់ធ្វើជាឧទាហរណ៍ យើងឥតមានបកប្រែពាក្យថ្មីឬពន្យល់ពាក្យពេចន៍ណាដែលមានន័យស្មុគស្មាញនោះទេ ។ បំណងធំរបស់យើងក្នុងការប្រើកំណាព្យខ្លី ៗ ជាឧទាហរណ៍នោះ គឺគ្រាន់តែសម្រាប់បង្ហាញនូវការទាក់ទងរវាងពាក្យពេចន៍ទាំងឡាយ នៅក្នុងបទនិមួយ ៗ ហើយនឹងរបៀបចាប់ចុងចួន ដែលនឹងជួបប្រទះនៅក្នុងសេចក្ដីដកស្រង់ផ្សេង ៗ នៅក្នុងសៀវភៅនេះ ចាប់ពីអត្ថបទនេះទៅ ។

១. បទកាកគតិ

បទកាកគតិនេះ ដូនកាលគេហៅថាបទពាក្យ ៤ ។ វគ្គនិមួយ ៗ នៃបទនេះមាន ៧ ឃ្លា ហើយឃ្លានិមួយ ៗ មាន ៤ ព្យាង្គ ។ ព្យាង្គទី ៤ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ ព្យាង្គទី ៤ នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៥ នឹង ៦ ។ ព្យាង្គទី ៤ នៃឃ្លាទី ៤ ចួននឹងព្យាង្គទី ២ នៃឃ្លាទី ៥ ។ ព្យាង្គទី ៤ នៃឃ្លាទី ៧ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៣ នៃវគ្គបន្ទាប់ ។

កាកគតិមានន័យថា ដំណើរក្អែក ។ បទនេះមានដំណើរទទ្លើន ៗ ទំនងដូចជាក្អែកដើរឬលោត ។ គេប្រើបទកាកគតិសម្រាប់រៀបរាប់ពិពណ៌នាទូទៅ ឬធ្វើការសន្ទនាធម្មតា ។ បទនេះជាបទខ្មែរបុរាណ មានប្រើតាំងពីសម័យអង្គរមក ។

របៀបចាប់ចុងចួន



គំរូ

ឱះឱព្រះពាយ
រំភើយរំភាយ
ផាត់ក្លិនគន្ធា
រសរូក្លិនស្រី
កាកីស្ងួនភ្ងា
បងចាំជាក់ជា
ក្លិនប្អូនមិញទេ ។

(រឿងកាកី)

២. បទពំនោល

បទពំនោលនេះក៏ជាបទខ្មែរបុរាណដែរ ។ ក្នុងចំណោមបទខ្មែរបុរាណទាំងប្រាំ មានតែបទនេះមួយទេ ដែលមានឈ្មោះជាពាក្យខ្មែរសុទ្ធ ។ 'ពោល' មានន័យថា : និយាយ ស្តី ថ្លែង ឬសំដែង ។ ក្នុងបទពំនោល វគ្គនិមួយ ៗ មានបីឃ្លា : ឃ្លាទី ១ មាន ៦ ព្យាង្គ ទី ២ មាន ៤ ព្យាង្គ ឃ្លាទី ៣ មាន ៦ ព្យាង្គ ។ ព្យាង្គទី ៦ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ ។ ព្យាង្គទី ៤ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ២ នៃឃ្លាទី ៣ ។ ព្យាង្គទី ៦ នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៦ នៃឃ្លាទី ១ នឹងព្យាង្គទី ៤ នៃឃ្លាទី ២ នៃវគ្គបន្ទាប់ ។

គេប្រើបទនេះសម្រាប់រៀបរាប់អ្វី ៗ ដែលមានចលនាខ្លាំង ដូចជាចម្បាំងរាំងជល់

ការឈ្លោះទាស់ទែងជេរប្រទេចគ្នា ខ្យល់ព្យុះបក់ច្រោក ឬកំហឹងកំហល់ជាដើម ។ គេច្រើនប្រើបទនេះដែរ សម្រាប់បង្ហាញឫទ្ធានុភាពនៃតួអង្គក្នុងរឿងណាមួយ ។

របៀបចាប់ចុងចួន គំរូ



ស័ព្ទស្រែកស្មើរបែកប្រឹថពី
ផុយផង់ធូលី
ធរណីសឹងទ្រោមទ្រុឌទោង ។

(រឿងពុទ្ធិសែន)

៣. បទភុជង្គលីលា

'ភុជង្គ' មានន័យថា : 'នាគ' ហើយនឹង 'លីលា' មានន័យថា : 'ដើរ' ភុជង្គលីលាបានសេចក្តីថា នាគដើរឬនាគលូន ។ ក្នុងបទភុជង្គលីលា វគ្គនិមួយ ៗ មានបី ឃ្លា ។ ឃ្លាទី ១ មាន ៦ ព្យាង្គ ឃ្លាទី ២ និងឃ្លាទី ៣ មាន ៤ ព្យាង្គ ។

បទភុជង្គលីលាមានសម្លេងទន់ភ្លន់ ផ្អែមល្ហែម ល្ងតល្ងូត មានទំនងដូចជានាគឬពស់លូន ។ គេប្រើបទនេះសម្រាប់រៀបរាប់ការសប្បាយរីករាយ រៀបរាប់ព្រៃព្រឹក្សា ឬធម្មជាតិផ្សេង ៗ ។

របៀបចាប់ចុងចួន គំរូ



បទទ្រង់ភុជង្គលីលា
ដំណើរពណ៌នា
គ្រុឌនឹងកាកី ។
សេពសមបន្ទុំលើទី
លុះព្រះសូរ្យសី
ឃ្លាត់បង់ជ្រុងភ្នំ ។

(កាកី)

៤. បទបន្ទោលកាក

គេតែងសន្មតថា 'បន្ទោលកាក' ក្លាយមកពីពាក្យ 'មណ្ឌុកគតិ' ដែលមានន័យថា : 'ដំណើរកង្កែប' ។ ការសន្មតនេះសមណាស់ ព្រោះសំនៀងនៃបទនេះមានដំណើរយារវែង ៗ កញ្ឆក់ ៗ ទំនងដូចជាកង្កែបលោតមែន ។ វគ្គនិមួយ ៗ នៃបទបន្ទោលកាកមាន ៤ ឃ្លា ។ ឃ្លាទី ១ មាន ៤ ព្យាង្គ ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៤ ព្យាង្គ ហើយនិងឃ្លាទី ៤ មាន ៦ ព្យាង្គ ។ ព្យាង្គទី ៤ នៃឃ្លាទី ៣ អាចនឹងចួននឹងព្យាង្គទី ២ ទី ៣ ឬទី ៤ នៃឃ្លាទី ៤ ។

គេប្រើបទនេះក្នុងការឆ្លើយឆ្លងគ្នា ការនិយាយក្រមិចក្រមើមដាក់គ្នា ។

របៀបចាប់ចុងចួន



គំរូ

ថ្លែងដោយទំនង
ដំណើរស្រីផងយាត្រា
ពេបនឹងដុចណា
ស្រីស្រែកថាហើយចៀសចេញ ។
ដុចថាអះអើ
បុណ្យអ្នកនេះតើម្ដេចមិញ
ក៏មកប្រើអញ
ចៀសចេញឱ្យអ្នកដាស្លែង ។

(ដុចនឹងស្រីជួបគ្នា)

៥. បទព្រហ្មគីតិ

'ព្រហ្មគីតិ' មានន័យថា 'ចម្រៀងព្រះព្រហ្ម' ។ បទនេះមានសំនៀងលន្លង់លន្លោចណាស់ ។ វគ្គនិមួយ ៗ មាន ៤ ឃ្លា ។ ឃ្លាទី ១ មាន៥ ព្យាង្គ ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៥ ព្យាង្គ ហើយនិងឃ្លាទី ៤ មាន ៦ ព្យាង្គ ។

គេប្រើបទនេះសម្រាប់ថ្លែងសេចក្ដីទុក្ខសោក ដំណើររអាក់រអួលក្នុងចិត្ត ការដំអូញ ឬពាក្យបណ្ដែបណ្ដាំ ។

របៀបចាប់ចុងចួន គំរូ



ស្ដេចគន់ស្ដេចគិតធ្ងល់
បទពុំយល់វេរជាយា
ផណ្ដឹងស្នំស្នេហា
នាងទៅណាច្បាស់ពុំយល់ ។
អស់ស្រីសឹងស្លាំងកាំង
ភ័យភិតភាំងរករចល់
រត់រកនាងនិម៌ល
សព្វមន្ទីមណ្ឌលា ។

(កាកី)

៦. បទជាប់ទង (ពាក្យ ៤)

របៀបចាប់ចុងចួន គំរូ



របរជាតិខ្មែរ
ខ្មែរយើងគួរតែ
តែជួយទិញគ្នា
គ្នាលក់មិនទិញ
ទិញឯចិនជា
ជាជាតិខុសគ្នា
គ្នាយើងធ្លាក់ក្រ ។
ក្រសេដ្ឋកិច្ច

៧. បទពាក្យ ៦

ឬ

បទកង្កែបលោតលើគោក

របៀបចាប់ចុងចួន | គំរូ



រឹងរែកទេគិតរឹតកាញ់
មនោអាក់ម្នាក់អញម្នេញអួល
ពោះខ្វាញ់ពេញខ្វោះពោះខ្វល់
ហៀវអួលហួលឯងហែងអង្គ ។

៨. បទពាក្យ ៧ (សាមញ្ញ)

បទពាក្យ ៧ នេះមានរបៀបចាប់ចុងចួន ៤ យ៉ាងដែលគេអាចប្រើលាយឡំគ្នា ក្នុងការតែងកំណាព្យ ។

របៀបចាប់ចុងចួន | គំរូ

ក.



ដើរដោយខ្វាលវែងស្រែតងដុះស្រោ
ទន់ទាបសុរិយាយាត្រាកាត់
មៀងមើលមេឃមីពពកសាត់
ដូចកលបងខ្វាត់ពីទាវមក ។

(ទុំទាវ)

ខ.



កាលនោះគោព្រាលជាស្វាមី
នាងស្រីត្រឡប់ពីព្រឹកស្រា
ឃ្វាលគោមកជិតដល់គ្រឹហា
ភរិយាឃើញហើយក៏ផ្ដោះផ្ដង ។

(រឿងភរិយាគោព្រាលនឹងសហាយពីរនាក់)

គ. 

មើលភ្នំធំធេងវែងរលីក
មើលទឹករលករលាមសាយ
មើលដីដុះវែងអន្លាយ
មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី ។

(សេកសារីកា)

ឃ. 

គួរលះបង់កាមឱ្យស្រឡះ
ថាបើមានះទប់ពុំជិត
គួរសេពភរិយាអាត្មាពិត
ផ្តេកផ្តិតតែមួយប៉ុណ្ណោះបាន ។

៥. បទនមោ

របៀបចាប់ចុងចួន



ន　ន៉ែនាងនោះកូនអ្នកណា
មោ　មើលមុខថ្លាសល្អះ
ពុ　ពង្រវង្រាមិនស្គាល់ច្បះ
ទ្ធា　ធនធានក្រាសក្រែលគ្រាន់បើ ។
យ　យល់យប់នេះនេះចង់ដឹង
សិ　សួរដំណឹងតាមដំណើរ
ទ្ធំ　ធាត់កត់ឈ្មោះពិគ្រោះស្មើរ
អ　អស់អ្នកដើរដេកនៅជិត ។
អា　អ៊ីញស្រឡាញ់នាងនេះណាស់
ឥ　ឥតមានផ្លាស់ប្រែគំនិត
ឦ　អីភ្លេចអស់មិនមានគិត
ឧ　អុកឡុកវិតវិលវល់ចិត្ត ។

។ល។

១០. បទកខ

របៀបចាប់ចុងចួន



គំរូ

ក កើតជាមនុស្សក្នុងលោកិយ
ខ ខំឃ្មាតខ្មីរករៀនធ្វើ
គ គិតឲ្យគ្រប់សព្វអន្លើ
ឃ ឃើញអំពើពេញជាមនុស្ស ។
ង ងាកឆ្វេងស្តាំមើលគេឯង
ច ចេះចាត់ចែងបែងឲ្យធ្លុះ
ឆ ឆើតកើតការយ៉ាងណានោះ
ជ ជាតិជាមនុស្សឲ្យដូចគេ ។
ឈ ឈានជើងដើរគិតជញ្ជឹង
ញ ញើតរឹលរឹងបើទំនេរ
ដ ដើរទៅណាឥតការទេ
ឋ ឋិតឋានថេរទៀបចំផ្ទះ ។
។ល។

១១. បទគោព័ទ្ធស្ទឹង

របៀបចាប់ចុងចួន



គំរូ

ស្រីល្បែងតែងតួចង់គួរគាប់

គាប់ចិត្តទំលាប់រាប់រកប្រាក់

ប្រាក់កាសក្រដាស់ឬលុយកាក់

កាក់ក្រក៏ធ្លាក់ហាក់មានក្រែល ។
ក្រែលគ្រាន់បើដែរបើប្រុសឆោត
ឆោតមិនពិសោធមើលក្រវិល
ក្រវិលវាជាល្អដូចដែល
ដែលដូចល្អក្រែលក្រាសដោយមេត្រា ។

១២. បទនាគកៀវក្រវាត់

របៀបចាប់ចុងចួន



គំរូ

ស្រីញីចិត្តពីរនាំបែកបាក់
បាក់បែកចិត្តស្ម័គ្រមិនស្មោះស្មាន
ស្មានស្មោះអស់ពីពោះប្រុងប្រាណ
ប្រាណប្រុងរាប់អានមិនលែងលះ ។

១៣. បទអក្សរសង្វាស

របៀបចាប់ចុងចួន



គំរូ

បងប៉ងយូរហើយនឹកថាការ
បានប្រាណកាលណានឹងបីស្រី
ច្រៀងផ្ទៀងបំពេបទថ្មីខ្លី
ផ្ទមបមបោសបីស្រីល្អ ។
ពៅទៅមិនមានប្រាប់បងផង
ចិត្តគិតស្នេហ៍ស្នងគូស្រករ
ប្តីសីមានទៀតឆ្លៀតត្រដរ
គេចភ្លេចបងក្រអូនឃ្លានមាន ។

១៤. បទកង្កែបលោតកណ្តាលស្រះ

របៀបចាប់ចុងចួន　　　　　　　　គំរូ



បងដើរបើដឹងខឹងនឹងបង
គិតម្តេចគេចម្តងបងភ្លេចគិត
មិត្តរកមករង់គង់ជួបមិត្ត
ដើរពេកដេកពិតគិតលែងដើរ ។

(អៀងសាយ 'មេកាព្យ')

ឃ្លាទាំងអស់មានចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



១៥. បទអក្សរល្បួន

របៀបចាប់ចុងចួន　　　　　　　　គំរូ



ទៀងទៀមរឹងរែងរិះទៀងរាល់
ទោទន់ទុក្ខទ័លទៀតទៀងទាត់
សុបសៅស៊ើបសួរសង្សាសត្វ
កែវកាត់កាមកួចកែកេរ្តិកាយ ។

ឃ្លាទាំងអស់មានចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



១៦. បទស្រុកទិនវិលាស

របៀបចាប់ចុងចួន　　　　　　　　គំរូ



ដែនកែវវៃរលក្ខណ៍ភក្ត្រនិម៌ល
កែវបងយាងផ្គុំស្កុបស្កល់ប្រាណ
ស្ងួនភ្ងាបើកទ្វារនិទ្រ្យបងបាន
ឃើញមុខកល្យាណបងនឹងលា ។

កែវ បងមិនគួរធ្វើដូច្នោះ
បងនឹកអាល័យស្រណោះណា
សូមធ្វើជាប្ដីស្រីពុំងា
ឃើញជារងាគ្រាម្ដងហ្នឹង ។

១៧. បទត្រឡាចឡើងទ្រើង

របៀបចាប់ចុងចួន



។

គំរូ

ចួបប្អូនខ្លួនអ្នកជាក់ចែនបង្អួប
នៅឃួបបួបយិតនិត្យ ឃើញនៅ
ពៅស្និទ្ធពិតស្នាលពាលស្នេហ៍ពៅ
គិតចង់ណ្គុងយ៉ៅ នៅ តែគិត ។
ចិត្តណែនសែនខ្ទួលក្តួលក្នុងចិត្ត
មិត្តខូចដូចខ្មោចរោចដូចមិត្ត
ក្ដៅចិត្តជ្រួតចា កលា កចិត្តក្ដៅ
ផ្ដល់ទុក្ខមុខផ្ដួលខ្លួលស្រទន់ផ្ដល់ ។

ឃ្លាទាំងអស់មានចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



។

១៨. បទមុក្រខ្លាក់កែវ

របៀបចាប់ចុងចួន



។

គំរូ

ស្ងៀមនៅឬនឹកមិននៅ ស្ងៀម
រីតរឹងមុខរៀមរាគរឹងរីត
គិតម្ដងចង់កាត់នឹកម្ដងគិត
បានម្ដេចចូលជិតធ្វើម្ដេចបាន ។

ឃ្លាទាំងអស់មានចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



១៩. បទសោរទិនវិលាស

របៀបចាប់ចុងចួន



គំរូ

គូអើយគូព្រេង ៣ វាសនា
បងមិនល្បួងលោមទេកល្យាណី
បញ្ឆោតភូតភរគូស្នេហា
ឱ្យខូចអសារបានទុក្ខា ៗ
បងស្បថជូនអ្នកមិនគួរណា
លន់តួតាមទោសឱ្យកនិដ្ឋា
ឆ្លងល្អងជាស្តេចគ្រងសីមា
ម្តេចគ្មានពនិតានឹងរួមរ័ក្ស ៗ

២០. បទថយក្រោយ

របៀបចាប់ចុងចួន



គំរូ

បងបានអូនមកដល់ធូរចិត្ត
ស៊ូទ្រាំផ្តេកផ្តិតគិតគ្រងគូ
គូគ្រងគិតផ្តិតផ្តេកទ្រាំស៊ូ
ចិត្តធូរដល់មកអូនបានបង ៗ
ស្មោះស្ម័គ្រចិត្តពិតគិតប៉ងជាប់
សងសូមរៀបរាប់តាមស្នេហ៍ស្នង
ស្នងស្នេហ៍តាមរាប់រៀបសូមសង
ជាប់ប៉ងគិតពិតចិត្តស្ម័គ្រស្មោះ ៗ

ដោយបទថយក្រោយមានរបៀបចួនខាងក្នុងឃ្លាយ៉ាងស្មុគស្មាញពេក ពាក្យាង្គនិមួយ ៣ ត្រូវយកលេខមកជំនួសវិញ ៗ ពាក្យាង្គណាដែលមានលេខដូចគ្នាបានន័យថាប្រើពាក្យដូចគ្នាឬពាក្យដដែល ៗ

១	២	៣	៤	៥	៦	៧	
៨	៩	១០	១១	១២	១៣	១៤	
១៤	១៣	១២	១១	១០	៩	៨	
៧	៦	៥	៤	៣	២	១	ៗ

២១. បទជាប់ទង (ពាក្យ ៧)

របៀបចាប់ចុងចួន គំរូ



ការងារទាំងអស់ពិបាកធ្វើ
ធ្វើបែបភ្លីភ្លើមិនកើតការ
ការដាំកុលាបមានបន្លា
ៗ បន្លានោះណាតែងតែមាន ៗ
មានស្រីមានក្ដីស្នេហាព្រម
ព្រមទាំងធាត់ស្គមតែងស្រេកឃ្លាន
ឃ្លានស្រេកតណ្ហាកុំថាគ្មាន
គ្មានស្រីណាហ៊ានកាត់តណ្ហា ៗ

២២. បទពាក្យ ៨ (សាមញ្ញ)

របៀបចាប់ចុងចួន គំរូ

ក.



ទៀមកាត់វាលកាត់ទីព្រៃតមកពឹង
លើព្រលឹងស្រស់ស្ងួននិមនួនល្អង
ធ្វើកន្ដើយពុំមានអាសូរបង
គួរកុំហ្មងបំណាច់បងស្នេហា ៗ
(ទិព្វសង្ហារ)

ខ.



យើងថាខាងយើងត្រូវខាងគេខុស
គេក៏ថាឯចុះដូចយើងដែរ
អ្នកមានប្រាជ្ញាពិតគិតបន្តែ
មិនហ៊ាននៅត្អូញត្អែរតែដដែល ។

គ.



។

យក្សស្រឡាញ់មិនត្រូវអង្គក្សត្រី
ដោយសិល្បជ័យទំរង់សង្ហារថ្កាន
ព្រះឥសូរប្រសិទ្ធិឱ្យកល្យាណ
ធ្វើម្តេចមិនត្រូវប្រាណកែវកល្យាណី ។
(ទិព្វសង្វារ)

ឃ.



។

ព្រះនាងផកទ័នរួចដោះទំរង់
កើតជាចក្រចោលរឹងឯនភី
ត្រូវស្លុរងចិត្តនុរាជអាប់រឹទ្ធិ
ក្ស័យជីវីដាច់ក្បាលធ្លាក់ដល់ដី ។
(ទិព្វសង្វារ)

២៣. បទផ្កាឈូករីក

របៀបចាប់ចុងចួន



។

គំរូ

ចៅល្អនលាដីរលើបរលីងយង់
ចៅល្អវង្សហនុពង្សដូចកុងលាយ
ចៅល្អនិសប៉ប្រឹមញញឹមព្រាយ
ចៅល្អដាយចុងសោតយានត្រយង់ ។
ចៅល្អកាយានស្រួលរៀបរកប្រៀបប្រក
ចៅល្អសដូចសុវណ្ណហង្ស

ចៅល្អកណ្ណដូចកលផ្កាបុស្បុង្គ
ចៅល្អវង្សវិលាសរាបរបៀបចែវ ។

២៤. បទឥ័ត្របីជាន់

របៀបចាប់ចុងចួន　　　　គំរូ



កម្មអើយនិ៍ហេតុម្ដេចនិ៍អើយកម្ម
សៅហ្មងមុខទុក្ខសាំមុខហ្មងសៅ
នៅឯងឯកវិវេកអង្គឯកឯងនៅ
តឹងទឹងទ្រូងទោលក្ដៅទ្រូងទឹងតឹង ។

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



២៥. បទនាគបរិព័ន្ធ

របៀបចាប់ចុងចួន　　　　គំរូ



មេឃមិនទូទឹមទាបស្រទំទន់
ស្រទំទៅគយគន់ពពកដាស់
ពពកដុំដូចភ្នំខៀវខាប់ក្រាស
ខៀវខាប់ទីក្រែកថ្ងៃប្រាសប្រែលិចបាត់ ។
ប្រែបលេចបែបប្រកហមអមលាយលឿង
អមលាយលយព្រឿងៗ មេឃស្រងាត់
មេឃស្រងូតឆ្ងួតវែងតែងរសាត់
តែងរសាយខ្លាយបាត់គួរស្រណោះ ។

២៦. បទត្រីពិធព័ន្ធ

របៀបចាប់ចុងចួន គំរូ



ក្រមុំសុទ្ធល្អសុទ្ធស្អាតសុទ្ធសោត
មិនគួរឆោតទៅឆោតពេញឆោតពេក
ឃើញតែប្រុសស្គាល់ប្រុសនាំប្រុសត្រេក
ទៅប្រះដេកដើរដេកហ៊ានដេកលេង ។
ដល់ប៉ោងពោះធំពោះឃើញពោះដើម
នឹកកាលដើមឃើញដើមពីដើមក្មេង
ប្រុសក្បត់ចិត្តបែកចិត្តប្រែចិត្តផ្សេង
ព្រួយព្រោះលេងដើរលេងហ៊ានលេងហួស ។

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



២៧. បទនាគរាជប្លែងឫទ្ធិ

របៀបចាប់ចុងចួន គំរូ



ពុំបានចាំបណ្ដាំពាក្យម៉ែឪ
ពីមុនឱ្យត្រឹមត្រូវប្រកាន់ក្រិត្យ
ប្រុងកាយក្រែកងគ្នានេតមករក្សិទ្ធ
មានទៀងស្នាមខុសក្រិត្យផតត្រូវការ ។

២៨. បទក្របច្រកវាទ្យ

របៀបចាប់ចុងចួន គំរូ



ចិត្តទៀមរ័ក្សស្ម័គ្រនួនស្ងួនត្រូវចិត្ត
នៅពិនិត្យគិតសង្វាសនេះណាស់ទៅ
ពៅពុំស្ម័គ្រសោះទេឬមាសពៅ
ៗ បងនេះនៅសង្កាណាមាសបង ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



(ជួនកាលមានតែចុងចួនទេ)

២៩. បទរមាំងដើរព្រៃ

របៀបចាប់ចុងចួន គំរូ



ស្តាយហើយនួនស្ងួនចិត្តឥតមួហ្មង
កម្មហើយបងនាំព្រាសនិរាសតន់
មនោហើយម្នេញពេញសង្វេគវិវេកលន់
ៗ ទុក្ខហើយធ្ងន់ធន់មិនបានវិវានស៊ុន ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣០. បទយតិភង្គ

របៀបចាប់ចុងចួន គំរូ



សង្សារហើយបងបង្លាប់ផ្គាប់ចិត្តឆោម
ឆ្លៅមិនឱ្យឱ្យទោមនស្ស -
ង្កៀសចិត្តចៅចៅនៅកើតភិម -
ៗ ង្គលប្រកបកបអង្គាគួរឡេ.... (ហា) ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣១. បទលញាត់សបឹង

របៀបចាប់ចុងចួន — គំរូ



ដឹងថាគេអន់អាក់មិនស្មាក់មិនស្មោះ
មកប្រឹងរ៉ែបរ៉ែតស្រណោះអាលោះអាល័យ
ចាប់ស្រឡាញ់ពេញកន្លងស្រេងងស្រឹង
នឿយស្រមៃហាក់ទីថ្លៃដល់រកល់រកាញ ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣២. បទពាក្យ ៨ (សាមញ្ញ)

របៀបចាប់ចុងចួន — គំរូ



ឱសម្លាញ់ អញរឭក ដេកមិនលក់
សែនជាទុក្ខ មុខជាទៀប ហៀបមរណា
ទ្រាំរឭក នឹករលង់ ហូរនេត្រា
សូមទេវា ជួយជីវិត គិតប្រណី
ធ្វើម្ដេចគេ លួចបានប្រាណ ថ្លៃវរមិត្រ
មាសមកផ្ដិត មិត្តមកផ្ដួល មូលមេត្រី
ទោះគេកាប់ ស្លាប់បង់ទៅ សូវបានស្រី
ប្ដូរជីវិត ផ្ដាច់ជីវី មិនស្ដាយឡើយ ៗ

(ព្រះហរិរក្សរាមា ព្រះអង្គឌួង)

៣៣. បទរលកខ្ទប់ច្រាំង

របៀបចាប់ចុងចួន គំរូ



បងស្រឡាញ់ញាញ់ស្រឡះប៉ះលើស្ងួន
គិតយ៉ាងមួនគួនយ៉ាងមាំនាំចង់បាន
ជាគូគាប់ជាប់កៀកគងរងរួមស្ថាន
បងនឹកស្មានបាននាងស្ត្រីជាក់ជាគូ ។
ប្អូនប្រែកែកផ្អែកប្រកាន់ចិត្តដូចម្តេច
គួរកុំភ្លេចគេចកំភ្លាំងគាំងគិតយូរ
ប្រាប់មកចុះប្រុសមកចាំត្រាំទ្រាំស៊ូ
ធៀបគិតគូរធូរគិតគួរសួរសម្រេច ។

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់- ដូចមានខាងក្រោមនេះ :



៣៤. បទកែវបណ្តោតស្លាក់ពេជ្រ

របៀបចាប់ចុងចួន គំរូ



រាំល្អពិតរិតល្អពាលរាស្ត្រល្អពេញ
ចេះទន្ទេញចេញទន្ទេងលេងទន្ទាំ
រីករលាយរាយរលាក់រាក់រលាំ
រៀងរញាំរាំរបៀបរៀបរបាយ ។
ភ្លេងភិរម្យផ្លុំពីរោះភ្លោះពីរាក់
ដោយចង្វាក់ដាក់ចង្វាយដាយចង្វោយ
សូរបណ្ដាក់សាក់បណ្ដើរសើរបណ្ដោយ
បែបមិនខ្សោយព្រោយមិនខ្សត់បទមិនក្រៀយ ។

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣៥. បទសទ្បាបល្បួន

របៀបចាប់ចុងចួន　　　　គំរូ



ញ្ញាប់ញ័រញ្ញាក់អាក់អន់អួលក្ដួលក្ដៅក្ដាត់
ភ្លឹកភ្លាំងភ្លាត់ស្វាត់ស្វប់ស្វួតហួតហែកហែង
នៅនឹងណែនសែនសោកសល់ខ្វល់ខ្វាយខ្វែង
ព្រួញបឹងប្រែងខឹងខំខាត់កាត់កាមកួន ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣៦. បទព្រះចន្ទ្រាំងឆ័ត្រ

របៀបចាប់ចុងចួន　　　　គំរូ



ត្រៃលក្ខណ៍យោគយោគមិនដល់ត្រៃលក្ខណ៍
ទុក្ខំដោតដោតចាករោគទុក្ខំ
រោគរាំងរោលរោលរលាករោគរាគរាំង
ព្រួញផ្សាតាំងតាំងកាត់គាស់អស់ព្រួញផ្សា ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់_ ដូចមានខាងក្រោមនេះ :



៣៧. បទសារថីទាញរថ

របៀបចាប់ចុងចួន គំរូ



ចូលចិត្តស្តាប់ត្រាប់ចំរៀងច្រៀងចូលចិត្ត
ទេសនាជិតគិតមិនចង់ត្រង់ទេសនា
ទៅផ្សារធំសំរួលចិត្តគិតទៅផ្សារ
ៗ ទៅធ្វើការថានឹកជិនមិនទៅធ្វើ ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់_ ដូចមានខាងក្រោមនេះ :



៣៨. បទសិង្ហតោលេងកន្ទុយ

របៀបចាប់ចុងចួន គំរូ



នៅទីណាធ្វើការស្លូតកុំកោងកាច
តែកុំខ្លាចខ្ទិនក្រាបខ្លបខ្លួនខ្លៅខ្លាំង
ក្រែងគេស្អប់ធុញថប់ឬករករឿងរាំង
ៗ ដែងប្រណាំងមើលងាយដាសដើរដៀមដាម ៗ

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៣៩. បទពាក្យ ១០ (សាមញ្ញ)

របៀបចាប់ចុងចួន គំរូ



មាតាបិតាណាដែលចង់ឲ្យកូនល្អ
ត្រូវខំធ្វើតាមខឲ្យកូនវាធ្វើតាម
កុំផឹតគ្នា បៀប្រសា ក៏កុំលេងចុះស្លាម
កុំឈ្លាះគ្នា ដៀមដាមកើតទុក្ខនៅមុខវា ។

៤០. បទត្រឡាចឡើងទ្រើង (ពាក្យ ១០)

របៀបចាប់ចុងចួន គំរូ



គោលឿនលន់គន់លឿនលើសទើសអស់ទាំងគោ
រងនឹមទោរោទីនឹមទៀងរៀងរៀបរ៉ាប់រង
តងកញ្ញយគយកញ្ញឹកនឹកឃើញនឹមតង
ព្រោះទាក់ទងគ្រងទាក់ទាឃាមវាមានគ្រោះ ។

ឃ្លាទាំងអស់មានរបៀបចួនខាងក្នុងឃ្លាដូចគ្នាទាំងអស់ - ដូចមានខាងក្រោមនេះ :



៥១. បទពាក្យ ១១

របៀបចាប់ចុងចួន	គំរូ
	អូនអើយលាក់បាំងអីទៀងដែលបងមានទុក្ខធ្ងន់ ដូចទឹកជន់ជោរហូរលិចលង់បងផុតជើងដៃ គឺរូបអូនដែលល្អក្ររកប្រៀបធៀបដម្លៃ នាំស្រមៃឃើញស្រីថ្លៃនឹកស្រឡាញ់ពេញចិត្ត ។

កាព្យសាស្ត្រខ្មែរ

កាព្យសាស្ត្រ /kaapəsaah/ prosody, versification, composition of verse

កំណាព្យ poetry, verse

តន្តី /tɑntəy/ classical (usually refers to texts in Sanskrit)

ថ្លៃថ្នូរ highly valued, prestigious

ក្រេប to sip

ក្រេបជញ្ជាក់ to taste, get the flavor of; Fig: to enjoy, appreciate

ជាបឋម /ciə pathɑm/ first of all, principally, especially

ការដឹងយល់ understanding

ចុងចួន rhyme, rhyming

ការរំជួលចិត្ត emotion, sentiment

យ៉ាងលាយឡំគ្នា mixed, intertwined; complex, subtle

ពិពណ៌នា /pipɔərəniə/ description, elucidation

បទ /bɑt/ meter, form of verse, rhyme pattern, style

វគ្គ /weə̆q/ stanza, verse (of a longer poem)

ឃ្លា one phrase or line bounded by space

ព្យាង្គ /pyiəŋ/ syllable

ចួនអក្សរដើមព្យាង្គ alliteration

ពាក្យដដែល repetition of the same word, complete reduplication

(Note: In traditional Cambodian treatises on versification the word /coŋ-cuən/ is used to refer to any kind of rhyme or poetic relation between words. Cambodian rhyme in fact involves three different kinds of relation between words:
1) reduplication of the vowel and final (i.e. rhyme in the Western sense);
2) reduplication of the initial consonant or consonant cluster (i.e. alliteration); and
3) reduplication or repetition of the whole word.
All the three kinds of reduplication occur both externally (i.e. from one phrase to another) and internally (i.e. within one phrase). We have used the word /cuən/ to refer to all three kinds of reduplication, i.e. 'rhyme' in the Cambodian sense, while reserving the word /coŋ-cuən/ to refer to 'rhyme' in the Western sense, as shown in the chart at the beginning of the article.)

ចួន euphony, poetic relationship between words

ចង្វាក់ rhythm, gait

ពាក្យតក់ a normally unstressed syllable which is stressed to conform to the rhythm
ក្រុងឧដុង្គមានជ័យ /kroŋ qutdoŋ-miən-cɨy/ Oudong (capital of Cambodia 1620-1867)
បទកាកគតិ /bɑt kaaqkəteq/ Crow's Gait Meter
បទពំនោល Narrative Meter

ភុជង្គ /phuucuŏəŋ/ snake (Lit)

លីលា to go (Lit)

បទភុជង្គលីលា Snake-Crawl Meter

បទបន្ទោលកាក Frog's Gait Meter

បទព្រហ្មគីតិ /bɑt prumməkɨt/ Song of Brahma Meter
សម័យ modern, recent

វង runner, tendril (of a vine)

បទជាប់វង Intertwined Meter

សាមញ្ញ /saamañ/ common, ordinary (here: plain, basic)
នមោ (beginning of a sacred incantation which prefaces the recitation of the Pali syllabary)
បទនមោ Namo Meter (cf. example)

បទកខ /bɑt kɑɑ khɑɑ/ Alphabetic Progression Style (Meter)
ស្នឹង tether-stake

បទគោព័ទ្ធស្នឹង Style of a Cow [wrapping his rope] around the Tether-stake
ក្សៀន to straddle, wrap the legs around
ក្រវាត់ to girdle, to tie around

បទនាគក្សៀនក្រវាត់ Encircling Naga Meter
សង្វាស union, relation

បទអក្សរសង្វាស Related Letters Style
កង្កែប frog

បទកង្កែបលោតកណ្ដាលស្រះ Style of a Frog Jumping into the Middle of the Pond
បទអក្សរល្បូន Slithering Letters Style (cf. internal rhyme pattern)
សុក្រទិន /sokkrətɨn/ Friday; Venus(?)
វិលាស be coy, be coquettish, to flirt
បទសុក្រទិនវិលាស (translation unclear; perhaps it should be treated simply as the proper name of this particular meter)

ត្រឡាច winter melon

រទ្រឹង frame, lattice, trellis

បទត្រឡាចឡើងរទ្រឹង Style of Melons Climbing a Trellis
មករ /məkɑɑ/ mythical sea monster
ខ្ជាក់ to spit out, emit

បទមករខ្ជាក់កែវ Style of a Sea Monster Spewing Jewels
សៅរ៍ទិន /saorətɨn/ Saturday; Saturn(?)
បទសៅរ៍ទិនវិលាស (meaning unclear; pr. n. of this meter)
បទថយក្រោយ Reverse [Word Order] Style (cf. internal rhyme pattern)
បទផ្កាឈូករីក Blossoming Lotus Style

បទឆ័ត្របីជាន់ Three-Tiered Umbrella Style (cf. internal rhyme pattern)
បរិព័ទ្ធ /bɑripoət/ to encircle, to encompass
បទនាគបរិព័ទ្ធ Encircling Naga Style

ត្រីពិធ /trəy-pɨt/ triple, three-sided
ព័ន្ធ /poən/ related, intertwined, tied together
បទត្រីពិធព័ន្ធ Triply Interrelated Style
នាគរាជ /niəqkəriəc/ King of the Nagas, Naga King
ប្លែង to change, change form, undergo metamorphosis
បទនាគរាជប្លែងឫទ្ធិ Style of the Naga King Magically Transforming [Himself]
ក្រប casing, binding, splint, cover, support
ចក្រវាឡ /caqrəwaal/ the mountains surrounding the universe;

limitless space

បទក្របបក្រកទាំទៀ Space-Binding Style (deriving from the fact that each line begins and ends with the same word, like bookends)

បទរមាំងដើរព្រៃ Style of a Deer Walking in the Forest

យតិភង្គ /yattephuŏəŋ/ hyphen

បទយតិភង្គ Hyphenated Style (deriving from the fact that each line ends with the first part of a word which is completed at the beginning of the next line; cf. rhyme pattern)

បទសញ្ញាត់សបឹង (meaning unclear; pr. n. of this style)

បទរលកខ្ទប់ច្រាំង Style of Waves Beating against the Shore

ស្លាក់ to choke on something, have something caught in the throat

បទកង្កែបលោតស្លាក់ពេជ្រ Style of a Frog Choking on Jewels

សទ្រាប conversation (?)

បទសទ្រាបលួន Mellifluous Conversation Style (?)

បទព្រះចន្ទ្រទ្រាំងឆ័ត្រ Style of the Moon Holding an Umbrella

បទសារថីទាញរថ Style of the Driver Pulling the Cart

សឹង្ហ (=សីង្ហ) /səŋ/ lion (Lit)

តោ lion (Lit)

បទសឹង្ហតោលេងកន្ទុយ Style of a Lion Playing with his Tail

ស្មុគស្មាញ complex, confused

ចាប់ចុងចួន to make rhymes (in the Cambodian sense); establish poetic relations between words

រៀបរាប់ to enumerate, give a consecutive account

សន្ទនា /sɑntəniə/ to converse

ការសន្ទនា conversation

ចលនាខ្លាំង violent action

ទាំង to stop, confront, block

ចំបាំងទាំងផល់ war, battle, confrontation

ទាស់ទែង to have a dispute, have a disagreement, be at odds

កំហល់ anger

ឫទ្ធានុភាព /rɨtthiənuphiəp/ power, authority

តួអង្គ character (in a story, play, etc.)

ទន់ភ្លន់ soft, gentle, smooth

ផ្អែមល្ហែម dulcet, sweet, gentle

ល្វតល្វត delicate, soft, effeminate

រៀបរាប់ព្រៃព្រឹក្សា to enumerate [the flowers, plants, and trees encountered in] the forest (it is a common device in Cambodian verse to give a poetic enumeration of the various species of flora and fauna encountered in nature; this device is particularly well exemplified in the selection from /tum-tiəw/)

សំនៀង sound, acoustic impression

យារ to be drawn out, extended, delayed, drawled

កញ្ជាក់ short, jerky, staccato

ឆ្លើយឆ្លង to spar, banter, exchange words, carry on a dialogue

ក្រមិចក្រមើម /krɑməc-krɑməɨm/ clownish, comical

ឆាក់គ្នា back and forth, with one another

លន្លង់លន្លាច lugubrious, solemn

រអាក់រអួល sad, upset, disturbed

ដំអូញ to express sadness, grief, sorrow

បណ្ដែរបណ្ដាំ to admonish, exhort, recommend

១០. បទអញ្ជើញគ្រូ

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

បទអញ្ជើញគ្រូនេះ មិនមែនជាចម្រៀងទេឡើយ តែជាទំនុកមួយដែលគេប្រើក្នុងពិធី 'បញ្ចូលអារក្ខ' ។ ធម្មតា គេធ្វើពិធីបញ្ចូលអារក្ខនៅពេលដែលមានអ្នកណាម្នាក់នៅក្នុងគ្រួសារមានរោគាព្យាធិមកបៀតបៀន ។ នៅពេលអារក្ខកំពុងចូល គេដណ្ដឹងសួរនូវដើមហេតុនៃជម្ងឺនោះ រួចហើយរូបដែលចូលនោះ ប្រាប់ឲ្យធ្វើដូចម្ដេចខ្លះដើម្បីឲ្យអ្នកជម្ងឺនោះបានសះស្បើយឡើង ។ មុនបញ្ចូលអារក្ខ គេអុជទៀនអុជធូបនៅតោក រួចគេប្រើបទនេះ សំបូងសង្រូងអញ្ជើញគ្រូឲ្យមកចូលរូប ។

អត្ថបទ

អញ្ជើញគ្រូតូច
អញ្ជើញគ្រូធំ
អញ្ជើញពីកំពូលភ្នំ
ក្រសាលសប្បាយ ។
ខ្ញុំអុជទៀនមួយ
បញ្ចាំនៅតោក
អញ្ជើញគ្រូមក
ក្រសាលសប្បាយ
អញ្ជើញគ្រូស្នេហ៍និមន្ត
អញ្ជើញគ្រូតន់
ធ្យានមកឲ្យឆាប់
ឃើញព្រៃកុំឈប់
ឃើញម្លប់កុំឈរ
អញ្ជើញគ្រូមកក៏
សន្ថិតនៅរូប ។
ស្លាក្រម្លូក
អញ្ជើញគ្រូមក
ទល់មុខនឹងមាត់

ចងខ្សែអ្នកកាត់

ចងព្រ័ត្រអ្នកស្រាយ

ជំងឺរសាយ

ពីរថ្ងៃនេះទៅ ។

បទអញ្ជើញគ្រូ

Introductory Note

អញ្ជើញ to invite, invoke, summon

គ្រូ mediating spirit

បទអញ្ជើញគ្រូ Chant for the Invocation of the Spirits

ចំនុក poem, verse, song, composition

បញ្ចូល cause to enter, put into

អារក្ខ /qaareəq/ capricious spirit, demon

បញ្ចូលអារក្ខ instill a spirit (in a medium); cause (a medium) to be possessed by a spirit

រោគាព្យាធិ /rookiəpyiəthiq/ illness, disease (Lit)

បៀតបៀន to harm, afflict

ដើមហេតុ origin, cause

រូប person; medium

សះ to heal, get better, recover

សះស្បើយ to heal, get better, recover

តោក low altar

សំបួងសង្រួង conjure, summon

Text

ក្រសាល to amuse oneself, enjoy oneself (Roy, Lit)

បញ្ចាំ prepared, made ready, put in place beforehand

ស្នេហ៍ /snae/ love

គ្រូស្នេហ៍ beloved spirit

តន់ tender, precious

ឥទ្ធាន have the power to transport oneself magically

មក៏ (=មក) (this spelling indicates that the word is to be pronounced /mɔɔ/ to rhyme with /chɔɔ/ in the preceding line)

សន្ថិត stay, reside (in)

ក្រ rare, scarce, hard to find

ទល់មុខនឹងមាត់ face to face

ចងខ្សែអ្នកកាត់ If someone ties you up with cord, cut it.

ព្រ័ត rope made of plaited leather

រសាយ to dissipate, slacken; be relaxed, relieved; lax, negligent

១១. សុបិន

ដោយ គីម-សំអុន

បុព្វកថា

សុបិនជាកំណាព្យមួយដ៏ខ្លី ដែលគួរឱ្យចាប់អារម្មណ៍ ។ ភាគច្រើននៃកំណាព្យក្នុងសម័យបច្ចុប្បន្ន ច្រើនតែទាក់ទងនឹងបញ្ហាក្នុងសង្គម : ការពុករលួយ អតិផរណា ថាមពល ។ល។ 'ចលនាត្រឡប់ទៅបុរាណកាលវិញ' បង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងកំណាព្យនេះ ដូចជា : ការជិះសេះ ការប្រើធ្នូ អស្ចារ្យ ។ល។ គេមិនសូវជួបប្រទះនៅក្នុងកំណាព្យសម័យបច្ចុប្បន្នទេ ។

អត្ថបទ

មាណពព្រានព្រៃ បំបោលអជនេយ្យ ហក់លោតសិលា
ផ្អើលអស់បក្សី បក្សាម្រឹគា កាត់ព្រៃបុព្វតា
ក្លៀវក្លាពេកក្ដាត់ ។

'អុះ ! អ្វីនោះទៅហ្ន៎ ? មើលទៅឃើញឈរ ឰដីទីស្ងាត់'
ព្រានព្រៃកំឡោះ ហេវហោះលោតស្ទាត់ ភ្នែកប្រុងប្រយ័ត្ន
ហត្ថចាប់កាន់ធ្នូ ។

ព្រួញហៀបនឹងចេញ ព្រានទប់ទុកវិញ មើលប្រើសយ៉ាងយូរ
ប្រើសធ្មៃព្រងើយ គ្មានទេវ្វីយគិតគូរ គន់គយយូរ ៗ
ឃើញស្រស់អស្ចារ្យ ។

ព្រួញធ្លាក់ពីដៃ ស្ទុះអោបប្រើសថ្លៃ ព្រានច្រៀងពោលថា :
' ឱ ! ប្រើសម្លាញ់ អង្គអញនេះណា កណ្ដាលវេហាសិ៍
រស់ដោយសេរី ' ។

ដៃច្បាស់អង្អែល កេសានៀនៀល បន្ទើរសំដី
ភ្នែកបិទរឹម ៗ ញញឹមប្រិមប្រិយ បក្សីផ្កាព្រៃ
ច្រៀងរាំរោយក្លិន ។

ពេលនោះឯងណា ចំឡែកអស្ចារ្យ ហាក់ដូចសុបិន
ព្រានបើកភ្នែកឡើង បីដូចគេឆ្កិន ប្រើសនោះប្រែក្លិន
ក្លាយកាយជាស្រី ។

'ឱទេពធីតា ! អូនស្រស់អស្ចារ្យ ភក្ត្រាប្រិមប្រិយ
សំណាងទៀមបង ពួនលួងនៅដៃ ឪ! ផែកវិចរណៃ

ថ្លៃស្នេហ៍បងឬ?' ។

កែវកល្យាណី អៀនពុំចេញស្តី ស្រដីឱ្យឮ

នាងស្ទុះគេចចេញ ច្រៀងរាំរន្ទឺ ព្រានព្រៃព្រួចព្រី

ចាប់រាំទាំងទ្វេ ។

ចង្កេះទៀវខ្ចី ទេវីស្រីមុំ រាំសមម្ល៉េះទេ!

នាងផ្ដេកកេសី ប្រុសច្រៀងបំពេរ រាំហោះហើរឆ្ពេរ

សំដៅទេវហាស៍ ។

រាំកាត់ពពក កាត់ខ្យល់រលក ចម្រៀងស្នេហា

នៅទីបង្ហើយ ខំបើកនេត្រា ដឹងខ្លួនការណា

ឱ! សុបិនសោះ ។

(គីម - សំអុន , ម៉្យាងទៅផែន , ទំព័រ ៤៣ - ៤៩)

សុបិន

Introductory Note

សុបិន a dream (Lit)

គីម - សំអុន Kim-Samon, a contemporary poet

ពុករលួយ corrupt, dishonest

អតិផរណា /qateq-phaqrənaa/ inflation

ថាមពល /thaaməpŭəl/ energy, source of energy

អស្ចារ្យ (used as a noun) the marvelous, the supernatural

Text

ព្រានព្រៃ hunter

អជនេយ្យ (=អាជនេយ្យ) /qacənɨy/ horse (Lit)

លីលា (=ដើរ) to go, walk (Lit)

ម្រឹគា (=ម្រឹគ) four-legged wild animal

បព្វតា (=ភ្នំ) /boppətaa/ mountain, hill (Lit)

ស្លៀវក្លា vigorous, dynamic, full of vitality

ក្ដាត់ intensifier for /craən/, /peek/ (Lit)

អុះ! interjection of surprise

អ្វីនោះទៅហ្ន៎? what's that?

ឰដ៏ (=ឯ) at (Lit)

ហោះហោះ (=ហោះ) to fly, soar

ស្កាត់ to intercept

ហត្ថ /hat/ hand (Lit)

ហៀបនឹង about to

គ្មានឡើយគិតគូរ (=គ្មានគិតគូរឡើយ) (normal position of /laəy/ changed to fit the pattern, i.e. to rhyme with /prɔŋəəy/ of the preceding line)

គន់គយ to watch, look at, observe

ស្រស់ charming, attractive

អង្គអញ of mine

ណា (euphonic filler word to rhyme with /thaa/)

ព្រោស to brush, to graze

អង្អែល to caress

ព្រោសអង្អែល to caress

កេសា (= ក្បាល) head (Lit)

ននៀល to twist and turn, roll about (i.e. against the deer)

បន្ធើរ to soften, to lighten

ទឹម ៗ half-closed

ប្រិមប្រិយ lovable, pleasing

រោយ to fall, drop, shed (petals, chaff, etc.)

រោយក្លិន give off odor, spread fragrance

បីដូច seem as if, just as if

ឆ្លិន deceive the eyes

ក្លាយ to change, alter

ទេពធីតា angel, celestial maiden

ភក្ត្រា (= មុខ) /phĕəqtraa/ face (Lit)

លួង term of endearment: Fair One

ចរណៃ /cαarənay/ cut glass, crystal

កែវចរណៃ term of endearment: Precious One

កល្យាណី /kαlyaanəy/ beautiful woman

អៀន shy

ចេញស្ដី to speak

ស្រដី to say, speak (Lit)

គេចចេញ to wiggle free, get away; avoid

វន្ទី menacingly, threateningly (here: saucily, flauntingly)

ព្រឺ to have a chill, get goose-bumps

ព្រួចព្រឺ to feel a thrill, have a sensation of excitement

រៀវ narrow, slim

ខ្លំ svelte; firm

ទេវី (= ទេពី) here: angel

ស្រីមុំ (= ស្រីក្រមុំ) /srəy mom/ young girl, virgin; term of endearment

ផ្ដេក to lay down, put to bed

កេសី (= កេសា) head (Lit)

បំពេរ to sing a lullaby to, sing to sleep, serenade

ឆ្មេរ in a dainty and mincing fashion

រលក a wave (of water, wind, etc.); to roll, churn (of water)

នៅទីបង្ហើយ at the end, finally

នេត្រា (= នេត្រ) eye (Lit)

សោះ rather, instead, really only

សុបិនសោះ [it's] only a dream

១២. ភ្លេងការ

(គ្មានឈ្មោះអ្នកនិពន្ធ)

ទី ១

ទំនុកច្រៀងរាំបើកវាំងនន

បុព្វកថា

ទំនុករាំបើកវាំងនន 'អន' នេះ សម្រាប់ច្រៀងអញ្ជើញសាមីខ្លួនខាងស្រីឱ្យចេញមកសំពះផ្កាស្លា ដែលជាពិធីមួយយ៉ាងសំខាន់ក្នុងពិធីរៀបការ ។ នៅពេលច្រៀងទំនុកនេះ អ្នកភ្លេងម្នាក់រាំយ៉ាងរំពើត ។ នៅពេលដែលសាមីខ្លួនខាងស្រីចេញមក គេលេងភ្លេង 'នាងនាគ' ហើយនៅពេលដើរចូលទៅបន្ទប់វិញ គេលេងភ្លេង 'លោមនាង ឫយខុនគូ ។ល។'

អត្ថបទ

អនអើយស្រីអន
សុំបើកវាំងនន
ជូនអនដេកលក់
សុំផាស់អនទឡឹង
រកទឹកលុបមុខ
ជូនអនដេកលក់
ស្រងាកលើខ្នើយ ។
អនអើយនាងអន
សុំបើកវាំងនន
នាំអនមកផ្ទឹម
អននឹងចេញមក
អនដើរសន្សឹម
នាំអនមកផ្ទឹម
ទន្ទឹមលើខ្នើយ ។
អនអើយផ្កាត់ជាយ
ផាត់ចេញឱ្យឆ្ងាយ
សោះវាសាន់វាន់
កន្ទុលខ្ពស់ខ្នើយ

បម្រុងគ្រប់គ្រាន់
សូមអនទួលទាន់
ពេលាបានហើយ! ៗ

(ក្បួនអាពាហ៍ពិពាហ៍, ទំព័រ ១១១)

ទំនុកច្រៀងរាំបើកវាំងនន

Introductory Note

វាំងនន curtain

អន proper name of the girl to whom the song is addressed, and title of the song itself

សាមីខ្លួនខាងស្រី bride (lit: female member of the bridal couple)

រំពើត graceful, lithesome

លោម (=លួងលោម) to cajole, entice

បាយខុនគូ name of a traditional wedding composition

Text

ជួន it happened that, by chance

ស្រងាក supine, motionless, in suspended animation

ផ្ទឹម to compare, put side by side (here: sit side by side)

ទន្ទឹម side by side, abreast

ផាត់ to brush back, brush away

ជាយ rim, edge, border (here: bridal train)

សាន់វាន់ /san-wan/ be in the way, impede

ខ្នល់ (< កល់) a support, block, cushion

បម្រុង to make preparations, be prepared

ពេលាបានហើយ the time is ripe, the auspicious moment has arrived

ទី ២

បទស្តេចផ្ទុំ

បុព្វកថា

តាមប្រពៃណីខ្មែរ ពិធីរៀបអាពាហ៍ពិពាហ៍មានកំណត់បីថ្ងៃ ។ ហើយនៅក្នុងពេលបីថ្ងៃនេះ មានភ្លេងលេងរងំមិនដាច់ឡើយ ។ អ្នកភ្លេងគេមិនគ្រាន់តែលេងភ្លេងទទេទេ គេថែមទាំងច្រៀងចម្រៀងប្រពៃណីជាច្រើន ស្ទើរតែមិនដាច់ពីមាត់ ។ បទស្តេចផ្ទុំ ជាចម្រៀងមួយដែលគេតែងតែច្រៀងនៅពេលនោះ ។

អត្ថបទ

ព្រះអង្គស្តេចផ្ទុំ ក្នុងព្រះបន្ទំ លើទែនរត្នមណី
ជាទីសុខសាយ ស្តេចផ្ទុំសម្ងំ ព្រះស្ងំហ្វបហ្វាយ
នួតលំអាង្គកាយ សាយសព្វឱរ ។
លើរងព្រះសិរ ទែនបអង្គទាំងទ្វេ ទែអបកាយទាំងគូ
ជាហ៊ុមរូបនាគ ទ្រង់ស្លៀកទទូរ ពីត្រឹមឱរ
ដល់ព្រះសូរង ។
ស្តេចផ្ទុំស្កប់ស្កល់ ជូនជំនោរខ្យល់ ផាត់ដល់ម្តង ៗ
ថែមសូរទ្រប៉ី ដន្ត្រីផ្សំផង ថ្វាយព្រះច្បាស់ច្បង
កំដរស្តេចផ្ទុំ ។
ស្តេចផ្ទុំស្កល់ហើយ មហោរីរោទិ៍ឆ្លើយ ពិរោះរងំ
នារីសកវាទិ៍ ធីតាក្រមុំ ច្រៀងបទស្តេចផ្ទុំ
សមដោយសម្លេង ។
សមរូបនារី សមនិងទែនទី សមដោយគ្រឿងភ្លេង
សមរូបរង្សី ចក្រីនៅក្មេង សមញ្ញាទមីព្រេង
ព្រះប្រិយមហាក្សត្រិយ៍ ។
ស្តេចផ្ទុំស្កល់ស្កប់ ពីពេលព្រលប់ លុះអធ្រាត្រស្ងាត់
ទ្រង់តើនចាកទែន ព្រះថែនចក្រពត្តិ ទៀងទែនមណីរត្ន
ក្នុងក្រឡាបន្ទំ ។
បឋមទៀបព្រឹក សូរស័ព្ទសន្ធឹក ត្រឹកត្រេងធរណី

ដោយសារស័ព្ទភ្លេង ក្រុមក្មេងនារី ដោយព្រះភូមិ

ទ្រង់ទីកំសាន្ត ៗ

(ក្បួនអាពាហ៍ពិពាហ៍, ទំព័រ ១២២ - ១២៣)

បទស្តេចផ្ទំ

Introductory Note

បទស្តេចផ្ទំ name of a wedding song (lit: Song of the Sleeping King)
រងំ droning, rumbling, indistinct
មិនដាច់ពីមាត់ unceasingly, incessantly, continually (of singing, speaking, eating, etc.)

Text

ផ្ទំ to sleep (Roy)
បន្ទំ bedroom, sleeping quarters (Roy)
ទែន bed, couch (Roy)
រត្ន /roət/ precious stone, jewel
មណី /mənii/ precious stone, jewel
សាយ (=សាន្ត) peaceful, tranquil, quiet
សម្ងំ (=ស្ងំ) be still, stay quiet (neither speaking nor moving)
ស្នំ concubine, female royal attendant
ឃ្មបឃ្មាយ to prostrate oneself in an attitude of obeisance
នួត to massage (Thai)
សព៌ាង្គ /sarəpiəŋ/ body (Roy)
សាយ to spread, diffuse, suffuse
ឧរូ /qaoruu/ chest (Roy)
សាយសព្វឧរូ all over [up to] the chest
ទង cushion, pillow
សិរ /sei/ head (Roy)
ជិត near, close, intimate
ទាំងទ្វេ both
ផ្អែប get close to, stay next to, get alongside
ផាហ៊ុម coverlet, spread, small blanket
រូបនាគ [with a design in] the form of a dragon
សូរង /sourŭəŋ/ neck (Roy)
ស្កប់ satiated, content, satisfied
ស្កប់ស្កល់ satiated, content, satisfied
ជំនោរ a puff (of wind), light breeze
ផាត់ to blow (Lit)
ទ្រ a two-stringed musical instrument
ប៉ី flute, clarinet
ផ្សំ combine, put together, add to, accumulate
ច្បង eldest
ច្បាស់ច្បង appellation for a king (lit: clearly the eldest)
មហោរី /məhaorii/ orchestra; stringed instrument
ទ្រាំទំ /roo/ to resound (of music); to roar (of lions); to moo (of cows); to race (of motors)
សក្កវា /saqkəwaa/ title of a palace song
នារីសក្កវា the girl [who sings] the /saqkəwaa/
ធីតា /thidaa/ girl, daughter (Lit)
សម /sɑm/ appropriate (to), fitting, becoming; to fit, go well with

រង្សី /reə̆ŋsəy/ brilliance, sparkle, ray of light

ចក្រី /cɑkrəy/ king, prince

ព្រេង the past, ancient times, antiquity; ancient, former

ប្រិយ pleasing, pleasant

មហាក្សត្រិយ៍ /məhaa-ksatrəy/ king

អធ្រាត្រ /qatriət/ midnight (Lit)

តើន awaken, get up (Roy, Clergy)

ថៃន platform

ចក្រពត្តិ /caqkrəpoə̆t/ kingdom, empire; royal, imperial

ក្រឡាបន្ទំ sleeping quarters (Roy)

បឋម /pathɑm, pathɑmmə-/ first, primary; here: early

គ្រឹកគ្រេង thunderous, tumultuous, clamorous

ធរណី /thɔɔrənii/ ground, earth (Lit)

ភូមី king

ទីកំសាន្ត amuse oneself, enjoy oneself (Roy)

១៣. សរសើរហេមន្តមាស

ដោយ

ព្រះបាទស្រីធម្មរាជា

បុព្វកថា

ព្រះបាទស្រីធម្មរាជា មហាក្សត្រខ្មែរពីឆ្នាំ ១៦២៧-១៦៣០ ជាកវីនិងជាអ្នកប្រាជ្ញខាងមគធៈភាសាដ៏ឆ្នើម ។ ព្រះអង្គជារាជបុត្រនៃព្រះបាទជ័យជេដ្ឋាទី ២ ឈ្មោះដើមគឺ 'ចៅពញ្ញាតូ' ។ ព្រះអង្គមិនមានគិតគូរដល់រាជសម្បត្តិប៉ុន្មានទេ ។ ហេតុដូច្នេះហើយបានជាព្រះអង្គលះបង់រាជសម្បត្តិ ក្រោយសោយរាជបានពីរឆ្នាំ ។

កំណាព្យដកស្រង់មកនេះ ជាការពិពណ៌នាដ៏រស់រវើក លន្លង់លន្លាច នៅពេលដែលព្រះអង្គសោយសោកអាឡោះអាឡ័យជាខ្លាំងចំពោះព្រះនាងបុប្ផាវតី ។

អត្ថបទ

(បទកាកគតិ)

ព្រលឹងមាសអើយ ថ្ងៃចើសព្រែហើយ ទន្ទាបសុរិយា
ស្រណោះសព្វសត្វ ឆ្សៀវឈ្ងាត់ទេវហាសិ ចុះចាប់ព្រឹក្សា
សសិតស្លាបយំ ។

ព្រលឹងមាសអើយ ស្តាប់ស័ព្ទសត្វឆ្លើយ ទៅមកសូរសម
ខ្លះហើរផ្លេកផ្លោះ ខ្លះទ្រោះទ្រៀវយំ សំកាំងស្លាបទំ
ទន្ទឹមគូវា ។

ព្រលឹងមាសអើយ អស្តង្គតហើយ បាំងបាត់សុរិយា
បងចាំប្អូនស្រី ប្រិមប្រិយ៍សោភា រែងរំលេចផ្កា
កាល់រែកមកេសី ។

ព្រលឹងមាសអើយ បងរកអស់ហើយ នៅនាលោកិយ៍
មានតែប្អូនតន់ លើសលន់អស់ស្រី រុងរឿងរស្មី
ប្រសើរថ្លៃថ្លា ។

ព្រលឹងមាសអើយ អស្តង្គតហើយ ជួបចូលសន្ធ្យា
ស្រណោះព្រះពាយ ផ្សប់ផ្សាយទេវហាសិ មេឃយង់យល់ថ្លា
ពពកសសាត់ ។

ព្រលឹងមាសអើយ ជួបសន្ធ្យាហើយ សែងសូរ្យបាំងបាត់

ព្រោងព្រះច័ន្ទ្រា	ថ្ងៃថ្លាទៀងថ្វាត់	រស្មីប្រចវាត់
	កើតកបណ្ណរាយ ។	
ព្រលឹងមាសអើយ	ព្រះចន្ទរះហើយ	តារាទៀងរាយ
ស្រណោះស័ព្ទសត្វ	ស្រងាត់ឮឆ្ងាយ	សូរស័ព្ទព្រះពាយ
	ត្រសាក់សន្ធិយា ។	
ព្រលឹងមាសអើយ	ដល់រាត្រីហើយ	គាប់ព្រះច័ន្ទ្រា
ប្រទក្សិណជុំ	ភ្នំសុមេរា	ព្រោងព្រាយទេវហាសី
	ចែងចាំងប្រចវាត់ ។	
ព្រលឹងមាសអើយ	ព្រះចន្ទចែងហើយ	ស្រណោះកាលគ្រា
យល់ព្រះប្អូនថ្លៃ	ប្រពៃលក្ខណា	គង់នៅបរិពារ
	លើសលើលោកា ។	
ព្រលឹងមាសអើយ	គាប់រាត្រីហើយ	មានព្រះចន្ទ្រា
ពាសពេញហ្វូមិ	រស្មីថ្ងៃថ្លា	កណ្ដាលតារា
	ឯកឯអម្ពរ ។	
ព្រលឹងមាសអើយ	ភូមិភពអាយហើយ	មានតែប្អូនវរ-
មិត្រមាសកល្យាណ	សាច់សាន្តសាទរ	ជាឯកបវរ
	មណ្ឌលទីអាយ ។	
ព្រលឹងមាសអើយ	ចូលអធ្រាត្រហើយ	ស្រណោះព្រះពាយ
ផាត់ផើយរំភើយ	លំហើយសព្វសាយ	ផុំសុរភីភាយ
	នារាត្រីកាល ។	
ព្រលឹងមាសអើយ	គាប់ថ្មើរនោះហើយ	ទៀមទែងស្នេហ៍ស្នាល
សំណេះនឹងចៅ	ស្ងួនពៅត្រកាល	សេពសមសងសារ
	សាន្តសោមនស្សា ។	
ព្រលឹងមាសអើយ	ឮស័ព្ទផ្គរឆ្លើយ	ទោះរាយនក្គា
ហាក់ព្រះប្អូនរ័តនី	ថែនបនិត្យស្នេហា	សំណេះចរចា
	នឹងបងសព្វថ្ងៃ ។	
ព្រលឹងមាសអើយ	ទៀមទែងរួមខ្នើយ	នឹងព្រះប្អូនថ្លៃ
ម្ដេចឡើយមិត្រមាស	ថែប្រព្រាសទីទៃ	មេមិនមូលទឹម-
	ត្រីដូចចិត្តបង ។	

ព្រលឹងមាសអើយ គាប់អធ្រាត្រហើយ ឮស័ព្ទសត្វផង
ឆ្លាស់ឆ្លើយយាលយំ ស្នូរសមរំពង ឯអាកាសកង
ត្រសាក់សន្ធិយា ៗ

ព្រលឹងមាសអើយ គាប់ថ្មើរណេះហើយ សត្វគៀងគូវា
ម្តេចឡើយមិត្រមាស ប្រែប្រួលឈ្លាឈ្លា ឲ្យតែបងផ្សា
អង្គងឯងអំព្យាយ ៗ

ព្រលឹងមាសអើយ ភ្នកដល់ប្អូនហើយ ធ្វេសធ្វរាយមាយ
និងស័ព្ទសត្វយំ ផ្សំស័ព្ទព្រះពាយ ត្រសៀកផ្សព្វផ្សាយ
ត្រសាក់ស្នូរសម ៗ

ព្រលឹងមាសអើយ អស់អធ្រាត្រហើយ ដល់ទៅដាស់ទុំ
ភ្នកដល់ប្អូនស្ងួន ខ្លឹមខ្លួនឧត្តម ទទៀមរែងសេពសម
សង្សារមាសមិត្រ ៗ

ព្រលឹងមាសអើយ ចូលដាស់ទុំហើយ បងមេរែងគិត
ដ្បិតមេមាសបាត់ ស្ងប់ស្ងាត់ក្នុងចិត្ត ម្តេចឡើយមាសមិត្រ
មិនមួលមេត្រី ៗ

ព្រលឹងមាសអើយ ពន់ដាស់ទុំហើយ ទៀបព្រឹកឡើងខ្ចី
ស្រណោះស័ព្ទសត្វ ស្រងាត់ឃ្មោលពៀវ ស្រណោះច្រើនទី
មាសមិត្ររែងចាំ ៗ

ស្រីមាសបងអើយ ស្រណោះមាសអើយ រដូវដើមឆ្នាំ
អាកាសដាសដេរ មេឃមីរជញ្ញាំ មាសអើយគួរចាំ
គិម្ហះមាសា ៗ

ស្រីមាសបងអើយ ដាច់ខែចែត្រហើយ ចូលវិសាខា
ស្រណោះស័ព្ទផ្គរ ខ្ទរខ្ទរនានា ព្រើលទ៌ព្រព្រឹកផ្សា
លូតលាស់ខៀវខ្ចី ៗ

ស្រីមាសបងអើយ រដូវភ្លៀងហើយ ធ្លាក់ចុះអំពី
បូព៌ាអគ្នេយ៍ ទក្សិណនីរតី បស្ចិមទិសទី
ពាយព្យឧត្តរា ៗ

ឦសាណសោតហោង ស្នូរស័ព្ទរំពង ទាំងទិសអដ្ឋា
ស្រណោះស័ព្ទផ្គរ ខ្ទរខ្ទរមេឃា ព្រមិគីព្រមិគា

លោតលងជើងលេង ។

ស្រីមាសបងអើយ សាយល្ហោហើយ ស្រណោះស័ព្ទសែង
ស័ព្ទសត្វបក្សី ឈ្មោលញីក្ដោចក្ដែង ដូចមាសប្អូនឯង
ដង្ហោយហៅបង ។

ស្រីមាសបងអើយ សាយល្ហោហើយ សព្វសត្វត្រសង
ហើរហែទាំងគូ នែបនៅស្នេហ៍ស្នង ដូចស្រីនួនល្អង
នឹងបងនែបនិត្យ ។

ស្រីមាសបងអើយ សូរស័ព្ទផ្គរឆ្លើយ ដោយទីឋានជិត
មើលភ្នំមើលព្រៃ ឆ្ងាយក្រែងងឹត ដង្គោលជុំជិត
គួរឱ្យស្រណោះ ។

ស្រីមាសបងអើយ ស្រឡប់ទៅហើយ សត្វផងផ្លេកផ្លោះ
ទៅដោយទ្រនំ ទៀងទំទ្រៀវទ្រោះ ផ្គរឆ្លើយឡឹងស្នោះ
ពីអាកាសនាយ ។

ស្រីមាសបងអើយ ចូលសន្ធិយាហើយ ផ្គរលាន់ឮឆ្ងាយ
ស្រណោះដើមឆ្នាំ គួរចាំសព្វសាយ ស្រណោះព្រះពាយ
រំភើយវាតា ។

ស្រីមាសបងអើយ ដល់សន្ធិយាហើយ ស្រណោះច្រើនគ្រា
ស្រណោះគិរី បក្សីបក្សា ស្រណោះទេវហាសិ
ពពកសាត់សល់ ។

ស្រីមាសបងអើយ ពន់ស្រឡប់ហើយ អធ្រាត្រមកដល់
ស្រណោះដើមឆ្នាំ គួរចាំដោយកល ស្រណោះផ្លាប់យល់
ស្រីមាសមិត្របង ។

ស្រីមាសបងអើយ ពេលអធ្រាត្រហើយ សូរផ្គររំពង
ស្រណោះស័ព្ទផ្គរ ខ្ញារខ្ញរឆ្លើយឆ្លង ស្រណោះដល់ហោង
ស្រីមាសមហាថ្លៃ ។

ស្រីមាសបងអើយ ចូលអធ្រាត្រហើយ ភ្លៀងនិរក្រាស់ក្រែ
ស្រងាត់សន្ធិយា បងមហាអាល័យ ស្រណោះនៅនែ
កំឡុងរាត្រី ។

ស្រីមាសបងអើយ ចូលអធ្រាត្រហើយ ភ្លៀងសាទៀតថ្មី

ផ្គរទឹងព្រលាន់   រន្ធាន់ខ្លាំងថ្មី   ស្រណោះដល់ស្រី
មាសបងឃ្លាតឃ្លា ៗ

ស្រីមាសបងអើយ   ពន់អធ្រាត្រហើយ   ផាស់ទុំរិញណា
ស្រណោះសព្ទសត្វ   ស្រងាត់ភាសា   ភ្លៀងនិរទេវហាសិ
អាប់អស់ទិនករ ៗ

ស្រីមាសបងអើយ   ចូលអធ្រាត្រហើយ   ស្រណោះសព្ទផ្គរ
រន្ធះម្តង ៣   សូរសង្ខារន្ធរ   អាកាសអម្ពរ
ភ្លៀងស្លើយផាយផាត់ ៗ

ស្រីមាសបងអើយ   ពន់ផាស់ទុំហើយ   ព្រលឹងសព្ទសត្វ
ស្រណោះស្រីមាស   ដែប្រព្រាសទៅបាត់   មាសអើយបងស្វាត់
ស្រណោះម្នាក់ឯង ៗ

ស្រីមាសបងអើយ   ទៀបទៅព្រឹកហើយ   ព្រផ្គរល្វើយល្វេង
ស្រណោះបក្សី   ឃ្មោលញៀសព្រេងង   ប្រទោះប្រទៀវយំឯង
សឹងចាកប្រទនំ ៗ

ស្រីមាសបងអើយ   ស្រណោះព្រឹកហើយ   បក្សីចេញទំ
សសិតស្លាបហើរ   ផ្លោះផ្លើរហើរទំ   នៅសព្វប្រទនំ
ទៅសព្វទិសផង ៗ

ស្រីមាសបងអើយ   បងគិតទៅហើយ   ស្រណោះសោតហោង
ចូលជេស្ឋមាសា   គង្គាចាំលង   ទឹកទល់ថ្លាខ្សង
ដំឡើងមកដល់ ៗ

ស្រីមាសបងអើយ   ផាច់ជេស្ឋទៅហើយ   អាសាធសោតសល់
ទឹកឡើងសាយព្រែក   ជលស័យសាយកល់   ជោរជែងមកដល់
សំណាត់ពេញពាស ៗ

ស្រីមាសបងអើយ   ទឹកដំឡើងហើយ   ត្រីមីរជេរផាស
ចូលសព្វព្រែកខ្វែក   បំបែកពោរពាស   ត្រីផងទាំងផ្ដាស
ចូលបឹងត្រៀបត្រា ៗ

មាសអើយមើលព្រែក   ទន្លេហូរបែក   ចូលសព្វសល់សា
សំណាត់សាត់ធ្លាក់   ព័ទ្ធពាក់លើគ្នា   ហូរដោយគង្គា
ចូលព្រៃពោរពេញ ៗ

មាសអើយកូនស្រី	ចង្វាឫស្សី	ដែលលេងខ្យល់ខ្សាញ់
កំភ្លាញកំភ្លក់	ក្អែកក្អកក្រុះក្រាញ់	ផ្ទក់ផ្កាងស្រាញ់
	សព្វស្មៅដែលបឹង ។	
មាសអើយមច្ឆា	ផ្លែកផ្លាះផ្កាប់ផ្ងារ	កូនផ្ទក់ប្រចឡឹង
មានត្រីតូចធំ	សម្ញុំស្រមឹង	ដែលដោយប្រែប្រឹង
	កន្ទុយវាយវាត់ ។	
មើលអស់ទាំងស្មៅ	លិចដើមអស់ទៅ	ឃើញចុងប្រេចីនក្ដាត់
ស្រមោចឡើងទៅ	ដោយស្មៅពេនព័ទ្ធ	ស្រណោះស្រីវ័ត្តនិ
	មេឃ្លាតពីបង ។	
មើលមានត្រីតូច	ប្រឡាយរអូច	ត្រីធំលាយផង
. . . .	. . . .	. . . .
	រញ្ជួយដើមផល់ ។	
មុខគួរស្រណោះ	ដំឡើងទឹកនោះ	បងមកយង់យល់
ស្រណោះបវ័ន្ត	កង្ហែកង្ហល់	ស្រណោះប្រេចីនសល់
	ដំណើរគង្គា ។	
មាសអើយផ្ទៃបឹង	ព្រលិតឈរស្រឹង	លាស់លូតមានផ្កា
ស្គន់ស្គុះត្រកៀត	សឹកសៀតស្លាបទា	ស្លាបស្លាបប្រចវា
	កំពីងពួយពាស ។	

(កម្ពុជសុរិយា , លេខ ១២, ឆ្នាំ ១៩៣៨)

សរសើរហេមន្តមាស

Introductory Note

ហេមន្តមាស /heimɑn-miəh/ winter months, cool season

សរសើរហេមន្តមាស 'In Praise of Winter', a romantic poem ascribed to King Sri Dhammaraja

ស្រីធម្មរាជា Sri Dhammaraja, King of Cambodia 1627-30

ឧត្ដម above all else, supreme

ជ័យជេដ្ឋាទី ២ Chey Chettha II, King of Cambodia 1618-26

ចៅពញា Chau Ponhea (a title meaning roughly 'Prince')

តូ To (given name of King Sri Dhammaraja)

គិតគូរ concern oneself with, pay attention to

រស់រវើក vivid, realistic

ព្រះនាង princess, queen

បុប្ផាវតី /bopphaawədəy/ Bopphavadi

(former sweetheart of King Sri Dhammaraja who later married King Udaya)

Text

ព្រលឹងមាសអើយ Oh, My Darling, My Precious One

ចើល about to set, low (of the sun)

ថ្ងៃចើលទីព្រៃហើយ the sun is sinking behind the trees

ទន្ទាប to be low, flat

សុរិយា /soriyaa/ sun (Lit)

ស្រណោះ to miss, remember nostalgically

ស្រណោះសព្វសត្វ rendered nostalgic [by] all the animals

ឆ្វៀលឈ្វាត់ circle around, go around crossing this way and that

សសិត to preen, to trim or dress the feathers with the beak (birds)

ផ្លេកផ្លោះ to jump up, leap over; to dash, to swoop

ទ្រោះទ្រៀន to cry, wail, screech (of animals)

សំកាំង to float, glide, soar

សោភា beautiful (Lit)

តែង usually, used to, as a rule, generally

តែកម to decorate around the edge, to embellish with a border

កាល់តែកម (= តែកម)

លោកិយ៍ (= លោកិយ) /lookəy/ this world, the temporal world

ឥន់ precious

លើសលន់ exceeding(ly)

រុងរឿង high, glorious, excellent

ថ្លៃថ្លា excellent, precious

អស្តង្គត /qɑhsdɑŋkŭət/ dusk, twilight, sunset; to set (of the sun; Lit)

សន្ធិយា (=សាណិយា) /sɑnthiyaa/ curtain; here: curtain of darkness, nightfall

ជួបចូលសន្ធិយា [the sun] has entered the curtain [of darkness]

ព្រះពាយ wind (Lit)

ផ្សព្វផ្សាយ to disperse, spread around, diffuse

យង់ intensifier for adjectives of clarity, brightness, etc.

ឈសាត់ (=រសាត់) to float along

សែង ray, gleam, light (of the sun)

សូរ្យ /sou, souriyĕəq/ sun (Lit)

ព្រោង sparkling, gleaming (usually from many points)

ពណ្ណរាយ /pŭənnəriəy/ to shine, excel; brilliance, excellence

រៀងរាយ distributed here and there, spread around

ស្ងាត់ quiet, tranquil

ត្រសាក់ to spread, suffuse

ត្រសាក់សន្ធិយា in the darkness, in the night

គាប់ (=គាប់ជួន) coincidentally, by fortunate coincidence

ប្រទក្សិណ /prɑtĕəqsən/ to encircle clockwise

សុមេរា (Mt.) Meru

ព្រោងព្រាយ to sparkle from many different points

ចែង to shine

ច្រវាត់ helterskelter, criss-crossing, in or from all directions

លក្ខណា (= លក្ខណ៍) quality, virtue

លោកា (=លោក)

ឯក one, first, alone

អម្ពរ space, air, sky

ភូមិភពអាយហើយ in this world

វរមិត្រ esteemed friend

កល្យាណ /kɑlləyaan/ good, virtuous, beautiful

សាច់ complexion

សាន្ត peaceful, tranquil, quiet; here: beautiful (of complexion)
សាទរ to empathize with, rejoice with
សាច់សាន្តសាទរ of lovely and desirable complexion
អធ្រាត្រ /qatriət/ midnight (Lit)
ផាត់ផើយ to blow (Poetic)
រំភើយ fluttering, floating on the breeze
លំហើយ to cool, refresh (of wind)
សាយ to spread, diffuse, suffuse
សព្វសាយ spreading all around; everywhere; everything
សុរភី fragrance, perfume
ថ្មើរ time, period of the day
រៀម elder brother; here: I
ស្នេហ៍ស្នាល to love (Poetic)
សំណេះ to reminisce, exchange fond memories
ស្ងួន to pamper, treat tenderly, caress
ត្រកាល precious, extraordinary
សេព /saep/ to partake of, indulge in, associate with
សងសារ (=សារសង) to converse, answer reciprocally
សេពសមសងសារ engage in pleasant dialogue
សោមនស្សា (=សោមនស្ស) /saomənoə̆hsaa/ pleased, delighted; pleasure, delight
ផ្គរ thunder
ខ្លើយ to resound, reverberate
រេរាះរាយ (=រួសរាយ) genial, cordial, expansive
រ័តន៍ /roə̆t/ gem, precious stone (here: Precious, Beloved)
រ័នបនិត្យ close, intimate
ចរចារ to negotiate; to converse, talk

រួមខ្នើយ to share a pillow, sleep together, make love
ព្រាស away from, different from, separated
មេ lady; mother; you (intimate, older to younger)
មៃត្រី (=មេត្រី) friendship, love; to feel friendly, to love (Lit)
មូលមេត្រី to love fully, to feel unreserved friendship
ឆ្លាស់ឆ្លើយ to answer
យាស to cry, to call (of animals)
សម /sɑm/ then, accordingly, so, thus
កង loud, roaring
គៀង to drive (cattle), round up, herd together, head off
ផ្សា to burn, smart, sting
អង្គឯង (=ខ្លួនឯង) myself, oneself
អំបាយ (=អម្បាយ) extremely (Arch)
ភ្នក to have a sudden inspiration, have it occur to one to; here: think about
ធ្វេសធ្វេ (=ធ្វេសធ្វើ) to be doubly negligent, doubly neglectful
រាយមាយ careless, negligent
ផ្សំ to combine, put together, add to, accumulate
ត្រសៀក blowing gently, wafting
ផ្សព្វផ្សាយ to disperse, spread around, diffuse
ដាស់ទុំ deepest part of the night (about 1-3 a.m.)
ខ្លឹម heart, core, essence
រ័រង increasingly
បងមេរ័រងគិត (=បងរ័រងគិតដល់មេ)
ពន់ past, beyond (Arch)
ទៀប near, close to; nearly, almost
ខ្មី quickly, immediately, soon; newly, recently (Lit)
ដាសដេរ (=ដេរដាស) full of, covered with, crowded with;

all over
មីរ cloudy, overcast, somber, dark
ងញាំ dark

គិម្ហៈ hot

មាសា (=មាស) month

ដាច់ខែ at the end of the month, after the month of...
ចែត្រ March-April (lunar system)

វិសាខា (=ពិសាខ) April-May (lunar system)

ខ្ញារខ្ញុរ (=ខ្ញុរខ្ញារ)

ព្រើស to be happy, delighted

បូព៌ា /boupiə/ east (Lit)

អគ្នេយ៍ /qaqknee/ southeast (Lit)

ទក្សិណ /teə̆qsən/ south (Lit)

និរតី /niərədəy/ southwest (Lit)

បស្ចិម /bahcəm/ west (Lit)

ពាយព្យ /piəyoə̆p/ northwest (Lit)

ឧត្តរា (=ឧត្តរ) /qotdαα/ north (Lit)

ឦសាន /qəysaan/ northeast (Lit)

អដ្ឋា (=អដ្ឋ) /qatthaq/ eight (Skt)

ម្រឹគីម្រឹគា female and male four-footed wild animals
លង to try, test, experiment with

សាយណ្ហេ (=សាយណ្ហ) /saayαn/ evening

ក្តោចក្តែង to cry, wail, lament

ផង្ហោយ to call from afar

ត្រសង moving along leisurely in a group
នែប near, close, intimate

នួន fair, beautiful (of complexion)
ល្អង powder, pollen, dust; beautiful (of complexion)
ដោយទីឋានជិត around the place where I am

ផង្គោល in a big cloud, in a vague mass
ជុំជិត close around, round about

ស្រទ្យប់ to faint; dusk, twilight

ទ្រៀងទ្រោះ (=ទ្រោះទ្រៀង) to cry, wail, screech (of animals)
លាន់ to sound, make a noise (of inanimate objects)
វាតា wind (Lit)

សាត់ (=រសាត់) to float along

សល់ many, in abundance, extremely

ដោយកល inarticulate because of tears (Skt. kala ?)

មហា before an adjective: really, immensely, extremely

ឱរ /qao/ to rain hard

កំឡុង in, during; period, interval (Arch)
សា to retrace, redo, recommence, repeat
រឹង increasingly

រន្ទាន់ repeatedly, in rapid succession
ទិនករ /tɨnnəkαα/ sun (Lit)

សង back again, in return

ផាយផាត់ to blow (Lit)

សឹង almost, almost all

ស្ងាត់ isolated, lonely, quiet

ល្វើយល្វេង vague, indistinct, weak (of sound or smell)
សង្រេង to grieve, suffer

ផ្លោះផ្លើរ to jump, leap, dash, swoop
ជេស្ឋ /ceeh/ May-June (lunar system)
គង្គាចាំលង (meaning unclear)

ទល់ to reach, touch, be against

ថ្លាខ្យង crystal clear

ដំឡើង to rise (Arch)

ជលាស័យ /cŭəlləsay/ ocean, sea, body of water (Lit)
កល់ intensifier: very much, very many (?)
ជោរ to rise (of ocean tide)

ជែង to struggle ahead, push ahead; to compete
សំណាត់ driftwood

មីរ in a great crowd, spread densely all over, stippled
ខ្វែក (meaning unclear)

បំបែក to break up, disperse, scatter (Archaic intransitive use)
ផ្តាស lax, careless, foolish

ចង្វាឫស្សី a kind of small fish (lit: bamboo oar)
ខ្វល់ខ្វាញ់ swirling turbulently, churning
កំភ្លាញ a kind of small fish

កំភ្លក់ a kind of fish

ក្អែក a kind of black fish

ក្អក a kind of small fish

ក្រុះ (=ក្រុស) a perch-like fish

ក្រាញ់ a kind of small fish

ផ្ទក់ a kind of small fish

ផ្ទោង a small tubular fish

សស្រាញ់ vigorously, with abandon

ដៃបឹង branch or bay of a lake

ប្រចឡឹង a kind of small fish

សម្ងំ (=សង៉ំ) be still, stay quiet (neither speaking nor moving)

ស្រមឹង to ponder in silence, be pensive (here: quiet, passive)
វ៉ាត់ to slash, swish, lash

ពេន to encircle, coil around

រ័ត្នន៍ (= រត្ន) /rŏət/ gem, precious stone; precious, beloved
រអួច to move the lips silently

រញ្ជួយ to shake, tremble

រញ្ជួយដើមផល់ causing the stalks [of grass] to tremble (?; apparently three preceding phrases of this stanza are omitted from the text)

យង់យល់ to see

បន្ដែ (=បណ្ដែ) /bɑndae/ pledge, promise
កន្ទ្វែកន្ទ្វល់ restless, impatient (?)

ដំណើរគង្គា appearance or action of the water
ស្រឹង tranquil (?)

លាស់លួត (=លួតលាស់)

ស្គន់ a kind of waterlily

ស្គុះ a kind of waterlily

ត្រកៀត an edible aquatic plant with straight stalks
សៀត to insert, stick in, wedge apart, pry apart
ស្លាបទា an aquatic plant (lit: duck feathers)
ស្លាម dense, crowded together

ស្លាបច្រវា an aquatic plant (lit: oar blades)
កំពឹងពួយ an aquatic plant used as a vegetable
ពាស (=ពាសពេញ)

១៤. អាយ៉ៃ (ទី ១)

ដោយ

ស្រី-អ៊ូ និង ញូង-សឿង

បុព្វកថា (សម្រាប់អាយ៉ៃទី ១ នឹងទី ២)

កំណាព្យខាងក្រោមទាំងពីរនេះ គេបានសរសេរទុកមកដើម្បីគ្រាន់ជាគំរូសំរាប់ច្រៀងអាយ៉ៃ ដែលជាសិល្បប្រជាប្រិយមួយ ដែលប្រជាជនទូទៅចូលចិត្តស្តាប់ជាទីបំផុត ។ គេមានថែមទាំងចាក់ផ្សាយតាមវិទ្យុជាតិជាញឹកញាប់ផង ។ ចម្រៀងអាយ៉ៃនេះ ធម្មតាគេមិនសរសេរទុកជាមុនទេ អ្នកច្រៀងអាយ៉ៃជាសិល្បករ ជាមនុស្សមានប្រាជ្ញាខាងវៃណាស់ ហើយជាពិសេសបំផុតជាកវីយ៉ាងចំណាន ។ ពាក្យពេចន៍ទាំងប៉ុន្មានគេប្រឌិតឡើងភ្លាម ៗ ឥតមានព្រាងទុកជាមុនឡើយ ។ ចម្រៀងអាយ៉ៃត្រូវមានមនុស្សពីរនាក់ ស្រីម្នាក់ ប្រុសម្នាក់ ច្រៀងឆ្លើយឆ្លង ដោះប្រស្នាគ្នាទៅវិញទៅមក ។

អាយ៉ៃផ្នែកទី ១ នេះពុំមានអត្ថន័យអ្វីជ្រៅទេ ព្រោះគ្រាន់តែសម្រាប់ចាប់ផ្តើមនៃចម្រៀងអាយ៉ៃតែប៉ុណ្ណោះ ។

អត្ថបទ

(បទពាក្យ ៧)

ប្រុស

ស្រីអើយ ! ស្រីស្រស់ល្អស់អង្គ   វង់ភក្ត្រផូរផង់ឥតហ្មងសៅ
ចូរនាងចេញមកណ៎ា ឆោមឆ្នៅ !   ព្រមច្រៀងទេពៅ ឬយ៉ាងណា? ។
បើព្រមមិនព្រមសូមឆ្លើយមក   បងនឹងលែលកទៀតកនិដ្ឋា
ទាន់អស់លោក - អ្នកនៅត្រៀបត្រា   ស្រីកុំសាវារង់យូរឡើយ ។

ស្រី

ខ្ញុំឮសំដីប្រុសផ្តោះផ្តង   ដោយមានបំណងឱ្យខ្ញុំឆ្លើយ
ប្អូនពុំប្រកែកទេបងអើយ !   សុខចិត្តតែឆ្លើយតាមចំណេះ ។
ប៉ុន្តែប្អូនសូមសួរប្រុសថ្លៃ   ឱ្យអស់សង្ស័យក្នុងពេលនេះ
ឱ្យញាតិដឹងស្គាល់បានចាំចេះ   តើអ្នកបងនេះនាមឈ្មោះអ្វី ? ។

ប្រុស

បងឈ្មោះ (ភូមិន្ទ) ពិតប្រាកដ   តាមដោយកំណត់ហោរាស្ដី
ដាក់ឈ្មោះយ៉ាងនេះទើបគប្បី   មហាជនប្រុសស្រីគេចូលចិត្ត ។

ចុះបងអាយុប៉ុន្មានឆ្នាំ?
កុំភូតកុហក់ខុសក្រមក្រឹត្យ

អាយុម្ភៃប្រាំឆ្នាំជាក់
មិនភរភូតទេណា៎នួនល្អង!

បងនៅភូមិណាឃុំណាក្ដី
សូមប្រាប់មកទៀតណា៎ប្រុសថ្លៃ!

ភូមិសាក់សំពៅឃុំសាក់សំពៅ
ក្នុងស្រុកភ្នំពេញណា៎ជីវ៉ា!

ចំណែកមាតានឹងបិតា
សូមប្រាប់មកទៀតប្រុសវិសាល

បិតាបងឈ្មោះ (សិរីវ័ឌ្ឍ)
មាតាបងឈ្មោះ (សុកណ្ណា)

មួយទៀតឯជាតិរបស់អ្នក
សូមប្រាប់ឆាប់មកប្រុសប្រិមប្រិយ

បងជាតិជាខ្មែរនគរវត្ត
សាវតារជាតិតពូជដ៏វែងឆ្ងាយ
បងឆ្លើយមកនេះសព្វគ្រប់ហើយ
ពេលនេះបងបែរសួរសៀតសឹក
សួរឈ្មោះអាយុលំនៅផង
នាងនៅភូមិណាឃុំណាក្ដី
សូមប្អូននិម្មលពៅពិសី

ស្រី

សូមឆ្លើយតាមចាំដោយពាក្យពិត
ឱ្យប្អូនស្នេហ៍ស្និទ្ធជឿបានផង ៗ

ប្រុស

ជឿចុះវរល័ក្ខណ៍ពិតកន្លង
មាសបងជឿចុះកុំសង្ស័យ ៗ

ស្រី

ស្រុកខ្មែរឈ្មោះអ្វីនៅសព្វថ្ងៃ?
ឱ្យជនដទៃដឹងផងណា៎ ៗ

ប្រុស

ដែលបងធ្លាប់នៅពីដូនតា
ខ្មែរសោតឈ្មោះថាខ្មែរកណ្ដាល ៗ

ស្រី

មានឈ្មោះយ៉ាងណា? សូមដំណាល
សមគួរដល់កាលដែលសន្យា ៗ

ប្រុស

រស់នៅទៀងទាត់ទាំងទ្វេហា
ចេះក្បួនតម្រាទាយល័ក្ខណ៍ស្រី ៗ

ស្រី

សូមប្រាប់ឱ្យជាក់កុំលាក់អ្វី
ឱ្យខ្ញុំដឹងក្ដីតាមតម្រាយ ៗ

ប្រុស

ជាក់ពិតប្រាកដមិនមែនក្លាយ
ជាប់សែស្រឡាយពីនាយមក ៗ
ណា៎ប្អូនត្រាណត្រើយពៅពន្លក!
ឆ្លើយឆ្លងទៅមករកប្អូនស្រី ៗ
សូមមាសស្នេហ៍ស្នងប្រាប់មកខ្ញី
ស្រុកខ្មែរឈ្មោះអ្វី? ប្រាប់ផងណា៎ ៗ
មុខស្រស់ប្រិមប្រិយប្រាប់ទៀមរ៉ា

ចំណែកមាតានឹងបិតា   មាននាមយ៉ាងណា ? ប្រាប់ទៀមផង ។
មួយទៀតសញ្ជាតិនាងជាអ្វី ?   ចូរប្រាប់ឆាប់ខ្មីកុំផ្សងផ្សង
ប្រាប់ទាំងសាវតារជាតិទៀតហោង   សោះនឹងសួរសងជាច្រើនគ្រា ។

ស្រី

ប្អូនស្ដាប់សំដីប្រុសវរមិត្រ   សាកសួរពិនិត្យទៀងនាមា
ប្អូនសូមឆ្លើយប្រាប់ឥតរួញរា   តាមវគ្គតាមឃ្លាណ៌ាទៀមរ័ក ! ។
ប្អូនឈ្មោះ (ថុល្លា) ពិតប្រាកដ   បិតាសន្មតឱ្យជៀងជាក់
សព្វថ្ងៃខ្ញុំនៅក្នុងសំណាក់   បិតាពំនាក់ពុំឃ្លៀងឃ្លាត ។
ខ្ញុំមានអាយុដប់ប្រាំឆ្នាំ   ត្រូវតាមចំណាំបញ្ជីជាតិ
នៅភូមិថ្មសព្វបជុំញាតិ   ឥតមុសាវាទគេចកែបែរ ។
ក្នុងឃុំស្វាយប្រជុំស្រុកស្វាយទៀង   ខែត្រសោតទាត់ទៀងស្វាយទៀងដែរ
មានស្ទឹងទន្លេនៅជិតក្បែរ   ពីដើមយើងខ្មែរហៅរំដួល ។
បិតាខ្ញុំឈ្មោះ (ធម្មសេរី)   ចេះពាក្យសំដីពីរោះស្រួល
វាចារាបសាមិនអាក់អួល   ស្ដីតាមទំនួលមានវោតវគ្គ ។
មាតាខ្ញុំឈ្មោះ (សុបិយា)   ត្រូវតាមត្រមាប្រាកដជាក់
ខ្ញុំជាតិជាខ្មែរសែសដូចអ្នក   ឥតភូតឥតលាក់ឥតក្លែងក្លាយ ។

ប្រុស

បងស្ដាប់បានហើយចម្លើយស្រី   ឆ្លើយមកខ្លី ៗ មិនវែងឆ្ងាយ
តែបងសើទើសួរឆោមឆាយ   ឱ្យប្អូនបរិយាយប្រាប់សេចក្ដី ។
ដែលនាងសាកសួរដេញដោលខ្ញុំ   សព្វស្រុកខែត្រឃុំគ្មានខ្វះអ្វី
តើនាងក្រមុំចង់បេតី   ឱ្យងាយប្អូនស្រីទៅរកបង ?

ស្រី

ខ្ញុំសូមជំរាបដល់អ្នកប្រុស   អ្នកស្មាននេះខុសទេស្នេហ៍ស្នង
គឺស្រីចោទសួរដោយបំណង   ដើម្បីអ្នកផងពិចារណា ។
ពីព្រោះនារាស្ត្រខ្មែរយើងសព្វថ្ងៃ   នៅល្ងង់ច្រើនក្រៃអាប់ប្រាជ្ញា
អ្នកខ្លះលំនៅដែនអាត្មា   ពុំដឹងយ៉ាងណាឱ្យប្រាកដ ។
ចួនកាលរាជការមានការគួរ   ត្រូវហៅខ្លួនសួរតាមកំណត់
ប្រាប់ផ្ទុយត្រឡប់ខុសបែបបទ   មិនត្រូវសន្មតតាមតែស្មាន ។
យកស្រុកជាភូមិភូមិជាស្រុក   ខែត្រឃុំអុកឡុកប្រួសដើមដាន

នឹងយកជាការផងពុំបាន   នាំឱ្យរំខានខាតវេលា ។
ចួនកាលសរសេរសំបុត្រខុស   ផ្ញើតាមផ្លូវប៉ុស្តិ៍ទៅគ្នីគ្នា
កាខ្ទងសំបុត្រដាក់នាមា   ឃុំស្រុកវគ្គឃ្លា ខុសទំនង ។
ប៉ុស្តិ៍កមិនឃើញតាមឈ្មោះពិត   ទាល់អស់បើគិតតាំងដេរផង
អាអន្តរធាននាំមួម៉ង   ហែកចោលតែម្តងកុំឱ្យធ្លាប់ ។
ខ្ញុំសួរសៀតសឹកដោយឧបាយ   ដេញដោលដែលបខាយឱ្យងាយស្តាប់
គឺឱ្យអ្នកផងយកតម្រាប់   គ្រាន់ទុកជាច្បាប់តវែងឆ្ងាយ ។
ខ្ញុំយល់ប្រយោជន៍ដូច្នេះឯង   បានជាខ្ញុំថែងថ្លែងបរិយាយ
សូមអស់លោក - អ្នកផងទាំងឡាយ   ស្តាប់ពាក្យអធិប្បាយខ្ញុំឱ្យជាក់ ។
ខ្ញុំសួររឿងនេះអីចេះទេ   កុំប្រុសមាសមេគិតចង់ស្ទើគ
កុំនឹកស្មានហួសប្រជ្រួសណាអ្នក !   កុំអាលផ្អើលភ្ញាក់ដោយតណ្ហា ។

ប្រុស

សាធុប្អូនស្រី! ស្រដីប្លែក   ពីរោះចំឡែកឥតឧបមា
ហេតុតែខ្លួនល្អងបានសិក្សា   ស្តីទៀងកាលណាបានជាច្បាប់ ។
ស្តីនេះចំជាត្រូវប្រាកដ   តាមដោយបែបបទរាជប្រញ្ញត្តិ
គួរណាស់អ្នកផងយកតម្រាប់   ទុកជាសណ្តាប់តរៀងទៅ ។
រឿងសួរអាយុរហូតជាតិ   បងប្រាប់នាងនាថគ្មានសល់នៅ
ចង់សួរអ្វីទៀតណាស្រីពៅ !   សួរចុះឆោមឆ្លៅកុំរួញរា ។

ស្រី

ខ្ញុំសូមជំរាបដល់អ្នកបង   ដែលបានឆ្លើយឆ្លងរឿងនានា
ឃើញថាពូជពង្សជាតិដូចគ្នា   បងជាពលរដ្ឋប្រទេសអ្វី ? ។

ប្រុស

បងជាពលរដ្ឋកម្ពុជា   មិនមែនចាមជ្វាទេណាស្រី !
កូនខ្មែរមានពូជមានឈ្មោះល្បី   ចេះអត្ថបាលីបកប្រែបាន ។

(ចម្រៀងជាតិនិយម, ភាគ ១, វគ្គ ២, ទំព័រ ១២ - ២៨)

អាយ៉ៃទី ១

Introductory Note

អាយ៉ៃ a kind of folk music involving a musical dialog between a man and a woman

ភាគ part, section (here: volume)

វគ្គ /weəq/ chapter, part, section, verse, paragraph (here: chapter)

គំរូ model, example

ប្រជាប្រិយ folk, popular (i.e. of the people), traditional

មានថែមទាំង even (to the extent of)

ចាក់ to play (phonograph, tape recorder)

វិទ្យុជាតិ National Radio (State-owned station)

សិល្បករ artist

វាងវៃ keen, sharp

ចំណាន skillful, talented

ប្រឌិត to create, invent

ព្រាង to draft, to compose

...ទុកជាមុន beforehand

ដោះ to resolve, to solve

ប្រស្នា enigma, philosophical problem, abstract question

ដោះប្រស្នា to elucidate a philosophical problem

អត្ថន័យ /qatthəniy/ meaning, significance

Text

ស្រីអើយ! ស្រីស្រស់ Oh, [My] Charming Girl

អង្គ /qaŋ/ body (Lit, Complimentary; normally specifier for sacred persons and Buddhist images)

ល្អអស់អង្គ lovely in every detail (lit: the whole body is pretty)

វង់ភក្ត្រ /wŭəŋ-pheəq/ face (Lit)

ផូរផង់ soft, smooth, fine, beautiful (of complexion)

ហ្មងសៅ (=សៅហ្មង) unclean, impure, offensive

ឆោម figure, body

ឆ្លោ beautiful

ឆោមឆ្លោ [My] Beautiful One

ពៅ youngest sibling; used here as affectionate term of address

ដើររកទៀត to look further (for a partner)

កនិដ្ឋា (=ប្អូនពៅ) youngest sibling (Lit)

ទាន់ while still, in time for

សាវ៉ា irresolute, fickle

រង់ to wait

ផ្ដោះផ្ដង to hint, imply, express one's intentions indirectly

ប្រកែក to object, argue, refuse

ឱ្យអស់សង្ស័យ to dispel one's doubts

ញាតិ our friends (i.e. the audience; lit: relatives)

ចាំចេះ to know, be informed

(ភូមិន្ទ) (the name is included in parentheses to indicate that the singer may substitute his own name)

កំណត់ decision, prescription

ហោរា (=ហោរ) /haoraa/ astrologer

គប្បី /koəpbəy/ auspicious, appropriate, proper

ភូត to lie, prevaricate

កុហក /kohaq/ to lie, prevaricate

ក្រឹត្យ law, rule, precept

ខុសក្រឹត្យក្រម to be against the law, be a transgression

ស្នេហ៍ស្និទ្ធ to be deeply in love (Lit)

ប្អូនស្នេហ៍ស្និទ្ធ [your] beloved younger sister (used here to refer to herself)

ជាក់ truly, really; exactly, precisely

វរល័ក្ខណ៍ /wɔɔleəq/ high virtue (here: [My] Virtuous [One])

កន្លង surpassingly, exceedingly, very

ភរភូត (= ភូតភរ) to lie, prevaricate

នួន fair, beautiful (of complexion)

ល្អង powder, pollen, dust

នួនល្អង [My] Fair [One], [My] Exquisite [One]

សាក់សំពៅ place name

ជីវា (= ជីវៈ) term of endearment; lit: [My] Life

វិសាល spacious; admirable, meritorious

សមគួរដល់កាលដែលសន្យា as you promised (lit: in accordance with the time [when you] promised)

(សិរីវ័ឌ្ឍ) /serəywoət/ personal name

ទៀងទាត់ precise, exact; really, truly

ទ្វេហា (= ទ្វេហារ) both (lit: two persons)

(សុកណ្ឋា) /sokkɑnthaa/ personal name

តម្រា manual, formulae

ទាយល័ក្ខណ៍ស្រី to analyze feminine qualities (based on visible characteristics)

តម្រាយ path, passage (from /triəy/ to clear a path)

ខ្មែរនគរវត្ត pure Khmer (lit: Khmer of Angkor Wat)

ក្លាយ changed, adulterated, mixed

សាវតា /saawədaa/ history, record

វង្ស patronym, lineage

វង្សស្រឡាយ lineage

តពូជ...ពីនាយមក lineage goes back many generations in unbroken line

ត្រាណត្រើយ support, comfort, refuge, consolation

ប្អូនត្រាណត្រើយ Younger [Sister], [My] Consolation

ពៅពន្លក [My] Tender [One] (lit: tender youngest sibling)

សៀត to insert, stick in, wedge apart, pry apart

សក to insert (into a preëxisting hole)

សួរសៀតសក to interrogate, pry into

ស្នេហ៍ស្នង to be deeply in love (here: beloved)

ខ្មី immediately

និម្មល /nimmuəl/ perfect, faultless

ពិសី precious

រៀម elder brother

រ៉ា euphonic final particle (to rhyme with /naa/; Lit)

ផ្សួនផ្សង to hang back, hesitate, delay, wait around

សោះនឹង so not to (here: so [I] won't have to)

សួរសង to ask again

វរមិត្រ /wɔɔ-mɨt/ [My] Esteemed Friend

នាមា name (នាម + ា ; a device frequently used for rhyming purposes)

រួញរា to be reluctant, hang back, hesitate

តាមវគ្គតាមឃ្លា point by point, by chapter and verse (lit: by stanza and phrase)

រ័ក lovely, beloved

(ធុល្លា) /thollaa/ personal name

សន្មត /sɑnnəmɑt/ agree (to), decide (to)

ជៀងជាក់ clear, precise, exact (here: really, truly)

សំណាក់ refuge, shelter, place to stay

នៅក្នុងសំណាក់ be under the care of

ពំនាក់ care, protection, guardianship (here: protects)

ឃ្លៀងឃ្លាត to be absent, away from, separated from

ពុំឃ្លៀងឃ្លាត vigilantly

ចំណាំ memory, recollection (here: record, what is recorded)

បញ្ជីជាតិ birth certificate

ថ្មស /tmαα sαα/ place name (lit: White Stone)

ចួបជុំ (=ជួបជុំ)

ចួបជុំញាតិ in the midst of [my] relatives (Poetic)

មុសា to lie, prevaricate; untrue, false

វាទ (=ពាក្យ)

មុសាវាទ to lie, prevaricate

គេចវៀកវៀរ to evade, elude, equivocate, hedge

ទាត់ទៀង (=ទៀងទាត់) true, exact

ទំដួល name of [her] village

រាបសា polite, circumspect, proper

អាក់អួល to stammer, stutter

ទំនួល ease, fluency, smoothness

វេវាត (=វគ្គ) stanza, paragraph, clause

មានវេវាតវគ្គ well organized (of speech, writing, etc.)

(សុបិយា) /soppeqyaa/ personal name

ក្លែងក្លាយ to falsify, adulterate, hedge

សើរើ to probe deeply, get to the bottom (of something)

ឆោមឆាយ beautiful (here: [My] Beautiful [One])

ដែល that, the fact that

ដេញដោល to pursue (a question), importune, press (for information), quiz

បេតី /paetəy/ to love (Lit)

អ្នកផង people, others, the public

លំនៅនៃអាត្មា one's own address

ការគួរ some business or other, item of business

សួរតាមកំណត់ ask for precise [information]

ប្រាប់ផ្ទុយត្រឡប់ say [just] the opposite

ខុសបែបបទ wrong, improper

អុកឡុក confused, mixed up

ប្រាស away from, different from

ដើមដាន origin, beginning, original [facts]

យកជាការ to rely on, depend on, have confidence in, take seriously

សរសេរសំបុត្រខុស to address letters incorrectly

កា to address a letter

ខ្នងសំបុត្រ the address side of an envelope (in Cambodian this is considered to be the 'back' of the envelope)

វគ្គឃ្លា form, arrangement (of speech or writing)

ខុសទំនង improper, incorrect

ទាល់ stalled, stymied, stumped

អស់បើគិត perplexed, nonplussed, bewildered

អាអន្តរធាន /qaa-qαndαα-thiən/ you idiot!, damn you! (lit: may you be ruined!)

មួម៉ង furious, irritated

ហែក to tear

កុំឱ្យធ្លាប់ that'll teach [him], so [he] won't do it again

តម្រាប់ example, model, sample

អីចេះ (=ដូច្នេះ ; Coll)

ប្រុសមាសមេ [My] Dear Sir

ប្រជួស to go beyond, go too far, overstep, make a mistake

ផ្អើលភ្ញាក់ be excited, exercised, have one's hopes up

សាធុ fine, so be it, amen!

ប្រដី to speak, say

ស្ដីទៀងកាលណាព្ធនជាច្បាប់ everything [you] say is examplary, your words are like pearls of wisdom

រាជប្រញ័ត្តិ /riəccəprañap/ (=/riəccəpaññat/) royal order

តាមដោយរបៀបបទរាជប្រញ័ត្តិ consistent with the royal order

គួរណាស់អ្នកផងយកតម្រាប់ people should really take [it] as an example

នាថ master, chief

នាងនាថ [My] Mistress (in the sense of 'boss, superior')

ពលរដ្ឋ /pŭəl-rŏət/ citizenry, population (here: citizen)

មានពូជ be of good breeding, of respectable background

ឈ្មោះល្បី (= ល្បីឈ្មោះ)

អត្ថ /qatthaq/ meaning, significance

បក to translate (Coll)

១៥. អាយ៉ៃ (ទី ២)

ដោយ

អាចារ្យ ឈឹម - ស៊ុម

(បទពាក្យ ៨)

អត្ថបទ

ស្រី

ខ្ញុំសួរពី គ្រូបង្រៀន គ្រូបង្ហាត់
ឬដែលចាត់ ឱ្យខ្ពស់ទៅ ហៅអាចារ្យ
ហៅបណ្ឌិត ហៅអ្នកប្រាជ្ញ តាមមុខងារ
តើមានការ ដូចម្តេចខ្លះ ជាករណីយ?

ប្រុស

នួនអើយនួន! ល្អនវរល័ក្ខណ៍ ស្តាប់សួរបង
ដោយបំណង ចង់ចែងការ អាថ៌សេចក្តី
គ្រូអាចារ្យ មានកិច្ចការ ជាករណីយ
តាមបាលី លោកសំដែង មានច្រើនយ៉ាង ។
គឺត្រូវខាត់ បង្ហាត់ខ្លួន កុំឱ្យឃ្លាត
កុំវង្វាត ពីវិជ្ជា ច្បាប់សំអាង
រៀនឱ្យចេះ ធ្វើឱ្យជាក់ ជាភ័ស្តុតាង
ជាសំអាង ឱ្យអ្នកក្រោយ ដោយសារខ្លួន ។
ហើយត្រូវខំ កុំសម្ងំ ចេះតែឯង
ត្រូវសំដែង ថ្លែងបង្រៀន កុំលាក់ពួន
ស័ព្ទពាក្យពេចន៍ អាថ៌សេចគ្រេច គ្រប់ទាំងក្បួន
ត្រូវបន្ទួន ផ្ទួនបន្ថែម កុំបន្ថយ ។
មើលបន្ថែ ក្បួនប្រាជ្ញប្រែ ប្រឹងបន្ថំ
កុំប្រចទ្បំ នាំប្រចទ្បាស ផ្តាសឱ្យស៊យ
ការសង្ស័យ ត្រូវដឹកដៃ ឱ្យញយ ៗ
នាំទៅឱ្យ ស្គាល់វិនាស ស្គាល់ចំរើន ។

ស្រី

បងអើយបង! អ្នកសារសង គួរសង្ស័យ

សូមប្រុសថ្លៃ អ្នកថ្លាថ្លែង ឲ្យបានច្រើន
ផ្លូវវិនាស អសារបង់ មិនចំរើន
តើមានច្រើន ប៉ុន្មានយ៉ាង យ៉ាងណាខ្លះ ?
គ្រូអាចារ្យ អ្នកដឹកដៃ ដែលនាំផ្លូវ
ឲ្យបានត្រូវ ស្គាល់វិនាស ជួបប្រទះ
ក្តីវេចវិល ហិលហិនហោច ខូចស្រឡះ
ឬមានះ នាំយ៉ាងណា ជាករណីយ ?

ប្រុស

ទេតូចតន់ ! កុំអាលភ័ន្ត គំនិតស្មោះ
មិនដូច្នោះ ទេមិត្តម៉ុម មាសពីសី
គ្រូអាចារ្យ មានកិច្ចការ នាំប្រុសស្រី
ឲ្យចៀសក្តី វិនាសទាំង ៤ ប្រការ :

១. គឺល្បែង លេងស្រីប្រុស ខុសក្រមក្រឹត្យ
២. ចូលចិត្ត ជិបមេរ័យ ឬសុរា
៣. គឺលេង ល្បែងស៊ីសង ល្បែងវាសនា
៤. ហ៊ីហា មានពួកម៉ាក មិនគប្បី ។

ផ្លូវលាមក ទាំងបួនបែប នេះឯងពិត
ពួកបណ្ឌិត ពិនិត្យចាស់ ជាផ្លូវក្តី
វិនាសបង់ លង់ប្រយោជន៍ ទាំងប្រុសស្រី
ជាករណីយ គ្រូអាចារ្យ ត្រូវចៀសចាក ។
ហើយចរចា ប្រាប់គ្នីគ្នា ជាសិស្សគណ
គ្រប់ដំបន់ ដំបូន្មាន កុំឲ្យស្រាក
នាំពន្យល់ ប្រាប់ហេតុផល ទាល់តែងាក
ទាល់តែលាក ចិត្តលះលែង ហើយស្វែងច្បាប់ ។
គ្រូអាចារ្យ មានកិច្ចការ ដូចសំដែង
មកនេះឯង ណ៎ាស្រីនួន ! ស្ងួនចំណាប់
នាងចំណាំ ឲ្យបានចាំ ហើយត្រងត្រាប់
នេះហើយច្បាប់ គ្រូអាចារ្យ ណ៎ាវរល័ក្ខណ៍ ។

ស្រី

ប្រុសអើយប្រុស ! ប្រាជ្ញប្រសើរ ប្រសប់ថ្លឹង
ឃើញច្បាស់ទែង ចែងទៀងទាត់ ប្រាកដជាក់
ប្អូនសូមសួរ ជាសំនួរ តាមពាក្យអ្នក
ព្រោះត្រង់វគ្គ ក្តីចំរើន ពុំទាន់ច្បាស់ ។
គ្រូអាចារ្យ ត្រូវដឹកនាំ ពួកប្រជា -
ជនគ្រប់គ្នា ឲ្យស្វះស្វែង យ៉ាងរហ័ស
ផ្លូវប្រយោជន៍ មានប៉ុន្មាន ប្រាប់ឲ្យច្បាស់
ចង់ដឹងណាស់ កិច្ចទាំងនេះ ណ៎ាអ្នកថ្លៃ ។

ប្រុស

ថ្លើមអើយថ្លើម! ឆ្នើមនារី ពិភពលោក
ដេញឲ្យគោក ចង់ឲ្យគើល ឬចរណៃ
ឬចង់ចេះ ចំណេះនេះ មែនស្រីថ្លៃ
សូមចរណៃ នាងចាំស្តាប់ ស័ព្ទសត្យា ។
ផ្លូវប្រយោជន៍ ក្តីចំរើន មានពីរយ៉ាង
មានសំអាង តាមគម្ពីរ ព្រះទេសនា
គឺប្រយោជន៍ បច្ចុប្បន្ន ទាន់នេត្រា
ហើយនឹងមហា ប្រយោជន៍ធំ ផ្លូវបរលោក ។
តាមច្បាប់ លោកចែងញែក ចែកមាត្រា
ប្អូនមាតិកា ទាំងពីរផ្នែក ចែកប្រយោគ
គឺប្រយោជន៍ នាលោកិយ នឹងបរលោក
ចែកប្រយោគ មានប្អូន ៣ ជាប្រាំបី ។

ស្រី

បងអើយបង! អ្នកសារសង គួរសរនា
តែវាចា ពាំសម្បុក ឆ្លុកសេចក្តី
ប្អូនខាងអាយ ប្អូនខាងនាយ ជាប្រាំបី
ផ្លូវលោកិយ ថាមានប្អូន តើយ៉ាងណា ?

ប្រុស

យ៉ាងនេះនែ! អ្នកមាសស្នេហ៍ នាងចាំស្តាប់

បងស្រាយប្រាប់   តាមគន្លង ,   ព្រះពុទ្ធដីកា
ទី ១. គឺ   ត្រូវខំប្រឹង   ហាត់សិក្សា
រកទ្រព្យា   ធ្វើការងារ   កុំទំរន់ ៗ
ទី ២. គឺ   ត្រូវរក្សា   វិជ្ជាទ្រព្យ
កុំឈោប់   ឱ្យអភ័ព្វ   ភ្លេចបាត់ធន
ទាំងវិជ្ជា   ទាំងទ្រព្យា   គួរគយគន់
ជានិរន្តរ៍   កុំឱ្យភ្លេច   កុំឱ្យបង់ ៗ
ទី ៣. គឺ   ត្រូវចែលក   យកចេញចាយ
កុំខ្ជះខ្ជាយ   តាមជំនោរ   ជោរតាមចង់
ឃើញចំណេញ   ចេញចាយទៅ   ទើបមិនបង់
មិនបាត់ទ្រង់   វង្សអ្នកប្រិត   គិតប្រយោជន៍ ៗ
ទី ៤. គឺ   ប្រុងប្រយ័ត្ន   ប្រវែងកាយ
កុំសប្បាយ   នឹងពួកមិត្ត   គំនិតហោច
នាំលេងស្រី   ចែលផឹកស្រា   ការអសោចិ៍
អ្នករុងរោចន៍   ត្រូវរាប់រក   យកជាគ្នា ៗ
ផ្លូវទាំងបួន   តាមចំនួន   នេះប្រិមប្រិយ
នាលោកិយ   អ្នកណាចេះ   អ្នកនោះជា
អ្នកណាកាន់   អ្នកនោះកើត   គាប់ណាស់ណា
អាចរិយា   ត្រូវនាំសិស្ស   តាមផ្លូវនេះ ៗ

ស្រី

ទៀមអើយទៀម!   អ្នករ៉ាយរ៉ាប់   ប្រាប់សេចក្តី
ផ្លូវលោកិយ   គាប់ប្រសើរ   ប្រសប់ម្ល៉េះ
បើតែម្លឹង   ខ្ញុំខំខឹង   ធ្វើអ្វីអេះ
ហេតុដូច្នេះ   សូមសួរផ្លូវ   បរលោកទៀត ៗ
តើអ្នកទាល់   ឬអ្នកឆ្ងល់   យល់ពុំឆ្ងាយ
ឬល្មមស្រាយ   ឱ្យស្រទ្បះ   ជ្រះសោះជ្រៀត
ផ្លូវបរលោក   សេចក្តីជ្រៅ   ផ្លូវចង្អៀត
ខ្ញុំសួរទៀត   ថាមានបួន   តើដូចម្តេច?

ប្រុស

ម្ដាយអើយម្ដាយ!　កុំមើលងាយ　ថាក្រែងទាល់

បើនាងឆ្ងល់　ហើយនិម្មល　នាងសួរល្ងួច

បងនឹងឆ្លើយ　ឲ្យអស់ហើយ　សព្វសេចក្រេច

តែពាក្យពេចន៍　ប្រែជាបន្តិច　ហើយសោភ័ណ ។

១. សទ្ធា　សម្បទា　តួចេតនា

ចិត្តជ្រះថ្លា　ជាសទ្ធា　យ៉ាងគ្រប់គ្រាន់

ការជឿជាក់　ចិត្តជឿជាប់　យ៉ាងជាក់ស្បាន់

ចិត្តប្រកាន់　ថាមានបុណ្យ　មានទាំងបាប ។

បុណ្យកុសល　តែងឲ្យផល　មកជាសុខ

សេចក្ដីទុក្ខ　អកុសល　ឲ្យដរាប ៖

បើចង់ល្អ　កុំត្រដរ　ចង់ធ្វើបាប

ខ្លាចថោកទាប　ត្រូវធ្វើបុណ្យ　សុន្ទរីទានទៅ ។

២. សីលៈ-　សម្បទា　ជាតួចិត្ត

តួគំនិត　ការប្រព្រឹត្ត　មិនមានសៅ-

ហ្មងមោះមឹម　ទៅលើកី　ទោសៈក្ដៅ

ប្រព្រឹត្តទៅ　ត្រូវត្រង់ផ្លូវ　សីលសិក្ខា ។

៣. ចាគៈ-　សម្បទា　ជាតួចិត្ត

មិនស្វាញស្វិត　ឥតកំណាញ់　កាញ់ទ្រព្យា

ចេះបរិច្ចាគ　ធនចេញជួយ　ជននានា

សាងសាលា　ប្រទេសជាតិ　ឲ្យចំរើន ។

៤. បញ្ញា　សម្បទា　ជាបំផុត

ញាណបរិសុទ្ធ　ស្គាល់គុណទោស　ទោះតិចច្រើន

ស្គាល់ទាបខ្ពស់　ស្គាល់វិនាស　ស្គាល់ចំរើន

គួរទទើន　ឬដកថយ　ឲ្យយល់ច្បាស់ ។

ផ្លូវប្រយោជន៍　បរលោកនាយ　បួននេះហើយ

មាសម៉ុមអើយ!　ប្រយោជន៍នេះ　ប្រសើរណាស់

គ្រូអាចារ្យ　ត្រូវពន្យល់　ឲ្យជាក់ច្បាស់

ទាំងក្មេងចាស់ គង់ប្រទះ ក្ដីចំរើន ៗ

(ចម្រៀងជាតិនិយម , ភាគ ១ , វគ្គ ៤, ទំព័រ ៦៤ - ៧៣)

អារីយ៍ទី ២

ឬដែលចាត់ឲ្យខ្ពស់ទៅ or to put it in more elevated [terms]

ករណីយ /kaqrənəy/ duty

នួន fair, beautiful (complexion)

នួនអើយនួន Oh, [My] Fair [One]!

លួន to pamper, treat tenderly (here: pampered, innocent)

វរល័ក្ខណ៍ /wɔɔleəq/ high virtue

លួនវរល័ក្ខណ៍ [My] Innocent [One]

ស្កាត់ to intercept, interrupt

ថែង to tell, explain, clarify

អាថ៌ hidden meaning, subtlety; substance; beginning

វង្វាត to deviate, stray from

វិជ្ជា (here: knowledge, learning)

សំអាង to rely on, count on, depend on; model, proof, evidence

ច្បាប់សំអាង (= សំអាងទៅលើច្បាប់)

ភ័ស្តុតាង proof, example, witness

ផ្អាយសារ depend on, rely on

សេចក្រេត substance, essence, hidden meaning

បន្ទួន to repeat, to do repeatedly

ផ្ទួន to repeat

បន្ថែម to add, supplement

បន្ថែន to take constant care of (here: carefully, vigilantly)

បន្ទំ to rush, hurry (tv); here: diligently

មើលបន្ថែន --- ប្រឹងបន្ទំ (= មើលថែ --- ប្រឹង ទៀង) (the words បន្ថែន and បន្ទំ are used for alliteration and symmetry with the words /bɑnthuən/, /bɑnthaem/, and /bɑnthɑɑy/ in the preceding line)

ប្រឡាស to deviate, to go astray

ផ្ដាស lax, careless

ស៊យ unlucky

កុំប្រឡំ --- ឲ្យស៊យ Don't be confused; [otherwise it will] lead [you] to misrepresent [the cbap] with unfortunate [results].

ការសង្ស័យ [when there is] doubt

ដឹកដៃ to lead by the hand

ស្គាល់វិនាស ស្គាល់ចំរើន to recognize [what] is destructive [and what] is beneficial

សារសង (= ឆ្លើយ)

អ្នកសារសង គួរសង្ស័យ your answer is vague (lit: you answer [but it is still] doubtful)

ថ្លាថ្លែង to say, expound, elucidate

អសារបង់ futile, useless

វៃ to manage, manipulate, find a way to

ទេចរិល worn out, deteriorated

ទិល dull, blunt

ទិនទោច ruined, destroyed, obliterated, in ruins

ស្រឡះ clear, unobstructed; here: completely

ក្ដី...ខូចស្រឡះ complete destruction,

rack and ruin (/kdəy/ nominalizes all the essentially synonymous av's that follow)

មានះ stubbornness, heedlessness, recalcitrance; stubborn, heedless, recalcitrant

តន់ precious

តូចតន់ [My] Precious Little [One]

កុំអាល don't yet

ភ័ន្ត /phoən/ to be mistaken, make a mistake

គំនិតឡោះមិនដូច្នោះ that's not the right idea

ម៉ុម (= ក្រមុំ)

ពិសី (= ប្រសើរ, ពិសេស, ថ្លៃថ្លា)

មាសពិសី [My] Dear, [My] Beloved (lit: precious gold)

ចៀស to avoid, stay away from

១. គីល្បែង must be read /muəy kɨɨ lbaeŋ/ to conform to the ពាក្យ ៩ meter (q.v.)

លេងស្រី to chase women

លេងស្រីប្រុស be promiscuous

ក្រម /krαm/ law, rule, decree

ក្រឹត្យ decree, regulation

ក្រមក្រឹត្យ law, decree

ជិប to sip, to taste (here: to drink)

មេរ័យ (= ស្រា)

ស៊ី to win (in gambling)

សង to pay

ល្បងវាសនា to test one's luck, to tempt fate

ល្បែងស៊ីសងល្បងវាសនា gambling

ហ៊ឺហា ostentatious, extravagant

គប្បី /koəpbəy/ proper, appropriate

លង់ to sink

ចៀសចាក (= ចៀស)

ចរចា /cαα-caa/ to talk, discuss

គណ (= ពួក, ក្រុម) /kun/

ស្រាក to slacken, abate

កុំឱ្យស្រាក relentlessly

ហេតុផល consequences (i.e. cause [and] effect)

ងាក to turn away, change (here: change [their ways])

ណាក to turn away

ណាកចិត្ត to change one's idea, have a change of heart

លះលែង (= លែង) to abandon, give up [bad practices]

ស្វែង to seek after, search for, study

ចំណាប់ exceedingly, the most, in the extreme

ចំណាំ to keep in mind, (deliberately) remember, commit to memory (as opposed to /cam/ 'to remember, recognize')

ត្រង to collect, gather, catch

ត្រាប់ to follow, imitate

ត្រងត្រាប់ to follow, accept, imitate

ទំង (intensifier for ច្បាស់, ភ្លឺ, ក្រហម)

ទៀងទាត់ accurately, precisely

ត្រង់ទិគ on the part of, on the subject of

ល្វះស្វែង (= ស្វែង)

ថ្លើម liver, heart, internal organ

ថ្លើមអើយថ្លើម! [My Dear] Heart!

ឆ្នើម above everything else, supreme

ដេញ to pursue

គោក ground; here: to be grounded, aground

ដេញឱ្យគោក pursue [it] to the limit, run [it] into the ground

ចង់ឱ្យគោក ឬចរណី [Do you] want to run [me] aground,

[My] Precious?

សត្យា (= ស័ត្យ, សត្យ) /satyaa/ truth

គម្ពីរ /kumpii/ the Scriptures, the (Buddhist) Bible

ទេសនា to give a sermon

នេត្រា (= ភ្នែក) (Lit)

ទាន់នេត្រា immediate, tangible, visible

បរលោក the next world, the life beyond

ចែល to apportion

ញែក to part, separate, divide

ចែលញែក to divide

មាត្រា part, section, division

ចែកមាត្រា divide [into] sections

មាតិកា important point; heading, title

ប្រយោគ statement, complete sentence; here: area, subject, idea

នា at, in, with regard to

លោកិយ this world, the temporal world

សវនា (= ស្តាប់) /sawəniə/ to listen to; ears (Lit)

គួរសវនា interesting (to hear)

ពាំ to carry in the mouth

វាចាពាំសម្បុក to equivocate, be vague (lit: speak with the mouth full of bark)

ឆ្លក spotty, flawed (as an improperly dyed cloth)

ឆ្លកសេចក្តី incomplete, spotty, random

មាសស្នេហ៍ My Beloved

ពុទ្ធដីកា /putdəykaa/ speech; to say (of Buddha or Clergy)

ព្រះពុទ្ធដីកា [what] Buddha said; words of Buddha

ទ្រព្យា (= ទ្រព្យ) /troə̆pyiə/

ទម្រន់ to feign weakness, claim to be delicate

លេលាប់ be negligent, careless

អភ័ព្វ unlucky, unfortunate

ធន /thŭən/ wealth, possessions

គយគន់ (= មើល)

និរន្តរ៍ /niqrŏən/ always, all the time

យកចេញចាយ to take [money and] spend [it]

ខ្ជះខ្ជាយ to be wasteful, extravagant

ជំនោរ vanity, gullibility, susceptibility to flattery

ជោរ flattered, susceptible to flattery

ឃើញចំណេញ [if you] anticipate a profit

ទ្រង់ (= រូប)

ញាត់ទ្រង់ to be ruined, destroyed (financially, socially, etc.)

ប្រិត economical, thrifty

ប្រយ័ត្នប្រយែង (= ប្រយ័ត្ន)

ហោច bad, degenerate, destructive

ចែល to figure, calculate, scheme

រុងរោចន៍ (= រុងរឿង) successful, respectable, well-to-do

រាប់រក consort (with), associate (with)

យកជាគ្នា to associate with each other, be friends

រាប់រកយកជាគ្នា to cultivate each other's friendship

កើត to prosper, be successful

គាប់ (= ប្រសើរ, ល្អ)

អាចរិយា (= អចរិយ, អាចារ្យ) /qaacaqriyaa/ teacher, master

រៀម elder brother (frequently used as a term of address)

ម្លឹង so, such, to that extent

បើតែម្លឹង since [you're] so...

ធ្វើអ្វី why?, what for?

អេះ (= អញ្ចេះ, ដូច្នេះ ; Coll)

ទាល់ to be stumped, stymied, stuck
ឆ្ងល់ (here: in doubt)

ស្រឡះជ្រះ (usually ជ្រះស្រឡះ)

លោះ so as not to have to, to get rid of, obviate the necessity of
ជ្រៀត to intrude, interfere, bother
ម្តាយអើយម្តាយ! Oh, [My] Mother! (used facetiously here to imply respect)
និម្មល /nimŭəl/ faultless

ឈ្លួច to squeeze, to crush

សួរឈ្លួច to press for an answer

សោភ័ណ [My] Beautiful [One]

សទ្ធា /satthiə/ religious faith

សម្បទា /sampatiə/ riches, possessions, attainments
សទ្ធាសម្បទា the possession of faith
រូប manifestation, representation (here: [whose] manifestation [is])
ចេតនា /caettənaa/ [good] intentions
ចិត្តជ្រះថ្លា sincere, pure, unreserved
ជាក់ fully (here: without reservation)
ជាប់ to adhere, stick to (here: firmly, tenaciously)
ស្បាន់ clear, evident

ចិត្តប្រកាន់ ថាមានបុណ្យ មានទាំងបាប believe in the existence of good deeds as well as bad deeds
កុសល /kosal/ merit, good deeds

អកុសល /qaqkosal/ bad deeds, demerit; misfortune
ប្រតដរ to persist (in), insist (on)
សុន្ទរទាន /son-tiən/ willing charity, unbegrudged gift

សីលៈ /səylaq/ virtue, moral excellence
សីលៈសម្បទា the possession of virtue
សៅហ្មង unclean, impure, offensive

មោះមែ (= សៅហ្មង)

ទៅលើ bring about, result in, involve
ទោសៈ injurious effect of bad actions
ក្តីទោសៈទក្តា misery and strife

សីលសិក្ខា (= សិក្សាសីល) /səl-sekkhaa/ pursuit of virtue

ចាគៈ /caakeəq/ liberality, generosity, munificence
ចាគៈសម្បទា the possession of generosity
ស្វាញ្ញិត stingy, miserly

កំណាញ់ stingy, miserly

កាញ់ to be thrifty, frugal (with)
បរិច្ចាគ to contribute, sacrifice

បញ្ញា /paññaa/ intelligence, reason, wisdom, insight, knowledge
បញ្ញាសម្បទា the possession of wisdom
ញាណ wisdom, intelligence, knowledge
បរិសុទ្ធ /baarisot/ clean, clear, pure, perfect
ស្គាល់ទាបខ្ពស់ to know [what things, actions, etc. are] mean [and what are] admirable
ទទើន (= តទើន) repeatedly (here: be persistent)
ដកថយ to retract, pull back, retreat
គង់ surely, sure to, certain to

១៦. គតិលោក

ដោយ

ឥន្ទ (ឧកញ៉ាសុត្តន្តប្រីជា)

បុព្វកថា

ឧកញ៉ាសុត្តន្តប្រីជា-ឥន្ទ ជាអ្នកប្រាជ្ញខាងមគធភាសា ជាកវីនិងជាអ្នកសីលធម៌និយមខ្មែរដ៏ឆ្នើមក្នុងសម័យអាណាព្យាបាល ។ លោកបានប្រែគម្ពីរបាឡីជាច្រើន ។ លោកបានទទួលការខុសត្រូវជាច្រើននៅពុទ្ធសាសនបណ្ឌិត ហើយបានជួយរៀបរៀងវចនានុក្រមខ្មែរផង ។

ស្នាដៃរបស់លោកមានច្រើនណាស់ ទាំងពាក្យរាយនិងកំណាព្យ ។ គតិលោកជាកម្រងរឿងសរសេរជាពាក្យរាយ ដែលលោកប្រឌិតឡើងគ្រាន់ជាមធ្យោបាយទុកឲ្យជនានុជន យកមកពិចារណា ឲ្យស្គាល់នូវបញ្ហាទាំងឡាយរបស់សង្គមមនុស្ស ដើម្បីនឹងចៀសវាងអកុសលនិងសេចក្ដីវិនាសផ្សេង ៗ ។

សេចក្ដីដកស្រង់មកនេះ ជាបុព្វកថានៃគតិលោក មិនមែនជាតំណាងនៃគតិលោកឡើយ ។ ក្នុងផ្នែកនេះ លោកអធិប្បាយពន្យល់អំពីលោកធាតុវិទ្យា ។

អត្ថបទ

តម្រាគតិលោកនេះ គឺខ្ញុំបាទទីឧកញ៉ាសុត្តន្តប្រីជា ឥន្ទអ្នកតែងឡើង ដើម្បីកុលបុត្រអ្នករៀនគតិបុរាណ ជាបែបយ៉ាង គ្រាន់អាងសេចក្ដីប្រៀប នាំយកប្រាជ្ញគតិលោកថ្មីដែលកើតមានឡើង ទើបតាំងជាពាក្យបុច្ឆានិងពាក្យវិសជ្ជនាក្នុងតម្រានេះ ជាទីសណ្ដាប់ដោយងាយ ។

ដើមឡើយ កូនសិស្សសួរគ្រូថា សូមទានមេត្តាប្រោស ពាក្យដែលថា គតិលោកនោះ តើប្រែដូចម្ដេច?

គ្រូប្រាប់ថា គតិលោកនោះ ប្រែថា ដំណើរប្រព្រឹត្តទៅ របស់ជនក្នុងលោកិយនេះឯង ។

- ស. លោកសព្ទនេះ តើអធិប្បាយជាពាក្យសម្រាយ ថាដូចម្តេច?

- គ. ទុ៏លោក ជាសភាវៈដែលកើតឡើងដោយអំណាចបដិសន្ធិនៃខន្ធ គឺជាសភាវៈមិនទៀង ដោយមិនជាប់នៅមិនប្រាកដ ជាអចលនភាព, ១ទៀតប្រែថា សត្វ ផែនដី ផ្ទៃមេឃ អាកាសទូទៅទាំងអស់ , លោកនោះប្រែថា ធម្មតាសត្វ ឬរបស់ដែលប្រព្រឹត្តទៅក្នុងលោក, ឯគតិសព្ទនោះ ប្រែបានច្រើនយ៉ាងគឺថា ដំណើរទៅ ត្រឡប់មកវិញ ត្រឡឹងដំណើរ បទសេចក្តីកម្លាំងអំណាចផ្លូវ ទីពឹង ក្តីអត់ធន់ ចិត្ត កំណើត ពាក្យឯណា ហេតុឯណា វត្ថុឯណា ដែលកើតឡើងមានឡើងក្នុងលោកនេះ ហៅថាគតិលោកទាំងអស់ ។

- ស. សួរថា លោកនេះមានតែ ១ ឬមានច្រើនយ៉ាងតទៅទៀត ?

- គ. ឆ្លើយថា លោកនេះបើយោគយកគតិធម៌មកសំដែងចេញទៅទៀតនោះ មានច្រើនយ៉ាងតទៅ គឺអារម្មណ៍ទាំងពួង មានរូប ដែលឃើញនឹងភ្នែកជាដើមនោះ ហៅថារូបលោក រូបដែលឃើញដោយចិត្តជាដើមនោះហៅថា កាមលោក ដោយហោចទៅ យ៉ាងសព្វសារពើទាំងពួង បណ្តាដែលមានចិត្តគ្រប់គ្រង ព្រមនៅក្នុងសភាវបញ្ញត្តិ ។

- ស. សួរថា លោកយើងនេះ ហៅថា មនុស្សលោក ឯខាងស្ថានទេវតានោះ ហៅថា ទេវលោក ហើយចុះដូចជាមនុស្សលោកយើងនេះ បែងចេញជាស្ថានមានប៉ុន្មានជាន់ ស្ថានទេវលោកនោះ តើមានប៉ុន្មានជាន់ ?

- គ. ឆ្លើយថា សត្វក្នុងមនុស្សលោកយើងនេះបែងចេញជា ២ ជាន់ គឺសត្វតិរច្ឆានជាន់ ១ មនុស្សជាន់ ១ រួមនៅក្នុងលោកជាមួយគ្នា ។

សត្វក្នុងបរលោក បែងជា ៥ស្ថាន គឺនរកប្រេតអសុរកាយ ស្ថាន ១ ទេវតាក្នុងឆកាមាវចរសួគ៌ស្ថាន ១ រូបព្រហ្មស្ថាន ១ អរូបព្រហ្មស្ថាន ១ នៅក្នុងលោកខាងមុខទាំងអស់ សត្វក្នុងមនុស្សលោក ជាពួកមានកាយគ្រោតគ្រាត សត្វក្នុងទេវលោកជាពួកមានកាយទិព្វខ្លះ ដែលពុំមានកាយ ជាពួកសោយអារម្មណ៍ជាទិព្វខ្លះ ដែលប្រាសចាករូបខ្លះ ។

- ស. សួរថា សត្វលោកទាំងពួងដែលនឹងកើតឡើងនោះ តើអាស្រ័យធម្មជាតិអ្វីឲ្យកើត ដែលកើតនោះ តើដូចគ្នាឬខុសគ្នា?

- គ. ឆ្លើយថា សត្វលោកទាំងពួង ដែលនឹងកើតនោះ អាស្រ័យដោយបុញ្ញាភិសង្ខារខ្លះ ដែលចំណែកខាងមនុស្សលោកនេះប្រកបដោយអារម្មណ៍ដែលជាឧតុនិយម និងពីជនិយម និងកម្មនិយម ៣ ប្រការផងគ្នា ។

ឧតុនិយមនោះ បានខាងឯរបស់ធាតុ គឺជាតិដីថ្មីក្រួសរវានផ្សេង ៗ ។

ពីជនិយមនោះ បានខាងរុក្ខជាតិ តិណជាតិ ស្មៅ វល្លិផ្សេង ៗ ។

កម្មនិយមនោះបានខាងឯបសាទរូប ដែលជ្រួតជ្រាបទៅក្នុងកាយសត្វជាដើម ព្រមទាំងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ រួមអារម្មណ៍ ៣ ប្រការនេះ ផ្សំចូលគ្នាជារាងកាយ ទើបបានជាសត្វទាំងពួង ក្នុងមនុស្សលោក ។

ឯចំណែកខាងទេវលោកនោះ មានតែអារម្មណ៍ដែលជាផលនៃកម្មម្យ៉ាង គឺឱបបាតិកៈកំណើត ១ទៀត ឯផែនដី ដែលជាទីអាស្រ័យនៅរបស់សត្វ និងរាងកាយរបស់សត្វ និងសារពើទាំងពួង ក៏កើតអំពីកម្មនិយមទាំងអស់ ។

មនុស្សលោកជាហេតុ ទេវលោកជាផលសម្រាប់ក្តីរស់នៅ របស់លោកទិព្វ ។

ទេវលោកជាហេតុ មនុស្សលោកជាផលសម្រាប់ក្តីរស់នៅ របស់លោកមនុស្ស ។

- ស. សួរថា សត្វលោក ដែលកើតមកជាមនុស្សយើង ហេតុអ្វីក៏ខុសគ្នា ។

- គ. ឆ្លើយថា ការដែលប្លែកគ្នានោះ ព្រោះសង្ខារតាក់តែងដោយអំណាចបុណ្យនិងបាប ដែលសត្វកសាងមកអំពីបុព្វជាតិ សត្វទាំងឡាយ បណ្តាដែលមានចិត្តគ្រប់គ្រងនៅជាដើមនេះ ក៏ជាធម៌និងលោកផ្សំគ្នាដូចយ៉ាងធាតុទង់ហ៊្វា ដែលជារបស់កើតអំពីធាតុមាសនិងទង់ដែងផ្សំគ្នាដូច្នោះ សត្វទាំងឡាយផ្សេងគ្នាក៏ព្រោះធម៌និងលោក ដែលផ្សំគ្នានោះមានចំណែកតិចច្រើនផ្សេងគ្នា ដូចយ៉ាងសាច់ទង់ហ៊្វាដែលផ្សេងគ្នា ព្រោះធាតុទង់ដែងផ្សំគ្នានឹងធាតុមាសនោះតិចច្រើនជាងគ្នា យ៉ាងនោះឯង ចូលចិត្តឬទេ បើពុំចូលចិត្តយើងនឹងញែកកាយ ញែកចិត្ត ចេញជាលោកជាធម៌ ឱ្យយល់ក្នុងកាលឥឡូវនេះ ។

- ស. ករុណា ពុំទាន់ចូលចិត្តសព្វគ្រប់ទេ និមន្តលោកគ្រូម្ចាស់ ញែកឱ្យទានស្តាប់បាន ?

- គ. អើឯងចាំស្តាប់ហ្ន៎ា ពណ៌លឿង ៗ ដែលឆ្លុះទៅក្នុងសាច់ទង់ហ៊្វានោះ ជាជាតិមាស ពណ៌ក្រហមមួយ ៗ ក្នុងសាច់ទង់ហ៊្វានោះ ជាជាតិទង់ដែង មានឧបមាយ៉ាងណា ចិត្តរបស់សត្វ ដែល

មានសេចក្ដីចេះដឹងនោះ ជាជាតិធម៌ ឯកាយឬអារម្មណ៍របស់សត្វដែលប្រាសចាកក្ដីចេះដឹងនោះ ជាជាតិលោក សេចក្ដីនោះ មានឧបមេយ្យដូច្នេះឯង ចិត្តនេះជាជាតិធម៌ទើបពុំស្លាប់ តែកាយឬអារម្មណ៍ជាជាតិលោក ទើបត្រូវស្លាប់ជាធម្មតា មាសបរិសុទ្ធក្នុងសាច់ទង់ហ្វា នោះពុំដែលទង់ហ្វា គឺជាមាសចំណែក ១ ផ្សេង ដូចគ្នាយ៉ាងនោះឯង ហេតុនោះ ទើបសត្វលោកកើតឡើងខុសគ្នាដោយអំណាចផ្សំធាតុ គឺបុញ្ញាភិសង្ខារ ដែលជាបុណ្យនិងអបុញ្ញាភិសង្ខារ ដែលជាបាប ។

(ឥន្ទ, ឧកញ៉ាសុត្តន្តប្រីជា , គតិលោក, ភាគ ១, ទំព័រ ១-៥)

គតិលោក

Introductory Note

ឧកញ៉ាសុត្តន្តប្រីជា a conferred title /qokñaa-sottɑn-prəyciə/

ឥន្ទ /qən/ In (a famous Cambodian author and scholar)

អ្នកសីលធម៌និយម moralist, preceptor

បាលី Pali (language)

ពុទ្ធសាសនបណ្ឌិត្យ Buddhist Institute /puttəsaahsənaq-bɑndɨt/

លោកធាតុវិទ្យា cosmology

Text

តម្រា manual, text, textbook

ទី having the status, title, or position of

កុលបុត្រ /kolləbot/ children of good families (highborn sons, since girls were not traditionally educated)

គតិ /kəteq/ path, way (i.e. of conduct, morality, etc.)

បែបយ៉ាង example, model, sample

គ្រាន់អាងសេចក្ដីប្រៀប to use as the basis (of comparison)

នាំយកប្រាប់ទៅ to relate [it] to

គតិលោកថ្មីដែលកើតមានឡើង modern morality, the new morality

ទើប so, so then, consequently

បុច្ឆា /pocchaa/ to question (Lit)

វិសជ្ជនា /wihsaccəniə/ to answer (Lit)

តាំងជាពាក្យបុច្ឆានិងពាក្យវិសជ្ជនា put it in the form of a dialogue

លំដាប់ order, sequence

ជាទីលំដាប់ងាយងាយ in easily understandable order

សូមទានមេត្តាប្រោស please be good enough to, do [me] the favor of

ស. (= សិស្ស)

លោកសព្ទនេះ this word /look/

សម្រាយ explication, explanation (in common terms)

ជាពាក្យសម្រាយ in everyday language

គ. (=គ្រូ)

សភាវៈ /saphiəweə̆q/ (= /saphiəp/) condition, state, being

បដិសន្ធិ /padeqsɑnthiq/ conception, rebirth, creation, on-going cycle

ខន្ធ /khan/ (Skt. khandhā) factors conditioning the appearance of life (usually listed as five: material form, feeling, perception, coefficients of consciousness (?), and consciousness)

ទៀង precise, exact, straight-

forward
មិនជាប់នៅ elusive, impermanent

អទស្សនភាព invisibility (here: something invisible)
គ្រឿង (used here as an abstract nominalizer)
គ្រឿងដល់គ្រឿងដំណើរ arriving [and] passing on

បទ /bɑt/ way, behavior, conduct
ព្យាយាម to try, attempt, make an effort to
គតិធម៌ the Dharma

អារម្មណ៍ /qaarɑm/ thought, concern, feeling, mood (here: objects of the senses)

រូបលោក /ruupəlook/ material things, visible things, tangible form (includes objects of the first /khan/: material objects)
កាមលោក /kaaməlook/ the intangible world, world of the senses (includes objects of the last four /khan/ above)

ដោយហោចទៅ in short, to summarize, at least
សព្វសារពើ (=ទាំងអស់) /sɑp-saarəpəə/ every, all, everything
ដែលមានចិត្តគ្រប់គ្រង which are governed by feelings
ព្រម as well as

សភាវបញ្ញត្តិ /saphiəwappaññat/ intellect, state of mind
ទេវលោក /teewəlook/ realm of gods, divine beings

តិរច្ឆាន /deirəchaan/ animal (as opposed to human)
ប្រេត /praet/ demon, ogre, monster, inhabitant of hell

អសុរកាយ /qasoraqkaay/ demon, ogre, monster, inhabitant of hell
ឆ six (in Pali and Sanskrit compounds)
កាមាវចរ /kaamaawəcɑɑ/ intangible or supernatural beings

ឆកាមាវចរសួគ៌ /chɑɑ-kaamaawəcɑɑ-suə/ six-level heaven of intangible beings
ព្រហ្មស្ថាន /prumməthaan/ the realm of Brahma
រូបព្រហ្មស្ថាន /ruuppəprumməthaan/ tangible (bodied) realm of Brahma
អរូបព្រហ្មស្ថាន /qaqruuppəprumməthaan/ intangible (bodiless) realm of Brahma
គ្រោតគ្រាត rough, ugly, crude

ទិព្វ /tɨp/ magic, magical, capable of being evoked by magic
សោយអារម្មណ៍ /saoy-qaarɑm/ to enjoy feelings, have conscious experiences
ប្រាសចាក devoid of

សត្វក្នុងទេវលោក... ដែលប្រាសចាករូបខ្លះ
'[of the] beings in heaven, some have magical bodies but no [real] bodies, [while] others enjoy sensual feelings and are partially devoid of form
បុញ្ញាភិសង្ខារ /poññaaphiqsɑŋkhaa/ accumulation of merit

អារម្មណ៍ /qaarɑm/ cause, condition (esp. of life); sense, feeling
ឧតុនិយម /qotoqniyum/ natural laws of the universe; the elements
ពីជនិយម /pɨccəniyum/ natural laws of vegetable life; vegetation

កម្មនិយម /kamməniyum/ natural laws of animal life; effects of karma
ទាក់ទង consists of, has to do with
របស់ធាតុ elements

ផែនដី earth, soil

ក្រួស gravel, stone

រវ៉ាន rocky soil, sedimentary rock
រុក្ខជាតិ /rukkhəciət/ trees, forest, vegetation
តិណជាតិ /tənnəciət/ herbs, grass

វល្លិ /wɔə/ vine

បសាទ /pasaat/ sense, feeling

បសាទរូប /pasaattəruup/ the organs of perception
ជ្រួតជ្រាប to pervade, infiltrate, seep into
វេទនា sensation, feeling

សញ្ញាសង្ខារ /saññaa-saŋkhaa/ signs of life
វិញ្ញាណ /wiqñiən, wiññiən/ consciousness, essence of life, soul

ឧប្បាតិកៈ /quppəbaatekaq/ spontaneous rebirth, self-generation
មនុស្សលោក--- លោកមនុស្ស Human beings are the cause [and] divine beings the effect in the existence of the supernatural world; divine beings are the cause and human beings the effect in the existence of the natural (human) world.

សង្ខារ /sɑŋkhaa/ life, existence, cycle of rebirth
តាក់តែងដោយ is determined by, dependent on
បុព្វជាតិ /boppəciət/ past lives, former incarnations

ធម៌និងលោក moral law and human form (i.e. spirit and feeling)

ទង់ហ្វ៊ា /tŭəŋwiə/ gold alloy

ទង់ដែង copper alloy

ចូលចិត្ត (here: to understand)

ញែក to divide, part with both hands (as hair, tall grass, etc.)
ឆ្លុះ to shine, give off (light)

មានឧបមាយ៉ាងណា as for example

ឧបមេយ្យ /quppəmay/ comparison, simile
បរិសុទ្ធ /bɑrisot/ pure, unalloyed

អបុញ្ញាភិសង្ខារ /qaqpoññaaphiqsɑŋkhaa/ accumulation of negative karma, demerit

១៧ - ច្បាប់ក្រម

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

(សម្រាប់ច្បាប់ទាំងអស់)

កាលពីដើម បើគេដើរទៅជិតវត្តណាមួយ គេនឹងឮសម្លេងច្រៀងយ៉ាងក្រលួច : "កេរ្តិ៍កាលពីព្រេងព្រឹទ្ធ សាងសុចរិតទៀងទុកនៅ..." ។ នេះគឺសម្លេងកូនសិស្សវត្ត សូធ្យាយទន្ទេញ "ច្បាប់" ក្រោយដែលគេចេះ ន មោ... និង ក ខ... ចប់សព្វគ្រប់ហើយ ។ បើគេចូលទៅជិតទៅទៀត គេនឹងសង្កេតឃើញសិស្សទាំងឡាយ អាយុប្រហែលៗគ្នា អង្គុយបត់ជើងក្រញ្ញឹមៗ ដៃទាំងពីរកាន់សាស្ត្រា ហើយយកចិត្តទុកដាក់ជាទីបំផុត ។ នៅជិតនោះ មានបុព្វជិតមួយអង្គនិមន្តក្រឡឹងចុះឡើង ត្រួតត្រាមើលសិស្ស ។ បុព្វជិតនោះឯងហើយដែលជាគ្រូអាចារ្យរបស់គេ ហើយដែលគេគោរពប្រណិប័តន៍លើសមាតាបិតារបស់ខ្លួនទៅទៀត ។

"ច្បាប់" មិនគ្រាន់តែមានកន្លែងដ៏ធំទូលាយនៅក្នុងអក្សរសាស្ត្រខ្មែរទេ... តែសំខាន់ជាងនេះទៅទៀត "ច្បាប់" មានអានុភាពយ៉ាងធំទូលាយទៅលើជីវិតនៃប្រជាជនខ្មែរ គ្រប់ជាន់ថ្នាក់ ។ "ច្បាប់" ជាមូលដ្ឋាននៃសីលធម៌ខ្មែរ ។

ក្នុងសម័យបច្ចុប្បន្ននេះ កម្មវិធីសិក្សាមិនអនុញ្ញាតិឱ្យបង្រៀន "ច្បាប់" ទៅកុមារាកុមារីដែលទើបនឹងចេះអានអក្សរនោះទេ ។ គេចាត់ច្បាប់ជាអក្សរសាស្ត្រ សម្រាប់បង្រៀននៅថ្នាក់ទី ៥ ទី ៤ និងទី ៣ ទំនើបនៃមធ្យមសិក្សា ។

"ច្បាប់" ទាំងបួនខាងក្រោមនេះ យើងដាក់បញ្ចូលក្នុងសៀវភៅនេះទាំងស្រុង...តាមលំដាប់ដែលគេបង្រៀនកូនសិស្សសាលាវត្តនៅសម័យពីដើម ។

១- ច្បាប់ក្រម

២- ច្បាប់កេរ្តិ៍កាល

៣- ច្បាប់ពាក្យចាស់

៤- ច្បាប់ប្រុស

អត្ថបទ

(បទកាកគតិ)

នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឲ្យលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។

នរអ្នកណា ទោះយកអាត្មា ចូលសាសនីពុទ្ធរត្ន
ចូរធ្វើឲ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន ។

នរអ្នកផង ទោះដឹងយល់ហោង ចិត្តនោះឲ្យហ៊ាន
បំពេញព្រះផ្នួស ដោយព្រះទូន្មាន កុំធ្វើលិកលាន
ដោយចិត្តអនុពាល ។

ម្ដាយអាពុកសោតណា ស្រឡាញ់ស្ងួនភ្ងា ហៅកូនសង្សារ
អាចមកបំបួស ហេតុចង់សម្ភារ ប្រើបង់អនុពាល
រៀនដោយក្រមច្បាប់ ។

សង្វាតសរសេរ អស់អញ្ញ កុំខ្ជិល ទើបបានជាគាប់
សង្វាតសូត្ររៀន ដោយគ្រូប្រញ្ញប្ត កុំធ្វើលីលាប់
ដោយចិត្តមាក់ងាយ ។

ឱអស់សាមណេរ! ម្ដាយមកបង្វែរ អ្នកជាបាធ្យាយ
សង្វាតសូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាយងាយ
ដូចនៅគ្រហស្ថ ។

កុំធ្វើរាយមាយ នឹងគ្រូបាធ្យាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឲ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឡាយ ។

អាសូរមេបា ចិញ្ចឹមរក្សា ពុំឲ្យអន្តរាយ

អាចយកមកធ្វើ   នឹងគ្រូបាធ្យាយ   ហេតុចង់ពណ៌នាយ
ប្រយោជន៍ទាំងបី ។

មួយចង់ក្ដីច្បាប់   ឱ្យបានខ្លួនគាប់   នៅនាលោកិយ
មួយចង់ប្រាជ្ញា   មិនឱ្យអប្រិយ   មួយចង់បារមី
នាំញាតិទាំងឡាយ ។

ទីហអស់សាមណេរ   កុំធ្វើដែលដែរ   ត្រង់ក្ដីពាយងាយ
លំឱតបំរើ   អ្នកជាបាធ្យាយ   ជូនបុណ្យទៅម្ដាយ
អាពុកទីទៃ ។

សង្វាតសូត្ររៀន   កុំធ្វើអៀនប្រៀន   ក្នុងចិត្តសព្វថ្ងៃ
លំឱតបំរើ   ផ្គាប់ដោយហឫទ័យ   បានម្ភៃម ៣
ក្ដីច្បាប់កុំបីបង់ ។

ច្បាប់នេះសោតណា   ទូន្មានអាត្មា   ដោយនូវក្រិត្យសង្ឃ
ត្រង់ណាហៅច្បាប់   កាន់ខ្ជាប់កុំបីបង់   ចំណេរទៅលង់
ខ្លួនបានជាធំ ។

សព្វថ្ងៃសោតណា   ទូន្មានអាត្មា   ដោយនូវក្រិត្យក្រម
បំរើបាធ្យាយ   ឱ្យមានបារម្ភ   ទើបខ្លួនជាធំ
ទៅដល់មហាក្សត្រ ។

ច្បាប់នេះសោតណា   ទូន្មានអាត្មា   ថេរនៅពុំបាត់
ទោះខ្លួនឥតបុណ្យ   បំរើមហាក្សត្រ   គោរពប្រណិប័តន៍
យសនោះពុំលែង ។

ហេតុបាននឹងច្បាប់   បានដូចបង្គាប់   ចិត្តគ្រូយល់ស្ដែង
ទោះនឹងបំរើ   ស្ដេចជាគម្ដែង   យសនោះពុំលែង
ប្រាកដពណ៌នាយ ។

ក្ដីនេះជាច្បាប់ ឱ្យសាមណេរត្រាប់ សព្វសិលទាំងឡាយ
កុំសើចនេះដៀល អ្នកជាបាធ្យាយ អ្នកហោងស្មើម្ដាយ
បង្កើតក្ដីច្បាប់ ៗ

សាមណេរណា ៣ ទោះមានប្រាជ្ញា នឹងចង់រៀនត្រាប់
ឱ្យយកត្រចៀក នោះឱ្យចូលស្ដាប់ ធ្វើដោយក្រមច្បាប់
នៃគ្រូបាធ្យាយ ៗ

សាមណេរណាសោត ចិត្តនោះក្រេវក្រោធ ឱ្យចៀសចេញឆ្ងាយ
ច្បាប់នេះមិនខំ សាមណេរទាំងឡាយ តាមចិត្តសប្បាយ
អាត្មាទីទៃ ៗ

នរូអ្នកណា នឹងស្វែងប្រាជ្ញា ឱ្យបានខ្លួនថ្លៃ
ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្គាប់ដោយហឫទ័យ
អ្នកជាបាធ្យាយ ៗ

ទោះនឹងស្វែងធម៌ ឱ្យមានសំគាល់ កុំធ្វើរាយមាយ
ទោះនឹងស្វែងច្បាប់ កាន់ខ្ជាប់កុំបីណាយ កុំឱ្យអន្តរាយ
នៃច្បាប់ក្រមផង ៗ

ទីគ្រូបាធ្យាយ ប្រដូចទូវម្ដាយ ឱពុកឯងហោង
ហ្វឹកហ្វឺនប្រដៅ មិនឱ្យមានឆ្គង តាមដោយគន្លង
ព្រេងព្រឹទ្ធបុរាណ ៗ

នរូអ្នកណា នឹងស្វែងប្រាជ្ញា ជារស្មីប្រាណ
ឱ្យគិតជញ្ជាំង រំពឹងថែងបាន កុំធ្វើបំពាន
ប្រទូស្ដរឹងស្អង ៗ

នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង
ទោះនឹងឆ្ពោះទៅ ស្រុកតូចធំផង សឹងដូចបំណង
នៃចិត្តចិន្ដា ៗ

រីនឹងចេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្វា
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា
ឥតអ្នកដឹកដៃ ។

សូមរ្សីរកផ្លូវ ពុំដែលនឹងត្រូវ សឹងពានងព្រៃ
ហេតុដ្បិតចេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ
ដូចដល់ពុំដល់ ។

នេះដូចអ្នកផង ពុំដោយគន្លង ដែនលោកណាយល់
សឹងធ្វើមោហោ ទោសោកំហល់ ពុំអាចទប់ទល់
នាធ្ងន់នាស្រាល ។

ប្រដៅក្ដីច្បាប់ សឹងថាពុំគាប់ ហេតុចិត្តអនុពាល
ក្ដីច្បាប់ទម្ងន់ សឹងថាជាស្រាល ហេតុចិត្តអនុពាល
ចង់តែសប្បាយ ។

ពុំដឹងដើមគ្រូ បង្កើតអភិរូហ៍ ប្រដូចនូវម្ដាយ
ភ្លឺពីមនុស្សលោក រួចដល់សួគ៌នាយ ចៀសចតុរាបាយ
នរកទាំងបួន ។

នាបីហៅគ្រូ កុំធ្វើមូទូ ចិត្តនោះឱ្យស្លូន
កុំធ្វើតម្កើង ចង់ធំតែខ្លួន ក្រែងច្បាបមកជូន
នៅនាលោកិយ ។

រីគ្រូបាធ្យាយ អាចឱ្យពណ្ណរាយ មានរូបរស្មី
ហើយឱ្យរុងរឿង អស់បញ្ញាត្រិយ ស្មើព្រះជននី
ជនកសោតហោង ។

ព្រះជនកសោតណា បង្កើតអាត្មា ឱ្យមានសរិលផង
រក្សាពីតូច មិនឱ្យមានឆ្គង អស់សុខទុក្ខផង
មិនដែលនឹងឆ្អន់ ។

ព្រះជនកព្រះជននី ទេពីនឹងស្រដី ប្រសើរពេកពន់
ថាភ្នំព្រះសុមេរុ នោះហោងមហាធ្ងន់ ថាទេពីនឹងគុណនី
ពុំអាចកន្លង ។

ទីគ្រូបាធ្យាយ ប្រដូចនូវម្ដាយ អាពុកឯងហោង
អាចឲ្យក្ដីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្លង
ព្រះពុទ្ធទាំងឡាយ ។

នរអ្នកណា ទោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ
គុណនោះទាំងបី ហៅមហាទូលាយ កុំឲ្យអន្តរាយ
ក្ដីពិព្យាយាម ។

ទីបុណ្យនឹងបាប អំពើសុភាព នោះវាតែងតាម
ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសឃ្លាន
ត្រង់ក្ដីសល់វ័ល់ ។

ឲ្យគិតជញ្ជឹង ហើយឲ្យរំពឹង ប្រាជ្ញាឲ្យយល់
ឲ្យមានវិរិយំ សច្ចំកុសល កុំធ្វើសល់វ័ល់
នឹងក្ដីទុក្ខសោក ។

នរអ្នកណា នឹងនាំអាត្មា ឲ្យលាពីអធ្យោគ
វែស្វងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាបថមោក្ខ
គឺនិព្វានហោង ។

(ច្បាប់ក្រម, ទំព័រ ១ - ១១)

ច្បាប់ក្រម

Introductory Note

ច្បាប់ codes of conduct, precepts, conventional morality

ក្រលួច sharp, wafting, melodious

កេរ្ដិ៍កាល /kei-kaal/ glorious period, honorable tradition

ព្រេងព្រឹទ្ធ /preeŋ-prɨt/ ancient, former; ancient times, antiquity

តាំង...ទុកនៅ established, set down, prescribed
សុចរិត honest, moral, just, of good character
ទៀង honest, straightforward

សុចរិតទៀង good conduct, upright character, morality
កេរ្តិ៍កាល... ទុកនៅ [The rules of] good conduct have been established since the glorious periods of antiquity.
ស្វាធ្យាយ /swaatyiəy/ to learn, memorize (Lit)
នមោ beginning of the Pali syllabary (used here to refer to the vowels, as opposed to the consonants, of the Cambodian writing system)

ស្របាល ៗ គ្នា of about the same [age]
ក្រញឹម sedate, composed

បញ្ឌិត /bɑppəcɨt/ (Buddhist) monk, priest
ប្រណិប័តន៍ /prɑnebat/ to respect, to obey
មូលដ្ឋាន /muuləthaan/ base, basis, foundation
សីលធម៌ /səlləthɔə/ morality, moral law
ទាំងស្រុង completely, in [their] entirety
ច្បាប់ក្រម Code of Conventions (deals with the conventions of proper conduct of a student toward his teacher)

ច្បាប់កេរ្តិ៍កាល Code of the Glorious Tradition (deals primarily with principles of domestic economy and practical success; a kind of 'Poor Richard's Almanac')
ច្បាប់ពាក្យចាស់ Traditional Morality (a collection of pithy admonitions about successful human relations in everyday life, many of which are known and recited as proverbs)
ច្បាប់ប្រុស Codes of Conduct for Men (deals with prescriptive morality for young men in the successful conduct of family life)

Text

ច្បាប់ក្រម /cbap krɑm/ can be translated 'Code of Conventions', but in fact it deals with the conventions of proper conduct of a student toward his teacher (Camb. /kruu/ from Skt. guru).

ប្រើ (= ឲ្យ) to have (someone do something)
លំអោន to bow, stoop (there is no English equivalent of this verb, since it describes a cultural trait not common in western countries; the action consists of bowing, stooping slightly, keeping the arms close to the body and legs close together; the whole action gives the impression of trying to shrink the body or to make one's physical body inconspicuous as a sign of respect in the presence of superiors or elders)

កុំបី (= កុំឲ្យ) so as not to

ប្រណិប័តន៍ /prɑnebat/ to respect, to obey
បុណ្យ (= ស័ក្តិ /saq/) status, rank

ប្រាជ្ញាបុណ្យផង កើតដោយប្រណិប័តន៍
knowledge [and] status come through obedience
នរូ (= ជន) /nɔɔruu, nəruu/

នរូអ្នកណា whoever, anyone [who]

ទោះ (= នឹង , ទើបនឹង)

រត្ន /roət/ jewels (implies the Three Jewels of Buddhism: the Buddha, the Dharma [law], and the Sangha [priesthood])

ពុទ្ធរត្ន /puttəroət/ Buddhism

ដោយគួរ in accordance with

បន្ទាត់ rules, discipline; line,

straightedge, rule

ស្វែងសម្បត្តិ /swaeŋ sɑmbat/ to seek after the rewards, attainments (i.e. of the Path to Nirvana)

នរអ្នកផង whoever, anyone [who]

ហោង /hɑɑŋ/ euphonic final particle

ចិត្តនោះឲ្យហ៊ាន let him dare (to)

ព្រះផ្នួស ordination (as a monk)

បំពេញព្រះផ្នួស to fulfill the rites of ordination

ដោយព្រះទូន្មាន as the Buddha instructed

កុំធ្វើ don't be

លិកលាន (= លីកលាន) negligent, careless

អន្ធ (= អន្ធ /qɑntheə̆q/ or អន្ធ /qɑnthuq/) blind (with passion, desire, etc.)

ពាល brash, immature, raw (of youth)

អន្ធពាល unenlightened, worldly, wicked (from the standpoint of Buddhist ethics); worldliness, wickedness

អាពុក (= ឪពុក)

ភ្ងា beloved

លួនភ្ងា to pamper, indulge, adulate

ស្រឡាញ់លួនភ្ងា to cherish, love tenderly

សង្សារ transmigration, reincarnation; here: beloved

អាច dare (to)

បំបួស to ordain, send [one's child] into the monkhood

សម្ភារ /sɑmphiə/ accumulation of merit; to accumulate merit

ប្រើ (= ឲ្យ)

ដោយ (= តាម) to follow, obey

សង្វាត work hard (at), try hard (to), be diligent (at)

អស់អញ (= អស់ពីចិត្ត) with all one's strength

គាប់ good, proper

ប្រញ្ញប្ត /prɑñap/ (= បញ្ញត្ត /paññat/) to order, command, prescribe

លីលាប់ half-hearted, careless, negligent

ដោយចិត្តមាក់ងាយ because of a disdainful attitude

ហើ hortatory particle: Hey!, Hey there!, Now listen!, Now hear this!

សាមណេរ /saamənei/ novice monk, student monk

បង្វើ to offer, give

បាធ្យាយ /baatyiəy/ teacher, master, preceptor, mentor

ម្ដាយមកបង្វើអ្នកជាបាធ្យាយ [your] mother [having] entrusted [you to] a master

ពាយងាយ negligent, nonchalant, unconcerned

គ្រហស្ថ /krɔhoə̆h/ layman

ដូចនៅគ្រហស្ថ as if [you were] still laymen

រាយមាយ careless, negligent

ទុកស្មើអម្ចាស់ consider [him] to be [your] Master

នាំញាតិទាំងឡាយ [so you can] guide all [your] relatives

អាសូរ have compassion for

មេ (= ម្ដាយ) (Archaic; used in modern Cambodian only to refer to female animals)

បា (= ឪពុក) (Archaic; used in modern Cambodian only to refer to male animals)

មេបា parents (Archaic)

អាច to dare (to), have the courage (to)

ផ្ញើ to entrust (to), consign (to), leave (with)

ពណ្ណរាយ /puə̆nnəriəy/ to shine, excel; brilliance, excellence

ប្រយោជន៍ទាំងបី all three goals (i.e. education, wisdom, and power)

ក្ដីច្បាប់ education, savoir-faire, law

ចង់ក្ដីច្បាប់ (= ចង់ឲ្យចេះច្បាប់ក្បួន)

នាលោកិយ /niəlookəy/ this life, this world (as opposed to the

next world)
ចង់ប្រាជ្ញា (=ចង់ឱ្យមានសិរី)

អាប្រិយ (=អាក្រក់) morally bad, disgusting, shameful, despicable
បារមី /baarəməy/ excellence, perfection; here: power, authority, status
ចង់បារមី (=ចង់ឱ្យមានបារមី)

ដែលដែរ furthermore, likewise

កុំ...ដែលដែរ don't...either

លំឱត /lumqaot/ be diligent (in), conscientious (about)
ទីទៃ other, opposite; here: respectively
អៀនប្រៀន shy, timid

ផ្គាប់ to please

ហឫទ័យ /haqrɨtɨy/ heart, mind (sacred, formal, Lit)
ផ្គាប់ដោយហឫទ័យ to be pleasing, satisfying, gratifying (to the teacher)
រឹម ៗ constantly

បារម្ភរឹម ៗ be constantly concerned [for the teacher's wishes]
ទូន្មានអាត្មា instruct yourself, become versed in
ក្រិត្យសង្ឃ /krət saŋ/ Code [of Conduct] of the Sangha (priesthood)
ចំណេរ future; afterward, henceforth
លង់ (=យូរ)

ចំណេរទៅលង់ in the future, later on
មហាក្សត្រ /məhaa-ksat/ king

ទើបខ្លួនជាធំ ទៅដល់មហាក្សត្រ then you'll be of [sufficient] stature to approach the king

ថេរ (=ឋិតថេរ) firm, solid, permanent
ថេរនៅពុំបាត់ permanently (lit: stay without disappearing)

ពុំលែង certainly, surely, inevitably
យសនោះពុំលែង [you will] inevitably achieve status

បាននឹង have an aptitude for, predilection for, natural ability in
បានដូចបង្គាប់ fulfill the wishes [of the teacher]
ស្តែង clearly

គម្តែង /kummədaeŋ/ King, Master, Supreme Ruler
សរិល /saqrəl/ body, oneself

សព្វសរិល everybody

អ្នកហោង (=អ្នកនោះឯង) /neə̆q haaŋ/

ក្រេវក្រោធ angry

ចិត្តនោះក្រេវក្រោធ [if] he is irritable, [if] he is quick to anger
ខំ (=បង្ខំ) to require, force

មិនខំសាមណេរទាំងឡាយ doesn't require all novices [i.e. to associate with ill-tempered persons]

តាមចិត្តសប្បាយ អាត្មាទីទៃ each may do as he wishes [in this regard]
អធ្យាស្រ័យ /qattyiəsray/ lenience, tolerance
សំគាល់ (=ស្គាល់) knowledge, familiarity (i.e. with the Dharma)
ឱ្យអន្តរាយ to violate, transgress, do violence to, harm

ប្រដូចនូវម្តាយឪពុកឯង comparable to your own parents

ហ្វឹកហ្វឺន /wək-wəɨn/ to train, drill, discipline (in a subject)
ព្រេងព្រឹទ្ធ the past, ancient times, antiquity; ancient, former
ជារស្មីប្រាណ as [the source of] personal radiance
លែង (= modern Cambodian /laəŋ/)

ឱ្យគិតជញ្ជឹងទំពឹងលែងបាន This line is open to two interpretations: 1) one should be

able to reason things out; 2) one should reason things out (with /ɓaan/ included as a semantically empty syllable to rhyme with /praan/ in the preceding line).

បំពាន to transgress, violate, infringe (intentionally or persistently)

ប្រទូស្ត /prɑtuuh/ to argue, quarrel

វិញ (= modern Cambodian /wɨñ/)

ប្រទូស្តវិញល្អង to argue back, oppose, be obstinate

នាបីទៅ (= ដែលទៅថា)

ផ្លោះទៅ (= ទៅផ្លោះ; order reversed for rhyming purposes)

ស្រុកតូចធំផង (literally this means 'whether a large or small country', but it is used figuratively here to mean 'whatever your destination, whatever your goal')

សឹង surely, almost certainly, precisely, just

សឹងដូចបំណង [you will get there (or achieve it)] just as you wish, precisely in accordance with your desires

ចិន្តា /cəndaa/ thoughts, thinking processes

រីឯរៀនឯង as for [one who tries to] learn on his own

អទ្វា (= ផ្លូវ) /qaqtwiə/ (Lit)

ពុំនោះ or rather (Lit)

ចរ /cɑɑ/ to go (Lit)

យាត្រា to go; trip (Roy, Lit)

ចរចេញយាត្រា to go out

ល្មើ although, even if, if; to the extent of, to the extent that

ហេតុដ្បិត since, because

ចិត្តនោះសង្ស័យដូចដល់ពុំដល់ such a person never knows whether he'll get there or not

មោហោ ignorance, blindness (here: one who is ignorant, morally blind)

ធ្វើមោហោ behave like an ignorant person

ទោសោ anger; here: one who is angry

កំហល់ anger; here: one who is angry

នា...នា whether...or

ពុំអាចទប់ទល់នាធ្ងន់នាស្រាល unable to cope [with anything], whether serious or unimportant

ទម្ងន់ (=ធ្ងន់) serious, important

ដឹងដើម to appreciate, feel gratitude (toward)

អភិរូហ៍ /qaqphiruu/ advancement, improvement, benefit

ភ្លឺ (=បំភ្លឺ) to enlighten, illuminate

សួគ៌នាយ heaven, the world beyond

ចតុរាបាយ /cattoraabaay/ the four levels (of hell)

មូទូ sullen, rude

ចិត្តនោះឱ្យល្ហួន [you] should be considerate

តម្កើង haughty, proud

ក្រែងប្រាបមកជួនទៅនាលោកិយ lest [you] meet with misfortune in this life

បញ្ចិន្ទ្រិយ /pañcəntrii/ the five senses (fig: consciousness, wisdom, intellect)

ឱ្យរុងរឿង to enhance, elevate, brighten

ជនី /cŭənii/ mother (Lit, Roy)

ជនក /cŭənŭəq/ father (Lit, Roy)

ឱ្យរុងរឿងអស់បញ្ចិន្ទ្រិយ ស្មើព្រះជនីជនក to improve [one's] intellect [to a point] equivalent to [one's] parents'

ធុញ be tired (of), weary (of), disgusted (with)

មិនដែលនឹងធុញ never tiring, never flagging; tirelessly, indefatigably

ពេកពន់ (=ពន់ពេក)

ថា if..., but; it stands to reason that..., but; it's

said that..., but

ភ្នំព្រះសុមេរុ /pnum preəh-soqmeeruq, -somae/ Mount Meru (of Hindu mythology)

មហាធ្ងន់ extremely heavy, extremely important

ថាបើ if

គណន៍ /kun/ to estimate, calculate

ថាភ្នំព្រះសុមេរុ---ពុំអាចកន្លង If it's said that Mt. Meru is heavy, if [one could] calculate [its weight], it couldn't surpass [the importance of one's parents]

គុណនោះទាំងបី the merit of these three (i.e. Mother, Father, and Teacher)

ពេក intensifier preceding av: really, extremely

មហាទូលាយ very large, vast

ក្ដីព្យាយាម (= សេចក្ដីព្យាយាម)

កុំឱ្យអន្តរាយក្ដីព្យាយាម don't ruin [their] efforts

សុភាព polite, kind, gentle, good

ស្រមោល shadow

អន្ទោល to follow (through transmigration)

សល់វ៉ល់ involved, attached (i.e. to this life, to worldly concerns)

ត្រង់ក្ដីសល់វ៉ល់ to the extent of your involvement [with Karma]

វីរិយំ /wiiriyaŋ/ diligence, effort

សច្ចំ /saccaŋ/ truth

កុសល /kosal/ merit, good deeds

ក្ដីទុក្ខសោក misery, things which cause suffering (i.e. sin)

ឱស្សាហ៍ (=ឧស្សាហ៍) diligent, conscientious

អធ្យោគ /qaqtyook/ to persevere

បថមោក្ខ (= បដិមោក្ខ) /patdemaok/ remedy, solution (i.e. to life's suffering)

១៨ - ច្បាប់កេរ្តិ៍កាល

(គ្មានឈ្មោះអ្នកនិពន្ធ)

(បទព្រហ្មគីតិ)

កេរ្តិ៍កាលពីព្រេងព្រឹទ្ធ	សាងសុចរិតទៀងទុកនៅ
សេដ្ឋីផ្ដាំប្រដៅ	បុត្រសង្សារទុកក្រោយហោង ៗ
កូនអើយកេរ្តិ៍មេបា !	ចូររក្សាគន់គិតគ្រង
ថែទាំចាំរួសរង	ប្រុងប្រយ័ត្នប្រយោជន៍យូរ ៗ
ធម្មតាអ្នកជាជាតិ	ការកេរ្តិ៍អាទិ៍ឱ្យគិតគូរ
កុំខ្ជិលដេកទទូរ	ដល់ថ្ងៃរះពេញពន្លឺ ៗ
តាក់តែងខ្ញុំកំដរ	ចេញទៅរកធ្វើស្រែភ្លឺ
ចិញ្ចឹមគោក្របី	រកខ្សែវល្លិ៍ចោះក្រោលឃ្នង ៗ
ធ្វើស្រែទិសប្រាំបី	ខ្ញុំប្រុសស្រីចេញជួញផង
មើលផ្ទះស្រាស់របង	រាំងចំណាររត្នរក្សា ៗ
ឱ្យមានក្ដីបារម្ភ	ធ្វើស្រែកុំចោលចំការ
ដឹងថែកកាំបិតព្រា	ទុកឱ្យជាកុំឱ្យបាត់ ៗ
ដេកយប់ឱ្យរាំងទ្វារ	ទ្រព្យសម្រាលទៀបប្រយ័ត្ន
ចងទូកកុំឱ្យសាត់	ផ្ទះបាក់បែកឆាប់ទល់ទ្រ ៗ
សារពើទ្រព្យអ្វី ៗ	មើលស្រដីទុកឱ្យល្អ
ឧសទឹកស្រូវអង្ករ	យកចេញចាយមានកំណត់ ៗ
កុំអាងតែទ្រព្យច្រើន	ពុំក្រទើនរកផ្គង់ផ្គត់
យកចាយ ៗ ដោយបទ	ទោះនឹងទុក ៗ ដោយខ្នាត ៗ
រទេះ សេះ ដំរី	រាប់បញ្ជីកុំឱ្យឃ្លាត
ខ្ញុំណាមានមារយាទ	ទុកដាក់ដៃឱ្យរក្សា ៗ
សប្បុរសយល់ដោយមុខ	ស៊ុកគ្រលុកពេកពុំជា

កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស ៗ
រក្សាខ្លួនឲ្យរុង - រឿងឧត្តុង្គឧត្តមខ្ពស់
ប្រដាប់ដោយសក្តិយស ខ្លួនជាធំឲ្យថែធ្នួន ៗ
ឲ្យទានចិត្តឲ្យស្មោះ កុំអាឡោះអាល័យស្ងួន
ទ្រព្យនេះនឹងនាំខ្លួន ទៅបរលោកពុំសោះសូន្យ ៗ
ទ្រព្យធនទោះថោកថ្លៃ កុំដាក់ដៃឲ្យតែកូន
នូវអស់ទាំងបងប្អូន អ្នកដទៃរក្សាតាង ៗ
ទុកចិត្តខ្ញុំឲ្យដាក់ ស្មើតែភ្នែកខ្វាក់ទាំងសងខាង
ឲ្យកូនគន់មើលតាង ស្មើតែភ្នែកម្ខាងពុំពេញពីរ ៗ
ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍
សំអាតអស់សរិល កុំឲ្យមានក្តីនិន្ទា ៗ
ដំណេកដេកជាខ្នាត ឲ្យសំអាតសំអាងជា
ទើបទេពតារក្សា ចំរើនសុខស្រីសួស្តី ៗ
គ្រឹហាឲ្យផ្ចិតផ្ចង់ កុំឲ្យផង់ផុយធុលី
ជម្រះច្បារច្បោសដី ឲ្យម៉ត់ម៉ងកើតសុខា ៗ
អញ្ជាលទុកឲ្យគង់ ប្រាក់ក្នុងថង់ទុកឲ្យជា
ប្រើខ្ញុំមើលមុខវា ទោះកាចជាមើលឲ្យស្តែង ៗ
សារពើរទួលទៀនទិះ ឲ្យចាំចេះ ៣ ចាំចែង
ចង់គាប់ប្រើស្វះស្វែង រកទៀនទិះសារពើក្តី ៗ
សប្បុរសពេកចាញ់ធន នាទុរជនចាញ់ឥន្ទ្រីយ
ប្រពន្ធល្អច្រើនចាញ់ប្តី ពាក្យអប្រិយចាញ់អាត្មា ៗ
ឈើផ្លែចាញ់សន្លឹក ត្រីច្រើនទឹកល្អក់ពុំជា
ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះគិត ៗ
ដេកយប់កុំដំអក់ ឲ្យលង់លក់ក្រៅសុចរិត

ខ្ញុំណា មានគំនិត   គួរឱ្យគិតប្រណីវា ៗ
ចងទូកចោះបង្គោល   រិះរកថ្នាលពូនឃុក្កា
ការខ្វល់ព្យុះការចដា   ក្រែកងពានពារចោកបែកបាក់ ៗ
ទៀនទិះសារពើក្ដី   ទោះស្រដីកាន់ពាក្យសត្យ
ចាំក្បួនចាំឱ្យស្ទាត់   កុំអៀនប្រៀនសមពាក្យពោល ៗ
ការក្រកុំគិតងាយ   ការសម្ងាយជាកំទោល
លនឡឹមកុំបំពោល   ក្រែកងពុំដល់ដូចប្រាថ្នា ៗ
ទៀនទិះរួសរទាំង   ធ្វើស្រែប្រាំងស្រែវស្សា
ធ្វើស្រែមានចំណារ   ធ្វើចំការចាររបង ៗ
ផ្លូវទៀចកុំចោះបង់   ផ្លូវណាត្រង់កុំដើរហោង
ដើរដោយផ្លូវគន្លង   តម្រាយអ្នកចាស់បុរាណ ៗ
តែ្កជាឱ្យចាយដី   រដែកនៅដីចាំធនធាន
ក្រៀងសឹកទុកទាហាន   កេរ្តិ៍ គម្ពីរទុកប្រាជ្ញប្រាយ ៗ
យល់តូចកុំអាលខំ   ទោះយល់ធំកុំអាលទាយ
គិតក្ដីកុំគិតងាយ   មើលពិនិត្យពិនិស្ស័យ ៗ
កូនអើយ! ពាក្យបណ្ដាំ   ចូរចងចាំទុកសព្វថ្ងៃ
ទ្រព្យធនទោះថោកថ្លៃ   រួមរក្សាកុំបីធ្លោយ ៗ
ពាក្យនេះជាត្រកាល   ជាខ្លឹមសារទៀងទុកឱ្យ
កូនចៅនៅខាងក្រោយ   ជាជំបូន្មានអាត្មា ៗ
ថែទាំទើបគង់ទ្រព្យ   ទ្រៀបសណ្ដាប់ទុកទើបជា
ចាយវាយក្រៅតម្រា   នូវវិនាសធនធានផង ៗ
បានមកទុកឱ្យគង់   កុំឱ្យបង់បាត់ទៀយហោង
ទៀនទិះរក្សាគ្រង   យកចេញចាយដោយរដូវ ៗ
ដឹងហាបឱ្យដឹងដុល   តែ្ធកឱ្យយល់ទៀងត្រាដូ

គិតគ្រប់សព្វដោយផ្លូវ ក្ដីចន្លោះកុំបីមាន ។

ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយ! ចូរចាំប្រាណ

អស់អាថ៌ឲ្យវាទាន ស្រេចប្រការទម្លុះឯងហោង ។

(ច្បាប់កេរ្តិ៍កាល, ទំព័រ ១-១០)

ច្បាប់កេរ្តិ៍កាល

តាំង...ទុកនៅ established, set down, prescribed

សុចរិតទៀង good conduct, upright character, morality

កេរ្តិ៍កាល--- ទុកនៅ [The rules of] good conduct have been established since the glorious periods of antiquity

សេដ្ឋី /saetthəy/ wealthy merchant, mandarin, person of high estate

ផ្ដាំ to warn, admonish: to delegate, leave instructions (with someone) to

ផ្ដាំប្រដៅ to counsel, advise, instruct

បុត្រសង្សារ beloved sons

កេរ្តិ៍ /kei/ honor, reputation, glory

គ្រង to watch over, take care of

រួសរង actively, alertly, vigilantly

ប្រុងប្រយ័ត្នប្រយោជន៍យូរ preserve [it and it will] benefit [you] for a long time

អ្នកជា respectable people, free men (as opposed to slaves)

ជាតិ the intrinsic nature or character of a person, animal, or thing

អ្នកជាជាតិ (= ជាតិអ្នកជា) the nature of respectable people

ការ (= ការពារ) to defend, protect

កេរ្តិ៍អាទិ៍ /kei-qaat/ personal honor, self-respect

ការកេរ្តិ៍អាទិ៍ឲ្យគិតគួរ you should be concerned about defending your honor

តាក់តែង (= ចាត់ចែង)

រក /rɔɔ/ (= /rɔɔk/; /kαα/ is cancelled for harmony with /kαmdαα/; also reflects colloquial pronunciation)

បោះ to drive in (stakes, nails, etc.), to erect, build

ក្រោល corral, pen (for animals)

ឃ្នង bar, pole (put across an opening)

ទិសប្រាំបី all around, everywhere (lit: in the eight directions)

ជួញ (= ជួយ)

ស្រាល់ to patch, cover over, block (with branches)

រាំង to enclose, encircle, obstruct

ចំណារ a stake fence

រាំងចំណារ to fence off, surround with a stake fence

ក្ដីទុក្ខ worry, concern, sense of responsibility

ព្រា a long-handled knife used for cutting bushes and small trees

សម្រាល to relieve, lighten; here: light (in weight)

ទ្រព្យសម្រាល valuables, small belongings (i.e. which can be carried off)

សាត់ (= រសាត់) to drift off, float away

សារពើ (= ទាំងឡាយ)

ស្រដី to say; here: to tell

[others] to
ឧស (=អុស) firewood

មានកំណត់ cautiously, sparingly, keeping account
ក្រវើន /krɑwəən/ make an effort, try hard (to)
ផ្គង់ផ្គត់ (=ផ្គត់ផ្គង់) to support, contribute to, add to

ដោយបទ sensibly, carefully, with a sense of proportion

ដោយខ្នាត with moderation, in proper proportion
មានមារយាទ to be worthy, be of [good] character
ទុកដាក់ដៃ to entrust to, trust someone with
យល់ to indulge, grant, be understanding
ដោយមុខ selectively, on an individual basis, with discrimination
សប្បុរសយល់ដោយមុខ be selective in your generosity
ស៊ុកគ្រលុក be involved, implicated; here: haphazard, disorganized
កំណាញ់ stingy, miserly

ក្រៅតម្រា inordinately, excessively, unreasonably
សោតសឹង inevitably

អាប់ to dim, tarnish, compromise

ឧត្តុង្គឧត្តម /qutdoŋ-qutdɑm/ high, glorious, excellent, illustrious
ថែធួន to preserve, care for

ឱ្យទានចិត្តឱ្យស្មោះ [if you] give charity, [do it] willingly
សួន parsimonious, stingy

សោះសូន្យ in vain, futile, to no purpose
ដាក់ដៃ entrust to, turn over to

នូវ or, and

តាង to replace, represent; here: instead, in your place

ដាក់ (= ទុកដាក់) to take care of, take charge of

ទុកចិត្តខ្ញុំ--- ទាំងសងខាង Entrusting [your things] to servants is like being blind in both eyes.
ធ្វើអ្វី--- បង្កើតកេរ្តិ៍ Finish whatever you start (don't let it go); [thereby] building up [your] reputation.
ដំណេកដេក (=កន្លែងដេក)

ជាខ្នាត as a rule

សំអាត to clean (tv)

សំអាង to decorate, adorn

ទេពតា (=ទេវតា)

ស្រីសួស្តី /srəy-suesdəy/ happiness, prosperity, wellbeing

គ្រឹហា /krɨhhiə/ house (Lit)

ផ្ចិត to take great pains (with), do carefully
ផ្ចង់ to take great pains (with), do carefully
ផង់ fine, powdered; here: dust, dirt
ផុយ crumbly, ready to disintegrate; here: dust, dirt
ធុលី dust, dirt

កុំឱ្យ (=កុំឱ្យមាន)

ជម្រះ to clear off, scrape clean (with a hoe)
ញារ to scrape up, dig out (with the hands)
ម៉ត់ម៉ង clean, spotless

សុខា health; happiness, wellbeing
អញ្ជាល (=ម្ជុល) needle

មើលឱ្យស្ដែង look carefully, determine clearly
ចេះចាំចែង know [it well enough to] recite
ប្រើ (=ឱ្យ)

ស្វះស្វែង to seek, search diligently
ចាញ់ to lose, be defeated, be inferior to; here, and in the next four phrases: is detri-

mental to, detracts from

សប្បុរសពេកចាញ់ធន excessive generosity wastes one's wealth

ទុរជន (=ទុជ៌ន) /tuurəcuən/ wicked people

អន្ទ្រីយ (= ខ្លួន) /qəntrii/ body, self (Lit)

អប្រិយ (= អាក្រក់) /qaprəy/ bad, malicious

ឈើផ្លែ (= ឈើណាដែលមានផ្លែច្រើន)

សន្លឹក specifier for leaves, pages, sheets; here: leaves (of tree)

ព្រួយរក្សា (=ពិបាករក្សា)

ព្រួយរិះគិត hard to get along, difficult to manage

ដំអក់ to be sluggish, to procrastinate

លង់ to sink, be submerged

លង់លក់ (=លក់លង់) to sleep soundly

ក្រៃសុចរិត excessive, extreme, abnormal

ដេកយប់--- ក្រៃសុចរិត Don't sleep so soundly [you] can't awaken quickly.

មានគំនិត thoughtful, conscientious

បោះបង្គោល drive in a stake (as a mooring for the boat)

ថ្នោល boat-pole (for punting a boat; cf. /daol/ to punt)

ពួរ rope

យុថ្កា /yuttkaa/ anchor

ការ (=ការពារ) to prevent, defend against

ពានពារ to hit, strike, go against

សត្យ /sat/ truth; truthful

អៀនប្រៀន to be bashful, embarrassed (through ignorance)

សមពាក្យពោល thus justifying criticism

ក្រ difficult

គិតងាយ to take lightly

សម្មាយ common, ordinary, insignificant

កំរោល violent, uncontrolled, tempestuous

ការក្រ--- ជាកំរោល Don't take difficult affairs lightly [and] don't overreact to ordinary affairs. (This could be equated to the English proverb 'Don't choke on a gnat and swallow a camel'.)

បំបោល to stampede, cause (an ox, horse, etc.) to run

ទន្ទាំង to be on the lookout, be careful, watch out

ចារ to put in stakes or branches (as a fence or barrier)

វេវៀច crooked, winding

ត្រយាយ swath, cleared area or path (cf. /traay/ to clear, cut a path)

ផ្លូវវេវៀច--- បុរាណ (This verse can be translated approximately by the English proverb 'The long way around is the sweetest way home'.)

ឆី to eat (Archaic, Lit)

ឆ្កែជា--- ធនធាន [If you have] a good dog [which] sleeps on the ground (i.e. under the house) [and] guards [your] possessions, feed [him] rice.

ទុក leave to

គេក្តីគម្ពីរ /kei-kumpii/ the Exalted Scriptures

ប្រាជ្ញប្រាយ scholars, philosophers

យល់តូចកុំអាលខំ [If something (profit, result, etc.)] seems small, don't get worked up.

ទោះ--- ទាយ If [something] seems large, don't make plans for it in advance. (This line might be translated by the English proverb 'Don't count your chickens before they hatch'.)

ក្តី court action, suit

គិតក្ដី to consider bringing suit

ពិនិច្ឆ័យ /pinɨhsəcay/ to examine, observe carefully, consider carefully

ចងចាំ to retain, remember, hold on to

កុំបី so as not to, in order not to

ធ្លោយ to overstep, make a mistake (with unfortunate results)

ត្រកាល precious, extraordinary

ទៀងទុក reliable, precise, dependable

រណ្ដាប់ order, sequence; here: in orderly fashion

នូវ (=នឹង) will

ញូនមក [if you] get something, [whatever] you acquire

ដោយរដូវ in season, by seasons; as needed, according to the circumstances

ហាប unit of weight and volume: approximately 60 kilograms

ដុល unit of weight: approximately 150 kilograms

ត្រាជូ scale (for measuring weight)

គ្រប់សព្វដោយផ្លូវ (= គ្រប់សព្វផ្លូវ) every way

ពាក្យនេះស្មើរខ្លួនហើយ These words [are worth] as much as I myself (i.e. the father who is speaking).

ចាំប្រាណ (=ចាំក្នុងខ្លួន) to remember, retain, assimilate, keep with oneself

ឱវាទាន (=ឱវាទទាន)

ឱវាទ /qaowiət/ advice, instruction, admonition

ស្រេចប្រការ to be over, come to an end, conclude (of a speech or composition)

អស់អាថ៌--- ម្ល៉េះឯងហោង The substance of the advice offered concludes at this point.

១៩ -ច្បាប់ពាក្យចាស់

(គ្មានឈ្មោះអ្នកនិពន្ធ)

(បទព្រហ្មគីតិ)

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមិលយល់ប៉ុននឹងភ្នំ ។
ចូលទីព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ
បានស្ករនឹងទឹកឃ្មុំ ពួនក្នុងផ្ទះឆីម្នាក់ឯង ។
បានហើយចង់បានទៀត ឆ្លៀតហើយឆ្លៀតពុំគិតឈ្វេង
មើលយល់តែមុខឯង មិនមើលគេឯទៀតផង ។
នឹងឆីចង់ពិសា ខ្ជិលទំពាឱ្យម៉ដ្ឋហ្មង
យល់នាមថាជាមង យល់ឯជងថាជាគួយ ។
យល់តាថាជាដូន យល់ឯកូនថាជាក្មួយ
យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។
យល់ទោសថាជាគុណ យល់ឯបុណ្យថាជាបាប
យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។
ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចាក់ធ្មេចនេត្រា
ឃើញសេះថាជាលា ឃើញគជាថាកណ្ដុរ ។
នេះពាក្យចាស់ពីព្រេង អ្នកណាឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកថាជាថ្នល់ ទីព្រែកឯកំហល់កំហុសមាន ។
អ្នកប្រាជ្ញការពាក្យទៀង កុំឱ្យល្អៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន ពាក្យអ្នកចាស់លោកតែងថា ។
ពាក្យនេះពីព្រេងព្រឹទ្ធ គួរឱ្យគិតពិចារណា
កុំអាងអួតអាត្មា ថាចំណេះចំណាំមាន ។

ដេកយប់កុំដេកយូរ ខ្លាចក្តីទុក្ខដល់ប្រាណ
បើនឹកុំតាមឃ្លាន មើលប្រមាណគ្រប់គ្នីគ្នា ៕
លើកដាក់តាមកម្លាំង កុំភើចឆាំងឈ្មោះប្រស្នា
ប្រើគេប្រើបុត្រា កុំស៊ាំលួចទេចៅទេ ៕
ទោះគិតកុំរួសរាន់ គិតឱ្យគ្រាន់ទើបដើរទៅ
កុំឱ្យអាប់អាស្រូវ កើតជំនៀលដល់អាត្មា ៕
កុំយកឆ្អិនជាឆៅ កិច្ចក្នុងក្រៅមានតម្រា
កុំអាងអួតអាត្មា ចេះច្បាប់ក្បួនពីព្រេងនាយ ៕
ស្រដីឱ្យស្រួលស្រេច គិតសេចក្តីគេចកុំគិតងាយ
ទពឹងគិតឱ្យឆ្ងាយ យល់ដោយផ្លូវសព្វនានា ៕
ពាក្យព្រេងលោកស្រដី ថាកុំបីចិត្តាមខ្លា
ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱ្យបាន ៕
កាន់កពល់ឱ្យខ្ជាប់ ប្រែប្រក្រទ្បាប់ខាំងប្រាណ
អួលទូកកុំឱ្យឃ្លាន ចាប់ត្រីបានកុំឱ្យល្អក់ ៕
ស្លឹកឈើឥតកម្រើក នឹងកក្រើកដង្ហិតខ្យល់បក់
ទឹកថ្លាល្អិកបើល្អក់ ដង្ហិតលកច្បោកលោះសា ៕
យល់តូចកុំអាលខំ ទោះយល់ធំកុំអាលថា
បានច្រើនកុំខំពារ ឱ្យសន្សំមសៀវតិចទៅ ៕
អ្នកមានរក្សាខ្សត់ ដូចសំពត់ទុក្ខពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ៕
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្ការ ៕
រក្សាទៅមុខទីង ឥតកំដឹងអស់អម្បាល
ចំណេះចិនកាន់កាល ដូចរបងចារបន្លា ៕

កុំឆីឆ្អែតតែឯង　　ពុំគិតក្រែងអស់គ្នីគ្នា
គេឃ្លានផ្ទៃខ្លាចផ្សា　　គេឆីរ៉ាពួនឆ្អែតផង ។
កុំមានចិត្តពល្លើ　　ពឹងក្រពើឲ្យចម្លង
កុំកាច់ឱសរបង　　រាំងចំណារងអាត្មា ។
មានទូកឲ្យមានថ្នោល　　មានបង្គោលពួរយុថ្កា
ទាំងចែវទាំងច្រវា　　ក្រដីងចាប់ដោយនូវគ្រប់ ។
ប្រយ័ត្នក្រែងព្យុះខ្យល់　　បក់មកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់　　ទើបហៅថាមានគំនិត ។
ពាក្យព្រេងគិតគួរចាំ　　ជាបណ្តាំប្រដៅស្និទ្ធ
ពាក្យព្រេងពាក្យព្រឹទ្ធ　　គួរឲ្យគិតៗឲ្យគ្រាន់ ។
ពាក្យនេះទុកជាច្បាប់　　ជាសណ្តាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់　　កំណត់នៅឥតឃ្លាតឃ្លា ។
សូរេចនូវនិទាន　　ពាក្យទូន្មានដោយប្រការ
អម្បាលនេះឯងណា　　ចូរចងចាំទៀងទៅហោង ។

(ច្បាប់ពាក្យចាស់, ទំព័រ ១-៦)

ច្បាប់ពាក្យចាស់

ទោស fault, wrong, guilt, culpability; punishment
មើលពុំយល់ not recognize, not realize, not see (figuratively)
សោតស់ however, to whatever extent
រមិល to look, see (Lit)
រមិលយល់ to look, see (Lit)
អំពាវ to call out, summon
រកអំពាវគ្នាមកជុំ [you] call on [your] friends to come together (for protection)
ទឹកឃ្មុំ honey
ឆ្លៀត to scheme, take advantage of the slightest opportunity, capitalize on any favorable situation, seize an opening (for one's own ends)
ឈ្វេង to think, realize (Lit)
មើលយល់តែមុខឯង to think only of oneself
ម៉ត់ហ្មង /mαt-mααŋ/ fine, smooth

(of texture)

ចង់ស៊ី --- ខ្ជិលញាំង [You] want to eat, but [you're] too lazy to chew it up. (Fig: You want to have things, but you don't want to work for them.)

យល់ (= ឃើញ)

នាម a small two-man fishing net

មង a fishing net

យល់នាមថាជាមង When you see a /niəm/, you say it's a /mɔɔŋ/. (This construction, in this and in the nine following phrases, implies that a stupid or uneducated person can't tell the difference between right and wrong, good and evil, etc.)

ឯ as for...on the other hand

ស្លៀកស្បង់មិនកោរសក់ [You] put on a monk's robe [but] don't shave [your] head. (The figurative meaning here and in the phrase that follows is that there is no point in doing something half-way; i.e. simply putting on a monk's robe doesn't make one a monk.)

ឆ្លុះ to direct one's gaze toward, peer into (cf. /cɑnloh/ torch)

លា donkey

គជា /kucciə/ elephant (Lit)

អ្នកណា --- យល់ everyone should ponder [these words] intelligently [and] understand

ថ្លុក a water-filled hole, buffalo wallow

ក្រែង --- មាន lest [he] have shortcomings (as enumerated in the preceding lines)

ឃ្លៀង deviate from

អាងអួត (= អួតអាង) to boast, brag, be arrogant

ចំណេះចំណាំ (=ចំណេះ) knowledge, learning

ក្ដីទុជ៌ន misfortune, bad results

មើលប្រមាណគ្រប់គ្នីគ្នា take everybody into consideration

លើកដាក់ to carry (lit: to lift and put down)

លើកដាក់តាមកម្លាំង carry in proportion to your strength

រភិច to lift or pull with a jerk

ផាំង sound of breaking or crashing

ប្រស្មា (=ស្មា) shoulder

ប្រើគេប្រើបុត្រា treat others [as you would] treat [your own] sons

ស៊ាំ over and over, repeatedly

ស៊ាំសួរ to nag, ask repeatedly

ចរ to act, behave, conduct oneself

ចៅរ៉ៅ /caw-raw/ kind, affable, gentle

កុំស៊ាំសួរចរចៅរ៉ៅ don't nag [but rather] be gentle

អាសៅ to degrade, smear, tarnish

ដំណៀល criticism, gossip

កិច្ចក្នុងក្រៅ affairs [both] internal [and] external (to the household)

ខ្លួនឯងនេះប្រៀបដូចសត្វមមៀច   យល់ភ្លើងព្រោងព្រាចថាជា ៗ
ហើរឆេវឆាបលុះឆេះក្ស័យជន្មា   ចូរនាំគ្នាទៅ ៗ ស្លាយជីវិត ។
ព្រះភិរុណសុរិយ៉ាវង្សទ្រង់តបខ្មី   ថាឪយែនអសុរីចិត្តមោហ៍មិត
កុំអួតធំដូចឃ្លោកស្គោកស្លុករិទ្ធិ   យើងតូចពិតដូចពេជ្រទ្រៀងរង្សី ។
យើងឈ្មោះព្រះភិរុណមានចេស្តា   ព្រះបិតាយើងនៅក្រៃត្របុរី
ផង្សងពង្សពិតដូចពាក្យខ្លួនឯងស្តី   តែយើងឃើញឯងអប្រិយពេកណាស់សា

លើកទ័ពមកកំហែងក្រុងប៉ុណ្ណេះ គង់អួតថាឯងចេះមានរិទ្ធិក្លា
អញនឹកខឹងប្រឹងខំនឹងប្រាថ្នា ចង់សុំក្បាលពីស្នាអាឲ្យហើយ ។
កុំឲ្យកើតកង្វល់តទៅមុខ នឹងពូជយក្សតំរក់នោះទៀតទេឡើយ
បន្ទូលភ្លាមស្រែកហៅថាយក្សអើយ មកលេងគ្នាឲ្យហើយកុំខ្លាចថ្វី ។
អង្គពិនរាជច្បាន់ព្រួសីជាក់ ក្រោធស្ទើរធ្លាក់ពីលើខ្នងដំរី
នេត្រក្រឡៅក្រឡាប់ក្រឡេកវែវ ស្ទើរនឹងស្ទុះទៅក្រញ៉ាំឲ្យក្សិណក្ស័យ ។
ហើយស្ទុះលោតលលេចគេចត្រវី ចោលនៅចក្រអគ្គីចំជៀវស្វជ័យ
ព្រះអង្គគេចយកព្រះខ័នកាប់វែវ ចក្រលវែលលឿនលត់ផុតទ័ពខាន់ ។
អសុរាវាយថែមនឹងដំបង ស្ដេចក៏រងគេចចាក់នឹងព្រះខ័ន
ពួកពលយក្សស្ទាក់វាយនោមសុវណ្ណ ពានរចាក់នឹងព្រះខ័នត្រូវសេនីយ៍ ។
វលាហកហោះហក់ផក់បែររខាក ញ្ញួសូរម៉ាកប្រួយធាក់យក្សស្លាប់ខ្មី
ឯក្រុងយក្សក្រឡះថយក្រោយប៉ី ព្រះចក្រីថយរាំងនាងសង្វារ ។
តែសេនាពលយក្សមួយសែនកោដិ ស្ទុះប្រទេញតលោតចាប់កាប់នាយស្វា
ហើយសំដៅសំដែងថ្លែងសរថ្លា លាន់សន្ធឹកកោលាទាំងផែនដី ។
មានសេនាឯកមួយឈ្មោះខុនពេជ្រ សែនក្រោធក្រៃក្រលោតលេចចេញមកខ្មី
ប៉ងប្រកាប់ចាប់យកអាជានេយ្យ សេះធាក់យក្សវែវវេះថយក្រោយ ។
វែវរតរាជបុត្រសែនខេងខឹង ប៉ងហោះមកតនឹងនាងសង្វារ
ព្រះភិរុណឈរខាងឃើតសរថ្លា ថ្លែងត្រូវអង្គអសុរាដាច់សិរសី ។
ញ័ររន្ធត់ស្លុតស្លាំងទាំងអង្គា ធ្លាក់ដល់ផែនពសុធារំពេចខ្មី
ព្រះលោហិតប្រចាសប្រចាលពាសពេញដី យក្សសេនីយ៍ភ័យរត់ស្លុតគ្រប់គ្នា ។
ខ្លះស្ទុះចូលឱបសោយសោកស្ដាយ ខ្លះភិតភ័យរត់ឆ្ងាយខ្លាចមរណា
ពង្រូនរាពានរិន្ទនិងអស្សពាហ៍ សឹងនាំគ្នាចូលគាល់ព្រះទសពល ។
ចៅក្រុងយក្សទតយល់រាជបុត្រា សូន្យជីវាក្នុងទ័ពរត់វិលវល់
សែនខេងខឹងនឹកស្ដាយបុត្រនិមល ស្ដេចស្ទុះស្ទាក់កៀងពលចូលប្រយុទ្ធ ។
ហើយទ្រង់បែរមកឃើតថ្លែងសរថ្លា ដោយចេស្ដាកើតជានាគសុទ្ធ ៚

ឲ្យសំឡេងខ ៗ ស្អុះចំហុត លូនដេញផុតនឹងទាន់ក្សត្រីថ្លៃ ។

ឯនោះមទិព្វសង្ខា រវិរា វង្ស យល់នាគដេញជិតអង្គភិតភ័យក្រៃ

ប្រឹងកាត់ខ្វាសស្អុះឲ្យបាទភូវនេយ្យ ព្រះភិរុណរិទ្ធិក្រៃយល់ច្បានការ ។

ស្តេចថែនបអង្គឯបអូនជូនជិតស្និទ្ធ ព្រះនាសិតជិតថ្ពាល់ថែមថើបថា

នាងអៀនអង្គឱនភក្ត្រខ្មាសសេនា ព្រះក្សត្រាត្រេវវង្សប្រខ័នរិទ្ធិ ។

សន្ធាប់ស័ព្ទសន្ធឹកក្ទាំង ៗ រស្មីចាំងមេឃមីរខ្មៅងងឹត

ហើយក្លាយកើតជាគ្រុឌរូបរសពិត ដេញចរិតចាប់នាគបរិភោគអស់ ។

ហើយស្តេចទ្រង់ថ្លែងសរឥសីសិល្ប បំណងនឹងផ្តាច់ផ្តិលជន្មយក្សស្មោះ

សស្អុះភ្លាមហើយហាក់ដូចរស់ស្រស់ លោតទៅដល់ហើយផ្លោះដេញតែពល ។

ហើយត្រឡប់មកចូលបំពង់រត្ន ព្រះមហាក្សត្រសង្ស័យគិតពីភាល់

ថាយើះ យើយក្សនេះរិទ្ធិសល់ សរចូលដល់ហើយចៀសមិនចាក់វា ។

បើដូច្នេះបងពានរនិងពាជី កុំបង្អង់រិទ្ធីចៅក្រុងមារ

ឲ្យឆាប់ ៗ កុំរង់ទ្រង់វីរា ទុកឲ្យវាបង្អង់កម្លាំងទាន់ ។

ព្រះភីលៀងទាំងពីរនិងអាជានេយ្យ ស្អុះចូលសង្គ្រាមជ័យនៃវសំខាន់

យក្សក៏ខ្លាំងសេះក៏ក្លាស្វាក៏ត្រាន់ លោតរន្ធាន់កាប់យក្សស្លាប់គរន្ធា ។

ពួកពលយក្សចាក់សេះលាន់សូរច្រស សេះធាក់ផសត្រូវយក្សស្លាប់មរណា

ម្តងប្រាំបីម្តងប្រាំបួនជួនគ្រប់គ្នា ខ្លះមរណាពីការខ្លះបែកក្បាល ។

ពង្រូនរាជា រាជភីលៀងស្តាប់ ស្អុះចាក់សាបកាប់សំណាមហូរច្រាល

ពាននិទ្ធលុកលុយទៅកណ្តាល កាប់ស្លាប់ហាលប្រមាណមួយសែនព្លាយ ។

ពួកពលយក្សស្លុតស្លាប់អាប់រិទ្ធា ខ្លះពិការត្រាំត្រាវារត់ឆ្ងាយ

ចៅក្រុងយក្សយល់ពលស្លាប់គរកាយ ស្តេចសែនស្តាយហើយក្រែកវេក្រោធសែនទ្វី ។

ស្អុះគគឹកគគាក់ធាក់ផែនដី ថាវ៉ុយ ៗ អាមាត្យមានរិទ្ធិ

ចេញលេងឲ្យអស់ដៃក្នុងទីពទី ចាប់មនុស្សនិងពាជីឲ្យឆាប់រ៉ា ។

ព្រះភិរុណសុរិយ៉ាវង្សទ្រង់សិល្បដែល យល់យក្សកំពុងវាសដៃដេញសេនា

ទ្រង់ថ្លែងសរការមសិទ្ធិព្រះអាចារ្យ ដូចកង្ហារប្រហារអសុរី ៗ
សរប្រឹងខាល់យក្សប្រឹងខំទ្រាំស្មុះ សរចាក់ធ្លុះយក្សធ្លាក់ដល់ផែនដី
ដួលសន្លឹងស្ពឹងស្លុកតែមិនអី អសុរីគិតតាំងសតិត្រង់ ៗ
ហើយសូត្រសែកគាថាដែលប្រសិទ្ធិ ព្រះសិរសាជាប់ស្និទ្ធដូចចិត្តប៉ង
ហើយហៀរហោះលោតឡើងកន្ទៀចមពង្ស ឈរសំដែងរិទ្ធិរង្គអសុរី ៗ
ព្រះភិរុណសុរិយ៍វង្សទ្រង់ចេស្តា យល់យក្សារួចរស់ជីវិតខ្មី
ព្រះក្សត្រាបន្ទូលកាន់ក្សត្រី ថារត្នពិសីសង្វារវង្ស ៗ
ថាអ្នកអូនឱអូនតរុណរេត សុរិលភក្ត្រពិនកេតជាតិរាជហង្ស
មើលយក្សាត្រូវសរន្ធូវកត្រង់ វាចេះផ្ចង់ទេវជាប់ជិតវិញបាន ៗ
ចូរអូនឱ្យសរមកបងលង ក្រែកងទំនងទំនាយយក្សរូហាន
កំណត់ជន្មចាំជួបសរទៅវិមាណ ទាន់យក្សវាធ្វេសប្រាណអ្នកចេស្តា ៗ
នោមតរុណ ៗ រេតកេតនារី ក្រាបទូលតបវាទីព្រះជេដ្ឋា
កុំថាតែសរសិទ្ធិរិទ្ធិក្លា ទោះប្រាថ្នាដួងចិត្តគួរថ្វាត់ថ្វាយ ៗ
ព្រោះព្រះបងព្រះបាទមានព្រះគុណ ហៅមហាធ្ងន់ត្នានអ្វីប្រៀបអំបាយ
នឹងក្រាបទូលឱ្យប្រដាប់ដោយបរិយាយ ពីរឿងយក្សកាយកើតដូចចិត្ត ៗ
ព្រោះព្រះឥស្សូរឱ្យពរវា ថាវៀរពីអនុធាខ្ញុំប្រសិទ្ធិ
ទោះនរណាក្លាហានចំណានរិទ្ធិ កាប់កាត់ជាប់សិរសិតគង់តបាន ៗ
ក្រោយទៀតទ្រង់ប្រទានព្រះទំរង់ នេះមួយវង់មកឱ្យប្អូនរក្សាប្រាណ
បន្ទូលភ្លាងនាងដោះរត្នសុរក្រាន្ត ពីហត្ថអង្គទៅវិមាណថ្វាយក្សត្រា ៗ
ព្រះហស្តស្តេចទទួលព្រះទំរង់ ព្រះករទ្រង់ទទួលកែវកញ្ញា
នាងក្រលៀសក្រឡេះទះហត្ថា ព្រះនាសាដល់ថើបព្រះគណ្ឌស្រី ៗ
ព្រះនាងបែរសំឡក់រឹតសំឡឹង ក្សត្រារឹងខិតជិតព្រះក្សត្រី
ព្រះនាងនឹកអៀនអន់ថយចេញខ្មី ព្រះចក្រីក្រេកទ្រង់ចិន្តាថា ៗ
ឱគន់ភក្ត្រ ៗ ល្អស្រតចះ ដូចព្រះចន្ទចែងច្បាស់ស្រឡះថ្លា

គន់ព្រះនេត្រព្រះនាងទតដេជ្ជា
ដូចតារាទេវីងរះក្រឡង់សម ៗ
គន់ព្រះកាយប្រកបព្រះលក្ខណា
គន់កេសាតូចឆ្មារខ្មៅឧត្តម
គន់ព្រះគណ្ឌាត់ផង់ប្រផូរសម
គន់ចង្កេះរៀវក្លុំជារាងស្រី ៗ
តែសុជន់ដោះប្អូនស្ងួនចមក្សត្រ
ម្ដេចក៏ច្បាត់គ្នានជាប់នូវឧរី
ឬមិនមែនជាអង្គព្រះក្សត្រី
ជាក្សត្រាធិបតីទេដឹងអើយ ៗ
ហើយលូកព្រះហស្តទៅថ្មមប្អូនថ្លៃ
ព្រះសង្ខារចេរីណបែរកន្តើយ
ព្រះអង្គកៀកថើបថែមពុំចេះស្បើយ
ធ្វើម្ដេចឡើយនឹងបានជាក់សេចក្ដី ៗ
បើជាប្រុសសុំទុកជាប្អូនធម៌
បើនារីប្រសើររួមមេត្រី
ចិន្ដាខ្វល់ស្រុះភ្លាត់ភ្លាំងស្មារតី
មិនគិតពីអសុរីនោះឡើយណា ៗ
ឯចៅក្រុងយក្សយល់ទ្រង់ក្រសោបបី
ស្រែកចំអកថាឱចៅមនុស្សា
មែនសរនេះរបស់ផងនរណា
ឯងកោតទេចេស្ដាពិនរង់ ៗ
ព្រះភិរុណថ្កើងថ្កានបានស្ដាប់ជាក់
ព្រឺព្រែប្រភក្ត្រចាប់សរនាងនោមយង់
យកចិញ្ចៀនសុរិយកាន្តដោតនូវចុង
ថ្លែងតម្រង់យក្សយង់កំពុងភ្លា ៗ
សន្ធឹកស្នូរថ្លស់ខ្ទាប់សរស្ទុះភ្លែត
លឿនត្រដែតដោយដានអាកាសា
ចូលចាក់ធ្លុះសុរង់អសុរា
ព្រះកេសាផ្ដាច់ធ្លាក់ចាកអង្គខ្មី ៗ
ព្រះលោហិតច្បាញ់ឆេះហូរច្រៀវទៃប្រ
ក្រហមប្រចាលទៃព្រៃផ្សាសផែនដី
អសុរាសូន្យជន្មសរិលខ្មី
ចូលបំពង់ក្សត្រីឆើតឆោមឆាយ ៗ
ឯសេនាអាមាត្យមន្ត្រីយក្ស
យល់ស្ដេចត្រូវសរចាកសូន្យបង់កាយ
ស្ទុះប្រញាប់ប្រញាល់រត់ប្រញាយ
ចូលទៃព្រៃឆ្ងាយខ្លះពួនខ្លះផ្អើលរត់ ៗ
ព្រះភិរុណយល់យក្សក្ស័យជីវិត
ទ្រង់លោមរាជវរមិត្រថ្លៃវិសុទ្ធិ
ហ៊្មអូនមើលយក្សវ៉ាទិវង្គត់
សូន្យរលត់ជិតគ្នាប្រគងកាយ ៗ
អាមុខខៀវចង្កូមជាងមួយហត្ថ
ដែលត្រូវសរកាត់ស្លាប់នៅមិនឆ្ងាយ
អានេះឯងដែលជិះតដេទ្រុក្លាយ
ជាកូននាយយក្សាចៅធានី ៗ
មិនដឹងគុណបុណ្យបាបដើរកំហែង
អួតថាឯងមានរិទ្ធិគិតញក់ញី

ចិត្តដូចលា មកនុករាធសាងទេវី លុះជីវិតមិនបានជាប់កាយា ។
ឯបណ្ដាពួកពលបានយល់យក្ស ស្លាប់ប្រពាក់ប្រពួនក៏ស្រែកហៅហា
ព្រះភីរលៀងពីរពង្សអង្គអស្ចា ចុះបង្គំក្សត្រាទ្រង់រិទ្ធី ។

(រឿងទិព្វសង្វារ, ខ្សែ ១, ទំព័រ ៦៤-៧៣)

ទិព្វសង្វារ

<u>Introductory Note</u>

ទិព្វសង្វារ Tip Sangvar, hero of the poem of the same name (lit: Magic Sash)
រាជបុត្រី /riəccəbottrəy/ princess, royal daughter
ព្រះបាទផៃសុរិយា King Phae Soriya, Tip Sangvar's father

ព្រះនាងផៃសុមាលី Queen Phae Somali, Tip Sangvar's mother

កេតុជម្ពូ /keetoq-cumpuu/ a kingdom in the Himalayas
សុវណ្ណគត /sowannəkuŏət/ to die (Roy)

ញ៉ម to be meek, submissive, subdued
ចុះញ៉ម to yield, submit

ព្រះភិរុណ Bhiruna, name of a prince
ព្រះបាទត្រៃបុត្តិ King Traipotti, Bhiruna's father
ព្រះនាងចន្ទរត្ថា Queen Chan Rattha, Bhiruna's mother
ត្រៃបុរី a kingdom in the Himalayas (lit: three cities)

<u>Text (Part I)</u>

ទ្រង់ព្រះមកុដ to put on a crown

សុទ្ធ all of

ព្រះភូសា clothing, costume (Roy)

កម្ពល /kαmpuŏəl/ woolen cloth

កោសេយ្យ /kaosay/ silk cloth

ឆ្លង shoes (Roy)

ឆៀង sash worn diagonally across the chest
មាល័យ /miəlay/ garland of flowers
ឆៀងមាល័យ sash of flowers, garland of flowers
ឆវង្ស /chαα wuŏəŋ/ six families (reference unknown)
សុទ្ធ exactly, just like

រឿណរង្គ /rɨən-ruŏəŋ/ battlefield

ក្លែង --- រឿណរង្គ disguised as a prince going to battle
ពិស្ណុការ /pɨhsnaokaa/ Vishnu

ទ្រង់ royal 3rd person or reflexive pronoun
កោទណ្ឌ (=កោទ័ណ្ឌ) a bow

សរ /sαα/ arrow

ព្រះទំរង់ (finger) ring (Roy)

សង្វារ chain or sash worn across both shoulders, crossing at the chest and fastened with a pin or brooch
ស៊ីសុវត្ថិ /siisowat/ auspicious, felicitous
ស្រស់ស្រួល (= ស្រស់)

អគ្គរេត /qaqkəreet/ wellborn, of high lineage (?)
នឿយណាយ to tire, flag

អញ្ជលី (= អញ្ជុលី) the joined palms

ឥស្សរាពង្ស Siva

អារក្ខ /qaareə̆q/ evil spirit,

demon
សក្តិសិទ្ធិ /saq-sət/ powerful, efficacious
ព្រម all together, including, even
ពុំលង់ straightaway, without delay
ព្រមពុំលង់ without neglecting, even including
កៃលាស name of a Himalayan mountain
ក្រុងកៃលាសច័ក្រ the realm of Kailāsa
ទ្រង់រិទ្ធិបីតាតារាវង្ស [and her] mighty father of stellar lineage
ឥស្សរៈ guardian

ផ្លែងផ្លាញ to destroy

ទមិឡ Tamil (i.e. pagan, wicked person)
ទេវង្ស angels, benevolent spirits
អនុជ /qanoc/ younger sibling (Roy)
អនុជនាថ young mistress (used as a possessive pronoun: her)
យាត (=យាត្រា) to go (Roy, Lit)

ល្វន់ល្វៃ graceful, supple

សាវ young unmarried girl

ប្រាង្គជ័យ (here: the palace)

ឆវី /chaa-wii/ of (lovely) complexion
សុរិល (=សរិល) body

សក្តិសម /saq-sam/ fitting, appropriate (Lit)
វិលវង់ to circle, encircle, orbit

ល្អៀង to deviate, be different, go astray
ឃ្លៀងឃ្លាត (=ឃ្លាតឃ្លៀង)

នឹកដើម to recall, think about

រំជួល moved, agitated

ព្រន័យនិ eyes (Roy)

ល្ហែង flowing softly

រារង់ to hesitate, hold back

ក្តៅឱរា agitated, suffused with emotion
សង្ខារ (= វិញ្ញសង្ខារ)

លួង to soothe, comfort, cajole

ប្រលោម to soothe, comfort, cajole
អសុរា (=អសុរ) demon, giant

ពាធី (=ពាធា) to kill

ឱ្យចំរើនតេជះ may [your] power be enhanced
មារ Mara, enemy of Buddha

យក្សា (=យក្ស) ogre, giant

ស្គាល់ to recognize

មណី precious stone, jewel

ដល់កំណត់ --- សុរិយា at the fore-ordained auspicious time of day
ទន់កាយា to feel weak (with fear), irresolute
កំឡា to encourage; here: to take courage
កំណាន់ close, intimate, favorite

និម៌ល (=និម្មល) pure, faultless

កើយ stile for mounting an elephant or chariot
មង្គល /mŭəŋkŭəl/ success, good luck, happiness
ផ្លេក to flash

យង់ intensifier for adjectives of clarity, brightness, etc.
រថា (=រថ)

សែង ray, gleam

សិល្ប magic, having magic power

កាប៉ូរាល់ (Fr. caporal) chief, commander
ត្រែ bugle, trumpet

ឡ loud, clear, sharp (imitative of the sound of a bugle)

សុកល happy, cheerful

ហ៊ោ to shout, to cheer

ទំរំពង loudly, clamorously

ព្រហ្មិន្ទ /prummɨn/ Brahma + Indra

សុរាល័យ heaven, abode of the angels

ព្រះពាយ the wind (Lit)

ប្រឹថពី (=ប្រថពី) the earth

ផ្លួចផ្លាញ to destroy

សៀម afraid, intimidated

លុត (=លូត ?) to extend above, project

លេបលយ to glide, float

ហែហម to follow along in procession

សារផាត់ /saarəphat/ all kinds, everything

ទ័ង to defend

ប្រុះប្រូង bristling, sticking up

កំរើករិទ្ធិ bursting with power

យកអាសា to protect, defend

ស្ទុះលេចលរ leap and feint

បំពារ to push against

លើក to dispatch, deploy (troops)

ខ្ទរ to vibrate, reverberate, resound

បញ្ជរទ័ព arrange troops in formation

Text (Part II)

វិរាធ /wɨyroə̆t/ name of the ogre with designs on Tip Sangvar

ស្កាត់មុខ across the path of, cutting off the advance of

ជីនករិទ (meaning unclear)

យោវិយាណ youth (i.e. Tip Sangvar)

អគ្គវេតកេតលោកា illustrious, glorious (?)

នគ្គក្រាន beautiful (?)

និរញ្ញន appellation for Bhiruna

ពាំង to shield, block

ភូមិត្រ (=ភូមិន្ទ)

ចក្រី king, prince (i.e. Bhiruna)

លែងកល្យាណ instead of the princess

ផ្លស់ to release, spring back

ខ្វាប់ with a whoosh, with a swish

ច្រេវច្រាវ with a clang, with a clash

ទូហាន brilliant; bold, brave

ហោទូហាន really brave

ពានរិន្ទ /piənərɨn/ name of Bhiruna's faithful monkey

វែធ (=វាត់) to slash, swish, lash

ធ្នូ bow, crossbow

ក្រទា to crouch aggressively

ពង្សនរា /puə̆ŋnəriə/ name of Bhiruna's faithful horse

តេជរិទ្ធ prowess, auspicious power

កុម្ភណ្ឌ /komphoə̆n/ inhuman ogres

ក្រែលក្រាស់ (=ក្រាស់ក្រែល) many

តតេជរិទ្ធ (=តរិទ្ធ) to fight back, resist

ព្រួត to join forces against, gang up on

សំពង to club, beat with a club

រា to hesitate, hold back; here: to subside, cease

នាំគ្នាវិល return together, go back (i.e. /piənərɨn/ and /puə̆ŋnəriə/)

ហត្ថី /hatthəy/ bull elephant

គិល imitative of the sound of a roar of anger or emotion: with a roar

សង្កៀតធ្មេញ to grit the teeth,

grate the teeth, gnash the teeth

ទឹម to take an aggressive stance with hands on the hips

គ្រហឹម to roar (of an animal); to produce a throaty sound of displeasure or disapproval

ងឹល imitative of the sound of a roar of displeasure

កុមារា boy (i.e. Tip Sangvar)

អ័ព្ទនភី darkening the sky, producing a fog, air heavy (with noise)

អគ្គី /qaqkii/ fire (Lit)

បរិទ្យាហ៏ burning, fiery hot

ទទៀប near, close to

ទង្លឹមស្មើរធ្លាក់ (= ស្មើរធ្លាក់ទង្លឹម) to feel shock, acute distress

ជួន it happened that, fortunately, by chance

ភូវនេយ្យ /phuu-nɨy/ master, lord

ទាំងអៀនអន់ shyly, diffidently

ព្រះទសពល /preəh-tuəhsəpuəl/ he who has the strength of ten powerful elephants (i.e. Bhiruna)

ទំថ្លង to shoot, fire (an arrow)

រង្សី /reəŋsəy/ brilliant

ជន់ to flood, inundate

រំលត់ to put out, extinguish

លន់ extremely

ពិនរាជ /pɨnnəriəc/ father of /wɨyroət/ and king of the ogres

អសុរី (= អសុរ) ogre

ហង្ស an appellation for ព្រះវង់សុរិយា

បុត្រី /bottrəy/ daughter (Eleg)

ឯង I (i.e. /pɨnnəriəc/)

វ៉ាន់ to estimate, calculate, figure

លេច to appear, show up

អាវ៉ែង pejorative term of address or reference: you [there]!, [that] bastard!

មិនជាពង្សនេះ are not of [Tip Sangvar's] family

តម្រិះ to think, decide (Roy)

ភ្លាង (= ភ្លាម)

ថ្វី why?

ហប to puff, pant with mouth open

ស្ងើយ unconcerned, indifferent, bland

ក្រឡាស់ត្រឡប់ on the other hand, contrarily; have a turn of fate, have a change of fortune

ឯងនេះ you (Pejorative)

ពូជពង្សា family, lineage

ព្រះវ៉ង (= ព្រះវង់សុរិយា)

ដំណូច (< តូច) smallness, (small) size

ប៉ាងឯង of your kind, of your type

ស្កប់ to be satisfied, sated, fulfilled

មមៀច gnat

ព្រាងព្រាច glimmering here and there

ជា ពា that it is harmless

ជន្មា /cuənnəmiə/ life

ស្តាយជីវិត regret the loss of life

ព្រះភិរុណសុរិយវង្ស Bhiruna

មោហាមិត in a rage, blind with anger

ឃ្លោក gourd

ស្គោក pithy, dried out, dessicated

ស្កក stunted, undeveloped

រៀងរង្សី brilliant, glorious

អា you (Derogatory)

គំរក់ filthy, wicked

លេងគ្នា (Idiom) to fight

ក្រឡាប់ to roll, rotate

ក្រញី to scratch, mangle, shred (with teeth or claws)

ច័ក្រ /caq/ a magical flying disc with jagged teeth

ជៀស្សជ័យ appellation for the Prince

លើល high in the air

លឿនលត់ extremely fast

ទឹព (=ក៏ទ)

ខាន់ (=ទ័ន)

វលាហក /wəliəhakaq/ horse (i.e. /puǝ̆ŋnəriə/)

ខោក to rap, strike (with the knuckles)

ម៉ោក imitative of the sound of rapping, knocking

ប្រួយ to start, spurt, lunge (of a horse)

ក្រុង king, prince, the great... (Lit)

ក្រុងយក្ស king of the ogres (i.e. /pɨnnəriəc/)

ក្រឡះ (=ក្រលាស់)

ចុី stealthily (?)

សំដែង to perform, display; here: to show off, posture

សរថ្លា (=សរទីថ្លថ្លា)

កោលា to throw into disorder, cause panic

ប្រចឡោត to jump up, leap up, burst out

ខុនពេជ្រ (personal name)

ប្រកាប់ do battle, spar (with knives, swords, etc.)

វេះ /weh/ to slip away

ខេខឹង (=ខឹង)

ស្លាំង pale, drained of blood

ព្រះលោហិត blood (Roy)

សោយសោក to grieve

អស្សពាហ៍ /qahsəpiə/ horse (Lit)

ចៅក្រុងយក្ស king of the ogres

និមល (=និម្មល)

កៀង (=គៀង)

ខ ពុ imitative of a gutteral hissing sound

ចំហុត (meaning unclear)

ផុត barely miss, almost reach, just about to, just out of reach

កាត់ខ្មាស to swallow one's pride

យល់ហ្បានការ realize that things were going his way (i.e. with regard to Tip Sangvar's affections)

ទែនប (=ទែនបនិត្យ)

ជូន (=បញ្ជូន)

ព្រះនាសិត nose (Roy)

ថា (empty alliterative word)

គ្រវែង to toss away, throw away (a long object)

ប្រទ័ន (=ព្រះទ័ន)

មីវ somber, dark

ចំរិត following closely behind (?)

សរឥសីសិល្ប an arrow imbued with magic by the hermit (who had raised Bhiruna from childhood)

ផ្ដាច់ផ្ដិលជន្ម to kill

បំពង់ quiver, arrow-holder

យើះយើ interjection of surprise

កុំបង្អង់--- ក្រុងមារ don't delay [in diminishing] the power of the ogre king

ទ្រង់ as if

រីរា (=រេរា) to hesitate, hold back

ទុកឱ្យ---ទាន់ [don't] let him have

the chance to diminish [our] strength

ព្រះភីលៀងទាំងពីរ the two servants (i.e. /piənərɨn/ and /puə̆ŋnəriə/)

សង្គ្រាមជ័យ victory

សំខាន់ crucial

គ្រាន់ pretty good, good enough

រន្ទាន់ repeatedly, in rapid succession

ច្រស /crɑh/ imitative of the sound of hacking, slashing (with a knife)

ផស /phɑɑh/ imitative of the sound of a dull thump or knock

ជួន appropriate, fitting

ពិការ to be crippled

សាប sable

ចាក់សាប to fence

សាំ riddled with marks, cuts, slashes

រិទ្ធា (= រិទ្ធី)

ត្រាំ to be damaged internally

ត្រាំត្រា mauled, injured internally

ទ្រែកទ្រោច (= ទ្រេកទ្រោច)

គគឹកគគាក់ imitative of a rumbling, thunderous sound (such as the approach of a train)

រុឹយ (= រុឺយ)

លេង (Idiom) to fight

ទៀរអស់ដៃ with all one's strength

សិល្បៃស (= សិល្បសរ) [taking] a magic arrow

វាស to gesture, wave, sweep

សរកាយសិទ្ធិ magical arrow

ព្រះអាចារ្យ the sage who raised Bhiruna from infancy

កង្ហារ fanwheel, gyroscope

ខាល់ to spin, twirl, whirl (of a fan or augur)

ទន្ទ្រំ to stomp the feet repeatedly, trample

ស្ដឹងស្ដូក (= ស្ដូកស្ដឹង) to lie motionless

មិនអី be O.K. (i.e. not really injured)

សតិ reason, memory, power of thought

តាំងសតិត្រង់ to think straight, deliberate, stop and think

សែក recite (magic formulae), incant

គាថា saying (esp. of the Buddha), proverb; incantation, magic formula

ប្រសិទ្ធ to bless (here: efficacious)

ឡូក to dance and posture playfully, to clown

ចមពង្ស king (i.e. Bhiruna)

រង្គ war, battle

តរុណរេត young

ពិន highest point, pinnacle; supreme one

សុរិលភក្ត្រពិនកេត extremely fair of face and form

ផ្ចង់ concentrate on

វេទ Veda; magic formula

លង to try, test, experiment with

ទំនងទំនាយ fate, destiny

កំណត់ជន្ម predetermine [the length of] one's life, predetermine one's death

ក្រែង ... ឃោរវិយាន in case the bold ogre is predestined to die by your arrow

ធ្វេសប្រាណ be off guard, careless of one's safety

វាទី the speaker, the one who spoke

ជេដ្ឋា older sibling (Roy)

ព្រះជេដ្ឋា king (i.e. Bhiruna)

កុំថាតែ not only

ថ្កាត់ថ្កាយ (=ថ្កាយ)

អំពាយ so, such, to such an extent

ឥតកាយកើតដូចចិត្ត be able to rejoin one's body at will

ទេវៀរ (=ពៀរ) retribution

អនុធា (=អនុធ)

ថាទេវៀរ--- ប្រសិទ្ធិ his retribution [will come only] from my effective weapon

សិរសិត (=សិរសី)

ទំរង់ ring (Roy)

វង់ specifier for rings

បន្ទូលភ្លាង when [she] had said [this]

សុរ្យកាន្ត /sourəkaan/ sunstone

កែវកញ្ញា precious girl (i.e. Tip Sangvar)

ប្រកលៀស slip away, wiggle free, evade

នាសា nose (Roy)

ព្រះគណ្ឌ cheek (Roy)

ចែង to shine

ក្រឡង់ perfectly round

ផាត់ to powder, dab on powder

ប្រផុរ fine, smooth, silky, powdery

សុដន់ breast

ឧរី /qaorii/ breast, chest (Roy)

ក្សត្រាធិបតី /ksattraathɨppədəy/ supreme king

ធម៌ when following a kinship term: adopted, foster

ខ្វល់ bothered, confused, preoccupied

លុះ until, to the point of

ភ្លាត់ភ្លាំង shocked, speechless, dumbfounded, in a state of suspended consciousness

ចំអក to taunt, mock, make fun of

មនុស្សា (=មនុស្ស)

វង់ (=វុងវៀង)

ភ្លែត quickly, immediately

ដាន path, furrow, trace

អាកាសា (= អាកាស)

សុរង់ neck (Roy)

ផ្ដាច់ (=ដាច់)

ឆរ imitative of the sound of gushing, pouring

ព្រេចវៀវព្រេច all over the place, spraying, spurting

ព្រៃព្រឹក្ស forest

ដាស spread all over, covered

ប្រញាយ scatter in all directions, pell-mell

ឆ្អើល (=ផ្អើល?)

វិសុទ្ធិ (=ពិសុទ្ធិ)

ប្រគង crisscrossing, lying across each other

អាមុខខៀវ a green-faced one (some ogres are traditionally thought to have green skin)

គជេន្ទ្រក្លាយ magically produced elephant

នាយយក្សា ogre chief

ចៅធានី ruler of the city (i.e. of the ogres)

ញាក់ញី to mangle, maul, crumple; here: to destroy, wreak havoc

ទោរី (=ទោរា) trouble, misfortune, negative karma

សាងទោរី create negative karma

ប្រពាក់ប្រពូន piled up higgledy-piggledy

អស្សា /qahsaa/ horse (Lit)

បង្គំ (=ក្រាបបង្គំ) to bow with palms joined, make obeisance

២៦. រឿងព្រះជិនវង្ស

ដោយ

ហ៊ឹង (ព្រះអរិយគាមណី)

បុព្វកថា

រឿងព្រះជិនវង្ស ច្បាប់ដើមមានពីរច្បាប់ប្លែកពីគ្នា ។ មួយច្បាប់មាន ១៩ ខ្សែ ។ ខ្សែទី ១ និងខ្សែទី ២ នៃច្បាប់នេះជាស្នាព្រះហស្តព្រះអរិយគាមណីហ៊ឹង ។ ពីខ្សែទី ៣ ទៅខ្សែទី ១៩ ជាស្នាព្រះហស្តលោកគ្រូញាណត្ថេរ ។ មួយច្បាប់ទៀតមាន ១៦ ខ្សែ ។ ច្បាប់នេះជាស្នាព្រះហស្តព្រះអរិយគាមណីហ៊ឹងទាំងអស់ និពន្ធនៅគ.ស. ១៨៥៦ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ។

រឿងព្រះជិនវង្សជារឿងមួយកំសត់ណាស់ ។ គេតែងយករឿងនេះទៅលេងល្ខោនជារឿយ ៗ ។ ព្រះជិនវង្សជាព្រះរាជបុត្រនៃព្រះបាទសុវណ្ណវង្ស និងព្រះនាងជិនបុប្ផា ។ ដោយការចាក់រុកនៃស្នំឯករបស់ព្រះបាទសុវណ្ណវង្សម្នាក់ទៀត ព្រះជិនវង្សក៏ត្រូវព្រះបិតាដាក់ទ្រុងដែកទម្លាក់ក្នុងសមុទ្រ តែហេតុតែបុណ្យរបស់ព្រះអង្គ ៗ ត្រូវបានភុជង្គនាគមកជួយហែកទ្រុងដែកយកចេញឱ្យបានរស់ជីវិត ។ ក្រោយមកទៀត ក៏ត្រូវមហាឥសីប្រោះឱ្យរស់ឡើងវិញក្រោយដែលយក្ខិណីម្នាក់វាសម្លាប់ ។

ក្រោយបានរស់ជីវិតហើយ ព្រះអង្គក៏ទៅបាននាងបទុមសុរិយា និងនាងសុវណ្ណរេខា ដែលជាបុត្រីរបស់ស្តេចយក្សឈ្មោះមាលិវ័ន និងមហេសីព្រះអង្គ នាងពិចិត្ររេខា ធ្វើជាព្រះអគ្គមហេសី ។

សេចក្តីដកស្រង់មកនេះ ថ្លែងអំពីព្រះជិនវង្សដែលមាននាងបទុមជាមួយផង ជួបប្រទះនូវគ្រោះថ្នាក់ជាលើកទី ៣ ។

អត្ថបទ

(បទភុជង្គ)

ហេតុពៀរពុំនៀរចាំចង ឱ្យនាងប្រាសផង ពីមហាក្សត្រា ។
មានខ្យល់កាចសល់មហិមា រំពេចវិលខ្វារ ទ្រលោមទឹកក្រៃ ។
គួចទ្រង់យន្តហង្សចមត្រៃ ឃ្លូឆខ្លាំងក្រៃ គួចហង្សក្សត្រា ។
គួចឡើងខ្ពង់ខ្ពស់ណាស់ណា ឆរឃូវិលខ្វារ ក្សត្រាក្សត្រី ។
ស្លុតស្លាំងភ័ន្តភាំងស្មារតី ហង្សយន្តពិសី ទៀបផ្កាប់ ៗ ផ្ងារ ។

ធ្លាក់នាងបទុមសុរិយា   ប្រាសពីក្សត្រា   មហាក្សត្រចមត្រៃ ។
ស្តេចខំប្រវា ស្រីថ្លៃ   មិនបានផុតដៃ   ក្សត្រថ្លៃផ្កាប់ផ្ងារ ។
ចាប់ទាន់តែធ្នូខាន់ថ្លា   ខ្យល់គួចក្សត្រា   ទៅទីទៃក្រៃ ។
ខ្យល់គួចនារីតែនិថ្លៃ   គួចហងស្អួក្រៃ   ឆ្ងាយណាស់ពីគ្នា ។
ធ្លាក់ហងស្រលិចក្នុងគង្គា   ធ្លាក់ព្រះរាជា   ទីទៃឆ្ងាយក្រៃ ។
អំពីនារីតែនិថ្លៃ   ធ្លាក់ព្រះចមត្រៃ   ដល់ក្នុងគង្គា ។
មច្ឆាភិតខ្លាចសម្ភារ   ផ្អើលផ្អូកមហិមា   ឆ្ងាយពីក្សត្រថ្លៃ ។
រលកបែកបោកខ្លាំងក្រៃ   បោកផាត់ក្សត្រថ្លៃ   ស្តេចហែលគង្គា ។

(បទកាកគតិ)

បទកាកគតី   យើងស្លេះស្រដី   ពីព្រះរាជា
ត្បិតមានបារមី   ដូចបានពណ៌នា   យើងស្លេះរាជា
ពុំបានថ្លែងឡើយ ។

យើងនឹងថ្លែងថ្លា   ពីនាងសុរិយា   នោះឯងវិញហើយ
កាលធ្លាក់ទេវី   ប្រាសពីត្រាណត្រើយ   ទៅទីទៃហើយ
ហេតុបារមីតា ។

កាលធ្លាក់ស្រីថ្លៃ   ដល់ទឹកជលស័យ   ឯអស់មច្ឆា
ព្រួសព្រួសឡើក   ខួងទឹកជលសា   ធ្លាក់នាងនោះណា
សែនមហាខ្លាំងក្រៃ ។

ហាក់សុមេរា   ធ្លាក់ចុះសោះសា   ខ្ទប់នឹងជលស័យ
ព្រួសស្ទុសឡើក   គ្រេងគ្រឹកខ្លាំងក្រៃ   ត្រីផងខ្លាចក្ស័យ
ភិតភ័យម្នីម្នា ។

ផ្អើលរត់ខ្ចាត់ខ្ចាយ   ប្រញាប់ប្រញាយ   ឆ្ងាយពីជាយា
មិនតែម្លោះហើយ   ហេតុបុណ្យសម្ភារ   កក្រើកដល់នា
នាមាមច្ឆា ។

សុវណ្ណឱឌ៏រ៍   ក្រពើមាសម័យ   រួងនៅបព្វតា
ក្នុងមហាសមុទ្រ   ក្រពើគិតថា   អញនៅនេះណា
កល្បសល់សែនហើយ ៗ

មិនដែលច្នេះណា   កក្រើកបព្វតា   រួងអញច្នេះឡើយ
នេះម្ដងឮទឹក   សន្ទឹកច្នេះហើយ   អញខានម្ដេចឡើយ
ចេញទៅមើលដែន ៗ

ក្រពើគិតស្រេច   ទំពេចហែលត្រាច់   ពីរួងវៃ ញ
ប្រៀវប្រែមុជរក   ឃើញនាងប្រពៃ   ទ្រង់ឆោមល្មមល្អៃ
ក្រពើនោះណា ៗ

ខ្លាចព្រះបារមី   ស្រឡាញ់ក្សត្រី   នឹកក្នុងចិន្តា
នឹងស្រង់នាងនាថ   ក្សិណប្រែកាឡា   ខ្លួនជាធីតា
កន្ទុយវែងផង ៗ

ចូលពជាយា   ពីក្នុងគង្គា   ដើបឡើងជាម្ដង
ពនាងទេវី   ខ្ពស់ពីទឹកផង   ក្សត្រីស្ទើស្ទង
ភ្ញាក់ព្រះស្មារតី ៗ

នាងអរកន្លង   លើកព្រះហស្ដផង   បង្គំឆាប់ក្រៃ
ហើយនាងធីតា   ថ្លែងថាម្ចាស់ថ្លៃ   ព្រះគុណធ្ងន់ក្រៃ
ឥតឯគណនា ៗ

មកស្រង់ខ្ញុំឆាប់   កុំអីខ្ញុំស្លាប់   នៅក្នុងគង្គា
ព្រះគុណនាងថ្លៃ   ធ្ងន់ក្រៃមហិមា   សូមទេពសម្ភារ
មេត្តាចម្លង ៗ

អញខ្ញុំនេះហើយ   ឱ្យបានដល់ត្រើយ   សមុទ្រនាយហោង
សូមថ្លៃធីតា   មេត្តាខ្ញុំផង   ឱ្យខ្ញុំនេះហោង
ដល់ត្រើយធរណី ៗ

ក្រពើនារី ព្ននាងទេវី អង្វរថ្នោះខ្សឹ
កញ្ញានោះមច្ឆា ដណ្ដឹងថាស្រី ក្រមុំប្រិមប្រិយ
នាងមកពីណា ។

បានជាមកធ្លាក់ ក្នុងទឹកតែម្នាក់ ឯងក្នុងជលសា
ហេតុម្ដេចដូច្នេះ ចូរប្រាប់យើងរ៉ា នឹងជូនធីតា
ឲ្យដល់ត្រើយផង ។

ក្សត្រីរស់ជន្ម ព្ននាងសុវណ្ណ ឲ្យរ៉ៃសួរសង
នាងប្រាប់សេចក្ដី ឥតបីខ្វះផង កញ្ញានោះស្នេហ៍ស្នង
សុវណ្ណឲ្យរ៉ៃ ។

ក្រពើកាឡា ព្ននាងធីតា ប្រាប់ហើយជឿក្រៃ
សឹងអាសូរនាង នេត្រភ្លាងថាហៃ បទុមថ្លាថ្លៃ
គាប់ចៃយើងបាន ។

មកស្រង់នាងឆាប់ កុំអីនាងស្លាប់ ក្នុងទឹកមិនខាន
យើងស្រង់នាងហើយ ជូននាងឲ្យបាន ទៅដល់ត្រើយត្រាណ
ត្រាច់រកសង្សារ ។

ក្រពើនារី ជាស្ដេចជលធី សំណេះចរចា
នឹងរាជមហេសី សព្វគ្រប់ប្រការ ស្រេចហើយមច្ឆា
កន្ទុយវីធរ៉ៃ ។

បក់ទឹកខ្លាំងក្រៃ ហែលលឿនប្រៀវប្រៃ ទៅលុះដល់នៃ
ត្រើយត្រាណធរណី ឆ្នេរខ្សាច់ប្រពៃ ក្រពើមាសម័យ
ដាក់នាងធីតា ។

លើខ្សាច់ហើយហោង ក្រពើស្នេហ៍ស្នង លានាងធីតា
ហិចហែលទៅវិញ មុជស្កាត់មច្ឆា ចាប់បរិភោក្ដា
ចូលរូងវិញហោង ។

(បទព្រហ្មគីតិ)

យើងថ្លែងជាបទព្រហ្ម- គីតិកាលអំពីនួនល្អង
ក្រពើមាសចម្លង ដាក់ដល់ផងលើឆ្នេរខ្សាច់ ៗ
ហើយក្រពើកាឡា លាធីតាទៅវិញស្រេច
ក្រោយនោះនាងខំត្រាច់ រកសម្ដេចព្រះរាជា ៗ
នាងភិតភ័យតក្កមា ហើយធីតារត់រេរា
រកមើលព្រះរាជា ដោយគង្គាឆ្នេរខ្សាច់ផង ៗ
នាងពុំយល់ចក្រវិត សម្លាញ់ចិត្តនាងទៀយហោង
នាងទ្រហោជាម្ដង គក់ទ្រូងផងស្រែកយំថា ៗ
ថាឱ្យព្រះជិនវង្ស ច្បាស់ព្រះអង្គទៅឯណា
មិនឃើញមហាក្សត្រា ច្បាស់ទៅណាអម្ចាស់អើយ ៗ
ខ្ញុំស្មានជាព្រះបង ស្ដេចហែលឆ្លងដល់ត្រើយហើយ
មិនដឹងច្បាស់ទៅទៀយ ឱប្ដីអើយដឹងជាម្ដេច ៗ
កម្មព្រេងអ្វីមកដល់ បាបអកុសលអ្វីមកផ្ដាច់
ព្រះមាសសង្សារសាច់ ផ្ដាច់ពីទ្រូងប្អូនច្បាស់ទៅ ៗ
កំពុងតែសប្បាយ ក្សត្រឆោមឆាយនឹងប្អូនពៅ
ជិះយន្តទត្រីនៅ សមុទ្រជ្រៅនៅនោះទេ ៗ
ម្ដេចមានខ្យល់អាក្រក់ ខ្លាំងដូចឆក់បក់វិលវេ
បម្រាសយើងទាំងទ្វេ ឱ្យទូរេប្រាសចោលគ្នា ៗ
នាងទួញនាងទូលទៅ ថ្លែងដោយនូវពាក្យសច្ចា
ឱគុណកែវថ្លៃថ្លា គុណទេវតាព្រះឥន្ទ្រា ៗ
សូមឱ្យគុណថ្លៃនោះ ជួយអនុគ្រោះព្រះរាជា
ឱ្យរស់ព្រះជន្មា បានជួបជាស្វាមីខ្ញុំ ៗ
សូមឆុតដូចសច្ចា ខ្ញុំនេះណាប្រាថ្នាសុំ
កុំឱ្យប្រាសពីខ្ញុំ សូមព្រះអង្គជួយនេះម្ដង ៗ
នាងផ្សងស្រេចហើយណា ទើបធីតាប្រះប្រាណផង

ននៀលនៅនោះហោង សោកភ័យផងច្បាស់ស្មារតី ៗ
សូនស្រព្វនៅនោះណា យូរមហិមា ទើបមហេសី
នាងភ្ញាក់ព្រះស្មារតី ហើយក្សត្រីត្រាច់លីលា ៗ
ខិតខំរកស្វាមី រាជមហេសីសោកមហិមា
ជោរជន់ព្រះនេត្រា នេត្រជាយាទតរំពៃ ៗ
សព្វថ្លុកចង្អូរខ្សាច់ ពុំឃើញស្ដេចនៅនោះនៃ
នេត្រនាងភ្លាងរំពៃ ទតទៅនៃសមុទ្រស្ដែង ៗ
សមុទ្រធំកន្លង រលកផងបែកផ្កាត្រែង
នាងមិនឃើញស្ដេចស្ដែង ឃើញតែផ្សែងងងឹតក្រៃ ៗ
នាងត្រាច់នាងរុករក ព្រះពន្លកដោយទីទៃ
សសិតបន្លាព្រៃ ថ្លក់ជាប់នៃព្រះកេសា ៗ
នាងសោយសោកបណ្ដើរ ដោយដំណើរនាងធីតា
ទតយល់ហង្សបក្សា ទំសាខាដើមមហាហង្ស ៗ
នាងនឹកដល់ក្សត្រា នឹងធីតាទាំងពីរអង្គ
ជិះលើសុវណ្ណហង្ស ហោះបង្អង់មើលមច្ឆា ៗ
នាងសោកហើយក្សត្រី ត្រាច់ទៅខ្មីរកសង្សារ
យល់ចាបព្រៃបក្សា ទំសាខាដើមធ្មេញត្រី ៗ
នាងនឹកដល់អង្គា កាលជាយានឹងស្វាមី
គង់ហង្សមាសមើលត្រី ហើយមហេសីសោកឥតស្បើយ ៗ
នាងសោករកសង្សារ ស្រក់នេត្រាត្រាច់ទៅហើយ
នាងរកពុំឃើញទេឡើយ ហើយធីតាយល់បក្សី ៗ
ពពេចទំពពាយ ព័ទ្ធឆ្វៀលឆ្វាយចង់ចុះខ្មី
នាងនឹកដល់ស្វាមី ហើយក្សត្រីសោកាថា ៗ
ឱ៍ដើមពពាយអើយ អញយល់ហើយហាក់វិតា

បំភ្លូកហង្សអញ្ញយោ   ផ្លាក់កន្ត្រានឹងអញ្ញហោង ៗ
អពីហង្សមាសម័យ   ផ្លាក់ចុះនឹងព្រាត់គ្នាផង
ពីព្រោះខ្យល់នោះហោង   ព្រាត់ព្រះបងដូច្នោះហើយ ៗ
ជាតិនេះខ្ញុំប្រាសស្តេច   កម្មមកផ្តាច់ព្រះត្រាណត្រើយ
សូមសព្វជាតិទៅហើយ   ថ្លៃបងអើយខ្ញុំប្អូនស្រី ៗ
សូមជួបសព្វ ពុ ជាតិ   កុំបីឃ្លាតពីចក្រី
បើស្តេចកើតជាអ្វី   ខ្ញុំប្អូនស្រីសូមកើតផង ៗ
សូមកើតជាពនិតា   នៃកន្ត្រាដូចបំណង
សូមកុំឱ្យឃ្លាតហោង   ដរាបផងដល់និព្វាន ៗ
និរទោសនិរទុក្ខា   និរតណ្ហាក៏មិនមាន
ពាក្យអើយពាក្យពេជ្ញញ្ញាណ   កុំឱ្យមានហៅឃ្លាតថ្លៃ ៗ
នាងខំត្រាច់យាត្រា   រកសង្សារទៅឆ្ងាយទ្រែក
វង្វេងភ្លេចអស់ព្វ   តែស្រីថ្លៃខំដើរទៅ ៗ
ប្រទះសឹងសព្វសត្វ   សាហាវក្តាត់ក្នុងព្រៃជ្រៅ
សត្វផងឃើញនាងទៅ   សត្វយោរយៅជៀសទៅឆ្ងាយ ៗ
នាងសោយសោកបណ្តើរ   ដោយដំណើរនាងឆោមឆាយ
ឃើងស្លេះពុំនិយាយ   នឹងបរិយាយពីកិន្នរី ៗ

(បទភុជង្គ)

ថ្លែងបទភុជង្គស្រដី   មានស្តេចកិន្នរី   ពិសីពីរប្រាណ ៗ
មេបាកិន្នរថ្កើងថ្កាន   ជរាបៀតបាន   លុងលុះជន្មា ៗ
នៅតែបុត្រីស្នេហា   នាងបងនាមា   សុវណ្ណកិន្នរី ៗ
នាងប្អូនស្រីស្ងួនពិសី   នាមកែវកិន្នរី   ទាំងពីរកិន្នរ ៗ
នៅនាគុហាមាសថ្ម   ក្បាច់ក្បូរស្អិតស្អ   ពណ៌ថ្មនោះណា ៗ

បវរកិន្នរថ្លៃថ្លា   មែនមានបរិវារ   កិន្នរច្រើនក្រៃ ។
ចោមចាំបំរើនាងថ្លៃ   មានកាលមួយថ្ងៃ   កិន្នរីទ្វេហារ ។
ទ្រង់គ្រឿងរុងរឿងសោភា   ហើយបបួលគ្នា   ទៅលេងព្រឹក្សព្រៃ ។
អស់ហ្វូងកិន្នរផងនៃ   ហែនាងល្មមល្មៃ   ចេញលេងព្រៃផង ។
ច្រៀងលេងសើចលេងអឹងកង   បេះបានផ្កាផង   ថ្វាយនាងកិន្នរី ។
ទាំងពីរនារីប្រិមប្រិយ   ច្រៀងប្រួចស្រដី   សរសើរផ្កាថា ។
បងអើយបងបេះពីណា   នេះផ្កាចម្ប៉ា   ក្រអូបឈ្ងប់ក្រៃ ។
កិន្នរថ្វាត់ថ្វាយផ្កាថ្លៃ   ខ្ញុំបេះពីព្រៃ   មកថ្វាយថ្លៃលេង ។
ទាំងពីរនារីទទ្នេង   ទទួលផ្កាលេង   ក្រសាលសប្បាយ ។
កាច់កែទេរាំថ្វាត់ថ្វាយ   ផ្អៀងផ្អងនាយអាយ   មើលផ្កាចម្ប៉ា ។
បក្សីកិន្នរីនានា   កាច់កែកាយា   រាំហែនាងថ្លៃ ។
នារីទាំងពីរប្រិមប្រិយ   កាន់ផ្កាពិសី   ដោយខ្លួនឈានឈរ ។
ព្រោះផ្លាស់ប្ដូរគ្នាវិលវែរ   ទទួលចាប់យកី   បានតម្រិតលំនាំ ។
ស្ទុយស្ទើតចំអើតទន្ទាំ   ទន្ទេររាំ   លំនាំត្រូវគ្នា ។
កិន្នរីពិសីសោភា   ត្រេកអរកាន់គ្នា   ប្ដូរផ្កាសប្បាយ ។
កិន្នរខ្លះផ្លាស់ផ្កាថ្វាយ   កិន្នរខ្លះឆ្ងាយ   ថ្វាយបន្តគ្នា ។
ខ្លះទៅបេះផ្កាម្ទីម្ទា   បានហុចឱ្យគ្នា   ផ្កាយ៉ាងល្អក្រៃ ។
លន្ដែពុតធ្លុងដកម៉ែ   មាលតីរីកក្រៃ   ចម្ប៉ាក្ដាំងងា ។
បេះបានថ្វាយបន្តគ្នា   ផ្លាស់ឱ្យពុំងា   បានលេងសប្បាយ ។
កិន្នរខ្លះទៅរកឆ្ងាយ   ឃើញនាងឆោមឆាយ   ក្នុងព្រៃនោះណា ។
ភ្ញាក់ព្រើតខំអើតងាកងា   ស្រទាងបក្ខា   ប៉ុនប៉ងនឹងហើរ ។
មើលជាក់ឃើញនាងប្រសើរ   មិនបានជាហើរ   សម្លបស្លាបវិញ ។
ធ្វើប្រាណកន្ត្រានមើលមិញ   សម្លបស្លាបវិញ   ប្របាំងនឹងព្រៃ ។
ផ្អៀងកប្រចហមាត់ដែន   រពឹងរំពៃ   យល់នាងល្អណាស់ ។

ភក្ត្រឈ្មួងបំព្រងត្រចះ ទៀងលេចល្អណាស់ ល្មមថ្លៃអង្គា ។
កិន្នរត្រេកអរមហិមា ខានរកមាលា វិលវិញជាម្តង ។
ដើរហើយទទះស្លាបផង ឆាប់ក្រែកក្លង ដល់នាងកិន្នរី ។
ឱនអង្គបង្គំទូលខ្មី ថាម្ចាស់ពិសី ខ្ញុំទៅរកផ្កា ។
ប្រទះនឹងស្រីនោះណា ក្នុងព្រៃព្រឹក្សា ម្នាក់ឯងហៅហ៊ាន ។
សម្បុរសំបកខ្លួនប្រណ ល្អពន់ប្រមាណ ព្រះភក្ត្រប៉ប្រែ ។
នារីទាំងពីរថ្លាថ្លៃ ញុហើយអរក្រៃ ចង់ឃើញពេកក្តាត់ ។
កិន្នរថែងផ្កាចោលថ្វាត់ រាជកិន្នរសត្វ បបួលគ្នាថា ។
ប្អូនអើយយើងទៅមើលរ៉ា ឱ្យឃើញដូចថា វាល្អម្តេចហោង ។
ប្រិមប្រិយស្រដីសើចផង ឆោមឆាយញ៉ែងញ៉ាង យាងយាសយាត្រា ។
ឯអស់កិន្នរបរិវារ ហែនាងយាត្រា កាន់ផ្កាភ្ញីផង ។
នារីទាំងពីរស្នេហ៍ស្នង ត្រាច់ទៅហើយហោង ដល់ហើយក្សត្រី ។
ឃើញនាងទ្រង់ឆោមពិសី ទាំងពីរកិន្នរី ដណ្តឹងទៅថា ។
នាងអើយនាងមកពីឯណា នាងល្អថ្លៃថ្លា មករកអ្វីនែ ។
នាងល្អមហាល្អប្រពៃ ចូរប្រាប់មកនែ ឱ្យយើងដឹងផង ។
បទុមសុរិយានួនល្អង ឃើញកិន្នរផង មកកាន់ក្សត្រី ។
នាងថ្លែងប្រាយប្រាប់ទៅខ្មី អស់សព្វសេចក្តី ហើយថាថ្លៃអើយ ។
អញមកម្នាក់ឯងឥតត្រើយ ព្រោះអញនេះហើយ ព្រាត់ប្រាសពីប្តី ។
អញមករកព្រះចក្រី ក្រែកងបងកិន្នរី បានឃើញព្រះបង ។
ស្វាមីអញឯងនេះហោង ក្រែកងបងឃើញផង ប្រាប់កុំលាក់ទៀយ ។
កិន្នរីប្រិមប្រិយឆ្លាស់ឆ្លើយ នាងបទុមអើយ យើងមិនឃើញទេ ។
ព្រៃអាយមិនមានទំនេរ នឹងភ្នែកយើងគេ យើងត្រាច់សុសសាយ ។
មិនឃើញប្តីនាងឆោមឆាយ សោះទេថ្លៃអាយ ព្រៃអាយស្វាត់ក្រៃ ។
យើងសូមអញ្ជើញស្រីថ្លៃ នាងនៅអាយព្រៃ នឹងយើងជាម្តង ។

ក្រែងបុណ្យប្ដីនាងបានផ្សង បានរស់រូបឆ្លង មកតាមនាងថ្លៃ ។
មកដល់ព្រៃអាយផងព្ង យើងនាំនាងថ្លៃ ស្កាត់រកព្រះបុង ។
បទុមសុរិយានួនល្អង ស្ដាប់ចូរចិត្តផង ទើបនាងឆ្លើយ ថា ។
បើនៅខ្ញុំសោតនៅណា បើនាងមេត្តា ដូចថានេះម្ដង ។
អរគុណនាងលន់កន្លង ខ្ញុំនឹងនៅផង ចាំរក្សាមី ។
ទាំងពីរនារីកិន្នរី ឮនាងពិសី ព្រាក់ព្រមនៅផង ។
កិន្នរត្រេកអរកន្លង ពោលអង្អែលខ្នង នែនាងស្រីថ្លៃ ។
ខ្លះបេះបន្លាពីស្បៃ ពីសក់ស្រីថ្លៃ ស្រេចហើយកិន្នរ ។
ទាំងពីរសោមនស្សស្មោះសរ អញ្ជើញបវរ បទុមសុរិយា ។
ថាថ្លៃអើយចូរយាត្រា ទៅនឹងយើងរ៉ា ឲ្យដល់គុហា ។
ឋានយើងសប្បាយមហិមា អញ្ជើញលីលា ទៅឥឡូវហោង ។
បទុមសុរិយានួនល្អង ឮកិន្នរផង អញ្ជើញក្សត្រី ។
ទៅឯគុហានោះខ្ញី ទើបនាងពិសី យាងយាសយាត្រា ។
កិន្នរនាំនាងធីតា ដលនេត្រទ្វារ បណ្ដើរនាងទៅ ។
បានដល់គុហាលំនៅ ឲ្យនាងស្រីពៅ ស្រង់ព្រះគង្គា ។
សឹងយកទឹកអប់គន្ធា កិន្នរទ្វារ កាន់ទឹកដោយដៃ ។
ទើបនាងផ្លាស់ព្រះពស្ត្រថ្លៃ ផ្លាស់គ្រឿងអស់ព្ង ហើយកិន្នរផង ។
ស្រោចស្រប់ស្រង់នាងនួនល្អង លាងធូលីផង នួនល្អងល្អក្រៃ ។
ភ័ក្ត្រប្រិមញញឹមប៉ប្រៃ នាងទ្រង់គ្រឿងថ្លៃ ស្រេចកិន្នរី ។
រើសយកផលាថ្នាងថ្មី មានរសពិសី ឲ្យនាងភោក្ដា ។
នាងនឹកដល់មហាក្សត្រា ខានសោយផលា សោយសោកាណល់ ។
កិន្នរឃើញនាងសោយសល់ ពុំបានសោយផល សោយតែសោកា ។
នាងកែវកិន្នរធីតា នាំនាងលេងណា កំសាន្តសោកផង ។
មិចភ្នែកនិយាយស្នេហ៍ស្នង ទៅកាន់នាងបង សុវណ្ណកិន្នរ ។

ថាអ្នកបងថ្លៃបវរ   សុវណ្ណកិន្នរ   ចូរអ្នកបងរ៉ា ៗ
មើលយាមឱ្យនាងសុរិយា   តើថ្ងៃឯណា   នឹងជួបប្តីផង ៗ
ត្បិតយាមអ្នកផុតកន្លង   តែងទាយត្រូវផង   មិនដែលខុសក្រៃ ៗ
មើលឱ្យពិនិត្យពិស្ម័យ   រាប់ខែរាប់ថ្ងៃ   ឱ្យជាក់ជាម្តង ៗ
សុវណ្ណកិន្នរស្នេហ៍ស្នង   មើលមុខគ្នាផង   ដឹងដោយប្រាជ្ញា ៗ
ថាប្អូននាំនាងសុរិយា   កុំឱ្យសោកា   នាំកម្លាផង ៗ
នាងដឹងដូច្នោះហើយហោង   ទើបនាងស្នេហ៍ស្នង   សុវណ្ណកិន្នរី ៗ
ធ្វើជារាប់ជើងរាប់ដៃ   រអួចស្រដី   យូរបន្តិចថា ៗ
ជាហេតុចៃដន្យទេវា   នាំបុត្រធីតា   សុវណ្ណកិន្នរី ៗ
ឱ្យនាងទាយត្រូវទៅថ្មី   ទើបរាជកិន្នរី   ស្រដីទាយថា ៗ
ប្អូនអើយយាមបងនេះណា   ចំណានទាយថា   មិនដែលខុសម្តង ៗ
ឯប្តីសុរិយាខ្លួនល្អង   ស្អែក ៣ នេះហោង   ជួបគ្នាហើយណា ៗ
ធ្វើស្លូតមុខមាត់ទាយថា   ប្រាកដច្នេះណា   ស្អែក ៣ នេះហោង ៗ
បទុមសុរិយាខ្លួនល្អង   ព្ទកិន្នរបង   ស្រដីច្នេះក្រៃ ៗ
នាងជឿមិនមានសង្ស័យ   នាងត្រេកអរក្រៃ   នឹងកិន្នរថា ៗ
នាងគ្រាន់រសាយទុក្ខា   ហើយទើបធីតា   នាងសោយផលផង ៗ
ឯនាងកិន្នរទាំងសង   យល់នាងខ្លួនល្អង   ស្បើយសោកហើយណា ៗ
ត្រេកអរដោយនាងកម្លា   កិន្នរទ្វេហារ   សោតសឹងអរក្រៃ ៗ
បងប្អូននាំនាងស្រីថ្លៃ   លេងសើចសព្វថ្ងៃ   មិនឱ្យមានហ្មង ៗ

(បទកាកគតិ)

បទកាកគតី   ថ្លែងពីមហេសី   ស្លេះនៅនេះហោង
យើងនឹងថ្លែងពី   ពោធីច្បាស់ច្បង   ហង្សភ្លូកហើយហោង
ធ្លាក់ព្រះរាជា ៗ

ស្ដេចភ័យរួសរាន់ ឈោងចាប់មិនទាន់ ព្រះប្អូនឃ្លាតឃ្លា
កាន់តែព្រះខ័ន នឹងធ្នូសរថ្លា ធ្លាក់ព្រះរាជា
ចុះដល់ទឹកខ្សឺ ។

មច្ឆាទាំងឡាយ ភិតភ័យរត់ឆ្ងាយ ខ្លាចព្រះបារមី
គឺមោះកម្មស្ដេច ពីព្រេងជាតី តាមទាន់ចក្រី
ឱ្យរងវេទនា ។

កាលធ្លាក់ពោធី ក្នុងមហានទី កាលនោះរាជា
ស្ដេចសៀតខ័នថ្លា ធ្នូរសោភា ធ្នូព្រះរាជា
អណ្ដែតស្កុងស្កល់ ។

ស្ដេចហែលពពាក់ នឹងធ្នូសរអ្នក អណ្ដែតដោយកល់
ដោយទឹករលក ខ្យល់បោកខ្លាំងសល់ ស្ដេចហែលតាមខ្យល់
ពុំយល់ទិសត្រើយ ។

ព្រះមហាក្សត្រក្សាន្ត ស្ដេចអធិដ្ឋាន សីលប្រាំស្រេចហើយ
ស្ដេចនឹកដល់គុណ ទូលទុក្ខជាត្រើយ ក្សិណពុំលង់ឡើយ
ស្ដេចសោយសោកា ។

ថាឱ្យអញមកក៏ ទែមនក្នុងសាគរ ទឹកទៃប្រនេះណា
ហេតុកម្មមកផ្ដាច់ សម្រេចសង្ខារ ច្នេះបានពីតា
អញបបួលផង ។

ផ្លូវនេះទៃន ស្លាប់ដោយទីទៃ ប្រាសម្ដេចច្នេះហោង
បងយកប្អូនមក ថាជាសុខផង មិនដឹងឡើយហោង
នេះម្ដងមកក្ស័យ ។

ពោធិសម្ភារ ស្ដេចទុកចិត្តថា ព្រះអង្គក្សិណក្ស័យ
តឿតយល់សមុទ្រ ទូលាយធំក្រៃ ទើបមហាក្សត្រថ្លៃ
ទួញទៅជននី ។

និងព្រះបិតា ព្រះឱស្ឋគិតថា ឱគុណទាំងពីរ
សមកូនពុំបាន សងគុណទាំងទ្វី ឱព្រះជននី
មកជួយខ្ញុំផង ។

គុណកែវទាំងបី នូវគុណកោសិយ សូមជួយខ្ញុំផង
ឱ្យខ្ញុំបានរស់ ជាមនុស្សនេះម្ដង ឱ្យខ្ញុំបានសង
គុណព្រះមាតា ។

ហេតុតែបារមី សច្ចំខន្តី កតញ្ញុតា
ស្ដេចសាងច្រើនជាតិ មកពេកណាស់ណា កាលមហាក្សត្រា
នឹកគុណនានា

ឱ្យជួយស្ដេចផង នឹកដូច្នោះហោង ហេតុបុណ្យរាជា
ព្រួតប្រជាបដឹងដល់ សម្ដេចឥន្ទ្រា ហាក់ដូចរាជា
ថានៅកាមា ។

ព្រះឥន្ទ្រឮជាក់ បែរបើកទិព្វចក្ខុ ទតយល់ក្សត្រា
ស្ដេចហែលលំបាក ក្នុងទឹកជលសា ព្រះឥន្ទ្រថ្លៃថ្លា
ដឹងថាចមត្រៃ ។

ព្រះឥន្ទគិតស្រេច តែមួយរំពេច ចាកឋានទិព្វថ្លៃ
ត្រៃត្រឹងស្រួគ៌ា ហៀវហោះច្រៀវទៃប្រច ដល់ទឹកជលស័យ
ឆ្ងាយពីក្សត្រា ។

សមមើលឃើញផង ព្រះឥន្ទច្បាស់ច្បង បានប្រែកាឡា
ជាចាស់មួយអ្នក សក់ស្កូវសោះសា ហើយកាន់ច្រវា
ឱនអុំនាវា ។

ធ្វើនេសាទផង ទូកតូចកន្លង ហើយលេចមហិមា
ប្លោងប្លោងអែបមក ទៀបដល់រាជា ធ្វើឈប់រេរា
បាចទឹកទូកផង ។

ឮតែរខាក	រលកខ្យល់បោក	ប្លេងប្លោងផ្អៀងផ្អង
ហាក់នឹងក្រឡាប់	ផ្កាប់លិចជាម្តង	ហើយស្រែកថាផង
	ខ្យល់ម្តេចម្ល៉េះណា ៗ	
ឯក្សត្រតោកយាក	ប្រឹងហែលលំបាក	ឮមាត់មនុស្សា
ស្តេចទតមើលទៅ	ស្មានជាពនិតា	ពុំឃើញសង្សារ
	ឃើញឯតាចាស់ ៗ	
ជិះទូកតូចលន់	ហើយលិចពេកពន់	គាត់ខំច្រាចណាស់
ស្តេចទតជាក់ហើយ	ឃើញជាមនុស្សចាស់	ស្តេចអរពេកណាស់
	ត្រាស់ហៅទៅផ្គង ៗ	
ថាតាអើយតា	ស្រង់ខ្ញុំផងណា	ឱ្យរស់នេះម្តង
តាមកអាយមក	យកខ្ញុំទៅផង	យកតែបុណ្យហោង
	មកណាអើយតា ៗ	
ឯតាកោសិយ	ឮព្រះនរបតី	ហៅថ្នាះហើយណា
ធ្វើជាមិនឮ	មិនឃើញសោះសា	ប្រឹងច្រាចឈូទា
	ប្រចវា វាតតាស់ ៗ	
តម្រង់ទូកក្រែ	តែនៅនោះនែ	ប្លេងប្លោងងោកងាស
ឱន ៗ ងើប ៗ	ទទាំងទទាស	ក្សិណឆ្ងូតក្សិណគាស់
	ធ្វើមិនឮផង ៗ	
ឯពង្សពុទ្ធា	យល់ចាស់ព្រឹទ្ធា	មិនឮហៅហោង
ទើបមហាក្សត្រា	ហៅទៀតជាម្តង	តាអើយស្រង់ផង
	នែតាអើយតា ៗ	
ឯអង្គកោសិយ	ឮព្រះចក្រី	ស្រែកហៅណាស់ណា
ទើបធ្វើជាភ្ញាក់	កន្ត្រាក់សិរសា	ចំអើតហើយណា
	បាំងដៃមើលក្សត្រ ៗ	

ធ្វើហាក់ខ្វាហើយ មិនចង់ស្រង់ឡើយ ទ្រគោះស្ដីថ្វាត់
ចង់ល្បងលចិត្ត ចិន្ដាមហាក្សត្រ ចង់ដឹងប្រតិបត្តិ
ព្រះមហាក្សត្រថ្លៃ ។

ទើបឆ្លើយទៅថា ខ្វាមកពីណា ហៅអញជួយក្រៃ
ស្រណោះពេកណាស់ ឲ្យស្រង់ម្ចាស់ថ្លៃ កោតតែចេះស្ដី
បញ្ញាតជាល្បែង ។

កំឡាំងគាត់ណា មកឧបការ បំរើអញឯង
មកលង់លិចទូក ស្រែកហៅក្តែងៗ ឲ្យស្រង់អ្នកឯង
មិនស្រង់ទេវី ។

ទូកអញផងអញ អញជិះម្នាក់អញ អញអំពល់អី
នឹងឯងដែលឃុំ យោបំហាស្ដី បញ្ញាតទេថ្វី
អញកោតតែថា ។

ស្មើអញជាខ្មោច មិនដឹងស័ព្ទសោច ជាមនុស្សឥតការ
ហាក់មកបញ្ញាត លើមើលទេណា មកររករបរការ
អ្វីឲ្យអញឯង ។

ក្សត្រហែលគង្គា ព្ទចាស់ព្រឹទ្ធា អស់ទោះថ្លាថ្លែង
ប្រកែកពីស្រង់ ព្រះអង្គជាក់ស្ដែង ទើបស្ដេចថ្លាថ្លែង
លោមទៅទៀតថា ។

ឲ្យតាម្ចាស់ថ្លៃ កុំថាច្នោះនៃ យកបុណ្យទៅតា
ស្រង់សត្វលង់ទឹក បានបុណ្យណាស់ណា ស្រង់ខ្ញុំផងរ៉ា
ទៅណាទៅផង ។

ខ្ញុំចេះអុំណាស់ នឹងខ្វាតនឹងគាស់ ខ្ញុំចេះណាស់ហោង
បញ្ញានូវខ្ញុំ អុំហើយបាចផង ឯអ្នកតាហោង
មិនឲ្យព្រួយឡើយ ។

ឯចាស់កាឡា ដឹងជាក្សត្រា បន្ទូលជាក់ហើយ
ស្ដីត្រូវនឹងវត្ត ប្រតិបត្តិជាត្រើយ ពាក្យប្រសើរហើយ
ទើបចែងទៅថា ។

ហៃមហាសប្បុរស បើចេះទាំងអស់ វាតគាស់ម្ដេចម្ដា
ប្រាកដដូច្នោះ តាស្រង់អ្នកណា ឱ្យរស់រូបា
យកបុណ្យនេះម្ដង ។

បុណ្យអ្នកឯងណា ឱ្យចម្លងតា ដល់និព្វានផង
ជាតិនេះឯតា ចម្លងអ្នកហោង ដល់ជាតិក្រោយផង
អ្នកចម្លងតា ។

ក្សត្រហែលជលធី ឮតាចាស់នី - យាយប្រាប់ច្នោះណា
ទើបពុទ្ធង្កូល បន្ទូលទៅថា តាអើយអីតា
អើខ្ញុំព្រមហោង ។

តាចាស់កោសិយ មាត់តែស្រដី កាន់ច្រវាផង
ខំអុំតម្រង់ ដល់ក្សត្រច្បាស់ច្បង ឯក្សត្ររិទ្ធិរង្គ
យល់ទូកតូចខ្លី ។

លឿនជិតមកហើយ ដល់ជិតបង្កើយ ទើបព្រះចក្រី
ស្ដេចលើកធ្នូសរ ដាក់លើទូកខ្ញី ទើបព្រះនរបតី
ឡើងលើនាវា ។

ស្ដេចឡើងគង់ហើយ ក្សត្រាត្រាណត្រើយ ប្រឹងទប់អង្គា
មិនឱ្យងោកទូក ខ្លាចតាព្រឹទ្ធា ហើយព្រះរាជា
បន្ទូលទៅថា ។

អ្នកតាកុំអុំ ទុកឱ្យតែខ្ញុំ ឱ្យតែច្រវា
មកខ្ញុំនឹងអុំ ទៅឥឡូវណា ប្រាប់តែផ្ទះតា
នៅត្រង់ណានែ៎ ។

តាចាស់កាឡា ឮក្សត្រថ្លៃថ្លា ទារប្រចាំដៃ
នឹងអុំនាវា ដូចថាច្នោះនៃ ទើបតាចាស់វៃ
រវៀសឆ្លើយថា ។

អ្នកកុំអុំឡើយ នៅតែស្ងៀមហើយ បាចទឹកឱ្យតា
អ្នកទប់តែខ្លួន ឱ្យនឹងអាត្មា ត្បិតទូកនេះណា
ពៀបហើយងោកក្រែក ។

ពោធិសម្ភារ ឮចាស់ចិត្តជា មិនឱ្យក្សត្រថ្លៃ
អុំនាវានោះ ក្សិណនោះចមត្រែ ស្តេចគង់ស្ងៀមក្រែក
ទប់តែអង្គា ។

ព្រះហស្តកាន់ស្នាច ប្រុងតែនឹងបាច ទឹកក្នុងនាវា
ទឹកសោតពុំមាន នឹងឱ្យរាជា បានបាចគង្គា
ក្នុងទូកនោះឡើយ ។

ឯឥន្ទកាឡា ដឹងជាក្សត្រា ពុំស្គាល់ស្តេចហើយ
ទើបអង្គឥន្ទអុំ ទៅពុំលង់ឡើយ ហើយឥន្ទត្រាណត្រើយ
ធ្វើសួររាជា ។

ថាអ្នកឯងហោង មកហែលថ្វីផង នៅក្នុងគង្គា
មានបើហេតុអ្វី មករងវេរា ម្នាក់ឯងកំព្រា
ចូរប្រាប់តាផង ។

មហាក្សត្រថ្លៃថ្លា ឮចាស់កាឡា សាកសួរដើមទង
ទើបសាស័ព្ទប្រាប់ អស់ស្រេចជាម្តង ហើយក្សត្រច្បាស់ច្បង
សួរទៅតាថា ។

តាឯងនេះផង ផ្ទះតានៅហោង ឯត្រើយខាងណា
ចៅនៅច្នោះកូវ ទៅត្រូវនឹងតា តាចាស់កាឡា
ថាហើយអុំផង ។

ខែមួយចង្ហូវ នំពេចដល់ទៅ ត្រើយនាយជាម្តង
ហើយទើបថ្លែងថ្វាត់ ប្រាប់ក្សត្រច្បាស់ច្បង ថាតាចម្លង
អ្នកដល់ត្រើយហើយ ៗ

ចូរអ្នកឯងណា ឡើងរកសងក្សារ កុំបង្អង់ឡើយ
ចូរអ្នកខំរក ទីព្រៃនេះឯងហើយ គ្មានផ្ទះនៅឡើយ
ឯនាយនោះណា ៗ

ពោធិច្បងច្បាស់ ឮពាក្យតាចាស់ ប្រាប់ឱ្យក្សត្រា
ឡើងរកមហេសី នៅទីព្រៃនោះណា ទើបក្សត្រថ្លៃថ្លា
ទ្រង់ផ្នួជយា ៗ

ស្តេចសៀតព្រះខ័ន ស្រេចស្តេចរួសរាន់ ចុះចាកនាវា
ហើយបន្ទូលថា តាអើយខ្ញុំលា អរគុណមហិមា
ខ្ញុំលាហើយតា ៗ

ឯព្រះឥន្ទ្រា ឮព្រះរាជា ចុះត្រាច់យាត្រា
លាទៅថ្នាះហើយ ទើបចាស់កាឡា ថាអ្នកទៅណា
តាលាទៅហើយ ៗ

ទើបព្រះឥន្ទ្រា ធ្វើអុំនាវា ទៅពុំលង់ឡើយ
កំបាំងអំពី ពោធិត្រាណត្រើយ ក្សិណពុំលង់ឡើយ
ប្រាណប្រែកាឡា ៗ

ជាព្រះឥន្ទ្រា ហោះហើរវេហាសិ៍ ទៅទីត្រត្រឹងក្សា
សោយសុខសម្បត្តិ នឹងរត្នពនិតា នាងស្រីសុជាតា
ដូចដើមសព្វថ្ងៃ ៗ

(រឿងព្រះជិនវង្ស , ខ្សែ ២ , ទំព័រ ១០៣ - ១១៩)

រឿងព្រះជិនវង្ស

Introductory Note

ច្បាប់ issue, version, copy; specifier for stories, books, newspapers, etc.

ព្រះអរិយគាមណី /preăh-qariyeăq-kiəmənii/ ecclesiastical title

ញ៉ឹង (personal name)

ញាណថេរ /ñiənəthei/ ecclesiastical title

សុវណ្ណវង្ស /sowannəwuŏŋ/ name of Preah Chinavong's father

ជិនបុប្ផា /cɨnnəbopphaa/ name of Preah Chinavong's mother

ចាក់រុក to sow discord, slander for one's own purposes

ស្នំឯក ranking concubine

ភុជង្គនាគ /phuccuŏŋ-niəq/ Naga

ហែក to tear open, tear a hole in

ប្រោះ to restore to life, resurrect (by magic)

យក្ខិណី /yeăqkhənəy/ female ogre

បទុមសុរិយា one of Preah Chinavong's wives

សុវណ្ណទេវា one of Preah Chinavong's wives

មាលិវ័ន ogre king, Preah Chinavong's father-in-law

ពិចិត្រទេវា ogre queen, Preah Chinavong's mother-in-law

Text

ពុំនៀរ (=ពៀរ)

ចង to ensnare, catch up with, devolve on

ហេតុពៀរពុំនៀរចាំចង by the inevitability of fate

នាង (i.e. បទុមសុរិយា)

មហាក្សត្រា (i.e. ព្រះជិនវង្ស)

រំពេច suddenly, instantly

ខ្វារ (=ខ្វាល់) whirling madly

ប្រមលោម forming a great cloud

គួច to whirl, churn (of wind, water)

យន្តហង្ស (=ហង្សយន្ត) a mechanized swan (frequently occurs as a magical conveyance for heroes in mythological literature)

ចមទ្រេត king (i.e. Preah Chinavong)

ឈូឆរ imitative of the sound of rushing, gushing

ផ្អុក to have something occur to one; here: euphonic after /pqaəl/

ផាត់ to blow (of wind)

យើងស្លេះរាជាពុំបានថ្លែងទៀយ we will leave off talking about Preah Chinavong

សុរិយា (=បទុមសុរិយា)

ត្រាណត្រើយ (here: ព្រះជិនវង្ស)

បារមីតា (= បារមី)

ជលស័យ /cuŏlləsay/ ocean

ខូង dented, sunken, concave

សែន extremely

សុមេរា (Mt.) Meru

គ្រេងគ្រឹក (=គគ្រឹកគគ្រេង) thunderously, tumultuously

ជាយា wife (Roy)

មិនតែម្ល៉ោះ not only that, furthermore

មា in large numbers, many

ឆ្វីរ៉ gold

កល្ប /kal/ (= កប្ប /kap/) an age, long period of time

កល្បសល់សែនហើយ for ages, for an extremely long time

អញ្ញខានរលួចទៀយ How can I not...

ល្មម well-proportioned and petite

ទ្រល្វ soft, pliant, supple

ក្សណ just then, thereupon

ធីតា girl, daughter (Lit)

កន្លង extremely

ឥតឯគណនា immeasurable, inestimable

ទេពសម្ភារ heavenly virtue (term of address for the mermaid)

ថ្នោះ (=ផ្លូថ្នោះ)

សង back, in return

នាងនេត្រ precious girl

បទុម (= បទុមសុរិយា)

គាប់ទិច (=គាប់ជួន) fortunately, by good fortune

ត្រើយត្រាណ (= ត្រើយ)

សំណេះ to reminisce, exchange personal information

វ៉ឆ (= វាត់) to swish, beat, flail

ទើវ (= វាយ) to hit, strike, beat

វ៉ឆទើវ to swish, beat, flail

បក់ to beat, fan, flap

ហិចហែល swim with undulating movements

បរិភោគគ្គា (= បរិភោគ)

តក្កមា /tɑqkəmaa/ frightened, alarmed

រត់រេរា run haltingly

ចក្រវិត (= ចក្កវត្តិ, ចក្រពត្តិ) king, emperor

សម្លាញ់ចិត្ត [her] beloved

ទ្រហោ to wail, moan loudly

គក់ beat with closed fists

សាច់ [my own] flesh (i.e. her husband)

វិលវៃ (= /wɨl-wɨy/; /wee/ to rhyme with /twee/ in next line)

បព្រាស to separate (tv)

ទូរ far, distant

ទួញ to lament

ទូលទៅ speaking to [Preah Chinavong]

សូមឆ្លុតឆ្លូចលច្ឆា please answer my prayers, fulfill my request

ផ្សង invoke aid, trust in [God]

ប្រះ throw oneself down (as from fatigue, exhaustion)

សូន្យសុញ (= សុញសូន្យ) to die out, be extinguished, completely silent

ជោរជន់ to overflow, brim with

ចង្អូរ small ditch, channel, canal

បែកផ្កាត្រែង (Idiom) to break violently (of waves)

រុករក to search

ព្រះពន្លក Tender One (i.e. Preah Chinavong)

ដោយទីទេ everywhere, in various places (?)

សឹត a kind of sharp-bladed grass

ថ្កក់ to hook, catch at

ដោយដំណើរ by the act of

បក្សា /baqsaa/ (Pali pl.) birds; male bird

មហាហង្ស a kind of tree

សុវណ្ណហង្ស /sowannəhɑŋ/ golden swan (i.e. Preah Chinavong's mount)

អង្គា (Pali pl.) themselves

ពពាយ a kind of vine with edible fruit

វេទ្យល្ហាយ circling around

វាតា wind (Lit)

បំភ្លូក to overturn, upset

ទិន (= ដូថ្ទះ)

ព្រាត់ be separated

សព្វជាតិទៅហើយ in future reincarnations

ពនិតា /pŭənnitaa/ woman, wife (Poetic)

និរទោស /niərətooh/ blamelessness, innocence, absence of

guilt
និរទុក្ខា /niərətukkhaa/ absence of pain, lack of suffering
និរតណ្ហា /niərətɑnnəhaa/ absence of passion
ពេជ្ជញ្ញាណ /pɨccəñiən/ precious, supreme, enlightened
ពាក្យពេជ្ជញ្ញាណ words of enlightenment (i.e. of the Buddha)
ពាក្យអើយពាក្យពេជ្ជញ្ញាណ may these words have the efficacy of Buddha's words
ឃ្លាតឃ្លៃ (=ឃ្លាតឃ្លា)

ភ្លេចអស់ព្ទ didn't know where [she] was
កិន្នរ /kənnɑɑ/ mythological bird-woman
ជរា old age, senility, decrepitude
បៀត to afflict, attain

លុងលុះ until, to the point of

លុងលុះជន្មា to the point that [they] died (lit: up to the point of [their very] life)
ទ្រង់គ្រឿង to put on one's regalia
ច្រៀងច្រួច (=ច្រៀង)

ឈ្ងុប (=ឈ្ងុយឈ្ងុប) intensifier for fragrance
ទន្ទេង descriptive of a smooth glide with arms extended gracefully
កាច់រ៉ក to twist and turn, posture, make exaggerated and slightly affected movements
ដោយខ្លួន each one, each on [her] own
លំនាំ manner, gait, stylized movement, gesture
ត្បិតលំនាំ as a result of [their] gestures
ស្ងុយ everted, pouting, turned outward
ទន្ទេ gracefully, lithely

ថ្វាយបន្តគ្នា pass [it] along, hand [it] from one to the other

លន្តៃ small plant with fragrant flowers
ពុតទ្លេ a kind of flower

ផ្កាម៉ែ a kind of tree with fragrant flowers
មាលតី /miələdəy/ gardenia

ក្តាំងងា a kind of flower

ពុំងា term of endearment for a woman: darling, precious one
នាងឆោមឆាយ beautiful maiden (i.e. Botum Soriya)
ភ្ញាក់ព្រើត to be startled, to start with surprise or alarm
អើត to crane the neck to see

ងា to gesture with the arm, move the hand in an arc
ស្រទាង to stretch out, extend, spread
បក្ខា /paqkhaa/ wings

កន្ត្រាន drawn up, contracted

ប្រយ៉ាំង to hide oneself, conceal oneself, cover oneself
ផ្អៀង to incline to one side

ប្រហ to gape, be open, be gaping

ប៉ិប្រែ fresh and pretty

រ៉ែញ៉ងញ៉ង coquettishly, with exaggerated movements
មិង (=មិន?)

មិងមានទីនេរ there's no place [we haven't seen]
អាយ (=អើយ)

ព្ទ in, at

ចូរចិត្ត to be pleased, happy, satisfied, gratified
បើនៅ --- នៅណា if [you let me] stay, I'll stay
ព្រាក់ព្រម (=ព្រម?)

ស្បៃ loosely-woven cloth, muslin

សោមនស្ស /saomənoə̆h/ pleased, delighted; pleasure, delight
ស្មោះសរ sincere pleasure, genuine cordiality; sincerely, genuinely
ជលនេត្រ /cuə̆lləneet/ tears (Roy)

ស្រង់ to bathe (Roy)

ស្រប់ (=ស្រព) to sprinkle

ថ្មោងថ្មី (=ថ្មីថ្មោង) fresh, new

សោយ to eat (Roy)

ណល់ desolate, sad

សោយតែសោកា double entendre: 'ate (partook of) only grief' or 'did nothing but grieve'

មិច to wink

យាម prediction; auspices, signs of the future

មើលយាម to tell fortunes, predict destiny

ពិនិត្យពិច្ឆ័យ /pinɨt-picay/ carefully

រាប់ជើងរាប់ដៃ to count on the fingers and toes

រអូច to move the lips silently (as if calculating half-aloud)

ជាហេតុចៃដន្យទេវា by divine fortune

ប្អូនអើយ --- ខុសម្តង Younger Sister, my skillful predictions, which are never wrong, predict the following

ធ្វើស្លូតមុខមាត់ (=ធ្វើមុខមាត់ស្លូត) to put on a serious face

សង two

សព្វថ្ងៃ all day

ពោធិ bodhisatva (i.e. Preah Chinavong)

ច្បាស់ច្បង appellation for a king

ភ្លូក to turn over, upset

មោះ it is (Archaic)

ជាតី (=ជាតិ)

នទី /nɔɔtii/ river, ocean (Lit)

ស្កុងស្កល់ bright, white

ពពាក់ in a huddle, piled up, overlapping one another

ស្តេចហែល --- ដោយកល he swam by the strategy of floating on top of his bows and arrows

អធិដ្ឋាន /qathithaan/ recite, invoke, swear by

សីលប្រាំ the Five Principles

គុណ merit [of the Three Jewels: Buddha, Dharma, and Sangha]

ទូលទុក្ខ to undergo suffering, endure grief; here: recite his woes

ក្រិណពុំលង់ទៀយ not long afterward

សាគរ ocean

សម្រេចសង្ខារ put an end to his life

បបួល be together, be in harmony (in dying)

ម្តេះ --- ផង would that my wife were here to die with me

ជននី (=ជនី) /cŭənnii/ mother (Lit, Roy)

ព្រះឱស្ឋ /prĕəh-qaoh/ mouth (Roy)

កោសិយ Indra

សច្ចំ /saccaŋ/ truth, honesty, goodness

ព្រះឱស្ឋគិតថា he said

កតញ្ញូតា /kattaññuutaa/ gratitude, recognition of service done

ហាក់ដូចរាជាថាទៅកាយា just as he wished

ចក្ខុ /caqkhoq/ eye (Lit)

ទិព្វចក្ខុ /tɨppəcaq, -caqkhoq/ magic eyes

ត្រៃត្រឹង្ស thirty-three (Skt)

អ្នក (=នាក់)

លេច to leak

ប្លេងឡេង to bob, pitch and roll

ញច to splash, scoop (water)

ររខោក sound of rattling of loose boards or slats

ខ្យល់ម្តេចម្ល៉េះណា (=ម្តេចក៏ខ្យល់ខ្លាំងម្ល៉េះ)

តោកយាក /taok-yaaq/ miserable, wretched, unfortunate

លិច (=លេច) to leak

ផ្ចង to direct (something) toward, to aim

ឈូឆា noisily

ទាត to turn a boat by paddling toward oneself

គាស់ to turn a boat by paddling away from oneself

ងោកងាល to nod forward and back, rock back and forth

ទទាំងទទាល to stagger, lurch from side to side

ឆ្វត to slice, split, crease

ពង្សពុទ្ធា Buddha's lineage (i.e. Preah Chinavong)

ព្រឹទ្ធា old (Lit)

ញ៉ាំងដៃ to shade the eyes with the hand

ទាទើយ unconcerned, nonchalant, detached

ព្រទគោះ crude, improper, excessive, nasty, rude

ស្តី to blame, criticize, scold

ប្រតិបត្តិ behavior, conduct; here: reaction

ស្រណោះពេកណាស់ (Idiom) how amusing, how interesting (sarcastic)

ម្ចាស់ថ្លៃ my lord, my good fellow

កំទ្យាំងតាស់ណា (=អ្នកណាមានកំទ្យាំង)

ឧបការ to provide assistance, render a service to (Lit)

អញឯង you

ដែក្តង ៗ clamorously and insistently

ទឹ (= ទើយ)

ផង (=របស់) of, belonging to

ទូកអញផងអញ my boat

អំពល់ to trouble, bother; to concern oneself with, go to the trouble to

អញអំពល់អី why should I bother?, what do I care?

ហោយំ wail, lamentation, cry

ថ្វី (=ឬអី)

អញកោតដែលថា I'm amazed that [you can] say [such things]!

ហោច rationality, sense, reason

មិនដឹងស័ព្ទហោច doesn't know what [he's] talking about

ហាក់ maybe, perhaps

របរការ business, affair

មករក... អញឯង what (business) do you want me to do for you?

អសុរោះ crude, rude, nasty

ទៅណាទៅផង I'll go wherever you're going

នឹង about, concerning, with respect to

វត្ត propriety, respect, respectful behavior

វត្តប្រតិបត្តិ propriety, respect

ជាទេព្រើយ (i.e. Indra)

ទម្ចបម្ចា whatever, whatever it may be

រូបា (=រូប) /ruupaa/

ពុទ្ធង្គល /putthuəŋkoul/ Buddha's lineage (i.e. Preah Chinavong)

មាត់ដែតស្រដី while talking, while saying [that]

ងោក to nod; to roll, rock

ររៀល to hurry, hasten

ពៀប to be low in the water from a heavy load (of a boat)

ឈ្លាច a hollowed-out log or bamboo, used for scooping water, feeding pigs, etc.

ធ្វើ to pretend

មានរឿងហេតុអី what happened; how is it that...

ដើមទង background, origin, cause

ចង្ហរ instant (?)

ជយា (=ជើយ)

ត្រៃត្រឹង្សា (= ត្រៃត្រឹង្ស) the second level of inanimate beings; heaven (lit: thirty-three)

VIII. RELIGIOUS EPIC

អក្សរសាស្ត្រខាងសាសនា នឹងអាចចែកបានជាពីរចំណែក ។ ចំណែកទីមួយគឺ : អក្សរសាស្ត្រខាងសាសនាដ៏សុទ្ធសាធ ។ អក្សរសាស្ត្រចំពូកនេះ គេសរសេរជាបាលីទាំងអស់ ។ ចំណែកខាងអក្សរវិញ គេប្រើអក្សរមូល ។ តំណាងនៃអក្សរសាស្ត្រចំពូកនេះ គឺព្រះត្រៃបិដក ព្រះវិន័យ ព្រះសូត្រ នឹងព្រះអភិធម្ម ។ ព្រះត្រៃបីតកសរសេរនៅចុងសតវត្សទី ១៨ ហើយនឹងដើមសតវត្សទី ១៩ ។ ក្នុងសៀវភៅនេះ យើងមិនយកអក្សរសាស្ត្រ ចំពូកខាងបាលីនេះមកបញ្ចូលទេ ដោយយល់ឃើញថាជាវិស័យនៃទេវវិទូ ។

ចំណែកទីពីរនៃអក្សរសាស្ត្រខាងសាសនាគឺ : អក្សរសាស្ត្រដែលប្រើសាសនាជាមូលដ្ឋាន ។ ក្នុងចំណែកទីពីរនេះទៀត យើងចែកជាចំណែកតូច ៗ ពីរទៀតគឺ ១.ដូចជារឿងសុបិនកុមារ គឺជារឿងខាងសាសនា តែប្រឌិតឡើងដោយអ្នកនិពន្ធតែម្តង ។ គេឥតឃើញមានរឿងនេះនៅក្នុងគម្ពីរបាលីផ្សេង ៗ ទេ ។ ២. ដូចជារឿងក្រុងសុភមិត្រ និងមហាវេស្សន្តរ ជារឿងប្រែមកពីគម្ពីរបាលីផ្សេង ៗ ។ ការបកប្រែនោះសោត ក៏មិនមែនបកត្រង់ ៗ ទេ តែមានបញ្ចេញបញ្ចូលបែបខាយតាមតែចំណង់របស់អ្នកនិពន្ធ ។

២៧. សុបិនកុមារ

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

រឿងសុបិនកុមារ ជារឿងមួយដ៏សំខាន់ក្នុងកម្មវិធីអប់រំកម្ពុជបុត្រ ក្នុងសម័យបុរាណ ។ ក្រោយពេលដែលកុមារសិស្សវត្ត រៀនអក្សរ អានច្បាប់ផ្សេង ៗ ចប់ហើយ គេចាប់អានរឿងសុបិនកុមារ ដែលដោយយើងមិនបាច់សង្ស័យ ជាជំហានយ៉ាងសំខាន់ដែលញុំាងឲ្យកុមារទាំងឡាយ មានជំនឿកាន់តែស្លុងឡើងចំពោះពុទ្ធសាសនា. ។

សេចក្តីដកស្រង់មកនេះ ថ្លែងពីមាតានៃសុបិនកុមារ ក្រោយដែលបានឃាត់កូនមិនឲ្យទៅ

បួសហើយ ក៏យល់សប្តិឃើញយមបាលចាប់យកទៅធ្វើបាប ទោះក្នុងភ្លើងនរក ។ តែដោយអំណាចបុណ្យនៃកូននាងដែលពុំនេះទៅបួស នាងក៏បានរួចរស់ជីវិតឡើង ។

អត្ថបទ

(បទពំនោល)

យមបាលចោលនាងក្នុងភ្លើង ឈូកមាសផុសឡើង ប្រមាណប៉ុនកង់រាជរថ ។

តេជះផលផ្នួសប្រាកដ ទទួលជើងផ្គត់ ឥតបីរន្ធត់ឡើយណាំ ។

នាងឋិតលើសុវណ្ណបទុមា តេជះសីលា សុបិនបានបួសសាមណេរ ។

ទៅគ្របឱបម្ដាយបំបែរ យមបាលខឹងខេ ក៏ភេចកន្ត្រាក់ធ្លាក់ទៅ ។

ទោះចុះទៅក្នុងរណ្ដៅ ភ្លើងមួយនោះជ្រៅ ទំហំមួយពាន់យោជន៍បាន ។

តេជះផលអានិសង្សមាន កូនបួសប្រធាន សំណាក់ក្នុងពុទ្ធសាសនា ។

មានឈូកមាសមួយសោភា ផុសទ្របាទា នាងនោះអណ្ដែតខ្ពស់ឡើង ។

យមបាលសោតចាប់បានជើង ចោលនាងក្នុងភ្លើង ទំហំមួយម៉ឺនយោជន៍យល់ ។

តេជះកូនបួសជាផល ផលនោះមកផ្ដល់ កណ្ដាលនៃភ្លើងអវិចី ។

មានឈូកមាសមួយរីកខ្ចី ផុសឡើងអំពី មហានរកធំនោះ ។

ទ្រទ្រង់បាទានាងនោះ ខ្ពស់ពីភ្លើងស្មោះ ឥតក្ដៅក្រហាយឡើយណាំ ។

តេជះហេតុផលសីលា សុបិនបួសជា ផលនោះជួយរក្សាម្ដាយ ។

ខ្ទះដែកធ្លាក់បែកខ្ទាត់ខ្ចាយ ភ្នក់ភ្លើងបីរលាយ រលំរលត់ទៅហោង ។

យមបាលភិតខ្លាចកន្លង លុតជើងដែផង បង្គំប្រណម្យហើយថា ។

ឱអស្ចារ្យក្រៃមហិមា ពុំដែលច្នេះណាំ អ្នកនាងនេះមានបុណ្យក្រៃ ។

យមបាលភិតញ័រជើងដៃ ក្រួញក្រាបទីទៃ រត់ពួនជ្រមួនក្រាបនៅ ។

ខ្លះសោតនាំនាងចូលទៅ ថ្វាយព្រះយមនៅ ក៏ទូលសំដែងថ្លែងថា ។

បពិត្រក្រាបទូលរាជា អ្នកនេះឯងណា មានបុណ្យប្រសើរកន្លង ។

បើដោយអស់ប្រការផង ប្លែកក្រៃពេកហោង យើងនាំមកថ្វាយករុណា ។

នោះទើបព្រះយមរាជា ត្រេកត្រាស់ទៅថា នេះធ្វើអំពើបុណ្យអ្វី ៗ

នាងទូលថ្លែងអស់សេចក្តី បពិត្រធិបតី ព្រះអង្គតែងដឹងលោកា ៗ

កូនប្រុសខ្ញុំបានបួសជា សាមណេរហើយណា សំណាក់ក្នុងពុទ្ធសាសន៍ថ្លៃ ៗ

ព្រះយមស្តាប់ហើយអរក្រៃ ព្រឺព្រួចហឫទ័យ បន្ទូលឲ្យសាធុការ ៗ

សាធុនាងមានសម្ភារ នាងទៅព្យាបាល រក្សាកូននាងហោងណា ៗ

បទខ្ញុំឃាត់កូនកំព្រា ពុំឲ្យបួសជា សំណាក់ព្រះពុទ្ធព្រះសង្ឃ ៗ

វេរានោះតាមមកត្រង់ ឲ្យអញលិចលង់ ក្នុងភ្លើងនរកមហិមា ៗ

មួយសោតបើអ្នកឯណា សំណាក់សាសនា ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ៗ

អ្នកនោះបានចរត្រាច់ត្រង់ ផ្លូវសួគ៌បីកម្លុង កន្លងលែងផ្លូវអកុសល ៗ

អ្នកណាបានសេពបានយល់ អ្នកមានធម៌សល់ អ្នកនោះប្រពៃពេកហោង ៗ

អ្នកណាបានសេពនៅផង អ្នកពាលឆ្គាំឆ្គង អ្នកនោះត្រូវទោសធ្ងន់ក្រៃ ៗ

លិចលង់ផុងទៅនៅព្វ នរកនេះនៃ ដូចអញបានយល់នេះឯង ៗ

នាងគិតរំពឹងយល់ឃ្វេង យល់មានពៀរព្រេង ភិតញ័ររន្ធត់ពុងពោះ ៗ

នាងភ្ញាក់ដោះឡើងពីនោះ ទូលអុសទៅស្មោះ ក៏ចូលអារាមវិហារ ៗ

នាងយល់អ្នកសុបិនកុមារ កូនស្ងួនសង្សារ ក៏រត់ទៅឱបបាទា ៗ

អ្នកសុបិនដណ្តឹងម្តាយថា អ្នកមកពីណា រលះរលាំងភិតភ័យ ៗ

នាងថាហៃកូនមាសថ្លៃ ម្តាយចូលក្នុងព្រៃ កាច់អុសដូចកាលសព្វផង ៗ

បានអុសវិលវឹងមកផ្គង ម្តាយនឿយឈឺខ្នង ម្តាយប្រះខ្លួនដេកលង់លក់ ៗ

ក្រោមដើមឈើមួយស្រណុក យមបាលធ្វើទុក្ខ ក៏ចាប់ម្តាយនាំយកទៅ ៗ

ដល់ព្រះយមរាជចមចៅ ចាប់ម្តាយបោះទៅ នាក្នុងរណ្តៅភ្លើងធំ ៗ

តេជះផ្នួសអ្នកឧត្តម ទុក្ខទោសទុគ៌ម របួតរលូតមកហោង ៗ

នាងប្រាប់អស់ប្រការផង ឲ្យកូនស្តាប់ហោង ថារួចពីភ្លើងហើយណា ៗ

នាងទួញយំហើយនាងថា ឱកូនកំព្រា អ្នកជាពំនាក់ម្តាយហោង ៗ

(រឿងសុបិនកុមារ, ទំព័រ ២០ - ២២)

RELIGIOUS EPIC

អក្សរមូល round script (a decorative style of script used for names, titles, and religious texts)

ត្រៃបិដក /traybəydɑq/ Tripitaka (the Three Baskets of Pali scripture)

វិន័យ /wiqnɨy/ Vinaya (discipline, rules of conduct for the Sangha)

សូត្រ /sout/ Sutra (includes Buddha's discourses and the 547 Jataka tales or stories of Buddha's earlier reincarnations as a Bodhisatva)

អភិធម្ម /qaqphiqthɔə/ Abhidhamma (metaphysics, highest law of Buddhism, in the form of questions and answers)

ទេវវិទូ /teeweəqwituu/ theologian

សុបិនកុមារ main character of the story of the same name

ក្រុងសុភមិត្រ /kroŋ-soppəmɨt/ main character of the story of the same name

សុបិនកុមារ

Introductory Note

កម្ពុជបុត្រ /kampuccəbot/ Cambodian children

ស្លូង fully, completely, wholeheartedly

យមបាល /yumməbaal/ Yamapala, guardians of hell

ពុំនះ defiantly, in defiance of

Text

នាង (i.e. Sobenkomar's mother)

ផ្នួស fact or state of being a monk, entry into the monkhood

ផ្គត់ to support, provide support

ឋិត (=ស្ថិត) to stand, be located

បទុមា (=បទុម) lotus

សីលា (=សីល)

សុបិន (=សុបិនកុមារ)

គ្របទ្ធិប to envelop, protect

បំបែរ turn aside, shunt aside, ward off

ខឹងខេ (=ខេខឹង) angry

យោជន៍ distance of approximately 1,600 meters, a mile

អានិសង្ស blessing, benefit

ប្រធាន (=ប្រណិធាន) to vow, swear an oath, promise

ញាទា (=ញាទ)

អវិចី /qawəcəy/ hell of ceaseless fire

បួសជា (= បួសជាសាមណេរ)

ខ្ទះ large round-bottomed skillet, wok

ភ្លក់ bonfire, outdoor fire

លុត to kneel

ពុំដែលធ្លះណា there's never been anything like this before

ជ្រមូន to cower (?)

ព្រះយម Yama, God of Death

បើដោយអស់ប្រការផង in every way, in all respects

នេះ (i.e. you)

បពិត្រធិបតី Your Highness

ព្រះអង្គតែងដឹងលោកា You who surely know everything about the universe

សាធុការ blessing, good wishes

បទខ្ញុំ because I (i.e. Sobenkomar's mother)

ក្នុង in

បីក្នុង therein, within

ភ្ញាក់ awoke (from her dream)

រលះរលាំង in a dither, all in a hurry

ផ្គង toward (home)

ព្រះយមរាជ /prĕəh-yumməriəc/
Yama, God of Death

ទុគ៌ម /tuurəkum/ deep, remote
(here: profound, great)

របូត to slip away

របូតរលូត to slip away, slip free, escape

តេជះ --- មកហោង [through] the power of your monkhood, [I] was spared great suffering.

២៨. ក្រុងសុភមិត្រ

ដោយ

កៅ (ឧកញ៉ាកោសាធិបតី)

បុព្វកថា

រឿងក្រុងសុភមិត្រនេះ ជារឿងមួយក្នុងបណ្ណាសជាតក ។ ច្បាប់ដើមនៃរឿងនេះ សរសេរជាបាលីទាំងអស់ ។

នៅឆ្នាំ ១៧៩៨ ទើបឧកញ៉ាកោសាធិបតីកៅ ចាត់ចែងបកប្រែតែងឡើងជាពាក្យកាព្យ ។ រឿងបណ្ណាសជាតកនេះ មាននៅតែស្រុកខ្មែរ ស្រុកសៀម ហើយនឹងស្រុកលាវទេ ឥតឃើញមាននៅប្រទេសកាន់ពុទ្ធសាសនាឯទៀតឡើយ ។

សេចក្ដីដកស្រង់មកនេះ ថ្លែងពីក្រុងសុភមិត្រ ក្រោយដែលលះបង់រាជសម្បត្តិទៅឲ្យក្រុងអសុភមិត្រ ព្រះអនុជដែលជាឧបរាជរបស់ព្រះអង្គនោះ ត្រូវព្រាត់ប្រាស់បុត្រនឹងព្រះជាយា យ៉ាងអាណោចអាធ័មជាទីបំផុត ។

អត្ថបទ

(បទភុជង្គលីលា)

ក្សត្រា ថ្លៃថ្លាល្អស្ដិ៍សល់ ត្រាច់ត្រង់ដើរដល់ ជ្រុងជ្រោះគិរី ។
មានអូរចង្ហូរទួលទី ស្រះបោក្ខរណី រេះរាបរងថ្លា ។
ព្រះអង្គពីរពង្សសោភា នាំបុត្រពុំងា ចុះស្រង់វារី ។
ស្រង់ស្រេចសម្ដេចចក្រី នាំបុត្រពិសី ដើរដោយត្បូងខ្សាច់ ។
មើលផ្កាបុប្ផស្រស់ស្រេច បូបុស្ស រំលេច រីករុះសាយសព្វ ។
ចម្ប៉ា ក្ដាំងងាឈ្ងុយឈ្ងប់ ដោរដូចអ្នកអប់ ទាំងព្រៃព្រឹក្សា ។
កាកែសចេកទេសយុក្កា ម្លិះរួតម្លិះលា ខ្ទឹងខំស្រូវភី ។
មហាហិង្គុប្រយង្គុនស្រី ស្រឡិតមាលតី លាយលេចច្បាប្រចាល ។
លន្តែពុតធ្លូរន្ទាល រំចេកដាសដាល ផុះដោយទីទួល ។

ព្រឹក្សាបុប្ផជង្គួរ ហាក់ដូចអ្នកព្យួរ សំយុងយោនយាន ៗ

កន្លង់ត្រាច់ត្រង់សព្វស្ថាន សៀងសូរទូហាន ភ្លេងតូរ្យតន្ត្រី ៗ

ត្រាច់ត្រើបជញ្ជាប់ក្លិនភ្ញី កេសរទីកថ្មី ពិដោរសព្វសាយ ៗ

ក្សត្រាថ្លៃថ្លារួសរាយ សំណេះប្រាប់ប្រាយ ត្នៃរាជក្សត្រី ៗ

ស្ដេចបេះប្របឡេះផលភ្ញី ឱ្យបុត្រទាំងពីរ បរិភោគសោះឃ្លាន ៗ

ស្ដេចចរនាំវរកល្យាណ ត្រាច់ក្នុងស្មសាន ស្ងប់ស្ងាត់ជ្រងំ ៗ

ដើរត្រាច់លុះលេចព្រៃភ្នំ វាលវែងធារធំ ដល់ឆ្នេរនទី ៗ

ព្រះមហាក្សត្រាក្សត្រី សែនសោយសោកពី- លាបលន់ទន្ទត់ ៗ

ចរចេរតាមឆ្នេរសមុទ្រ ពៀងពរាជបុត្រ ទាំងពីរអង្គា ៗ

ឈរឈប់ក្រោមម្លប់ព្រឹក្សា ទៀងទួញថែថា ឱគ្រានេះម្ដង ៗ

សមក្រកប្រមក្ដាត់ហោង គ្មានទូកនឹងឆ្លង ឱ្យដល់ត្រើយត្រាណ ៗ

ក្សត្រីទេវីកល្យាណ សោយសោកប្រេះប្រាណ លន្លោចឯកឯង ៗ

នាងទួញទំនួញក្ដែង ៗ នាងភិតខ្លាចក្រែង ពុំរួចជីវី ៗ

គិតបុត្រពិសុទ្ធទាំងទ្វី គិតព្រះស្វាមី សោយសោកឥតល្ហើយ ៗ

ស្ដេចថាពុំងាស្ងួនអើយ បងយល់ច្នេះហើយ ពុំយកប្អូនមក ៗ

ឱស្ងួនខ្លឹមខ្លួនពន្លក បងយកប្អូនមក ឱ្យប្អូនអម្ចេញ ៗ

នាងទូលឥសូរសម្លាញ់ ទុក្ខខ្ញុំវែងម្ចេញ សូវមកច្នេះណា៎ ៗ

តាប់ខុសស្លាប់រស់ផងគ្នា តាមកម្មវេរា ពីព្រេងនាយនៃ ៗ

ព្រះមហាក្សត្រាថ្លាថ្លៃ បន្ទូលថាហៃ ព្រលឹងបងអើយ ៗ

កុំនាងបារម្ភពេកឡើយ ងារបងឯងហើយ នឹងហែលចម្លង ៗ

យកប្អូនខ្លឹមខ្លួនស្នេហ៍ស្នង នានាំទៅផ្គង ដាក់ដល់ត្រើយត្រាណ ៗ

ទុកបុត្រពិសុទ្ធកល្យាណ នៅអាយឱ្យខាន ចាំនៅនេះណា ៗ

សឹមបងវិលចរយាត្រា យកបុត្រទៅហារ វិលវឹងទៅឋាន ៗ

ជួបជួននឹងស្ងួនកល្យាណ មូលបរិបូណ៌បាន សឹមយើងចេញចរ ៗ

នាងស្ដាប់សាសព្ទភូធរ ស្រីរ័ត្នបវរ ទង្គិះខ្លោចផ្សា ៗ

នាងនាថសញ្ញាប់ភក្ត្រា គិតបុត្រទូហារ ត្រមោចឯកឯង ៗ

ក្សត្រីទេវីចំបែង អួលឱរាវែង ថែថប់ពេកក្រៃ ៗ

នាងសោកអរមោក្សអាល័យ បីបុត្រថ្លើមថ្លៃ បំពៀរស្រេចហើយ ៗ

ផ្ដាំថាពុំងាម្ដាយអើយ ម្ដាយឆ្លងទៅត្រើយ នាយនឹងបិតា ៗ

ចូរចៅចាំនៅនេះណ៎ា មើលប្អូនឱ្យជា កុំឱ្យយំឡើយ ៗ

កម្សងឯពីព្រេងផ្ដល់ហើយ ធ្វើម្ដេចស្ងួនអើយ ចៀសចាកពុំបាន ៗ

ផ្ដាំស្រេចសម្ដេចក្សត្រក្សាន្ត ពនាងកល្យាណ ហិចហែលច្រៀវច្រៃ ៗ

កណ្ដាលប្រវាលជលស័យ ស្ដេចពុំភិតភ័យ នឹកខ្លាចមច្ឆា ៗ

សមុទ្រទន្ធត់មហិមា រលកជលសា បោកបែកផ្កាត្រែង ៗ

សន្ធឹកពន្លឹកគគ្រេង គគ្រាំបែកផ្សែង ភ័ព្ទអស់ទិសា ៗ

ព្រះពាយផាត់ផាយគគ្គា ពន្លឹកមហិមា សូរស័ព្ទរំពង ៗ

ក្រពើលលើហែលឆ្លង មករពិទុង បបែលឆ្លាមឆ្លាំង ៗ

ទេរាហែលហាសំកាំង សឹងភិតភ័យភាំង ខ្លាចព្រះបារមី ៗ

ព្រះអង្គពូជពង្សពោធី ខ្លាំងស្មើឥរី ប្រាពីរមហិមា ៗ

ដូចអង្គភុជង្គនាគា ទ្រង់ឫទ្ធពលា ឡើងលើជលធី ៗ

ស្ដេចឆ្លងចម្លងទៅទី នានាំប្អូនស្រី ហិចហែលសំដៅ ៗ

ឆ្វៀរឆ្វេរសមុទ្រជ្រាលជ្រៅ ទឹកថ្លាយង់ខ្មៅ គួរស្បើមមហិមា ៗ

ហេតុបុណ្យលើសលន់ក្ដាត់ណ៎ា បានសាងប្រាថ្នា សរពេជ្ញជិនស្រី ៗ

ព្រះមហាក្សត្រាធិបតី នានាំមហេសី លុះដល់ត្រើយត្រាណ

ស្ដេចចរនាំវរកល្យាណ ឡើងឈប់សម្រាន្ត ទីទួលថ្នាក់ថ្នល់ ៗ

គិតបុត្រពិសុទ្ធស្ដី សស់ នេត្រាជោរជល ទួញទៅបុត្រា ៗ

    នឹងថ្លែងសំដែងកាលគ្រា កាលមហាក្សត្រា នាំនាងទេវី ៗ

ហែលឆ្លងចម្លងជលធី ក្រោយនោះមានទេ - សាទពីរអង្គា ៗ

ស្វះស្វែងឯលះ វែងសីមា ទ្វីនអុំនាវា ប្រែបទន្លេរជលធី ។

ព្រាហ្មណ៍ព្រានដឹងជាននទី ចរចេញរកស៊ី ស្ទាក់ស្ទុចមច្ឆា ។

ទាំងយប់ព្រលប់សន្ធ្យា ទៅទៀបបុត្រា ក្បត្រថ្លៃច្បាស់ច្បង ។

ព្រានវៃព្រវ៉ាតវៃវចូលផ្គង យល់បុត្រច្បាស់ច្បង នៅទន្លេវជលសា ។

ព្រានគិតក្នុងចិត្តឯងថា អេះកូននរណា មកនៅនេះនៃ ។

ភ័ព្វអញចរចេញមកព្រៃ ឥឡូវលាភជ័យ ដល់ដូចប្រាថ្នា ។

គួរវិះសំណេះចរចា ជាកូននរណា មកនៅទូរទី ។

ជាខ្មោចអសោចិអប្រិយ ឬយក្ខិនី ប្រែប្រួលកាឡា ។

ឬជាទេវតានៅនា វែងចាំរក្សា ស្ថិតស្ថាននគិរី ។

អម្លុងយូរលង់អំពី ដើមទៀងមកក្តី ពុំដែលច្នេះណា ។

ទើបព្រានសាកសួរទៅថា ចៅមកពីណា ទាំងយប់រាត្រី ។

ម្តាយចៅនិត្យនៅបុរី បុរាណទិសទី តំបន់ស្ថាននណា ។

អ្នកស្តាប់ពុំប្រាប់សោះសា ពុំប្រែភក្ត្រា ខ្លាចព្រានយាយី ។

អ្នកគង់ទ្វីនអង្គសិរសី ភិតភ័យរឥន្ទ្រិយ រន្ធត់អង្គា ។

អ្នកគិតក្នុងចិត្តឯងថា ព្រាននេះពីណា យល់អគ្គិក្តី ។

អ្នកខ្លាចអំណាចដើមឫ្សី នឹងហ៊ានស្រដី ប្រាប់ព្រានឡើយណា ។

ស្ងាស្ងប់ចំប្រែប់អង្គា ពុំហ៊ានចរចា សួរសងវាទី ។

ព្រានឆ្ងល់ក៏កលស្រដី ប្រសោមពាក្យពី- រោះរួចចរចា ។

ចូរចៅមកនៅនឹងតា តានឹងរក្សា ទុកជាបុត្រហោង ។

កុមារពិសាលស្នេហ៍ស្នង វែងភិតកន្លង កន្លងសោតសល់ ។

អ្នកសោកអមោកន្សៃជារជល ទៀងទួញទៅដល់ រកព្រះជននី ។

ផ្សារក្មេងពុំដឹងសេចក្តី វែងជាភិតពី- លាបលន់ឥតស្បើយ ។

ព្រានព្រឹទ្ធចូលជិតទៅហើយ ពិតពុំលង់ឡើយ ឈោងចាប់ប្រវា ។

ឈរឈានបីបានបុត្រា ទាំងពីរអង្គា ចុះទូកវិលវៃ ។

បុត្រាសោកាពេកក្រៃ អាឡោះអាល័យ មាតាបិតា ។
ផ្សាខ្លោចលខ្លោចន្ទ៏រា ខ្លាចព្រានព្រៃវា បំបាត់ជីវី ។
យំទួញទំនួញទៅខ្មី រកក្សត្រទាំងទ្វី ញ័រអស់អង្គា ។
ឯចៅប្អូនពៅពុំងា សោតសឹងសោកា ទួញទៅជននី ។
ក្សិណនោះព្រានស្មោះចេញពី ឆ្វៀរឆ្វេរជលធី ត្រាច់ត្រង់ជលសា ។
អុំទៅលំនៅអាត្មា ដាស់តឿនជេរគ្នា ពុំឱ្យសម្រាន្ត ។
រូតរះលាកលះទើបបាន ទៀងទៅគ្រឹះស្ថាន ទាល់តក្កសិលា ។
ឯអង្គពីរពង្សក្សត្រា ព្រានពីរថែកគ្នា យកទៅទីទៃ ។
ព្យាបាលកុមារថ្លាថ្លៃ ថ្នាក់ថ្នមសព្វថ្ងៃ ពុំឱ្យមានហ្មង ។

(បទព្រហ្មគីតិ)

នេះយើងនឹងស្រដី ដំណើរពីក្សត្រច្បាស់ច្បង
កាលស្តេចហិចហែលឆ្លង នាំនាងនាថរាជធីតា ។
ព្រះអង្គឈប់សម្រាន្ត លង់លុះបានស្រាងសុរិយា
ព្រះអង្គតែងសោកា និត្យនៅលើគោកថ្នាក់ថ្នល់ ។
គន់គិតរាជបុត្រា នៅកំព្រាព្រាត់ទុព្វល
ព្រះអង្គសោកាណាស់ ទូវនាងនាថរាជទេវី ។
ស្តេចផ្តាំវរជាយា រាជធីតាអង្គមហេសី
ប្អូនអើយបងនឹងលី- លាទៅថ្កានបុត្រទ្វេហារ ។
ចូរចៅនៅប្រយ័ត្ន ក្រោយក្រែងសត្វវាហិង្សា
ប្អូនចាំនៅនេះណ៉ា នេត្រទំព្រៃសព្វទិសទី ។
បងនឹងលាទៅផ្គង ទៅចម្លងបុត្រទាំងទ្វី
ឱ្យជួបជួនទាំងបី ស្រេចហើយបងនឹងរុករាន ។
ចរចេញពីនេះទៅ កាត់សំដៅព្រៃហិមពាន្ត
នាងនៅឱ្យសុខសាន្ត សោះអំពល់សេចក្តីគិត ។

សនំស្រាងសីលា
ផទាបអស់ជីវិត
ស្តេចផ្តាំហើយផ្តាំទៀត
ស្រយុតអស់អង្គា
នាងនាថសឹងសោយសោក
ព្រះនេត្រាជោរជល
ព្រះអើយបើព្រះបង
ព្រះអង្គឆាប់ទួសរ៉ា
ខ្ញុំខ្លាចទីព្រៃនេះស្ងាត់
ព្រឹក្សាបើវាយង់
ស្តេចលោមស្តេចលាកលា
ផ្តែផ្តាំស្រេចអស់ក្តី
កាលនោះពោធិសត្វ
ហែលឆ្លងក្នុងជលសា-
ស្តេចហែលហើយសោយសោក
គន់គិតតៀតនាងនៅ
ឱអាសូរប្អូនក្តាត់
និត្យនៅកណ្តាលព្រៃ-
ម្ល៉ះហើយសមប្អូនស្ងួន
កន្សែងសោកឡឹនឡង់
ឱបងអាសូរចៅ
សមខ្លាចសត្វម្រឹគា
តែងមើលផ្លូវបងបាត់
លាបលន់ជន្មជីវី
បងមហាថប់ពេកក្តាត់
យកប្អូនទៅភោក្តា
ព្រះអង្គសោយសោកា
ស្តេចទួញហើយទួញទៀត
ដំណើរពោធិសត្វ

ពឹងព្រឹក្សាឱ្យស្នេហ៍ស្និទ្ធ
ឱ្យទៀងទួចពៀររវេរា ៗ
ស្រទូងចង្អៀតឈើខ្លាចផ្សា
គិតព្រះប្អូនពន់ពេកសល់ ៗ
សែនអមោក្សផ្តាំទសពល
ស្រក់សស្រោកព្រះភក្ត្រា ៗ
ទៅចម្លងបុត្រទ្វេហារ
កុំស្តេចចោលខ្ញុំលំនង់ ៗ
ព្រុសព្រុសត្វស្រៀវស្រែកក្នុង
យល់ចោមចាប់ផាចំណី ៗ
វរជាយាអគ្គមហេសី
ហើយស្តេចចុះក្នុងគង្គា ៗ
បុរសរ័ត្នស្តេចលីលា
គរគម្ពីរាជ្រាលជ្រៅ ៗ
សែនអមោក្សឱរាក្តៅ
ក្រោយកំព្រាព្រាត់ឃ្លាឃ្លៃ ៗ
ម្ល៉ះសមស្វាត់ងក្រោយទីក្រក
ព្រឹក្សស្មសានងងងកអង្គ ៗ
មាសខ្លឹមខ្លួននាងនាថទ្រង់
តែងទន្ទឹងទល់ទុក្ខា ៗ
ចាំនិត្យនៅក្នុងព្រឹក្សា
ញ័ររន្ធត់អស់ឥន្ទ្រិយ ៗ
ហើយប្អូនរ័ត្នសោយសោកពី-
នៅកណ្តាលទីព្រៃអដ្វា ៗ
មួយវែក្រងសត្វវាពាធា
អសារសូន្យសោះបង់មេត្រៀត ៗ
ឈើខ្លាចផ្សាស្រទូងចង្អៀត
នៅកណ្តាលគម្ពីរា ៗ
បុរសរ័ត្នស្តេចលីលា

ហិចហែលក្នុងគង្គា　　យើងបញ្ឈប់ស្លេះសិនហោង ។
ទើបយើងនឹងសំដែង　　និទានថ្លែងដោយទំនង
កាលក្រោយក្សត្រច្បាស់ច្បង　　មានភេត្រាបើកចេញចរ ។
ឯនាយភេត្រានោះ　　សោតនាមឈ្មោះហៅសាគរ
ពាណិជនាំអស់ប -　　រិពារប្រាំរយគណនា ។
បើកក្តោងឆ្ពោះសំដៅ　　តម្រង់ទៅនគរា
បើកតាមឆ្នេរជលសា　　លុះព្រឹកព្រាងស្រេចមកដល់ ។
ដែនដាក់នាងធីតា　　វរជាយារ័ត្ននិម៌ល
នៅនាទីថ្នាក់ថ្នល់　　ទៅទឹមទៀបវរជាយា ។
ខ្លះប្រាប់នាយសំពៅ　　ថាអ្វីហ្ន៎ដូចមនុស្សា
គួរយើងបោះយុថ្កា　　ចូលទៅមើលឱ្យប្រាកដ ។
ខ្លាចក្រែងអស់ទេព្តា　　នៅរក្សាឆ្នេរសមុទ្រ
ឬមួយមនុស្សកំសត់　　ក្រែងវង្វេងព្រៃព្រឹក្សា ។
ទើបអស់អ្នកទាំងនោះ　　ដាក់ក្តោងឈ្មោះបោះយុថ្កា
ស្រេចហើយទើបនាយពា -　　ណិជនាំក្មួយចុះសំប៉ាន ។
ចែវចូលដោយជោរជល　　លុះបានដល់ឆ្នេរត្រើយត្រាណ
ឯនាយទៀងទៅថ្កាន　　យល់នាងនាថឆោមប្រពៃ ។
ក្មួយកើតការស្នេហ៍ស្និទ្ធ　　ត្រេកអរក្តាត់នឹងស្រីថ្លៃ
សាសងសួរសម័យ　　សព្វដំណើរវរជាយា ។
នាងប្រាប់ដោយសេចក្តី　　ថាស្វាមីខ្ញុំយាត្រា
ហិចហែលក្នុងគង្គា　　ទៅយកបុត្រទាំងពីរពង្ស ។
នាងប្រាប់អស់ប្រការ　　ឯភារាក្មួយចិត្តចង
ថាហៃប្អូនស្នេហ៍ស្នង　　កុំចៅចាំនៅនេះណ៎ា ។
អញបងនឹងយកទៅ　　រួមលំនៅជាភរិយា
កុំប្អូនដោះសាថា　　ធ្វើកោតការក្តីឆ្គាំឆ្គង ។
អញបងបានពើបពះ　　ជួនប្រទះមាសស្នេហ៍ស្នង
អញនឹងរក្សាគ្រង　　ជាភរិយារួមមេត្រី ។

(កៅ (ឧកញ៉ាកោសាធិបតី), ក្រុងសុភមិត្រ, ទំព័រ ២៦ - ៣៦)

ក្រុងសុភមិត្រ

Introductory Note

ក្រុងសុភមិត្រ /kroŋ-soppəmɨt/ King Subhamitra, hero of the epic of the same name

ឧកញ៉ាកោសាធិបតីកៅ Oknha Kosadhipati Kao, author of the story 'King Subhamitra'

បញ្ញាសជាតក /paññaasaq-ciədɑq/ Fifty Jatakas (50 apochryphal birth stories not included in the Tripitaka, but very popular in Cambodia, Thailand, and Laos)

ក្រុងអសុភមិត្រ King Asubhamitra

ឧបរាជ /quppəraac/ Vice-King

អាណោចអាធ័ម sad, pathetic, pitiable

Text

ក្សត្រា King (i.e. Subhamitra)

ជ្រោះ gorge, mountain stream, spring

អូរ seasonal stream

ចង្អូរ ditch, gully, small channel of water

បោក្ខរណី /paokkhaarənəy/ lotus-pond

រេះ to wear away, shave off, chip away

រង settled, cleared up

រេះរាបរងថ្លា [water] wears down [the earth around the pond, where it] settles [to the bottom, leaving a] clear [surface]. (This is a good example of the common poetic device of portraying an entire picture with a few basic words.)

ពីរពង្ស (= ពីរអង្គ)

ត្បូងខ្សាច់ sandbar, sand dune

បូ bow (of ribbon or cloth)

បុស្ប /bos/ flower (Lit)

បូបុស្ប bow-shaped blossom

រុះ to untie, undo, unfold; to fall, drop, sprinkle down

ផោរ (= ពីរផោរ) odor, fragrance

កាកែស a plant with fragrant flowers

ចេកទេស a kind of flower (canna lily?)

យុថ្កា a kind of flower

ម្លិះរួត a variety of jasmine

ម្លិះលា a variety of jasmine

ចិន្រង a kind of flowering tree

ចំរុ a kind of flowering tree

សូរភី (= សុរភី) a kind of flower

មហាហិង្គុ /məhaahɨŋ/ the plant asafetida

ប្រយង្គុ /prɑyɑŋ/ the plant Panicum Italicum

នួនស្រី a variety of jasmine

ស្រទិ្វត dwarf fig tree

ច្វា an odorless flower

លនែ្ត a small plant with fragrant flowers

រំចេក a kind of cactus with fragrant blooms

ផាសផាល all around, all over

ផ្គួរ cluster, bunch

សំយុង hang down, point down; downward

យោនយោន hanging all around, suspended all over

ស៊ាន buzzing, humming

សៀង sound, voice

ត្រឹប to suck

ជញ្ជាប់ to suck

រួសរាយ genial and entertaining, expansive

សំណេះ to reminisce, exchange memories

ព្រាប់ព្រាយ (= ព្រាយព្រាប់)

ប្រឡេះ to shell (corn); shell out, rub off, gather

ឫស្សាន jungle, deep forest

ជ្រងំ dead, complete (intensifier for quiet, calm, peaceful)

ធារ immense, huge

ពិលាប to lament, mourn and weep (Lit)

ចរចេរ go, walk (Lit)

ពៀង carry in the arms

ទៀង to continue

ថែ to care, be concerned

សម since, given the fact that

សន្លោច sad, melancholy, plaintive

ឥតល្ហើយ relentlessly, without respite, unrelievedly

បង--- មក If I had known it would be like this, I wouldn't have brought you along.

អម្មេញ /qαmmənɨñ/ to suffer (mental anguish)

រែង increasing(ly)

គាប់ខុស [whether] right or wrong

ព្រលឹង soul

ជួបជួន to meet

មូលបរិបូណ៌ to form a complete whole (i.e. be all together)

ភូធរ king (Poetic)

ទគ្គឹះ anxious, worried; feel anxiety about

សញ្ជាប់ sad and pensive (of facial expression)

ចំបែង to brood, agonize, worry

អមោក្យ sad, disconsolate

ប្រវាល expanse, wide surface

រន្ធត់ agitated, surging

ពន្លឹក strong, loud, great

បែកផ្សែង to break into spray, throw up a mist

គគ្រេងគគ្រាំ (= គគ្រាំគគ្រេង) with a constant roar

អស់ទិសា (= អស់ទិស) in every direction, all around

ផាត់ to blow (Lit)

ផាត់ផាយ (= ផាយផាត់) to blow (Lit)

ពិន្ទុង a kind of whale

បបែល ray fish

ឆ្លាម shark

ឆ្លាំង catfish

សំកាំង to float, glide, soar

ភាំង have a mental lapse, go blank

ពលា /pŭəllie/ force, strength

ឆ្នៀរឆ្នេរ beach, shore

ជ្រាលជ្រៅ (= ជ្រៅ)

ស្ញើម to be amazed at, impressed by, stand in awe of

សរពេជ្ញ /sarəpɨc/ the one who knows all (i.e. the Buddha)

ជិនស្រី /cɨnnəsrəy/ the victorious one (i.e. the Buddha)

ថ្នាក់ថ្នល់ terrace, bank, elevation

ជល /cŭəl/ water (Lit)

ជោរជល brim with tears

សីមា boundary, border; here: land, shore

ដឹងដាននទី know the coastline well

សន្ធ្យា /sαntyiə/ dusk, twilight

លាភជ័យ good luck

ទូរ remote, distant

អម្លុង period of time, lapse of time

អម្លុង--- ទេះណា there hasn't been

anything like this for quite a long time
ពួក they (i.e. the children)

យាយី to harm, hurt

អង្គឹ (=មិនដែន)

យល់អង្គឹក្ដី seemed unusual

ស្មាស្មប់ to crouch and move from side to side in anticipation of an attack
ចំប្រប់ trembling, shaking

វាទី the speaker

កល (here: to use the strategy of, to trick by)
ពិសាល (=ពិសេសពិសាល) excellent, special
កន្លេង agitated

ផ្សា (=ព្រោះ; Archaic)

ពុំដឹងសេចក្ដី inexperienced, immature
បំបាត់ជីវី to kill, take [their] lives (Lit)
ទំនួញ a lament, wail, cry

រួតរះ to hurry

តក្កសិលា Takkasila (place name)

ថ្នាក់ថ្នម cherish, pamper, treat gently
ស្រាងសុរិយា to be just light, light as at predawn
តែង still, typically, continuing to, in the process of

ទុព្វល /tuppŭəl/ debilitated

ណស់ (=ណាស់)

ចៅ you (Lit)

ប្រយ័ត្នក្រោយ be careful (lit: keep a lookout behind)

ហិង្សា to harm, bother, mistreat

សន្សំស្រាងសីលា accumulate merit (i.e. by keeping the precepts)

ពឹង --- ស្មុទ្ធ ask for the benevolence of the forest

ស្រយុត to sag, droop, collapse, feel enervated
ទសពល the strength of ten [elephants](i.e. Subhamitra)
សស្រោក profusely

លន្លង់ desolate, melancholic, sad

ស្រៀវ to feel a chill of fear, to shiver
យង់យល់ to see

ផ្ដែផ្ដាំ to admonish, counsel, leave final instructions
ពោធិសត្វ /poothisat/ Bodhisatva (i.e. Subhamitra)
ជលសាគរ /cŭəlləsaakɔɔ/ ocean

គម្ភីរា (=គម្ភីរ) deep, profound, unfathomable
ឃ្លាឃ្លៃ (=ឃ្លាតឃ្លៃ) exhausted and dejected
កន្សែង to weep, cry (Roy)

ទ្រឹនទ្រង់ wide-eyed (with fear or surprise)
ទន្ទឹង to wait expectantly

ទល់ទុក្ខ facing grief, in misery

ថប់ be worried lest, have a negative premonition about
ពាធា to hurt, harm, do damage to
បង់មស្សៀត needlessly, to no good purpose
ភេត្រា seagoing sailing vessel

សាគរពាណិជ name of a ship's captain (lit: seagoing merchant)
ទីមទៀប next to

ឬមួយ or, or perhaps

ដាក់ក្ដោង to lower the sails

ជោរជល ocean tide

ក្ដួចកើតកាន់ស្នេហ៍ស្និទ្ធ [a feeling of love] arose toward her
សម័យ information, matter, circumstances
ភារា (=ក្រុង) the ship's captain

ធ្វើកោតការក្ដីស្នាំគ្គង pretend that you respect [your husband and that this would be] an impropriety

២៩. សព្វសិទ្ធិ

ដោយ

ឥន់ (ហ៊ួនភក្ដីអក្សរ)

បុព្វកថា

រឿងសព្វសិទ្ធិជារឿងមួយនៃបញ្ញាសជាតក ។ ច្បាប់ដើមសរសេរជាបាលី ។ នៅឆ្នាំ១៨៩៩ ទើបហ៊ួនភក្ដីអក្សរឥន់ រៀបរៀងឡើងជាពាក្យកាព្យ ។

កាលព្រះសម្មាសម្ពុទ្ធនៅជាពោធិសត្វនៅឡើយ ទ្រង់កើតជាសត្វជៀបកប្បាស មានភរិយាព្រមទាំងកូនខ្ចី ។ ព្រឹកថ្ងៃមួយ ជៀបកប្បាសឈ្មោលហើរទៅរកចំណី ។ នៅពេលកំពុងត្រឹបលំអងកេសរផ្កាឈូកធំមួយ ជៀបកប្បាសក៏ត្រូវផ្កាឈូកក្ដោបជាប់នៅក្នុងត្របកទៅ ។ នៅថ្ងៃដដែលនោះ ភ្លើងព្រៃរាលមកឆេះសំបុកនិងកូនស្លាប់ទៅ ។ លុះដល់យប់ជ្រៅផ្កាឈូកក៏រីកឡើងវិញ ជៀបកប្បាសឈ្មោលក៏ហើរទៅរកប្រពន្ធកូន ដោយមានទាំងគន្ធបទុមជាប់ជិតនឹងខ្លួនផង ។ ឯជៀបកប្បាសញីខឹងនឹងប្ដីទៅបាត់មួយថ្ងៃទាល់ល្ងាច ហើយដោយគិតថាប្ដីទៅមានសហាយ ក៏ស្ទុះចូលក្នុងភ្លើងស្លាប់ទៅ ។ ជៀបកប្បាសឈ្មោលឃើញដូច្នោះ ក៏ហើរចូលភ្លើងស្លាប់នៅគ្រានោះដែរ ។

អត្ថបទ

(បទពាក្យ ៧)

ចាបឈ្មោលតែងហើររកចំណី   ទុកនាងបក្សីឲ្យរក្សា ។
ថែទាំចាំកូននៅសំបុក   ជាទីឥតទុក្ខជាសុខា
សម័យមួយនោះព្រះសុរិយា   រឿងរះជ្រះថ្លាព្រហាមស្មោះ ។
ចាបឈ្មោលហើរចាកលំនៅស្ថាន   ទៅតែមួយប្រាណហើរផ្លេកផ្លោះ
ចូលពនាល័យព្រៃព្រោះ   ហើរហោះទៅទៀបទីស្រះស្រី ។
មួយមានឈូកឈរដុះទហង់   លំចង់ស្បង្កីដចង្កុលណី
រីកបែកបុប្ផកេសរថ្មី   ដោយព្រះសុរិយទើបរឿងរះ ។
បក្សានេត្រាក្រឡេកយល់   បុប្ផនិម៌លព៌ណ៌ល្អះ
ហោះពួយឆៀងឆាបស្លាបទទះ   ចុះទៅក្នុងស្រះទំចឹកផ្កា ។

ល្មមព្រះទិនករចរទគ្រៀយគ្រៀន អណ្តែតលយលឿនចាកព្រឹក្សា
ស្រឡះច្បាស់ទង់ព្រះសុរិយា ចំហាយឧណ្ហាចំផែនដី ៗ
រីងបុស្សបង្កក្នុងស្រះនោះ លង់លុះត្រូវក្តៅព្រះសុរិយ
រីតរួតក្តោបជិតទៅវិញខ្មី ចាបនោះឥតបីដឹងទៀយណា ៗ
កំពុងចឹកចាប់ជាតិបទុម លោដូចគេរុំរួបកាយា
រួតរីតជិតជាប់នៅក្នុងផ្កា បក្សាភិតភ័យក្រៃស្ទើរស្លាប់ ៗ
ខំប្រឹងបម្រះក្រឡាស់ស្ទុះ នៅក្នុងផ្កានោះជាប្រញាប់
ខ្លួនសោតទម្លួលជ្លួលផ្ងាផ្កាប់ ស្ទើរនឹងសូន្យស័ព្ទស្លាប់អសារ ៗ
រីងថប់ញ័ររញាប់អស់អង្គប្រាណ ទំខានខ្សឹកខ្សួលក្តួលសោកថា
ឱះឱ ! ភរិយាបុត្រស្នេហា សមនឹកបិតាស្វាមីច្បាស់ ៗ
ខំស្វែងត្រាច់មករកផលា ព្រោះក្តីស្នេហាសង្សារសត្វ
ឥឡូវពាំនៀវទៀវមកកាត់ ឱ្យកាយខ្វាយខ្វាត់ដូចច្នះណ៌ា ៗ
ខ្លួនស្លាប់តាមកម្មពុំចាំគិត អាណិតតែកូននៅឯកា
ប្រពន្ធនៅក្រោយសមខ្លោចផ្សា ទោមនស្សទុក្ខាឃ្លានចំណី ៗ
រឿងនេះលើកទុកពុំចារចែង នឹងចាត់សំដែងទៅបក្សី
កាលបក្សាហើរចេញទៅខ្មី ថ្ងៃនោះព្រោះក្តីអកុសល ៗ
បង្កើតភ្លើងព្រៃឆេះព្រៃព្រឹក្ស សន្ធៅសន្ធឹកដោយស័ព្ទខ្យល់
ច្បាកបក់ផ្សែងផ្សាចលាចល រាលទៀបមកដល់ទីសកុណី ៗ
នាងចាបឃើញជាក់ផ្លាក់ថ្លើមក្តុក រំជួលក្តួលចុកសព្វមសី
ស្រយុតស្រយង់អង្គឥតបី ហើរចាកឃ្លាតខ្មីព្រោះភ័យខ្លាំង ៗ
ស្ទាស្ទុះឆ្លេឆ្លាផ្សាដោយគិត អាណិតដល់កូនស្មើជីវំ
សោកាទន្ទត់ស្លុតស្លាំងកាំង ញាប់ញ័ររអស់ទាំងអង្គកាយា ៗ
អន្ទះអន្ទែងទែងផ្សាខ្លោច កណ្តោចកណ្តែងឯងឯកា
ទើបទួញថាឱ្យកូនសង្សារ សមក្ស័យជីវាម្តងនេះហើយ ៗ

ឱ្យអ្នកជាប្តីថ្លៃពន្លក ម្តេចពុំឃើញមកណា៎អ្នកអើយ
ភ្លើងព្រៃឆេះកូនសូន្យឥតត្រើយ កូនអើយម៉្លេះសមអ្នកក្តៅផ្សា ។
សោកហើយនាងចាបឆាបហើរចុះ ទើបហាចំពុះនឹងអាត្មា
ចឹកពាំនាំកូនស្ងួនសង្សារ នឹងពាំយាត្រាក៏ពុំបាន ។
អនិច្ចាចាបញីញ័ររអស់អង្គ ហើរហក់វិលវង់សោកប្រះប្រាណ
ទួញថាឱ្យកូនស្ងួនកល្យាណ ម៉្លេះសមម្តាយខានឃើញមាសថ្លៃ ។
ហើយថ្លែងអង្វររអស់ទេព្រឹក្ស ស្ថិតស្ថានសំណាក់និត្យនៅព្ធ -
ប្រោះប្រោយសូមជួយគិតកែខៃ ឱ្យកូនរួចក្ស័យគ្រានេះណា៎ ។
ភ្លើងនោះឆេះរាលដាលត្រដួច ឆាបឆួចសំបុកនៃបក្សា
ឆេះរោលទាំងកូនសូន្យសង្ខារ ក្សិណក្ស័យជីវាវិទំពេចខ្ចី ។
នាងចាបឃើញកូនក្ស័យដូច្នោះ ស្លុតស្លក់ពុងពោះបាត់ស្មារតី
ទួញថាឱ្យកូនស្ងួនពិសី កម្មអ្វីមកកាត់ឱ្យខ្ចាត់បង់ ។
ទាំងកូនក៏សូន្យក្នុងភ្លើងព្រៃ ទាំងប្តីក៏ព្រាត់បាត់ទាំងអង្គ
ព្រឹកមិញនៅជុំគ្នារហង់ នឹកឡើងមិនចង់រស់ថ្វីឡើយ ។
រស់នៅធ្វើអ្វីអប្រិយប្រាណ ឱ្យតែរំខានមិនត្រាស្បើយ
បើភ្លើងឆេះផ្លាញស្លាប់ឱ្យហើយ ទ្រូងអើយសោះនឹងរងវេទនា ។
ថ្លែងពីចាបឈ្មោលដែលចូលជាប់ នៅក្នុងស្រទាប់បទុមា
លង់លុះព្រលប់យប់សន្ធ្យា ចន្ទ្រាទៀងរះជ្រះនភា ។
សន្សើមស្រាក់ធ្លាក់សស្រោក ចុះជោកព្រឹក្សាសព្វមាលី
រីករាយរំសាយស្រទាប់ភ្ញី បក្សារួចពីក្នុងបុស្បី ។
ហើយហើរម្នាក់ឯងវិវេកពេក ផ្លោះផ្លេកផ្លេចភ្លាមតាមរស្មី
ព្រះចន្ទភ្លឺយង់ក្នុងរាត្រី ឥតបីបង្អង់លង់ឡើយណា ។
ក្លិនរសកេសរដែលរួបអង្គ ក្រអូបផុំហ្វង់ជាប់កាយា
លុះហើរមកដល់ទីអាត្មា ឃើញព្រៃព្រឹក្សាភ្លើងឆេះអស់ ។

ចាត់ចាំងសំបុកដែលទុកកូន
ប្រពន្ធក៏ចាត់ពិតចំពោះ
រឹងរឹតញ៉ាំ រញ៉ាប់ចំប្រប់ប្រាណ
ឱ្យកូនកំសត់បុត្រទ្វេហារ
គ្រានោះឯនាងសកុណី
ទើបចេញពីទីព្រៃព្រឹក្សាសាល
អ្នកឯងទៅទីព្រៃបានសប្បាយ
ឥឡូវភ្លើងទីព្រៃឆេះព្រឹក្សា
សព្វកាលទៀងមកមកត្រូវពេល
គ្រានេះប្រែចិត្តកាត់អាល័យ
យល់ជាត្រូវចិត្តស្និទ្ធរួមរ័ក្ស
ថែមផ្កុំក្លិនផ្កាជាប់ក្លិនស្រី
ហើយធ្វើជានឹករឭកកូន
នរណាមិនដឹងកលក្លែងក្លាយ
សកុណាបក្សាបានស្ដែងស្ដាប់
ទើបឆ្លើយនាងអើយបងរែងគិត
តែបងបានហើរដើរដោយជ្រោះ
មានផ្កាឈូករីកច្រើនក្រាស់ក្រៃ
ជួនថ្ងៃទៀងរះស្រឡះពិត
ដោយសារកំដៅព្រះសុរិយា
លុះសែងអាទិត្យអស្ដង្គត
សនៀមរាយរុះចុះសព្វស្ថាន
ឯបងក៏រួចអង្គកាយា
នាងកុំកាន់ចិត្តកើតទុក្ខម្នេញ

ឃើញស្ងាត់សោះសូន្យក្នុងសានគ្រោះ
គឺមោះជាកម្មនៃអាត្មា ៗ
រំខានខ្ញុំកខ្វល់ក្ដួលសោកា
ទៅណាពុំឃើញដូចសព្វកាល ៗ
ឃើញប្ដីមកដល់សោកដាសដាល
មកផ្ទាល់ស្រដីឱ្យប្ដីថា ៗ
ត្រេកនឹងសហាយត្រូវចិន្ដា
ឆេះកូនទ្វេហារមរណាក្ស័យ ៗ
មិនដែលខាតខានខុសមួយថ្ងៃ
គេចវេះដោះដៃរកស្នៀតថ្មី ៗ
ស្មោះស្ម័គ្រស្រឡាញ់ពេញបេតី
នឹងមកធ្វើអ្វីអ្នកថ្លៃអាយ ៗ
ដែលសូន្យប្រល័យក្ស័យអន្ដរាយ
ឱបាយមាយាជាពាក្យពិត ៗ
សារស័ព្ទប្រពន្ធប្រចណ្ឌចិត្ត
ដល់មិត្តមាសស្ងួននឹងកូនថ្លៃ ៗ
ឃើញស្រះមួយនោះណា៎កែវថ្លៃ
បងសោតប្រស្រ័យចុះចឹកផ្កា ៗ
ផ្កាឈូកសោតរឹតរួតកាយា
បងជាប់ក្នុងផ្កាចេញពុំបាន ៗ
ចរផុតបិទបាំងព្រះសុរិឆាន
ទើបបានផ្កាសោតរីកឡើងវិញ ៗ
ហិចហើរយាត្រាមកនេះមិញ
ទោមនស្សទន្ទេញថាច្នោះឡើយ ៗ

បក្សីស្ដាប់ជាក់ទើបតបថា   កុំប្រែប្រាជ្ញាណាអ្នកអើយ
ប្រសិនអាល័យខ្ញុំមែនហើយ   ម្ដេចធ្វើតោះតើយដូច្នោះណ៎ា ៗ
វិស័យកើតជាប្រពន្ធប្ដី   គប្បីដឹងទុក្ខដឹងសុខា
ទើបហៅស្រឡាញ់ពេញស្នេហា   នេះមាត់តែថាអាណិតណាស់ ៗ
ឯចិត្តបែកបែរប្រែប្រឹងឆ្លៀត   គិតរកថ្មីទៀតចោលឯចាស់
ហើយថាផ្កាក្ដាបជាប់ក្នុងស្រះ   ខ្ញុំដឹងចិត្តច្បាស់យ៉ាងនេះឯង ៗ
ហ៊ានចោលទាល់ភ្លើងឆេះសំបុក   ធ្លាក់កូនត្រសុកទៅក្នុងត្រែង
គ្មានសល់រូបសោះអស់ឆ្អឹងឆ្អែង   ឃើញមានតែផ្សែងហុយដង្គាល ៗ
ឱកូនសំឡាញ់ពេញចិត្តស្ម័គ្រ   ម្ដាយនឹកដើមអ្នកធ្លាក់ថ្លើមក្ដួល
ម្ដាយសោកពិលាបសព្វខ្សឹកខ្សួល   ឈឺឆ្អៀបឆេះឈ្លួលញ៉ាំទ្រុងពោះ ៗ
បក្សាបៀតបែរតែចាំស្ដាប់   ប្រពន្ធសារស័ព្ទស្ដីបញ្ជោះ
ខឹងខ័ណ្ឌប្រចណ្ឌប្រជែងឈ្លោះ   គំរោះគំរាមតាមក្រោធា ៗ
ទើបលោមប្រលោមថាព្រលឹង   មាសនឹងខឹងថ្វីពៅពុំងា
បងត្រង់គំនិតឥតមាយា   ជាក់ជាស្រឡាញ់ពេញពីពោះ ៗ
ដែលពុំបានមកដោយពេលពិត   ដោយសារផ្កាវីតស្ទើរពុំរស់
កម្មអើយកម្មកាត់ឱ្យព្រាត់ឈ្មោះ   សូមប្អូនសង្គ្រោះអត់ទោសា ៗ
សកុណីស្ដីហើយឆ្លើយឥតក្រែង   ថាចិត្តអ្នកឯងចំបូសព្រា
ខ្ញុំដឹងជាក់ស្រេចកុំបាច់ថា   អាងតែប្រាជ្ញាចេះកែខៃ ៗ
នាងរឹងរំជួលក្ដួលឥន្ទ្រិយ   ហាក់ដូចអគ្គីឆេះឧទ័រ
ឧរារឹតរឹងតឹងស្ទើរក្ស័យ   តែងសោកាល័យពុំស្រាកស្រាន្ត ៗ
បក្សាជាប្ដីស្ដីហេតុប្រាប់   ពុំចូលចិត្តស្ដាប់ជឿស្មោះស្មាន
វិយោគស្រណោះចោះចោកប្រាណ   រំខានទៀងទួញទំនួញថា ៗ
ឱកូនកំសត់មាសម្ដាយអើយ   ពីនេះទៅហើយម្ដាយឈឺផ្សា
នឹងទ្រាំតែទុក្ខទៅដល់ណា   សូវសូនព្រៃវិវាតាមមាសថ្លៃ ៗ

ថា ហើយកាងស្លាបក្រាបបង្គំ ប្រណម្យទេវតាសួគ៌ាល័យ
ទាំងទេពស្ថិតស្ថានដានព្រឹក្សព្រៃ នៅនៃគិរីទីបព្វតា ។
សូមអស់លោកជួយជាសាក្សី ទោះបីខ្ញុំកើតជាតិកាណា
ខ្ញុំសូមតាំងចិត្តគិតសច្ចា ប្រាថ្នាកុំឲ្យទៅរួមកាយ ។
នឹងជាតិជាប្រុសគ្រប់អង្គប្រាណ ហើយកុំឲ្យបានថែងអភិប្រាយ
មេត្រីស្តីស្តាប់សព្ទបរិយាយ ឲ្យឆ្ងាយវៀងរាល់ជៀសឲ្យបាន ។
ទោះបីទៅកើតភពណា ៣ ជាសត្វមនុស្សាសព្វគ្រប់ស្ថាន
ជាតិប្រុសកុំស៊ីគ្រនីក្សរួមប្រាណ កុំឲ្យរាប់អានស្ពានមេត្រី ។
គ្រានោះសកុណាបក្សាសត្វ សម្ងាត់ចាំស្តាប់ស័ព្ទបក្សី
ពុំនាងសច្ចាថាថ្នោះខ្មី ទើបស្តីឆ្លើយឆ្លងស្នងវិញថា ។
សូមអស់ទេពទសសោឡសស្ថាន ស្ថិតក្នុងត្រើយត្រាណឆកាមា
ជួយជាសាក្សីខ្ញុំប្រាថ្នា តបស្នងវាចានាងបក្សី ។
ដ្បិតគេប្រាថ្នាអនាគត ឲ្យចៀសឲ្យផុតខ្ញុំជាប្តី
ជាតិប្រុសគេថាមិនមេត្រី មិនស្តីមិនស្តាប់សព្ទវាទី ។
ថាខ្ញុំស្រឡាញ់មិនពេញស្ម័គ្រ នឹងនាងនេះជាក់ស្មើជីវី
ពុំមានបែកបែរប្រែចិត្តពីរ ដែលរកកញ្ញាឯទៀតសោះ ។
ជាតិក្រោយសូមឲ្យបានរួមរ័ក្ស នឹងនាងនេះជាក់ជាគូស្មោះ
ខ្ញុំស្តីឲ្យស្តាប់ស័ព្ទស្រណោះ កុំឲ្យរដោះលុះនិព្វាន ។
ឯនាងសកុណីបានស្តែងស្តាប់ បក្សាសារសព្ទតាំងប្រណិធាន
ចិត្តក្តៅគិតក្តួលឆួលវិះធ្យាន មិនមាននឹកស្តាយដល់ជីវា ។
ហើរចុះចូលស្លុងក្នុងកងភ្លើង ឆេះទៀងរលត់ផុតកាយា
ចាបឈ្មោលឃើញជាក់ឆ្លាក់ថ្លើមផ្សា ស្ទុះផ្លោះចូលឆ្លាក្នុងអគ្គី ។

(តន់ (ហ៊ីនភក្តីអក្សរ), ទេវ្រីងសព្វសិទ្ធិ, ទំព័រ ៧ - ១៥)

សព្វសិទ្ធិ

Introductory Note

សព្វសិទ្ធិ /sɑp sət/ Sabvasiddhi (name of one of the fifty apocryphal Jatakas popular in Cambodia, Thailand, and Laos)

ម៉ឺនភក្ដីអក្សរ /məɨn-pheəqkədəy-qaqsɑɑ/ royal title for a scholar

ឥន name of the Cambodian author of Sabvasiddhi

ព្រះសម្មាសម្ពុទ្ធ /preəh-sammaasamput/ the Enlightened One (i.e. the Buddha)

ដៀបកបព្យាស a kind of small sparrow

កូនខ្ចី baby, newborn infant

ចំណី food (Lit)

លំអង pollen

រាល to spread, expand

គន្ធ /kŭən/ fragrance

បទុម /patum, botum/ lotus

មួយថ្ងៃទាល់ល្ងាច all day long

Text

ជាទី...សុខា happily, with no problem

រះ to appear, come out, shine

រៀងរះ to come out gloriously, shine brightly (of the sun)

ព្រហាម dawn

តែមួយប្រាណ alone, by himself

ពនាល័យ forest, forest abode

រពៀះ sparse, spaced

លំចង់ a kind of aquatic flower

ចង្កុលណី /cɑŋkollənəy/ an aquatic plant (same family as lotus, water lily)

ព្រះសុរិយ /preəh-sorəy/ the sun

ហោះពួយ to dive (from the sky), make a pass at

ល្មម just as, at the same time as

ព្រះទិនករ /preəh-tɨnnəkɑɑ/ the sun (Lit)

គ្រឿយគ្រឿន slowly, gradually

ចំហាយ steam (here: heat)

ឧណ្ហា /qonnəhaa/ hot (Lit)

បុស្សបង្គ /bohsəboŋ/ lotus (i.e. flower [which rises from] the mud)

រឹតរួត to constrict, tighten, contract

លោដូច as if

រួប to squeeze

រួតរឹត (=រឹតរួត)

រមួល twisted

ក្ដួល to be in a torment, heart-sick

ខ្វាយខ្វាត់ (=ខ្វាត់ខ្វាយ)

ពុំចាំគិត not concerned, doesn't matter, don't have to worry

លើកទុក to set aside, put aside

ចាត់ undertake to

សន្ធៅ fiercely, like an inferno

ផ្សែងផ្សា acrid smoke

ចលាចល [causing] turmoil, confusion, pandemonium

សកុណី /saqkənəy/ female bird

ចុក to have a pain, have a cramp

មំសី /meə̆ŋsəy/ (=/meə̆ŋsaq/) flesh, meat (Roy, Clergy)

ស្រយង់ to be numb, asleep (of a limb)

ឥតបី (=ឥតបីឧបមា) extremely

ស្ទា to sidle back and forth evasively, dodge back and forth

ឆ្លេឆ្លា to cast about in a panic

ជីវំ /ciiwĕəŋ/ life

ស្លាំងកាំង stupified, stunned

ផ្សារខ្លោច (=ខ្លោចផ្សារ) anguished

កណ្ដោចកណ្ដែង lonely, desolate

ចំពុះ beak, bill

អនិច្ចា preceding a noun in Cambodian literature: the poor..., the unfortunate...

ទេព្រ័ក្ស guardian angels

ជ្រោយ cape, point (of land)

រើករើ to reflect, deliberate, resolve (a problem)

ផាល to spread, extend

ត្រដួច to loom, tower, rise above all else

ឆាប to reach, lick at (of flames)

កួច to swirl, twist, revolve, whirl

រោល to scorch, singe

ស្លក់ to be pale

ស្រា to cease, die down, diminish

ផ្លាញ (=បំផ្លាញ)

ជោក soaked

មាលី flower

ស្រទាប់ petal, layer, stratum

រំសាយ to loosen, spread, distribute loosely

បុស្បី /bohsəbəy/ flower (Lit)

វិវេក sad, lonely, desolate

ផ្លោះផ្លេក (=ផ្លេកផ្លោះ)

ផ្លេច quickly, with a dart, like a flash

ហ្វង់ /wɑŋ/ extremely (clear, bright, fragrant)

សាន (=ស្មសាន) jungle

គ្រោះ dangerous, full of danger

ចំពោះ (here: from [him])

សាល (=សាន)

ផ្ចាល to rebuke, reprove

ស្រដី (=ស្ដី) to say, speak (Lit)

ខាតខាន (=ខាន)

កាត់អាល័យ to stop loving, betray love

ស្នៀត trick, strategem

រកស្នៀតថ្មី be unfaithful, have an affair, find a lover

ពេញបេតី with all one's heart

ប្រល័យ to ruin, destroy; to die; death, destruction, ruin

ឱព្រាយ---ពិត to pass off your pretensions as truth

សកុណា /saqkonnaa/ male bird (Lit)

ប្រចណ្ឌ /prɑcan/ jealous (of one's spouse or lover)

ប្រស្រ័យ to like, desire (Lit)

ព្រះសុរិឆាន sun (?)

កាន់ចិត្ត maintain, insist on; here: stubborn, unyielding

រ៉ែប្រព្រាផ្ទា to scheme, look for excuses

វិស័យ chance, fortune, fate; here: [since it was our] fate

ផឹងទុក្ខផឹងសុខា share the bad and the good

នេះ this, in this present case; you, in your case

មាត់តែថា just saying, saying insincerely

ត្រសុក disappearing among, burrowing through

ឆ្អឹងឆ្អែង (=ឆ្អឹង)

ហុយ to rise, puff (of smoke, steam, etc.)

ផង្គោល in a big cloud

ឆៀប scratchy, prickling (as a hair in a shirt)

ឈួល feel a burning, biting sensation (as from horseradish)

បញ្ឆោះ to provoke, egg on, taunt

ចណ្ណ to dictate, order imperiously

ប្រជែង to dispute querulously

គំរោះ rude, crude, coarse

ពេញពីពោះ wholeheartedly, from the bottom of my heart

កាត់ to destroy, alienate, cut off

ឫស្យា /rɨhsyaa/ covetous, begrudging; corrupt

ធុរិន (=ធុរា)

លោកាល័យ (=លោក + អាល័យ)

សួគ៌ាល័យ /suəkiəlay/ heaven

បព្វតា (=បុព្វតា) mountain, hill (Lit)

អភិប្រាយ to talk, converse (Lit)

ទៀងទាល់ continuously, forever

រ័ករួម (=រួមរ័ក្ស) live a conjugal life

ស្ពានមេត្រី to form an alliance, ally with

ស្នង back, reciprocally, in reply

ទស /tŭəh/ ten (Skt)

សោឡស /saolαh/ sixteen

ទេពទសសោឡសស្ថាន the ten angels of the sixteen heavens

ឆកាមា /chαα-kaamaa/ six-level heaven

មាន...ចិត្តពីរ to be unfaithful, have divided loyalties

រដោះ come untied, come loose; be separated

ឆួល to burn, consume

ធ្យាន to meditate

ស្លុង speedily

កង loud, roaring

ឆ្លា vigorous, energetic (here: without hesitation)

ផេះ ashes

៣០. មហាវេស្សន្តរជាតក

(គ្មានឈ្មោះអ្នកនិពន្ធ)

បុព្វកថា

រឿងមហាវេស្សន្តរជាតក ជារឿងមួយនិយាយអំពីកំណើតព្រះពោធិសត្វ មុនព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។ រឿងនេះមាននៅក្នុងព្រះសូត្រដែលជាផ្នែកមួយនៃគម្ពីរព្រះត្រៃបិដក ។ ខ្មែរអ្នកកាន់ពុទ្ធសាសនាចូលចិត្តរឿងនេះជាទីបំផុត ។ នៅពេលចេញវស្សា គេតែងយករឿងនេះមកទេសនាមួយថ្ងៃមួយយប់ ។

រឿងនេះគេប្រទះឃើញជាច្រើនច្បាប់ ជាភាសាខ្មែរ ខ្លះវែងខ្លះខ្លី ។ ចំណែកឯការបកប្រែវិញ គឺមិនមែនជាការបកប្រែត្រង់ ៗ ទេ គេដកស្រង់អត្ថបទបាលី មានវែងមានខ្លី ហើយគេធ្វើអត្ថាធិប្បាយបញ្ចេញបញ្ចូលនូវរឿងរ៉ាវជាច្រើនដែលជាខ្មែរសុទ្ធ ៗ ។ យើងពុំបានដាក់អត្ថបទបាលីបញ្ចូលផងទេ ដោយយល់ឃើញថា ភាសាបាលីជាការសិក្សាដោយឡែក ។ កន្លែងត្រង់ណាដែលមានអត្ថបទបាលី យើងគ្រាន់តែដាក់សេចក្ដីសង្កេតប្រាប់ឲ្យដឹងថា តើនៅកន្លែងនោះ មានអត្ថបទបាលីចំនួនប៉ុន្មានបន្ទាត់តែប៉ុណ្ណោះ ។

រឿងមហាវេស្សន្តរជាតក មិនមែនសរសេរជាពាក្យរាយធម្មតា ឬជាពាក្យកាព្យទៀយ តែអ្នកនិពន្ធប្រើបច្ចេកទេសម៉្យាងដែលហៅថា "ពាក្យកែវ" ដែលជួនកាលមានពាក្យចួនគ្នារដឹក មានទំនងស្រដៀងគ្នានឹងកំណាព្យ ។

អត្ថបទខាងក្រោមនេះ ដកស្រង់ចេញមកពីកណ្ឌឈ្មោះ "កណ្ឌកុមារបព៌" ត្រង់កាលដែលព្រះពោធិសត្វ ឲ្យបុត្រទាំងពីរទៅតាជូជក ។

អត្ថបទ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

[បាលី ៩ បន្ទាត់] ហៃភិក្ខុអើយ នាកាលតថាគតនៅជាព្រះវេស្សន្តរបវរពោធិសត្វ ជាស្ដេចធំតែងចំរើនអ្នកស្រុកស្រីពិរាស្ត្រ ទ្រង់យកព្រះរាជកុមារទាំងពីរ គឺចៅជាលីនិងនាងក្រស្នាព្រះរាជទានដល់ព្រាហ្មណ៍ចាស់ជរា ក្នុងគ្រាកាលនោះក៏កើតជាអស្ចារ្យមហិមា ក្រឡាមហាប្រឹថពីកក្រើកក្រើករញ្ជួយញាប់ញ័រ រីភ្នំព្រះសិនេរុរាជ ក៏សឹងឱនលំទោនទៅកាន់ភ្នំគិរីវង្កតបព៌ត រីព្រះឥន្ទ្រាធិរាជដ៏មានអំណាចជាឥស្សរកំពូលនៃទេវតាទាំងឡាយ ក៏ទះព្រះហស្តទ្រង់ព្រះសំរួល រីអស់ទេវតានិងមហាព្រហ្ម ក៏ពោលពាក្យថ្វាយសព្ទសាធុការ ដ៏អធិកពន្លឹកមហិមានៅនាព្រៃហេមពាន្តសឹងមានរាជសីហ៍ជាដើម ក៏សឹងស្រែកទ្រហឹងអឺងអាប់នូវសព្ទពន្លឹក

ដ៏ក្រៃពេក ។

[បាលី ១ បន្ទាត់] កាលព្រះបាទស្រីវេស្សន្តរបរមពោធិសត្វ ទ្រង់ព្រះរាជទានព្រះរាជឱរសទាំងពីរទៅព្រាហ្មណ៍នោះហើយ ទ្រង់មានព្រះបីតិសោមនស្សថាទ្រង់បានឲ្យទានជាអស្ចារ្យណាស់ ហើយស្តេចឋិតទតរមិលមើលព្រះរាជកុមារទាំងពីរក្នុងកាលណោះឯង ។

[បាលី ១ បន្ទាត់] កាលនោះ ជូជកព្រាហ្មណ៍បានព្រះរាជកុមារទាំងពីរមកនៅក្នុងកណ្ដាប់ដៃហើយក្រវ៉ ក៏ម្នីម្នារលះរលាំងចូលទៅក្នុងដង្គុមព្រៃ ដៃប្រវាព្រាចវល្លិមកខាំកាត់នឹងធ្មេញបានហើយ ប្រវាចាប់ដៃឆ្វេងនាងក្រស្នា ប្រវាចាប់ដៃស្តាំចៅជាលី បានហើយរួបរួបចងជាមួយគ្នា ហើយបណ្ដើរទៅ យកចុងវល្លិវាយដំ នៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តរបវរពោធិសត្វនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ដែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានបន្ទូលនូវបាទព្រះគាថាដូច្នេះ

[បាលី ៤ បន្ទាត់] រីជូជកព្រាហ្មណ៍វាយដំព្រះរាជកុមារទាំងពីរ មានសរីរៈដែកពុះពងរងឈាមក្រហមប្រចាល នៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តរ ។ កាលណាតាព្រាហ្មណ៍វាយនាងក្រស្នា ចៅជាលីយកខ្នងទៅរងតាង កាលបើវាយចៅជាលី នាងក្រស្នាក៏យកខ្នងទៅរងតាង តាជូជកចាប់អូសទាញក្រន្ទាក់នឹងខ្សែវល្លិ ទៅដល់ថានមួយពុំរាប តាព្រាហ្មណ៍ដួលស្រាប់ ខំប្រឹងស្ទុះក្រោកឡើងម្នីម្នា រីព្រះហស្តព្រះរាជកុមារទាំងពីរដែលចងនឹងវល្លិក៏របូតចេញទៅ ទើបព្រះរាជកុមារទាំងពីរបបួលគ្នាម្នីម្នារត់ទៅកាន់សំណាក់ព្រះបរមពោធិសត្វ ថ្វាយបង្គំប្រណម្យ ហើយទ្រង់ព្រះកន្សែងសោកា ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ដែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ

[បាលី ២២ បន្ទាត់] ភិក្ខុអើយ លំដាប់នោះ ព្រះរាជកុមារទាំងពីរផុតរបូតពីកណ្ដាប់ដៃព្រាហ្មណ៍ ក៏នាំគ្នាម្នីម្នារត់មកក្រាបក្រោមព្រះបាទានៃសម្តេចព្រះវរបិតា មានទឹកព្រះនេត្រាហៀរហូរសស្រាក់ ញាប់ញ័រចំប្រប់អស់អង្គប្រាណ ចៅជាលីសំឡឹងមើលព្រះវរបិតាហើយ ខំស្រដីថា បពិត្រព្រះវរបិតាអើយ សូមទានអម្ចាស់ករុណាយើងខ្ញុំបន្តិចសិនរ៉ា ទំរាំព្រះមេនៃយើងខ្ញុំ អ្នកត្រឡប់មកអំពីព្រៃ ដល់ថ្ងៃល្ងាចនឹងស្តេចមកដល់ ហើយសូមអម្ចាស់លួងលោមព្រាហ្មណ៍ឲ្យបង្អង់បន្តិចសិន សឹមអម្ចាស់ឲ្យដំណើរយើងខ្ញុំទៅនឹងព្រាហ្មណ៍ ។ បពិត្រព្រះវរបិតា កាលណាយើងខ្ញុំទាំងពីរ បានក្រាបលាផ្ដាំផ្ញើអ្នកមេយើងខ្ញុំ នូវព្រះបាទអម្ចាស់រួចស្រេចហើយ សឹមយើងខ្ញុំដើរទៅតាមព្រាហ្មណ៍ ដើម្បីបំពេញព្រះបារមីទានអម្ចាស់ ឲ្យបានត្រាស់ជាព្រះពុទ្ធប្រាកដហោង ។ បពិត្រព្រះវរបិតា រីព្រាហ្មណ៍នេះ វាអាក្រក់ក្រៃលែងព្រាហ្មណ៍ទាំងឡាយ

វាប្រកបដោយបុរិសទោស ១៨ ប្រការ អកុសលកម្មនាំមកបង្កើតនៅនាលោកិយនេះ [ប្រាលី ១ ឃ្លា] នឹងគន់មិលមើលទៅបាទជើងនោះធំស្លក់ដំបានកោងក្ងក់ [ប្រាលី ១ ឃ្លា] ដីមាន ក្រចកព្រាមទាំង ១០ នោះខ្មៅស្លុយគ្រប់ទាំងអស់ [ប្រាលី ១ ឃ្លា] មានកំភួនជើងប្រកប ដោយសាច់ដុំរយេងរយោងដូចផ្លែរនោងទុំ [ប្រាលី ១ ឃ្លា] ពពីរមាត់លើយុរយារគ្របពពីរ មាត់ក្រោម [ប្រាលី ១ ឃ្លា] កាណាហាមាត់ស្រដី មានទឹកមាត់នោះហូរសស្រាក់ជោក ថ្គាល់ទាំងសងខាង [ប្រាលី ១ ឃ្លា] មានចង្កូមស្វាចផុះចេញពីមាត់ដូចជាខ្នាយជ្រូក [ប្រាលី ១ ឃ្លា] ច្រមុះនោះបាក់គន្លាក់ពុំស្មើ [ប្រាលី ១ ឃ្លា] ពោះធំកំប៉ោងកំប៉ោក ៣ ប៉ុន ក្អម [ប្រាលី ១ ឃ្លា] មានខ្នងបាក់កោងក្ងក់ [ប្រាលី ១ ឃ្លា] ភ្នែកស្រលៀងស្រទៀវ ខ្ពស់ម្ខាងទាបម្ខាងមិនស្មើគ្នា [ប្រាលី ១ ឃ្លា] មានពុកចង្កាស្រមូវរឹងដូចល្មួសទង់ផង [ប្រាលី ១ ឃ្លា] រីសក់នោះប្រចាលប្រចាញ់រមួលកន្ត្រញរួញលឿងមុខគួរខ្ពើម [ប្រាលី ១ ឃ្លា] តាមរាងកាយមានសរសៃឡើងរវីមរវាម ហើយមានអាចម៌រុយនឹងប្រជ្រុយពេញសព្វខ្លួន [ប្រាលី ១ ឃ្លា] មានកែវភ្នែកលឿងដូចភ្នែកឆ្មា [ប្រាលី ១ ឃ្លា] មានដងខ្លួនវៀចក្ងក់ ត្រង់កត្រង់ខ្នងនឹងចង្កេះដូចជាគេធ្វើលេង [ប្រាលី ១ ឃ្លា] ជើងទាំងពីរក៏កន្ធែកញែកចេញ ពីគ្នាខុសធម្មតា [ប្រាលី ១ ឃ្លា] រោមតាមសព្វខ្លួនរឹងដូចរោមជ្រូក ខុសពីវិស័យមនុស្សធម្មតា ស្លៀកពាក់សៀកខ្លា មិនមែនមនុស្ស មុខគួរស្ញែង ជាមនុស្សឬជាយក្ស ដែលស៊ីតែសាច់ ឈាមទេក៏ពុំដឹង [ប្រាលី ១ ឃ្លា] ចេញអំពីស្រុកមកកាន់ព្រៃនេះមានបំណងប៉ងចូលមកសុំទ្រព្យ សម្បត្តិនឹងព្រះវរបិតា កាលព្រាហ្មណ៍បិសាចនាំយកកូនទៅ វាវាយដំឥតប្រណី ម្តេចឡើយ អម្ចាស់នៅស្ងៀមព្រងើយពុំនាំពា ព្រះហឫទ័យហាក់ដូចជាដុំថ្មសិលា ឬហាក់ដូចគេចងរឹតដោយដែកយ៉ាង ខ្ជាប់ខ្ជួន ឱព្រះវរបិតាអើយ ព្រះអង្គឥតព្រះទ័យអាសូរករុណាដល់កូនបន្តិចឡើយ តាព្រាហ្មណ៍ មានចិត្តកាចឃោរឃៅ ចង់បានតែទ្រព្យ ចាប់យកទៅវាយដំប្អូនក្រស្នាឥតមេត្តាសោះឡើយ មានគួរនាដូចនាយគោបាលវាយប្រហារហ្វូងគោ ដោយឥតមានចិត្តអាណិតអាសូរ ឱក្រស្នាមាស បងអើយ យើងទាំងពីរនាក់នេះ បីដូចកូនម្រឹគដែលនៅកំពុងបៅដោះមេ ហើយព្រាត់ប្រាស និរាសចាកមេទៅ កាលបើរកមេមិនឃើញ ក៏ស្រែកយំរកមេក្នុងព្រៃប្រឹក្សា ប្រាថ្នាតែនឹង បៅដោះមេវាប៉ុណ្ណោះ ។ ព្រះគុណអើយ កូនទាំងគូនេះកំសត់មកប្រទះគ្រាហើយ ពុំមាន ញាតិវង្សាឯណាដល់មួយឡើយ អម្ចាស់ខ្ញុំអើយ យល់តែមាតាបិតាមកគង់ក្នុងព្រឹក្សាជាសន្តោស បើពុំទ្រង់ព្រះមេត្តាប្រោសប្រណី ខ្ញុំជាលីក្រស្នា ពុំដឹងបើអាស្រ័យនឹងអ្នកឯណា ឱ្យរំដោះលែង លើសព្រះអង្គនេះឡើយ ។

កាលព្រះជាលីកុមារ ក្រាបបង្គំទូលព្រះវរបិតាយ៉ាងនេះហើយ ព្រះបាទស្រីវេស្សន្តរ បវររាជឫសី ក៏ទ្រង់គង់នៅស្ងៀមមិនបានមានព្រះបន្ទូលដូចម្តេចឡើយ ។ ព្រះរាជកុមារទាំង

ពីរក៏សោយសោកកន្ទក់កន្ទេញយ៉ាងមហិមា ក្រាបទូលទ្រង់ព្រះកន្សែងពិលាប ដោយបាទព្រះគាថាតទៅទៀតថា

[បាលី ២៨ បន្ទាត់] ឱព្រះរាជកុមារឱព្រះរាជកុមារា កាលអ្នកថ្វាយបង្គំលាទៅ អ្នកសៅសោករអាក់រអួលតានតឹងក្នុងឧរា ទាំងបងទាំងប្អូន ព្រះវរបិតាពុំមានព្រះបន្ទូលស្នងព្រះរាជបុត្រសោះឡើយ ទ្រង់ព្រះចិន្តាតែក្នុងព្រះរាជហឫទ័យ ឱ្យបានសម្រេចដូចក្តីប្រាថ្នា ៗ ឯចៅជាលី ក៏បន្ទូលទៅនឹងនាងក្រស្នាថា ឱក្រស្នាប្អូនអើយ ព្រះវរបិតាអ្នកយកយើងឱ្យទៅជាទានព្រាហ្មណ៍ ម្ល៉េះហើយសមយើងនឹងបានសេចក្តីលំបាកវេទនា យើងនឹងចេញចាកទៅជាមួយនឹងព្រាហ្មណ៍ព្រឹទ្ធាចារ្យ គាត់នឹងវាយដំបែកក្បាលឈាមសព្វខ្លួន ក្រស្នាប្អូនអើយ ធម្មតាសត្វនៅក្នុងលោកិយ សឹងតែជំពាក់នឹងក្តីវដ្តសង្សារ ពុំទាន់បានលុះព្រះពោធិញ្ញាណ គឺព្រះនិព្វានជាបរមសុខ កាលណាតែងមានរោគាព្យាធិភ័យតាមមកទាន់អាត្មាពុំដែលរំដោះ ទើបយើងត្រូវឃ្លាងខ្ទាះ ប្រទាក់អន្ទាក់ណែងណងចងវាយ ដីពុំដែលចៀសវាងបាន មានឧបមាបីដូចប្រាណយើងទាំងពីរនេះឯងហើយ ៗ ឱក្រស្នាមាសបងអើយ នេះជាប្រពៃណីសព្វសត្វផង បងនេះបានរម្ភត្បិតចាកព្រះមាតាស្តេចមកអំពីព្រឹក្សាដល់ព្រះអាស្រម សូន្យឈឹងជ្រងំស្ងប់ស្ងាត់តែម្នាក់ឯង ហើយអ្នកនឹងទ្រង់ព្រះកន្សែងសោយសោកា អ្នកនឹងទួញយំរកយើងទាំងពីរ តាមដោយស្រះស្រង់ សព្វម្លប់ឈើព្រៃ បើពុំឃើញយើងទាំងពីរហើយនែ ឱក្រស្នាមាសបងអើយ សមអ្នកនឹងសោយសោកាសល់សែនអាមោក្ខពន់ប្រមាណ ននៀលប្រះប្រាណ ទួញយំយកព្រះករដំព្រះឧរា សោកស្តាយយើងជាកូនកំសត់ទាំងគូមកនៅក្នុងព្រៃ អ្នកមកអំពីព្រៃព្រលប់បានយល់មុខយើងទាំងពីរ អ្នកត្រេកអរក្នុងព្រះទ័យ បីផ្ទុមអាល័យ ហើយព្រះមេអ្នកឱ្យអស់ផលាសារពើ ដំឡូង ត្រាវ ចេក អំពៅ បង្គា សីរ មាន់ ចន្ទី ម៉ឹកប៉ែន គូលែន លាំងសាត គ្រប់សព្វពណ៌ផលា ហើយអ្នកនាំយើងចូលអាស្រមលំនៅ ហើយអ្នកបំបៅ ផ្លូតទឹកដុសអស់អង្គ អ្នកយករមៀតផង់មកផាត់បំព្រង ទើបឱ្យយើងប្អូននឹងបងឆីផលាផល សឹងដីមានរសពីសា តាមដោយនូវអាហារនៃព្រៃភ្នំ លុះកាលវេលាល្ងាចនឹងចូលផ្ទុំ តែងពិលាបទួញយំទាំងរាត្រី ប្រាមប្រាប់ប្រដៅសព្វសេចក្តី ពុំឱ្យមានខ្វះ ត្បិតយើងលាកលះមកនៅក្នុងព្រឹក្សា ពុំមានញាតិវង្សាឯណាដល់មួយនាក់ឡើយ អ្នកបានយល់តែមុខយើងប្អូននឹងបងនេះហើយ អ្នកគ្រាន់បានស្បើយលំហើយលំហែទុក្ខ ឥឡូវនេះអ្នកពុំបានយល់មុខយើងតទៅទៀតឡើយ ឱម្ល៉េះសមអ្នកនៅតែឯង សមនឹងសោកសង្រេងងដួលសន្លប់ អំពីល្ងាចព្រលប់លុះដល់ព្រឹក សមអ្នកនឹងសន្ធៃសន្ធឹកលុះតែអស់ព្រះកំឡាំង ដូចទឹកត្រពាំងខែប្រាំងត្រូវថ្ងៃក្តៅ ទឹកនោះក៏ស្រកស្រុតរីងហែងហួតស្ងួតខះបាត់បង់ទៅ ក្រស្នាប្អូនអើយ ទុក្ខនេះយូរលង់ក្រៃលែងទុក្ខផងទាំងឡាយ ដែលព្រាហ្មណ៍គាត់វាយដំធ្វើទោសយើងទាំងពីរនេះទៅទៀត [បាលី ១ ឃ្លា] ប្អូនអើយ ទីដើមជម្ពូព្រឹក្សអធិកនូវដើមពោធិ៍បាយ ដីមានមែកត្រសាយត្រសុំសាខា ម្លប់ព្រឹក្សា

ផាលំនៅនឹងសប្បាយ នឹងមានព្រីង ព្រូល ភ្លូ ភ្លង បង្គោ ដូង ផងអង្គាល់ ជ្រៃ ជ្រៃ ខ្ពស់ស្រឈឹងត្រឈៃឆើតឆាយ ឬសវាដុះវែងឆ្ងាយ ពាក់ព័ន្ធទៅមកទាក់សៀតសឹករកគ្នា យើងតែងយកធ្វើជាទោងយោលលេង យើងប្រចៀងលេងជាល្បែងក្រសាលសប្បាយ ព្រះពាយផាយផាត់ត្រជាក់ក្រេមក្រាន្ត បុប្ផាសោតសឹងមានដោយពណ៌ល្អ ៗ ក្រហម ខៀវ ស លឿងប្រសើរ យើងតែងតែដើរទៅបេះយកបុប្ផាមកថ្វាយសែមសៀតព្រះកេសា ប្រដាប់អស់អង្គប្រាណ ទាំងស្រះស្រង់ក៏សប្បាយ ទឹកថ្លាស្អាត មានផ្កាបទុមជាតិដុះដូចអ្នកចារ ទាំងផ្កាលត្បារ ឈូកច្រាលលឿងសល្អ ៗ ដុះជាជួរ ៗ ឯអស់មច្ឆាសោត ក៏មានដោយហ្វូងទីទៃ ៗ យើងតែងប្រស្រ័យមើលលេងជាល្បែងសព្វវេលា [បាលី ១ ឃ្លា] ឱស្តាយរូបប្រមឹគ សេះ ដំរី គោ ទន្សាយ រមាំង ប្រើស ទ្រាយ គជសីហ៍ ដែលព្រះវរបិតាទ្រង់សូនឲ្យព្រះរាជទានឲ្យយើងលេង ៗ ឥឡូវនេះយើងបង់ល្បែង ព្រាត់ប្រាសពីទីសប្បាយ ចេញទៅនៅឆ្ងាយធ្វើជាខ្ញុំព្រាហ្មណ៍នេះហោង ៗ

[បាលី ១ ឃ្លា] ម្នាលសង្ឃដ៏ទ្រង់នូវសីល សមាធិ បញ្ញា នាកាលព្រះជាលីកុមារកំពុងពិលាបកន្ទ្រងក្រាបទូលព្រះវរបិតា ឯតាជូជកព្រឹទ្ធាចារ្យក៏តាមមកទាន់ វាយដំចាប់ចងព្រះរាជកុមារទាំងពីរ នៅចំពោះព្រះភក្ត្រព្រះវរបិតា ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះគាថាឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ

[បាលី ៦ បន្ទាត់ហើយនឹង ១ ឃ្លា] ហៃភិក្ខុផងទាំងឡាយអើយ វីព្រះរាជកុមារទាំងពីរដែលតាជីចាស់ជរាកំពុងតែមកចាប់នាំយកទៅនោះ បានក្រាបទូលព្រះជនកដូច្នេះទៀតថា បពិត្រព្រះជនកអើយ សូមទានអម្ចាស់ត្រាស់ប្រាប់ព្រះមេយើងខ្ញុំផងថា យើងខ្ញុំទាំងពីរ ជាលីក្រឞ្ណាសុខសប្បាយឥតរោគាព្យាធិមកបៀតបៀនឡើយ បពិត្រព្រះវរបិតាអើយ ឯព្រះអង្គសោត ក៏សូមឲ្យប្រកបដោយសេចក្តីសុខសប្បាយគ្រប់ទិវារាត្រី [បាលី ១ ឃ្លា] បពិត្រអម្ចាស់អើយ វីសំនួនដំរី ពាជី គោ តោ សិង្ហ រាជសីហ៍ ដែលអ្នកសូនឲ្យនឹងដី ឲ្យយើងខ្ញុំលេងជាល្បែងតែសព្វថ្ងៃនោះ សូមព្រះអង្គប្រគល់បង្ហាញទៅព្រះមេឲ្យទានផង ក្រែងព្រះមេយើងខ្ញុំ អ្នកយល់សំនួនអស់នោះហើយ ព្រះមេយើងខ្ញុំ នឹងបន្ទោបង់សេចក្តីសៅសោកបានខ្លះសោះអ្នកនឹងនឹករលឹកយើងទាំងពីរពន់ពេក ៗ

[បាលី ២ បន្ទាត់] កាលនោះព្រះបាទស្រីវេស្សន្តរបរមហាសត្វ ស្តេចស្តាប់ពាក្យព្រះរាជកុមារទ្រង់ព្រះកន្ទ្រងពិលាបជាពន្លឹកដូច្នោះ ព្រះអង្គក៏មានព្រះហឫទ័យសៅសោក អាណិតអាសូរព្រះរាជបុត្រទាំងពីរលើសលន់ពន់ប្រមាណ មានព្រះហឫទ័យក្តៅផ្សានៅពុំស្រណុករអាក់រអួលក្នុងព្រះឧរា ញ័រចំប្រប់អស់ទាំងព្រះអង្គ មានឧបមាបីដូចកេសររាជសីហ៍ចាប់ដំរីសារចុះប្រេង ឬមួយដូចព្រះចន្ទ្របានចំណាប់ព្រះរាហូ [បាលី ១ ឃ្លា] ទើបស្តេចចូលទៅកាន់បណ្ណ

សាលា មានព្រះហឫទ័យក្រៀមក្រំជាំព្រះភក្ត្រា ទ្រង់ព្រះចិន្តាគន់គិតអាណិតព្រះរាជបុត្រ ញាប់ញ័ររន្ធត់អស់ទាំងព្រះកាយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ទីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះ

[បាលី ២ បន្ទាត់] លំដាប់នោះ ព្រះបាទស្រីវេស្សន្តរ លុះស្តេចព្រះរាជទានព្រះរាជបុត្រទាំងពីរទៅព្រាហ្មណ៍ហើយ ស្តេចចូលទៅក្នុងព្រះបណ្ណសាលា ទ្រង់ព្រះកន្សែងសោកាពិលាបយោបំប្រើនមហិមា ។ លំដាប់តពីនោះ ព្រះបរមពោធិសត្វ ទ្រង់ថ្លែងព្រះពិលាបជាបាទព្រះគាថាដូច្នេះ

[បាលី ១២ បន្ទាត់] ឱ៎កូនសំឡាញ់ទាំងពីរឱពុកអើយ ថ្ងៃល្ងាចថ្ងៃនេះហើយ សមបានឹងឃ្លានអាហារ នរណានឹងរមិលមើលឱ្យអាហារអ្នកឆ្អែត យល់តែតាជូជកព្រឹទ្ធាចារ្យ នឹងមានតែសេចក្តីភ័យតក់ស្លុតមហិមា អ្នកស្រេកទឹកនរណានឹងបំផឹក កូនសង្សារឱពុកអើយ នាថ្ងៃល្ងាចព្រសយាល ម្ល៉េះហើយបាផ្លាប់តែងទារអាហារម្តាយថា បពិត្រអ្នកមេអើយ យើងខ្ញុំឃ្លានបាយ ម្តាយបាក៏រកចំណីឱ្យឆ្អែត អ្នកស្រេកទឹក ម្តាយអ្នកក៏រកទឹកឱ្យផឹក ម្ល៉េះហើយបានឹងទារនរណា ៗ នឹងករុណាប្រណីឱ្យចំណីបានឆ្អែត [បាលី ១ ឃ្លា] ឱ៎កូនស្ងួនឱពុកអើយ អាសូរបាទជើងទៀវតូចដើរជាន់លើខ្សាច់ក្តៅ មុខជាពុះពងបែកហូរឈាម ត្រូវព្រាហ្មណ៍ចងវាយបណ្តើរទៅ [បាលី ១ ឃ្លា] កូនអើយ នរណានឹងដឹកដៃដបាក់ដរដើរដោយមាត្រា [បាលី ១ ឃ្លា] ឱ៎ដូចអញគិតនេះហើយ ព្រាហ្មណ៍នោះវាឥតខ្មាសអ្វីមាលស្មាយ វាវាយបញ្ចោះនៅមុខអញ ពុំត្រាប្រណីហើយនាំបណ្តើរទៅ លើសទៀតក្រៃលែងជាងខ្ញុំលោះនឹងប្រាក់ចាក់ពីថង់ [បាលី ១ បន្ទាត់] ទោះអ្នកឯណាមួយមកធ្វើជាខ្ញុំប្រុសខ្ញុំស្រីនៃអញ ទោះយោបីខុសគាប់អម្បាលម៉ាន គេញ៉ាំងគិតក្រែងចិត្តថាជាខ្ញុំព្រះបាទស្រីវេស្សន្តរ គេកោតខ្លាចអំណាចពុំអាចវាយដំឡើយ ។ ឯព្រាហ្មណ៍កញ្ចាស់កន្ត្រឹសឫស្យាសាហាវយង់ឃ្នងឥតខ្មាស វាវាយដំនឹងឈើប្រចត់ វាត់នឹងចុងវល្លិ៍ ដាលបែកឈាមហូរស្រោកនៅចំពោះមុខអញ ឥតចិត្តអាណិតអាសូរបន្តិចឡើយ [បាលី ១ បន្ទាត់] ដូចកព្រាហ្មណ៍វាដេរស្តីវាយដំកូនទាំងពីរជាទីស្រលាញ់ នៅចំពោះមុខអញនេះ អញក្តៅចិត្តពន់ពេកណាស់ អញគិតមើលទៅ កូនអញទាំងពីរដូចកល់ត្រីចូលត្រូ នឹងថយមកក្រោយទាល់នឹងថ្នក់ រុលទៅមុខទាល់នឹងប្រើស ព្រះបរមពោធិសត្វទ្រង់ព្រះកន្សែងសោកពិលាបដោយស្រលាញ់ព្រះរាជបុត្រទាំងពីរលើសលន់ពន់ប្រមាណ ព្រះអង្គរិះគិតតែក្នុងកំឡុងព្រះរាជហឫទ័យថា ព្រាហ្មណ៍កញ្ចាស់វាបៀតបៀនកូនអញអ្វីមាលស្មាយអេះ ទ្រង់ត្រិះរិះដូច្នោះហើយ ព្រះអង្គមិនអាចទប់ទល់ព្រះកន្សែងសោកបានឡើយ ទើបទ្រង់ព្រះចិន្តាថា អាត្មាអញតាមទៅកាត់កព្រាហ្មណ៍កញ្ចាស់នោះក៏បានអេះ យកកូនអញត្រឡប់មកវិញក្នុងកាលឥឡូវនេះឯង ។

លុះព្រះមហាក្សត្រទ្រង់ត្រិះរិះដូច្នេះហើយ បែរជាទ្រង់ព្រះចិន្តាក្នុងព្រះទ័យវិញថា ធម្មតាអ្នកមានធម៌សប្បុរសតាំងចិត្តប្រាថ្នាជាព្រះពុទ្ធ នាំសត្វឆ្លងវដ្តសង្សារ បានយកកូនឱ្យទៅជាទានស្លូមហើយ យល់តែស្លូមវា ធ្វើទុក្ខទោសកូនដល់ម្ល៉ោះកូវ ត្រឡប់ជាប្រែខ្វិចិត្តគំនិតគិតក្ដៅក្រហាយស្ដាយក្រោយ ហើយមានគំនិតគិតទៅធ្វើទុក្ខទោសគេវិញនោះ មិនសមគួរឡើយ មានព្រះបរិវិតក្កគាថា ថ្លែងព្រះតម្រិះនៃព្រះបរមពោធិសត្វនោះ ឱ្យចែងច្បាស់ដូច្នេះថា

[បាលី ៤ បន្ទាត់] ហៃភិក្ខុផងទាំងឡាយអើយ កាលព្រះបាទស្រីវេស្សន្តរបរមបពិត្រទ្រង់គិតរំពឹងក្នុងព្រះរាជហឫទ័យថា អញនឹងយកព្រះកៅទ័ណ្ឌនូវព្រះខាន់សរថ្លាស្ពាយស្នាខាងឆ្វេង ហើយអញនឹងតាមទៅសម្លាប់ព្រាហ្មណ៍ឱ្យក្ស័យជីវិត សឹមអញយកកូនអញទាំងពីរវិលមកវិញ ត្បិតវាពុំស្រឡាញ់ស្លូតត្រង់ឡើយ វាតែងបៀតបៀនវាយដំកូនអញជាពន្លឹកមហិមា ឱ្យជាទុក្ខពេកពន់ប្រមាណ ។ ព្រះបរមពោធិសត្វ ទ្រង់ខ្ញាល់នឹងព្រាហ្មណ៍នោះមហិមា តែដោយហេតុព្រះអង្គស្រឡាញ់ប្រាថ្នាសព្វញ្ញុតាញាណនោះខ្លាំងណាស់ ទើបខ្វិប្រែព្រះរាជហឫទ័យគិតថា ឱ! បាទវេស្សន្តរអើយ រីទុក្ខឯណា ដែលព្រាហ្មណ៍វាវាយដំបៀតបៀនកូនទាំងពីរ រីទុក្ខមានសភាពដូច្នោះ អង្គីជាថានជាហេតុនឹងទៅបៀតបៀនព្រាហ្មណ៍នោះឡើយ ធម្មតាប្រពៃណីនៃព្រះបរមពោធិសត្វ ឱ្យកូនសង្សារទៅជាទានហើយ លោកមិនដែលក្ដៅក្រហាយ ស្ដាយក្រោយឡើយ ។

រីព្រះពោធិសត្វ ព្រះអង្គរំលឹកទៅដល់ប្រពៃណីនៃព្រះពោធិសត្វ អំពីបុរាណនាយដែលលោកប្រាថ្នាជាព្រះពុទ្ធនោះ លោកមិនដែលខានធ្វើមហាបរិច្ចាគទាំង ៥ ប្រការគឺ ធនបរិច្ចាគ ១ អង្គបរិច្ចាគ ១ ជីវិតបរិច្ចាគ ១ បុត្តបរិច្ចាគ ១ ភរិយាបរិច្ចាគ ១ ។ លុះតែធ្វើមហាបរិច្ចាគនោះនៃ ទើបបានត្រាស់ជាព្រះពុទ្ធហោង ។ ឯអញសោត បើមិនបានចូលក្នុងលំនឹងព្រះពោធិសត្វអំពីបុរាណ មិនបានឱ្យប្រពន្ធកូនជាទានឡើយ នាបីអញប្រាថ្នានឹងឱ្យបានត្រាស់ជាព្រះពុទ្ធនោះមិញ មិនបានឡើយ ។ កាលព្រះអង្គទ្រង់ត្រិះរិះដូច្នោះហើយ ទើបដៀលត្មះព្រះអង្គឯងថា ហៃបាទវេស្សន្តរអើយ បាមិនដឹងទេឬ ការឱ្យទានកូនទៅធ្វើជាខ្ញុំអ្នកដទៃនោះ វាជាទុក្ខ ក៏បាសឹងដឹងស្រាប់ហើយតើ ហេតុអ្វីឡើយក៏បាគិតទៅតាមសម្លាប់ព្រាហ្មណ៍នោះមិញ ធម្មតាអស់អ្នកផង តែគេឱ្យទានហើយ គេមិនដែលថុចថយក្រោយដូចបានេះឡើយ ។ ហេតុនេះតាំងអំពីថ្ងៃនេះទៅ កុំថាព្រាហ្មណ៍វាវាយដំនាំទៅឡើយ សូម្បីវានឹងសម្លាប់កូនអញបង់ទៅក្ដី ក៏ស្រេចនៅអំពើពុតវាចុះ ។ រីព្រះបរមពោធិសត្វ ព្រះអង្គទ្រង់អធិដ្ឋានសមាទានខ្ជាប់នូវទានបារមី តម្កល់ទុកក្នុងព្រះហឫទ័យហើយ ទើបស្ដេចចេញអំពីបណ្ណសាលា មកគង់នាមាត់ទ្វារលើតម្បារថ្ម មានព្រះអង្គនោះល្អបីដូចរូបបដិមាមាសគិតដីជាងអ្នករចនាប្រពៃពេកក្ដាត់ហោង ។

(មហាវេស្សន្តរជាតក, ទំព័រ ២៨១ - ២៩៨)

មហាវេស្សន្តរជាតក

Introductory Note

មហាវេស្សន្តរជាតក /mɔhaa-weehsəndαα-ciədαq/ Mahā Vessantara Jātaka

ត្រាស់ to attain enlightenment (i.e. reach Nirvana)

មួយថ្ងៃមួយយប់ a full day, 24 hours

អត្ថបទ /qattəbαt/ article, composition, text

អត្ថាធិប្បាយ /qatthaathibaay/ commentary, explanation; to explain, describe

បច្ចេកទេស /paccaekkəteeh/ technique; technical

កម្រង garland, braid

ពាក្យកម្រងកែវ rhythmical prose (lit: style of interwoven jewels)

កណ្ឌ /kan/ episode, part, section; fascicle (of a palm-leaf manuscript)

កណ្ឌកុមារបព៌ one of the 13 sections of the Maha Vessantara Jataka

ជូជក /cəcuə̆q/ Jujaka (name of the Brahman to whom Vessantara gave his two children)

Text

តមត្ថំ បកាសេន្តោ សត្ថា អាហ /taqməthaŋ paqkaaseentao satthaa qaahaq/ a Pali formula which typically precedes quotations from the Tripitaka; its general meaning is 'Then the Buddha said...'

លា to tell one's story, recount past misfortunes

ញទ line, phrase (of verse or scripture)

គាថា poetry, verse (Pali)

តថាគត /təthaakuə̆t/ general pronoun for the Buddha

ស្រីពិរាស្ត្រ (Kingdom of) Srībirāstra

ជាលី Jālī (name of Vessantara's son)

ក្រស្នា /krəhsnaa/ Krishna (name of Vessantara's daughter)

កើតជាអស្ចារ្យ something extraordinary happened, a marvelous thing happened

ក្រឡាប្រឹថពី surface of the earth

រញ្ជួយ to shake, quake

សិនេរុរាជ /səneeruriəc/ (Mt.) Meru

លំទោន to bow, bend over; to submit

គិរីវង្កត /kiriiwuə̆ŋkαt/ name of a Himalayan mountain

បព៌ត /bααrəpoə̆t/ mountain (Lit)

ឥន្ទ្រាធិរាជ /qəntriəthiriəc/ Indra

ឥសូរ /qəysou/ top, highest, foremost

ព្រះសំរួល (= ព្រះសម្រួល) to laugh (Roy)

ថ្វាយសព្ទសាធុការ to bless, bestow a blessing

អធិក extremely

អឹងអាប់ tumultuously, clamorously

ព្រះបីតិ to be delighted, ecstatic; ecstasy, delight

រលះរលាំង to shuffle hurriedly along, to bustle

ជង្គុម bush, brush, underbrush

តួប joined together

វាយដំ (= វាយ) to beat, hit (Coll)

ចំពោះព្រះភក្ត្រ before the very eyes of, right in front of (Vessantara)

សរីរៈ /sərəyreə̆q/ body (Lit)

ពុរ /pul, poo/ bruised, pulpy

ពង to blister

រង to undergo, suffer (hardship, grief, etc.)

តាង to represent; in place of, instead of

ស្រយ៉ាប flat, prostrate

ដំណើរ (= ដើរ)

ផ្តាំផ្ញើ to have final words with, leave final instructions with

ក្រៃលែង beyond, exceeding

បុរិសទោស /borihsatooh/ human fault, mortal defect

ស្វក់ swollen and lifeless

ដុំញូរ slab-like, block-like

ក្ងក់ crooked, hooked, twisted

កំភួន calf of the leg

សាច់ដុំ muscle

រយេងរយោង sagging, hanging down here and there

ននោង a kind of rough-skinned squash, Chinese okra

ពពីរ lips, rim of the lips

យុរយារ /yuu-yiə/ sagging, protruding, hanging down

ខ្នាយ tusk, fang, spur

ញាក់ broken, irregular

តន្លាក់ notch, crease, depression

កំញ៉ោង swollen, bloated

កំញ៉ោក swollen, bloated, rotund

ស្រលៀង cross-eyed

ស្រឡៀវ cross-eyed

ពុកចង្កា beard

ស្រមូវ bushy

ប្រចាលប្រចាញ់ brush-like

រមួល twisted (here: tangled, matted)

កង្កញ kinky, curly, coiled

រួញ kinky, coiled, curled

សរសៃឡើង veins stick out, veins protrude

ររីមររាម in crisscrossing helter-skelter lines

អាចម៍រុយ freckles (lit: fly-specks)

ប្រជ្រុយ mole (on the skin)

កែវភ្នែក cornea of the eye

ដងខ្លួន body

កន្ធែក spread apart, spraddled

ស្ញែង to fear, stand in awe of, dread

នាំពា to care, be concerned

គួរនា (=ដូច , ដូចជា) /kuərənia/ like, as if (Lit)

គោបាល cattle herdsman

សន្តោស to support, help out, assist; support, assistance, kindness

ពុំសឹងរបី (=ពុំសឹងជា)

ឫសី /rɨhsəy/ hermit, holy man, rishi

កន្ទក់កន្ទេញ to whine, plead, beseech

សៅសោក (=សោកសៅ)

តានតឹង constricted, choked up

លុះ attain, achieve

ពោធិញ្ញាណ /poothiññiən/ enlightenment

បរមសុខ /barommәsok/ great joy, perfect peace of mind

ណែងណង a weight, encumbrance (attached to an animal to restrict his movement)

អាស្រម /qaasram/ hermitage, forest retreat

អាមោក្ខ (=អមោក្ស)

ននៀល to twist and turn, roll about

ដំ to pound, beat

សីរមាន់ /sei-moŏn/ a variety of rambutan

ចន្ទី a sweet-smelling fruit

ម័កប៉ែន a sweet-smelling fruit

លាំងសាត a variety of litchi

ផ្ងូត to bathe, give a bath to

ដុស to rub, scrub (to remove dirt)
រមៀត tumeric

ពិសា delicious

សំហើយ to relieve, lessen, ease (tv)
សង្រេង to grieve

សន្ធិលសន្ធឹក (= សន្ធឹកសន្ធិល) sprawled despondently, prostrate with dejection
ស្រក to recede (of water)

រីង dried up (by evaporation)

ហែង parched

ហួត to evaporate

ខះ dried out, dried up, dehydrated
ទុក្ខនេះ---ទាំងឡាយ This [kind of] suffering is more persistent than any other [kind of] suffering.
ជម្ពូ rose apple

អធិក great, extreme, many

ពោធិញ្ញយ a kind of banyan tree

ត្រសាយ extended, spread out, branchy
ត្រសាយត្រសុំ (= ត្រសុំត្រសាយ) spread out, overhanging, providing deep shade
ព្រីង a kind of tree with edible fruit
ព្រួស a variety of mangosteen

ភ្លូ a kind of tree

ភ្លង a kind of red hardwood tree

ដងអង្កាល់ 'plow-handle' tree

ត្រឈឹងត្រឈៃ cool and shady

ទោង a swing

